# លោកទស្សនៈ

## ការមិនស្មោះត្រង់នាំឱ្យជាប់ជំពាក់



ព្រះរាជមហាវិហារវត្តកល្យាណីកោះស្រីលង្កា

រៀបរៀងដោយៈ

ឧបាសក នា-សុខា

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស**

# លោកឧស្សនៈ

ការមិនស្មោះត្រង់នាំឱ្យជាប់ជំពាក់

**ឆ្នាំកុរ នព្វស័ក ព.ស.២៥៥១**

**រៀបរៀងដោយ**
**ឧបាសក នា~សុខា**

បានស្កានឡើងវិញសម្រាប់ជាធម្មទាន
ដែលបានអនុញ្ញាតដោយ ឧបាសក នា សុខា

Scan by:

www.5000-years.org

# សោកទស្សនៈ

## ការមិនស្មោះត្រង់នាំឱ្យជាប់ជំពាក់

ឆ្នាំកុរ នព្វស័ក ព.ស ២៥៥១

រៀបរៀងដោយ

**ឧបាសក ឆា សុខា**

# អារម្ភកថា

ការអប់រំចិត្តឱ្យនៅពីលើលោក ជាការកម្រយ៉ាងក្រៃលែងក្នុងព្រះពុទ្ធសាសនា ព្រោះថាលោកធ្លាប់តែគ្របដណ្ដប់លើអ្វីៗទាំងពួង ។

លោកអវិជ្ជា លោកកាមគុណ លោកកិលេស លោកតណ្ហា លោកឧបាទានក្ខន្ធនិងលោកអភិសង្ខារបានប្រែក្លាយជាមារ ប្រើឫទ្ធិនិមិត្តនូវអំណាចផ្សេងៗ ញ៉ាំងសត្វលោកឱ្យត្រេកអររីករាយ "***នន្ទិសម្ពន្ធនោ លោកោ***" ប្រែថា សត្វលោកមានសេចក្ដីត្រេកអរជាគ្រឿងចងនិងលោកដទៃទៀត ដូចជា ***សព្វេ សង្ខារា អនិច្ចាតិ*** ប្រែថាសង្ខារទាំងឡាយមិនទៀង ។

ដើម្បីបង្ហាញនូវលក្ខណៈលោកឱ្យកាន់តែច្បាស់លាស់ជាងនេះក្នុងសង្គម ខ្ញុំបានរៀបរៀងចងក្រងសៀវភៅមួយ មានចំណងជើងថា "**លោកទស្សនៈ**" ដោយសេចក្ដីថា មើលលោកនេះ ។

**វណ្ណគតិនេះ** ចាត់ទុកជាកម្រងមាតិកាមួយជ្រកនៅក្រោមម្លប់ព្រះពុទ្ធសាសនា ដែលមានលោកគ្រូអគ្គបណ្ឌិតជាម្ចាស់ជួយបំភ្លឺ និងបូជា ចំពោះគុណព្រះរតនត្រ័យព្រមទាំងឧទ្ទិសជូនដល់គុណមាតាបិតា និងគោរពជូនគុណលោកគ្រូឧបជ្ឈាយាចារ្យព្រមទាំងញាតិមិត្ត ពុទ្ធបរិស័ទគ្រប់គ្នា ។

សូមមេត្តាជួយកែសម្រួលដោយទឹកចិត្តថ្លាស្អាត ។

រាជធានីភ្នំពេញ

ថ្ងៃ ០១ រោច ខែ ស្រាពណ៍

ឆ្នាំ កុរ នព្វស័ក ព.ស ២៥៥១

**ឧបាសក នា សុខា**

**ពិនិត្យផ្ទៀងផ្ទាត់ និងកែសម្រួលដោយ**

១-**ភិក្ខុព្រះមហាឧត្តមវីរិយោ ហ៊ុំ សុន្ធា** ជាសមណនិស្សិតនៃពុទ្ធិកសកលវិទ្យាល័យព្រះសីហនុរាជ

២-**ឧបាសក ជាំ-កុយ** ផ្នែកខាងអក្សរសាស្ត្រខ្មែរ

៣-**ឧបាសក វី-ស្រ៊ាង** ប្រធានសមាគមទ្រទ្រង់អក្សរសាស្ត្រ និងវប្បធម៌ខ្មែរ

# បញ្ជីមាតិកាធម៌


| ល.រៀង | លំដាប់មាតិកា | ទំព័រ |
|---|---|---|
| 1 | លោកទស្សនៈ | 01 |
| 2 | អត្ថន័យរបស់ចិត្តបរមត្ថ | 08 |
| 3 | សម្រួលឱ្យងាយក្នុងការសិក្សា | 23 |
| 4 | មើលលោកនេះដោយការពិចារណា | 26 |
| 5 | មើលលោកនេះដោយការប្រុងប្រយ័ត្នខ្ពស់ | 27 |
| 6 | ជីវភាពក្នុងសង្គម | 31 |
| 7 | សង្គហធម៌រវាងមាតាបិតានិងបុត្ត | 37 |
| 8 | សង្គហធម៌រវាងលោកគ្រូ និងសិស្ស | 43 |
| 9 | សង្គហធម៌រវាងស្វាមី និងភរិយា | 47 |
| 10 | អរិយធម៌ | 53 |
| 11 | មើលលោកនេះក្នុងគំនិតជួយបណ្តុះពូជល្អដល់បុត្ត | 62 |
| 12 | មេរៀនសម្រាប់យុវវ័យ (កំណាព្យ) | 66 |
| 13 | សង្គហធម៌រវាងមនុស្សរស់នៅជុំវិញ | 69 |
| 14 | សង្គហធម៌រវាងទាសៈ និងកម្មករ | 71 |
| 15 | ការបដិបត្តិរវាងគ្រហស្ថ និងសមណព្រាហ្មណ៍ | 75 |
| 16 | ហេតុនាំឱ្យមានការថ្វាយបង្គំទិសទាំងឡាយ | 80 |

| | | |
|---|---|---|
| 17 | បណ្ដាំម៉ែឪ ( កំណាព្យ ) | 83 |
| 18 | អំពីការសេពគប់មិត្ត | 85 |
| 19 | សេចក្ដីពិស្ដាររបស់ភរិយា ៧ជំពូក | 95 |
| 20 | អំពីការមិនស្អាត | 104 |
| 21 | បទពិចារណា ( កំណាព្យ ) | 108 |
| 22 | មើលលោកនេះដោយការកសាងធនធានមនុស្ស | 110 |
| 23 | កំណើតរបស់មនុស្សសត្វ | 117 |
| 24 | ការអប់រំចិត្ត | 122 |
| 25 | លក្ខណៈសម្គាល់នូវប្រយោជន៍ធម៌ | 132 |
| 26 | អធ្យាស្រ័យ | 141 |
| 27 | សីលគុណអប់រំ ( កំណាព្យ ) | 145 |
| 28 | សតិប្បដ្ឋាន ( ជំហានទី៥ ) | 151 |
| 29 | លក្ខណពិសេសរបស់អនត្តា | 158 |
| 30 | សំយោគមតិ | 167 |
| 31 | មេរៀនជីវិត ( កំណាព្យ ) | 184 |

# លោកទស្សនៈ

បានសេចក្តីថា **"មើលលោកនេះ"** ដោយការពិចារណាក្នុងមហាកុសល ៨ ដួង ណាមួយដែលសង្ខារលោកតាក់តែងពីហេតុប្បច្ច័យ អាស្រ័យធាតុទាំងឡាយ ប្រមូលផ្តុំប្រជុំគ្នាបានជារូបធម៌នាមធម៌ កើតរលត់ៗមិនចេះចប់ក្នុងសង្សារវដ្ត បង្កើតជាកម្លាំងចលនារុញច្រានសាកលលោកឱ្យមានការប្រែប្រួលតាមទំនាញផែនដី ជារបស់គ្មានខ្លឹមសារដល់មនុស្ស សត្វ សម្ភារទាំងឡាយកើតវិនាសៗជាប្រក្រតីបណ្តាលពីតណ្ហាកិលេសនៃក្រសែជីវិតជាប់តគ្នា មានកុសលវិបាកនិងអកុសលវិបាកលាតត្រដាងលោក ឱ្យមើលឃើញជាក់ច្បាស់ថា លោកនេះមានគ្រឿងផ្សំអ្វីខ្លះ ដែលធ្វើឱ្យមនុស្ស សត្វ ឃ្លាន ស្រេក ចង់បាន ចង់ឃើញ ក្រាញរស់នៅមិនសុខចិត្ត ដើរចេញទៅរកកន្លែងដទៃផ្សេង តើមានមូលហេតុអ្វី ?

កាលបើសត្វលោកដកចិត្តទៅណាមកណាមិនរួច ព្រោះគេចូលចិត្ត ពេញចិត្តរីករាយដោយឆន្ទរាគៈរបស់សុខសោមនស្ស ដែលលោកនេះមានគ្រឿងផ្សំប្រណីតៗ ដោយមានចិត្តជាអ្នកវិចិត្រនូវ

អារម្មណ៍ទាំងឡាយរបស់មារក្នុងចិត្តសន្តានឱ្យភ្លេចស្មារតី ទោរទន់បង្អោនចិត្តមិនចេះនឿយហត់ ឱ្យតែបានជួប បានឃើញ បានឮ បានស្រូបក្លិន បានដឹងរស បានក្បៀកកើយប៉ះពាល់និងទទួលដឹងនូវធម្មារម្មណ៍ទាំងឡាយ ដូចជាសង្គមមនុស្សនេះ តែងមានការទាក់ទងគ្នាក្នុងការរស់នៅជាមួយមាតាបិតានិងបុត្រ, គ្រូអាចារ្យនិងសិស្ស, ស្វាមីនិងភរិយា, មិត្តអាមាត្យ (អ្នកបម្រើ) និងម្ចាស់ ចៅហ្វាយនាយនិងកម្មករ ការចងមិត្ត គ្រហស្ថនិងសមណព្រាហ្មណ៍ ទាំងនេះសុទ្ធតែលោក ដែលនឹងត្រូវពិគ្រោះពិភាក្សាគ្នារកផ្លូវ ឬ មធ្យោបាយណា នឹងត្រូវយកអ្វីមករៀបចំ យកអ្វីមកជាគោល យកអ្វីមកជួយសម្របសម្រួលនូវសភាវៈទាំងនេះ ។ តាមការសម្លឹងឃើញ ដោយបញ្ញា គ្រឿងផ្សំអ្វីដែលមាននៅក្នុងលោក មិនអាចរៀបចំលោក នៅក្នុងសង្គមនេះបានល្អត្រឹមត្រូវទេ ព្រោះជារបស់ដែលលោកធ្លាប់ ប្រាស្រ័យទាក់ទងរួចមកហើយ ដូចជាការឃើញ ការឮ ការធុំក្លិន ការដឹងរស់ ការប៉ះខ្ទប់និងការដឹងធម្មារម្មណ៍ដែលគេបានយកមក ប្រើប្រាស់ជាយូរយារណាស់ ជារបស់គ្រោតគ្រាតឬថាជាធម៌ធុនអន់ក៏ បានដែលមនុស្សក្នុងលោកកំពុងជ្រួលច្របល់មិនចេះចប់ធ្វើឱ្យសង្គម មនុស្សពោរពេញដោយសេចក្ដីលោភលន់ ក្ដៅក្រហាយច្រណែនឈ្នានីស ចងកំហឹងដាក់គ្នារហូតកើតឡើងនូវ

លទ្ធផលជាវិជ្ជមានដែលចេញ រូបរាងពិតប្រាកដធ្វើឱ្យយើងកំពុងឃើញជាក់ស្តែងដូចសព្វថ្ងៃនេះ ។

តាមការសិក្សាស្រាវជ្រាវកន្លងមក ការដែលអាចនឹងជួយផ្សំផ្គុំលោកនេះឱ្យបានទៅជាលោកមានអរិយធម៌រុងរឿងនិងសុខសន្តិភាព មានតែការគោរពតាមឱវាទានុសាសនីរបស់ព្រះជិនស្រី ដែលព្រះអង្គភ្ញាក់រឹងចេញពីស្រោមលោកអវិជ្ជាត្រាស់ដឹងនូវអរិយសច្ចធម៌៤ មិននៅក្នុងលោកទើបសម្លឹងមើលឃើញជាក់ច្បាស់លោកដោយញាណនូវ **កាយកម្ម, វចីកម្ម, មនោកម្ម** ដែលទ្រង់សម្តែងព្រះធម្មទេសនាប្រោសដោយមហាករុណាទិគុណ ដល់សព្វសត្វឱ្យបានរស់នៅយ៉ាងសុខសាន្តប្រកបដោយចរិយាធម៌និងមានសីលធម៌ល្អពិតប្រាកដ ជាហេតុញ៉ាំងលោកសង្គមឱ្យបានទទួលនូវភាពសុខដុមរមនា មានវឌ្ឍនភាពជឿនលឿនគ្រប់វិស័យ ពិសេសវិស័យខាងព្រះពុទ្ធសាសនាដែលជាគន្លឹះបើកទ្វារផ្ទះបញ្ចាំង ឱ្យឃើញអ្វីៗពិតប្រាកដ (សច្ចធម៌) មិនបិទបាំងលាក់ទុកដូចក្នុងសម័យ ពុទ្ធកាលមាននៅក្នុងរឿង "**សិង្គាលកគហបតិបុត្ត**" ដែលព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងធម្មទេសនាដោយពិស្តារយ៉ាងពីរោះក្បោះក្បាយប្រោសដល់សត្វ ។

ម្យ៉ាងទៀតធម្មៈ គឺធម្មជាតិ ជាសភាវៈអាថ៌កំបាំង ក៏មិនមែនយល់ដឹងងាយៗស្រួលៗឡើយ ជាធម៌ជ្រៅល្អិតសុខុមមានគម្ពីរភាព

ណាស់ លុះត្រាតែខំព្យាយាមសិក្សាឱ្យបានច្រើនទើបជ្រាប បើមិនទាន់ជ្រាបច្បាស់ ការបដិបត្តិក៏មិនបានលទ្ធផលល្អបណ្ដាលឱ្យប្រព្រឹត្តខុសក៏មាន ព្រោះព្រះពុទ្ធអង្គទ្រង់សម្ដែងធម៌មានរាក់, មានកណ្ដាល, មានជ្រៅ ជាការពីរោះបទដើម, បទកណ្ដាល និងបទចុងបានដល់មគ្គផលព្រះនិព្វានទើបឆ្លងលោកបានទៅតាមអធ្យាស្រ័យសត្វដែលជាធម៌ត្រាស់ដឹង ។ ពាក្យថា ត្រាស់ដឹង បានសេចក្ដីថា ព្រះអង្គទ្រង់ជ្រាបច្បាស់ដោយព្រះសព្វញ្ញុតញ្ញាណ មិនមែនដូចធម៌របស់អ្នកប្រាជ្ញខ្លះក្នុងលោក ឬ លទ្ធិសាសនាដទៃណាឡើយ ជាធម៌យ៉ាងកម្រក្រៃលែងដូចជាទ្រង់ប្រទាននូវឱវាទម្ដងៗសុទ្ធតែពាក្យពិតផង មានខ្លឹមសារផងធ្វើឱ្យសត្វលោកស្ដាប់បានសម្រេចមគ្គផលច្រើនរាប់មិនអស់ដោយព្រះអនាវរណញ្ញាណ ពុំមានធម៌ណាមួយដែលមនុស្សលោកអាចជ្រាបយល់សព្វគ្រប់ដូចជា **កុសលាធម្មា អកុសលាធម្មា អព្យាកតាធម្មា** ជាដើមសុទ្ធតែជាធម៌ល្អិតក្នុងជីវិតប្រចាំថ្ងៃ មិនអាចមានអ្នកយល់ជ្រាបដឹងបាន ឬ គិតគូរយ៉ាងណាឱ្យទៅជាសច្ចធម៌ដូច ព្រះដ៏មានព្រះភាគមិនមាន ថែមទាំងសាសនាដទៃមិនអាចត្រងចាប់យក នូវពាក្យប្រៀនប្រដៅនោះក៏ពោលពាក្យថា **"គ្មានអ្នកណាធ្វើតាមបាន ឬថានាំឱ្យមនុស្សក្រទៅវិញក៏មាន"** ព្រោះគេពុំបានសិក្សារៀនសូត្រពីព្រះពុទ្ធ

វចនៈឱ្យយល់ច្បាស់ត្រឹមត្រូវក៏ចេះតែចោទប្រកាន់តាម គំនិតរបស់ខ្លួនក្នុងភាពជាអ្នកល្ងង់ខ្លៅទៅវិញ ។

ព្រះពុទ្ធសាសនា ជួយកសាងលោកឱ្យបានរីកចម្រើនខ្លាំងណាស់ចំពោះតែសត្វណាមានសទ្ធា ដោយធម្មបរិយាយនៃព្រះធម្មទេសនាបានដឹកនាំសត្វឱ្យស្វែងរកសុខ ចៀសវាងពីការប្រព្រឹត្តខុសទាំងឡាយមានការកាប់សម្លាប់ កេងប្រវ័ញ្ច ប្រព្រឹត្តខុសក្នុងកាម វៀរចាកការពោលពាក្យកុហក និងផឹកនូវទឹកស្រវឹងធ្វើឱ្យវង្វេងភ្លេចភ្លាំងស្មារតី ។ សង្គមមនុស្សដែលខ្វះការយល់ដឹងពីព្រះពុទ្ធសាសនា,មិនអាចជួយជ្រោមជ្រែងលោកឱ្យបានសុខសន្តិភាពទេ ព្រោះជាសាសនាធម្មជាតិ, ជាសាសនាហេតុផល, ជាសាសនាបញ្ញា, ជាសាសនាសិក្សា បើមិនបានសិក្សាប្រាកដជាមិនចេះមិនដឹងមែន កាលបើបានសិក្សាវិជ្ជាព្រះពុទ្ធសាសនា ទើបធ្វើឱ្យមានបញ្ញាចម្រើនរាល់ថ្ងៃ ដឹងអ្វីៗកាន់តែច្រើនឡើងជាលំដាប់ធ្វើចិត្តឱ្យសប្បាយរីករាយជ្រះថ្លាគ្មានអ្វីប្រៀប ដូចមានសំនួរថាការដែលទៅស្តាប់ធម៌ ឬ តាមទៅស្តាប់ធម៌នៅទីកន្លែងណាផ្សេងៗ មានសប្បាយឬទេ ? ឆ្លើយថា សប្បាយណាស់ ព្រោះនាំឱ្យចម្រើនបញ្ញាកាត់បន្ថយនូវកិលេសជាខណៈៗ ដូច្នោះទើបព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា **សុតាមយបញ្ញា**, បញ្ញាកើតពីការស្តាប់ធម៌, **ចិន្តាមយបញ្ញា**, បញ្ញាកើតពីការត្រិះរិះ, **ភាវនាមយបញ្ញា**, បញ្ញាកើតពីការអប់រំចម្រើនដោយ

យោនិសោមនសិការៈនិងសេចក្ដីព្យាយាម ។ ការដែលមានបញ្ញាឈ្មោះថាជាគោលដៅសំខាន់ក្នុងព្រះពុទ្ធសាសនាយ៉ាងប្រសើរក្រៃលែង ព្រោះព្រះអង្គជាសព្វញ្ញុពុទ្ធ ត្រាស់ដឹងធម៌ដោយសព្វញ្ញុតញ្ញាណ គឺបញ្ញាបានមកពីការកសាងបារមីជាបញ្ញាធិក ។

ដើម្បីចូលដល់ការសម្លឹងមើលលោក នៃសង្គមមនុស្សរាល់ថ្ងៃឱ្យបានច្បាស់ពិតប្រាកដ សូមសិក្សាពីចិត្តឱ្យបានយល់ខ្លះៗជាមុនសិន ព្រោះមនុស្សយើងមានតម្លៃថ្លៃថ្នូរ ឬថោកទាបក៏មកពីចិត្ត ដែលតែងតែប្រែប្រួលមិននៅស្ងៀម ពុំដឹងពីមូលហេតុអ្វី ។ លោកនេះបានដល់សង្ខារលោកមានវិញ្ញាណនិងអវិញ្ញាណទាក់ទងទៅនឹងការវិលចុះវិលឡើងរបស់ចក្រវាល បង្កើតឱ្យមានការប្រទង់ប្រទាញគ្នាមិននៅស្ងៀមតាមចរន្តធាតុនៃផែនដី មានមនុស្ស, មានសត្វ, មានភ្នំ, ដើមឈើ , ទន្លេ, បឹងបួ, សមុទ្រ, ព្រះអាទិត្យ, ព្រះចន្ទ ព្រមទាំងពពួកផ្កាយជាសារជាតិនៅក្នុងអាកាស ពួកសត្វនៅលើដីនិងក្នុងទឹក ធ្វើឱ្យធម្មជាតិទាំងនោះរស់រវើកប្រែប្រួលដូចគ្នា ។

**មើលលោកនេះគឺតួបញ្ញាចេតសិក** ជាអ្នកមានសិទ្ធិសេរីភាពក្នុងការពិនិត្យនូវអ្វីៗរបស់លោកដែលតែងតែវិនាសប្រែប្រួលទៅវិញ **យំ កិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មន្តិ** ប្រែថា ធម្មជាតិណាមួយកើតឡើងហើយតែងតែវិនាសទៅវិញជាធម្មតា ។

**ធម្មជាតិនោះ បានដល់ :**

ចក្ខុគូ នឹងរូប, សោតៈគូ នឹងសំឡេង, ឃានៈគូ នឹងក្លិន

ជិវ្ហាគូ នឹងរស, កាយគូ នឹងផោដ្ឋព្វៈ, ចិត្តគូ នឹងធម្មារម្មណ៍ ។

ធាតុទាំង ៤ និងអាកាសធាតុ ហៅថា លោកធាតុ ឬចក្កវាឡ ឬផែនដី ឬមហាកប្បឬឱកាសលោកក៏បាន អន្ទោលទៅមកមិនចេះចប់ មិនទៀងទាត់ជានិច្ចកាល អណ្តែតឃ្លេងឃ្លោងប៉េលប៉ាលនៅលើទឹក ប្រៀបដូចក្បូន ជួនត្រូវខ្យល់បក់បោកខ្លាំងធ្វើឱ្យកក្រើករញ្ជួយតាម ចលនារបស់ធាតុ ឯទឹកប្រតិស្ឋាននៅលើខ្យល់ ចំពោះខ្យល់វិញ ប្រតិស្ឋាន នៅលើអាកាស ល្ហល្ហេវ គ្មានកោះ គ្មានត្រើយឡើយ ។ ម្នាលអានន្ទ សម័យណាមានខ្យល់បក់ធំ ខ្យល់ធំដែលបក់ខ្លាំងនោះរមែងធ្វើទឹកឱ្យ រលកកក្រើក ឯទឹកដែលមានរលកបក់បោកខ្លាំងក៏ធ្វើផែនដីឱ្យកក្រើក ជាហេតុឱ្យមានបាតុភូតផ្សេងៗកើតពីធម្មជាតិដូចជារដូវប្រែប្រួល ជួនក្តៅ ជួនត្រជាក់ ជួនមានភ្លៀងធ្លាក់ច្រើន ឬតិចមិនតាមរដូវកាល ជួនមាន ខ្យល់បក់តិចខ្យល់បក់ខ្លាំងនាំឱ្យមានខ្យល់ព្យុះបក់បោកមកលើភពផែនដី ជាសង្ខតធាតុ មិនទៀងទាត់តាមប្រក្រតី ដែលហៅថា **អនិច្ចំ ទុក្ខំ អនត្តា** ព្រោះពុំមានអ្វីឱ្យពិតប្រាកដហ្នឹងហ្នំច្បាស់លាស់ដែលខ្ញុំបាន ជម្រាបជូននៅក្នុងសៀវភៅសរសេរពីក្រសែជីវិតរួចមកហើយ ( ស្រង់ចាក

បិដកលេខ ១៦/២២៦ ទីឃនិកាយមហាវគ្គ) ។ ដូច្នោះ ជីវិតសត្វលោក ដែលរស់នៅក្នុងលោកធាតុនេះ ក៏ជាធម្មជាតិមានភាពមិនទៀងទាត់ ជាទុក្ខដោយអត្តថាអនត្តាដូចគ្នា ទាំងរូបធាតុនិងអរូបធាតុមានចិត្តវិញ្ញាណជាដើម ។ ការប្រែប្រួលរបស់ធម្មជាតិធ្វើឱ្យរូប ២៨ ត្រូវប្រែប្រួលវិនាសទៅវិញជាធម្មតាមិនស្ថិតស្ថេរយ៉ាងណា ចិត្ត ១ ដួង ដែលបំបែកចេញមាន ៨៩ ដួង ឬ ១២១ ដួង ក៏ប្រែប្រួលដូចគ្នា ។

## *អត្ថន័យរបស់ចិត្តបរមត្ថ*

ក្នុងបរមត្ថជោតិកៈ បរិច្ឆេទទី ១-២-៦ បានអធិប្បាយថា : ពាក្យថា "ចិត្ត" ជាធម្មជាតិដឹងអារម្មណ៍ជាលក្ខណៈ**អារម្មណវិជាននលក្ខណំ** គឺបានទទួលអារម្មណ៍ស្មើនោះឯង ទើបហៅថាដឹងអារម្មណ៍ ដូចមានសម្តែងជាវចនត្ថៈថា **អារម្មណំចិន្តេតីតិ=ចិត្តំ** ធម្មជាតិណារមែងដឹងអារម្មណ៍គឺបានទទួលអារម្មណ៍ស្មើ ដូច្នោះធម្មជាតិនោះឈ្មោះថាចិត្ត ។ ឬន័យមួយទៀត **ចិន្តេន្តិ សម្បយុត្តធម្មា ឯតេនាតិ=ចិត្តំ** សម្បយុត្តធម៌ គឺចេតសិកទាំងឡាយរមែងដឹងអារម្មណ៍ដោយ អាស្រ័យ ធម្មជាតិនោះ ដូច្នោះធម្មជាតិដែលជាហេតុនៃការដឹងអារម្មណ៍របស់
ចេតសិកទាំងនោះឈ្មោះថាចិត្ត ។ ឬន័យមួយទៀត **ចិន្តនមត្តំ=ចិត្តំ** ធម្មជាតិដែលដឹងអារម្មណ៍ បានទទួលអារម្មណ៍នោះឯង ឈ្មោះថា **ចិត្ត** ។

ម្យ៉ាងទៀត **ចិត្តីករោតីតិ ≈ ចិត្តំ** ធម្មជាតិណាធ្វើសត្វទាំងឡាយឱ្យវិចិត្រ ធម្មជាតិនោះហៅថា **ចិត្ត** មាន ៨៩ ដួង ឬ ១២១ ដួង ដោយពិស្តារដែលចែកចេញជា ៣ ភូមិ និង ៤ ជាតិ ដូចតទៅ ÷

**១-កាមាវចរភូមិ មាន ៤ ជាតិ :**

អកុសលជាតិ បានដល់អកុសលចិត្ត ១២ ដួង

កុសលជាតិ បានដល់មហាកុសលចិត្ត ៨ ដួង

វិបាកជាតិ បានដល់វិបាកចិត្ត ២៣ ដួង

(មហាវិបាក ៨ អហេតុកវិបាក ១៥ ដួង)

កិរិយាជាតិ បានដល់កិរិយាចិត្ត ១១ ដួង

គឺ(មហាកិរិយា៨ អហេតុកកិរិយា ៣ ដួង)

រួមទាំងអស់កាមាវចរចិត្ត មាន ៥៤ ដួង ។

ចំណែកកិរិយាជាតិនិងវិបាកជាតិ ទាំងពីរនេះរួមគ្នា ហៅបានថា **អព្យាកតជាតិ** ។ ដូច្នោះកាមាវចរភូមិ អាចមានត្រឹម ៣ ជាតិក៏បាន គឺមហាកុសលជាតិ ១, អកុសលជាតិ ១ និងអព្យាកតជាតិ១ ។

មហាកុសលជាអ្នកតាក់តែងជាតិភពសម្បត្តិ ជាអ្នកដឹកនាំឱ្យកើត ។ មហាវិបាកជាតួបដិសន្ធិ ជាអ្នកសោយនូវសម្បត្តិ ។ មហាកុសល និងមហាកិរិយាដូចគ្នា ឧបមាដូចតួត្រា និងស្នាមត្រាដែលគេបោះចុះ ឬដូចស្រមោលក្នុងកញ្ចក់ និងអ្នកដែលឆ្លុះនូវកញ្ចក់នោះឯង ផ្សេងគ្នាតែទីកើត

គឺមហាកុសលកើតក្នុងសន្តាននៃបុថុជ្ជននិងសេក្ខបុគ្គល ឯមហាកិរិយ កើតចំពោះតែក្នុងសន្តាន ព្រះខីណាស្រពប៉ុណ្ណោះ ។

មហាវិបាក ៨ ឱ្យសម្រេចកិច្ច ៤ យ៉ាង គឺបដិសន្ធិ ១, ភវង្គ ១ ចុតិ ១ និងតទាលម្ពណៈ ១ ។

## អកុសលចិត្ត១២ ដួង

* លោភចិត្ត ៨ ជាលោភមូល
* ទោសចិត្ត ២ ជាទោសមូល
* មោហចិត្ត ២ ជាមោហមូល ។

### លោភមូលចិត្ត ៨ ដួង :

១-សោមនស្សសហគតំ ទិដ្ឋិគតសម្បយុត្តំ អសង្ខារិកំ មានចេតសិក ចុះ ១៩ គឺ អញ្ញសមានា ១៣ និងមោហៈ អហិរិកៈ អនោត្តប្បៈ ឧទ្ធច្ចៈ លោភៈ ទិដ្ឋិ

២- សោមនស្សសហគតំ ទិដ្ឋិគតសម្បយុត្តំ សសង្ខារិកំ មានចេតសិក ចុះ ២១ គឺ អញ្ញសមានា ១៣ និងមោហៈអហិរិកៈ អនោតប្បៈ ឧទ្ធច្ចៈ លោភៈ ទិដ្ឋិត្រូវជា ១៩ ដូចទី ១ ហើយថែម ថីនំ, មិទ្ធំ បានជា ២១ ដួង

៣-សោមនស្សសហគតំ ទិដ្ឋិគតវិប្បយុត្តំ អសង្ខារិកំ មានចេតសិក ចុះ ១៩ គឺអញ្ញសមានា ១៣ និងមោហៈ អហិរិកៈ អនោត្តប្បៈ ឧទ្ធច្ចៈ លោភៈ មានះ

៤- សោមនស្សសហគតំ ទិដ្ឋិគតវិប្បយុត្តំ សសង្ខារិកំ មានចេតសិក ចុះដូចទី ៣ ដែរ ហើយថែម ថីនំ មិទ្ធំ ត្រូវជា ២១

៥- ឧបេក្ខាសហគតំ ទិដ្ឋិគតសម្បយុត្តំ អសង្ខារិកំ មានចេតសិក ចុះ ១៨ គឺអញ្ញសមានា ១២ (វ/បីតិ) និងមោហៈ អហិរិកៈ អនោត្តប្បៈ, ឧទ្ធច្ចៈ, លោភៈ, ទិដ្ឋិ

៦- ឧបេក្ខាសហគតំ ទិដ្ឋិគតសម្បយុត្តំ សសង្ខារិកំ មានចេតសិក ចុះ ២០ ថែម ថីនំ និងមិទ្ធំ

៧- ឧបេក្ខាសហគតំ ទិដ្ឋិគតវិប្បយុត្តំ អសង្ខារិកំ មានចេតសិក ចុះ ១៨ គឺអញ្ញសមានា ១២ (វ/បីតិ) និងមោហៈ, អហិរិកៈ អនោត្តប្បៈ ឧទ្ធច្ចៈ, លោភៈ, មានះ

៨- ឧបេក្ខាសហគតំ ទិដ្ឋិគតវិប្បយុត្តំ សសង្ខារិកំ មានចេតសិក ចុះ ២០ គឺ អញ្ញសមានា ១២ (វ/បីតិ)មោហៈ, អហិរិកៈ, អនោត្តប្បៈ, ឧទ្ធច្ចៈ, លោភៈ, មានះ, ថីនំ មិទ្ធំ ។

**ចំណាំ :**

បើមានទិដ្ឋិមិនមាន មានះ, បើមាន មានះ , មិនមានទិដ្ឋិ ។ សោមនស្ស មានបីតិ, ឧបេក្ខាគ្មាន បីតិទេ ។ អសង្ខារិកំគ្មាន ថីនំ, មិទ្ធំ, សសង្ខារិកំមានថីនំ, មិទ្ធំ ។ សោមនស្ស, ទោសធ្ងន់ជាង ឧបេក្ខា ។ ប្រកបដោយទិដ្ឋិ មានទោសធ្ងន់ជាងគ្មានទិដ្ឋិ ។ អសង្ខារិកំ ទោសធ្ងន់ ជាងសសង្ខារិកំ ។

( ទាំងនេះសម្រាប់តែលោភមូលចិត្ត ៨ ដួង)

## ទោសមូលចិត្ត ២ ដួង :

១- ទោមនស្សសហគតំ បដិឃសម្បយុត្តំ អសង្ខារិកំ មានចេតសិក ចុះ ២០ គឺអញ្ញសមានា ១២ (វៀរបីតិ) ថែមមោហៈ, អហិរិកៈ, អនោត្តប្បៈ, ឧទ្ធច្ចៈ, ទោសៈ, ឥស្សា, មច្ឆរិយៈ កុក្កុច្ចៈ

២- ទោមនស្សសហគតំ បដិឃសម្បយុត្តំ សសង្ខារិកំ មានចេតសិក ចុះ ២២ ( ទី១មានចេតសិក ២០ ថែម ថីនំ, មិទ្ធំ) ។

## មោហមូលចិត្ត ២ ដួង :

១- ឧបេក្ខាសហគតំ វិចិកិច្ឆាសម្បយុត្តំ មានចេកសិក ចុះ ១៥ គឺ អញ្ញសមានា ១០ (វៀរបីតិ អធិមោក្ខៈ ឆន្ទៈ) ថែម មោហៈ អហិរិកៈ, អនោត្តប្បៈ, ឧទ្ធច្ចៈ, វិចិកិច្ឆា

២- ឧបេក្ខាសហគតំ ឧទ្ធច្ចសម្បយុត្តំ មានចេតសិក ចុះ ១៥ គឺ អញ្ញសមានា ១១ ( វៀរបីតិ, ឆន្ទៈ) ថែមមោហៈ អហិរិកៈ, អនោត្តប្បៈ ឧទ្ធច្ចៈ ។

## មហាកុសល ៨ដួង :

១- សោមនស្សសហគតំ ញាណសម្បយុត្តំ អសង្ខារិកំ មានចេតសិក ចុះ ៣៨ គឺអញ្ញសមានា ១៣ សោភណចេតសិក ២៥

២- សោមនស្សសហគតំ ញាណសម្បយុត្តំ សសង្ខារិកំ មានចេតសិក ចុះ ៣៨ ដូចទី១ ខុសគ្នាតែត្រង់សសង្ខារិកំ គឺមិនមានអ្នកដឹកនាំ

៣- សោមនស្សសហគតំ ញាណវិប្បយុត្តំ អសង្ខារិកំ មានចេតសិក ចុះ ៣៧ គឺអញ្ញសមានា ១៣ សោភណចេតសិក ២៤ (វៀរបញ្ញា)

៤- សោមនស្សសហគតំ ញាណវិប្បយុត្តំ សសង្ខារិកំ មានចេតសិក ចុះ ៣៧ ដូចទី២ ដែរ ខុសគ្នាតែត្រង់សសង្ខារិកំ

៥-ឧបេក្ខាសហគតំ ញាណសម្បយុត្តំ អសង្ខារិកំ មានចេតសិក ចុះ ៣៧ គឺអញ្ញសមានា ១២ (វៀរបីតិ) សោភណចេតសិក ២៥

៦- ឧបេក្ខាសហគតំ ញាណសម្បយុត្តំ សសង្ខារិកំ មានចេតសិក ចុះ ៣៧ ដូចទី ៥ ដែរ ខុសគ្នានៅត្រង់សសង្ខារិកំ

៧- ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ អសង្ខារិកំ មានចេតសិក ចុះ ៣៦ គឺ អញ្ញសមានា ១២ (វៀរបីតិ) និងសោភណចេតសិក ២៤ (វៀរបញ្ញា)

៨-ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ សសង្ខារិកំ មានចេតសិក ចុះ ៣៦ ដូចទី ៧ ដែរខុសគ្នានៅត្រង់ សសង្ខារិក ។

**មហគ្គតកុសល ៩ដួង :**

រូបាវចរកុសល ៥ អរូបាវចរកុសល ៤

**លោកុត្តរកុសល ៤ដួង :**

សោតាបត្តិមគ្គចិត្ត ៤ សកទាគាមិមគ្គចិត្ត ៤

អនាគាមិមគ្គចិត្ត ៤ អរហត្តមគ្គចិត្ត ៤

**អព្យាកតចិត្ត ៥៦ ដួង** ចែកជា ២ ពួក :

* វិបាកចិត្ត មាន ៣៦ ដួង
* កិរិយាចិត្តមាន ២០ ដួង

វិបាកចិត្តជាផលរបស់កុសល និងអកុសល ដូចជា មហាកុសល ៨ នាំឱ្យមានវិបាក ៨ និងកុសលវិបាកអហេតុក ៨ ត្រូវជាវិបាកចិត្ត ១៦ អកុសលចិត្ត ១២ នាំឱ្យមានអកុសលវិបាក ៧ ហៅថា អកុសលវិបាក អហេតុក ៧ ។

**អកុសលវិបាកចិត្ត ៧ ដួង:**

១- ឧបេក្ខាសហគតំ ចក្ខុវិញ្ញាណំ មានចេតសិក ចុះ ៧ គឺសព្វចិត្តសាធារណចេតសិក ៧

២- ឧបេក្ខាសហគតំ សោតវិញ្ញាណំ មានចេតសិក ចុះ ៧ ដូចគ្នា

៣- ឧបេក្ខាសហគតំ ឃានវិញ្ញាណំ មាន ចេតសិក ចុះ ៧ ដែរ

៤- ឧបេក្ខាសហគតំ ជិវ្ហាវិញ្ញាណំ មាន ចេតសិក ចុះ ៧

៥- ទុក្ខសហគតំ កាយវិញ្ញាណំ មានចេតសិក ចុះ ៧

៦- ឧបេក្ខាសហគតំ សម្បដិច្ឆន្នចិត្តំ មានចេតសិក ចុះ ១០ គឺ សព្វចិត្តសាធារណចេតសិក ៧ ថែម វិតក្កៈ វិចារៈ និង អធិមោក្ខៈ

៧- ឧបេក្ខាសហគតំ សន្តីរណចិត្តំ មានចេតសិក ចុះ ១០ ដូច សម្បដិច្ឆន្នដែរ ។

## អហេតុកកុសលវិបាកចិត្ត ៨ ដួង :

១- ឧបេក្ខាសហគតំ ចក្ខុវិញ្ញាណំ មានសព្វចិត្តសាធារណៈ ចេតសិក ចុះ ៧

២- ឧបេក្ខាសហគតំ សោតវិញ្ញាណំ មានចេតសិក ចុះ ៧ ដែរ

៣- ឧបេក្ខាសហគតំ ឃានវិញ្ញាណំ មានចេតសិក ចុះ ៧ ដូចគ្នា

៤- ឧបេក្ខាសហគតំ ជិវ្ហាវិញ្ញាណំ មានចេតសិក ចុះ ៧ ដែរ

៥- សុខសហគតំ កាយវិញ្ញាណំ មានចេតសិក ចុះ ៧ ទៀត

៦- ឧបេក្ខាសហគតំ សម្បដិច្ឆន្នចិត្តំ មានចេតសិក ចុះ ១០ គឺ សព្វចិត្តសាធារណចេតសិក ៧ ថែម វិតក្កៈ វិចារៈ និងអធិមោក្ខ

៧- ឧបេក្ខាសហគតំ សន្តីរណចិត្តំ មានចេតសិក ចុះ ១០ គឺ អញ្ញសមានា ចេតសិក ១៣ ( វៀរបីតិ, វិរិយៈ, ឆន្ទៈ)

៨- សោមនស្សសហគតំ សន្តីរណចិត្តំ មានចេតសិកចុះ ១១ ថែមបីតិ ។

**ពន្យល់** : អនិដ្ឋារម្មណ៍ គឺអារម្មណ៍មិនល្អ មិនជាទីគាប់ចិត្ត, បើឥដ្ឋារម្មណ៍ គឺអារម្មណ៍ល្អគួរជាទីគាប់ចិត្ត,ដល់ទៅអតិឥដ្ឋារម្មណ៍ គឺអារម្មណ៍ល្អក្រៃលែង ។

**មហាវិបាក ៨ ដួង** ចែកដូច មហាកុសលដែរ :

១- មហាវិបាកទី ១ និងទី ២ មានចេតសិកចុះ ៣៣ គឺអញ្ញសមានា ១៣, សោភណ ២០ ( វៀរវិរតិ ៣ និង អប្បមញ្ញា ២)

២- មហាវិបាកទី ៣ និងទី៤ មានចេតសិក ចុះ ៣២ គឺ អញ្ញសមានា ១៣, សោភណ ១៩ ( វៀរបញ្ញាថែម មួយទៀត)

៣-មហាវិបាកទី ៥ និងទី ៦ មានចេតសិក ចុះ ៣២ គឺ អញ្ញសមានា ១២ ( វៀរបីតិ), សោភណ ២០ ( វៀរវិរតិ ៣, អប្បមញ្ញា ២)

៤-មហាវិបាកទី ៧ និងទី ៨ មានចេតសិក ចុះ ៣១ គឺ អញ្ញសមានា ១២ (វៀរបីតិ), សោភណ ១៩ (វៀរបញ្ញា, វិរតិ ៣, អប្បមញ្ញា ២) ។

## មហគ្គតវិបាក ៩ ដួង :

១- រូបាវចរវិបាក ៥ ជាតួបដិសន្ធិ

២- អរូបាវចរវិបាក ៤ ជាតួបដិសន្ធិដូចគ្នា មានចេតសិក ចុះដូច មហគ្គតកុសលដែរ ។

### លោកុត្តរវិបាក ៤ គឺ

១- សោតាបត្តិផលចិត្ត ៤ សកទាគាមិផលចិត្ត ៤

២- អនាគាមិផលចិត្ត ៤ អរហត្តផលចិត្ត ៤ ។

## សរុបវិបាកចិត្ត :

| | |
|---|---|
| អកុសលវិបាកអហេតុក | ៧ ដួង |
| កុសលវិបាកអហេតុក | ៨ ដួង |
| មហាវិបាក | ៨ ដួង |
| មហគ្គតវិបាក | ៩ ដួង |
| លោកុត្តរវិបាក | ៤ ដួង |
| ត្រូវជាវិបាកចិត្ត | ៣៦ ដួង |

## កិរិយាចិត្ត ២០ ដួង :

### * អហេតុកកិរិយា ៣ ដួង:

១- ឧបេក្ខាសហគតំ បញ្ចទ្វារាវជ្ជនចិត្តំ នឹករាវរកអារម្មណ៍ក្នុងទ្វារ ទាំង ៥ ព្រមដោយឧបេក្ខាវេទនា មានចេតសិក ចុះ ១០ គឺ សព្វចិត្តសាធារណ ចេតសិក ៧ + (វិតក្កៈ វិចារៈ អធិមោក្ខៈ)

២- ឧបេក្ខាសហគតំ មនោទ្វារាវជ្ជនចិត្តំ នឹករាវរកអារម្មណ៍ក្នុងមនោទ្វារព្រមដោយឧបេក្ខាវេទនា មានចេតសិក ចុះ ១១ គឺ អញ្ញសមានា ១១ (វៀរបីតិ និងឆន្ទៈ)

៣- សោមនស្សសហគតំ ហសិតុប្បាទចិត្តំ ហៅថាចិត្តរីករាយរបស់ ព្រះអរហន្ត ប្រកបដោយសោមនស្សវេទនា មានចេតសិក ចុះ ១២ (វៀរឆន្ទៈ) ។

### * មហាកិរិយា ៨ ដួង :

ចែកដូចមហាកុសល ៨ ដែរ ប៉ុន្តែមហាកិរិយា ៨ នោះមានតែក្នុងព្រះអរហន្តប៉ុណ្ណោះ ដែលមានចេតសិក ចុះ ដូចតទៅនេះ ÷

១-២ ចេតសិក ចុះ ៣៥ (វៀរវិរតិ ៣)

៣-៤ ចេតសិក ចុះ ៣៤ (វៀរបញ្ញា + វិរតិ ៣)

៥-៦ ចេតសិក ចុះ ៣៤ (វៀរបីតិ + វិរតិ ៣)

៧-៨ ចេតសិក ចុះ ៣៣ ( វៀរបីតិ + បញ្ញា + វិរតិ ៣)

**ចំណាំ** : ចេតសិកក្នុងមហាកិរិយា ៨ នេះ ដូចចុះក្នុងមហាកុសល ដែរ ប៉ុន្តែគ្មានវិរតិ ៣ ទេ ។ នៅក្នុងន័យនេះ សោភណចេតសិក ២៥ ចុះតែ ២១ ព្រោះវៀរវិរតិ ៣ និងបញ្ញា ១ ។ ចំនួនចេតសិក ដែលប្រកបក្នុង មហាកិរិយាចិត្តទាំងអស់មានត្រឹម ៣៥ ដួងគត់ ។

## * មហគ្គតកិរិយា ៩ ដួង :

- រូបាវចរកិរិយា ៥ មានតែក្នុងសន្តានព្រះអរហន្ត ។
- អរូបាវចរកិរិយា ៤ ក៏មានតែក្នុងសន្តានព្រះអរហន្តដែរ ។

មហគ្គតកុសលក្តី, មហគត្តវិបាកក្តី, មហគ្គតកិរិយាក្តី ចេតសិកចុះ ដូចៗគ្នាទាំងអស់ ។

## សរុបកិរិយាចិត្តទាំងអស់ :

| | |
|---|---|
| - អហេតុកកិរិយា | ៣ ដួង |
| - មហាកិរិយា | ៨ ដួង |
| - មហគ្គតកិរិយា | ៩ ដួង |
| ត្រូវជាកិរិយាចិត្ត | ២០ ដួង |

## **សរុបចិត្ត ៨៩ ដួង :**

| | | |
|---|---|---|
| - កុសលចិត្ត | ២១ ដួង | |
| - អកុសលចិត្ត | ១២ ដួង | |
| - វិបាកចិត្ត | ៣៦ ដួង | អព្យាកតចិត្ត ៥៦ |
| - កិរិយាចិត្ត | ២០ ដួង | |
| ទាំងអស់ត្រូវជាចិត្ត | ៨៩ ដួង | |

## **អំពីចិត្តពិស្តារ ១២១ ដួង :**

មហាកុសលចិត្ត ៨ ដួង ចែករួចហើយ

មហគ្គតកុសលចិត្ត ៩ ដួង ចែករួចហើយ

**លោកុត្តរកុសលចិត្ត ២០ដួង** ដោយពិស្តារចែកតាមឈាន៥ :

-ក្នុងបឋមជ្ឈានមានមគ្គ ៤ ចេតសិក ចុះ ៣៦ គឺ អញ្ញសមានា ១៣ សោភណ ២៣ ( វៀរអប្បមញ្ញា ២)

-ក្នុងទុតិយជ្ឈានមានមគ្គ ៤ ចេតសិក ចុះ ៣៥ (វៀរវិតក្កៈតពីបឋមជ្ឈាន)

-ក្នុងតតិយជ្ឈានមានមគ្គ ៤ ចេតសិក ចុះ ៣៤ ( វៀរវិចារៈ មួយទៀត) បន្ទាប់ពីទុតិយជ្ឈាន

-ក្នុងចតុត្ថជ្ឈានមានមគ្គ ៤ ចេតសិក ចុះ ៣៣ ( វៀរបីតិ មួយទៀត)

- ក្នុងបញ្ចមជ្ឈានមានមគ្គ ៤ ចេតសិក ចុះ ៣៣ ដែរ ដូច ចតុត្ថជ្ឈាន គឺ អញ្ញសមានា ១០ (វៀរវិតក្កៈវិចារៈបីតិ) សោភណ ២៣ (វៀរអប្បមញ្ញា២) ។

**<u>បញ្ជាក់ថា</u>** : អប្បមញ្ញា ២ មិនមានក្នុងលោកុត្តរចិត្តទេ ។

ពាក្យថា អប្បមញ្ញា បានន័យថា ប្រមាណមិនបាន ។

### រួមកុសលចិត្តពិស្តារ ៣៧ ដួង គឺ

- មហាកុសល ៨ដួង
- មហគ្គតកុសល ៩ដួង

} ១៧ ដួងនេះជាលោកិយ

- លោកុត្តរកុសលល ២០ ដួង

អកុសលចិត្ត ១២ ដួង ចែករួចហើយ ។

### វិបាកចិត្តពិស្តារ ៥២ ដួង គឺ

- អកុសលវិបាកអហេតុកចិត្ត ៧
- កុសលវិបាកអហេតុកចិត្ត ៨
- មហាវិបាកចិត្ត ៨
- មហគ្គតវិបាកចិត្ត ៩

} ចិត្ត ៣២ ដួងនេះ ជាលោកិយវិបាក

លោកុត្តរវិបាកចិត្តពិស្ដារ ២០ គឺ រាប់តាមឈាន ៥ ដូចតទៅ :

ឈានទី ១ មានផល ៤

ឈានទី ២ មានផល ៤

ឈានទី ៣ មានផល ៤

ឈានទី ៤ មានផល ៤

ឈានទី ៥ មានផល ៤ ត្រូវជាផល ២០ ដូចលោកុត្តរកុសលដែរ ។ រួមលោកុត្តរវិបាកចិត្ត ២០ និង លោកិយវិបាក ៣២ ត្រូវជាវិបាក ចិត្តដោយពិស្ដារ ៥២ ។

## សរុបចិត្តពិស្ដារ :

| | | |
|---|---|---|
| កុសលចិត្ត | ៣៧ ដួង | |
| អកុសលចិត្ត | ១២ ដួង | |
| វិបាកចិត្ត | ៥២ ដួង | អព្យាកតចិត្ត ៧២ ដួង |
| កិរិយាចិត្ត | ២០ ដួង | |

ត្រូវជាចិត្តទាំងអស់មាន ១២១ ដួង ដោយពិស្ដារ ។

ពាក្យថាអហេតុកចិត្តបានដល់ចិត្តពុំមានហេតុ ៦ ឯហេតុដទៃក្រៅពីនេះនៅមាន ចំណែកសហេតុកចិត្តប្រកបដោយហេតុ ៦ ផង និងហេតុដទៃផង ។

## សម្រួលឱ្យងាយក្នុងការសិក្សា ៖

១- ទ្វិបញ្ចវិញ្ញាណចិត្ត ១០ មានចេតសិកប្រកប ៧ គឺ សព្វចិត្តសាធារណចេតសិក ៧ ។

២- ឧបេក្ខាសហគតំ បញ្ចទ្វារាវជ្ជនចិត្តំ មានចេតសិក ចុះ ១០ បានដល់ សព្វចិត្តសាធារណចេតសិក ៧ + ( វិតក្កៈ វិចារៈ អធិមោក្ខៈ ) ។

៣- សម្បដិច្ឆន្នចិត្តំ ២ ដួង ឧបេក្ខាសន្តីរណចិត្ត ២ ដួង បញ្ចទ្វារាវជ្ជនចិត្តំ ១ ទាំង ៥ នេះមាន ចេតសិកប្រកប ១០ ដួង ( វៀរ វីរិយៈ បីតិ ឆន្ទៈ ) ។

៤- សោមនស្សសហគតំ សន្តីរណចិត្តំ មានចេតសិកប្រកប ១១ ដួង ( វៀរវីរិយៈ ឆន្ទៈ ) ។

៥- ឧបេក្ខាសហគតំ មនោទ្វារាវជ្ជនចិត្តំ មានចេតសិកប្រកប ១១ ដួង គឺអញ្ញសមានាចេតសិក ១១ ( វៀរបីតិ និងឆន្ទៈ )

៦- សោមនស្សសហគតំ ហសិតុប្បាទចិត្តំ មានចេតសិក ចុះ ១២ បានដល់ អញ្ញសមានា ១២ ( វៀរឆន្ទៈ ) ។

## អសោភណចិត្ត ៣០ គឺ

អកុសលចិត្ត ១២ + អហេតុកចិត្ត ១៨ ។ ក្នុងចិត្ត ៨៩ ឬ ១២១ ដួង ចែកចេញជា ៣ ភូមិ ៖

១- ភូមិកាមាវចរមាន ៥៤ ដួង ចែកចេញជា ៤ ជាតិ គឺ កុសលជាតិ ១ អកុសលជាតិ ១ វិបាកជាតិ ១ កិរិយាជាតិ ១ ។

**សរុប** វិបាកនិងកិរិយាបានជាអព្យាកតជាតិ ព្រោះពុំមានកុសល និង អកុសល ។

២- មហគ្គតភូមិចែកជា ២ គឺរូបាវចរភូមិ ១ និងអរូបាវចរភូមិ ១ មាន ៣ ជាតិ បានដល់ កុសលជាតិ ១ វិបាកជាតិ ១ និង កិរិយាជាតិ ១ ។

៣- លោកុត្តរភូមិមានតែ ២ ជាតិ គឺមគ្គ ៤ ហៅថាកុសលជាតិ និងផល ៤ ហៅថា វិបាកជាតិប៉ុណ្ណោះ ។

(ដកស្រង់ពីក្នុងមេរៀនបង្រៀន ដោយលោកគ្រូអគ្គបណ្ឌិតជាម្ចាស់) ។

ចិត្តទាំងអស់ត្រូវប្រែប្រួលវិនាសទៅដូចគ្នា ព្រោះជាជីវិតកើតរលត់ៗ បន្តគ្នារៀងរហូតពុំមានឈប់សម្រាកធ្វើការងារអ្វីផ្សេងៗ ក្រៅពីប្រមូលកៀរគរនូវវិបាកកម្មទាំងឡាយតាំងពីអតីតជាតិ និងបច្ចុប្បន្នជាតិដែលកំពុងរស់នៅ ចងក្រងលោកដោយកិលេសតណ្ហា ធ្វើជាសំណុំរឿងបញ្ជូនទៅថ្វាយសក្កទេវរាជឯឋានសួគ៌និងស្ដេចយមរាជឱ្យជម្រះបញ្ជីរឿងនៅឋាននរក ។ ការប្រែប្រួលបែបនេះ ពុំមានអ្វីឱ្យពិតប្រាកដមាំទាំកក់ក្ដៅ ព្រោះត្រឹមតែជាសង្ខារតាក់តែងពីហេតុប្បច្ច័យរបស់លោកដែលពុំមានខ្លឹមសារ ឬស្នូល ឬមានខ្លួនច្បាស់លាស់សម្រាប់ឱ្យជ្រកនៅ

ប្រៀបដូចជា វាលល្ហល្ហេវ ពុំមានកោះត្រើយគួរនឹងសំចត ដែលជាហេតុបណ្ដាលគ្រប់វត្ថុសម្ភារៈ ឱ្យប្រែប្រួលមានសភាពមិនទៀងទាត់នោះឯង។

លោក គឺធម្មជាតិទាំងឡាយ (អនុបាទិន្នកសង្ខារ) ដូចជាដើមឈើ ព្រៃភ្នំ ក្រំថ្ម វាលខ្សាច់ សមុទ្រ បឹងបួរ មច្ឆាជាតិ នៅក្នុងទឹក សត្វហើរក្នុងអាកាស សត្វចតុប្បាទ ទ្វេបាទ ក៏ត្រូវប្រែប្រួល វិនាសដូចគ្នា ដែលឋិតនៅក្នុងភាពមិនទៀងទាត់តាមកម្លាំងអូសទាញ ពីទំនាញផែនដី ពុំមានសត្វបុគ្គលអ្នកកសាង អ្នកទទួលផលនូវចំណែកបច្ចយុប្បន្នធម៌ ជាទុក្ខដោយអត្ថថា មិនទៀងនោះឡើយ ។ លោកនៃការវិនាស បែកធ្លាយនេះ មិនមែនសុទ្ធតែពុំមានសារៈខ្លឹមសារប៉ុណ្ណោះទេ អ្នកខ្លះគេយកពាក្យលោកនេះទៅប្រើប្រាស់ក្នុងកិច្ចការ តាមក្រសួងមន្ទីរ តាមការិយាល័យ ឬក្នុងគ្រួសារសម្រាប់ជាពាក្យហៅឱ្យ ពីរោះស្ដាប់ក្នុងសភាពថ្លៃថ្នូរ ដូចគេហៅថា លោកប្រុស លោកស្រី លោកកូន លោកឪពុក លោកម្ដាយ ឬលោក "ក" លោក "ខ" តាមដែលគេធ្លាប់និយមចូលចិត្តប្រើប្រាស់ទៅតាមសម័យ ។

លោកបរមត្ថនៃការរស់នៅនេះ ពុំដែលចិត្តល្អសម្រាប់យើងម្ដងណាឡើយ ចូលចិត្តទាញយកផលកម្រៃពីយើងគ្រប់ពេលគ្រប់ដង្ហើមចេញចូល ទោះបានអ្វីៗបន្តិចបន្តួចក៏មិនដែលអនុគ្រោះ តែងឆក់ទាញយកទៅទំពាស៊ី តាមអំណាចខ្លួន ឬកេងយកកម្លាំងពលកម្មតាំងពីរូប សំឡេង

ក្លិន រស ផោដ្ឋព្វៈ ក៏ប្រលោមលួងលោមចិត្តយើងឱ្យបម្រើតាមចំណង់ចំណូលចិត្តខ្លួន រួចក៏បោះបង់ចោលគ្មានអាណិតមេត្តា ។ មិនតែប៉ុណ្ណោះ លោកនេះតែងបង្ខិតបង្ខំយើងជានិច្ចកាលក្នុងការរកប្រាក់កាស ដើម្បីបម្រើម្ចាស់បំណុល (ចៅកែតណ្ហា) មិនចេះគ្រប់គ្រាន់ថែមទាំងទាមទារយកអាយុជីវិតរៀងរាល់ថ្ងៃ ទោះបីអង្វរករលោកនេះយ៉ាងណាក៏ពុំព្រមដែរ ដូចមានព្រះគាថាទ្រង់ត្រាស់សំដែងថា :

**យថា ទណ្ឌេន គោបាលោ គាវោ បាជេតិ គោចរំ**

**ឯវំ ជរា ច មច្ចូ ច អាយុំ បាជេន្តិ បាណិនំ**

ប្រែ : គង្វាលគោ កៀងគោទាំងឡាយទៅកាន់ទីគោចរ ដោយអាជ្ញាគឺដំបង និងរំពាត់យ៉ាងណាមិញ ជរា គឺសេចក្តីទ្រុឌទ្រោមគ្រាំគ្រា និងមច្ចុរាជ (សេចក្តីស្លាប់) ក៏កៀងទៅនូវអាយុសង្ខាររបស់សត្វទាំងឡាយក៏យ៉ាងនោះដែរ ។

**មើលលោកនេះ ដោយការពិចារណា :**

លោកគឺ រូបារម្មណ៍,សទ្ទារម្មណ៍, គន្ធារម្មណ៍, រសារម្មណ៍, ផោដ្ឋព្វារម្មណ៍ និងធម្មារម្មណ៍ គឺមើលអ្វីៗ នៅក្នុងខ្លួនយើងម្នាក់ៗជាមុនថា តើកន្លងផុតទៅអាត្មាអញ បានប្រព្រឹត្តធ្វើអ្វីខ្លះ បើមានការខ្វះខាតពុំទាន់បានធ្វើសេចក្តីល្អទេក៏គួរ ប្រឹងប្រែងបំពេញនូវ អំពើកុសល

ទាំងឡាយកុំបណ្តែតបណ្តោយធ្វេសប្រហែស ទុកឱកាសឱ្យបាបខ្ចីយកទៅប្រើប្រាស់ចោលទទេគ្មានបានអ្វីសោះ គួរបំពេញទាន សមាទានសីល ចម្រើនបញ្ញាឱ្យទាន់ពេលកំពុង មានជីវិតរស់នៅ ។

**មើលលោកនេះ ដោយការប្រុងប្រយ័ត្នខ្ពស់** ព្រោះសុទ្ធតែអន្ទាក់នៃមារដែលជានិមិត្តរបស់កលមាយាចិត្តតាមអារម្មណ៍ ៦ ក្នុងទ្វារណាមួយធ្វើឱ្យយើងស្រមើស្រមៃរាល់ថ្ងៃ ដោយការច្នៃប្រឌិតរបស់តណ្ហាបណ្តាលជា រូបភាពគួរស្រឡាញ់ចូលចិត្តត្រេកត្រអាល នៅក្នុងកាមគុណទាំងឡាយ ជូនស្អប់បដិឃៈ ប្រទូស្តនឹងអារម្មណ៍ខ្លួនឯងដែលអារម្មណ៍នោះៗ គ្មានអ្វីគួរឱ្យភ័យតក់ស្លុតឬជាប់ជំពាក់ ព្រោះអារម្មណ៍ណាៗក្នុងលោកសុទ្ធតែមានម្ចាស់របស់គេហួងហែងថែរក្សា ដោយ អនិច្ចំ, ទុក្ខំ, អនត្តារួចហើយ ពុំចាំបាច់មានអ្នកដទៃណាមកជំនួស មានតែជួយបំភ្លឺផ្លូវដល់អ្នកវង្វេងឱ្យភ្ញាក់រឭកមករកភាពល្អត្រឹមត្រូវជាប្រក្រតីធម្មតា ដែលគួរណាស់មានមេត្តាចិត្តគាំទ្រលោកឱ្យដល់គ្នានឹងគ្នា បណ្តុះចិត្តល្អខ្លួនឯងនេះហៅថា ការជួយអ្នកដទៃឱ្យបានសុខពុំគិតពីផលប្រយោជន៍ព្រោះពុំមានអត្តាតួខ្លួនអ្នកទទួលផល មានត្រឹមតែសភាវៈជារបស់ឧបត្តិកឡើងតាមហេតុប្បច្ច័យគ្មានសារៈខ្លឹមសារសម្រាប់បុគ្គលណាម្នាក់ដែលលោកនេះគ្របសង្កត់ចិត្តរាល់ថ្ងៃនាំឱ្យមានសេចក្តីទុក្ខរាប់កប្បជាតិ ពុំមានអ្នកណាមកជួយស្រោចស្រង់ប្រោសប្រណីអាណិតអាសូរក្រៅពីករុណាទិគុណ

របស់ព្រះអនាវរណញ្ញាណ ។ លោកនេះ សុទ្ធតែគ្រឿងស្មោកគ្រោក ដែលពុំមានអ្វីធ្វើឱ្យសុខស្ងប់ក្រៅពីគិតតែរឿង សប្បាយភ្លើតភ្លើន នូវរបស់ខាងក្រៅ ។ កាលបើមានទ្រព្យសម្បត្តិច្រើន មានបុណ្យសក្តិខ្ពង់ខ្ពស់ឧត្តុង្គឧត្តម មានគេសរសើរនិងមានសេចក្តីសុខមួយគ្រាតូច ក៏រីករាយសោមនស្សយ៉ាងក្រៃលែងដែលជីវិតរស់នៅមួយអត្តភាពត្រឹមមួយជួរខណៈនៃវិថីចិត្ត លុះអារម្មណ៍ទាំងនោះប្រែប្រួលវិនាសទៅវិញ ក៏មានសេចក្តីភ័យព្រួយ យំសោកកន្ទក់កន្ទេញចង់បានរបស់នោះមកវិញ ។ ម្យ៉ាងទៀត សត្វលោករស់នៅសព្វថ្ងៃចូលចិត្តត្រេកត្រអាល តែនឹងអារម្មណ៍ខាងក្រៅ ទោះបីឋិតក្នុងសភាពណាក៏ដោយ សំខាន់គឺការស្វែងរកទ្រព្យសម្បត្តិរៀងរាល់ថ្ងៃមិនឈប់ឈរ ទោះបីបានតិចឬច្រើនទៅតាមលទ្ធភាពរបស់ខ្លួនហាក់ដូចមិនចេះឆ្អែតសោះ រហូតដល់ទៅរកទ្រព្យបានច្រើនៗធ្វើជាមហាសេដ្ឋីក៏នៅតែពោលថាមិនគ្រប់គ្រាន់ មិនស្កប់ស្កល់ដោយចេះតែត្រូវការនេះត្រូវការនោះ (កម្លាំង តណ្ហាខ្លាំង) លុះត្រាតែលែងត្រូវការទើបរកសេចក្តីស្ងប់ឃើញ ។ រូប, សំឡេង, ក្លិន, រស, ផោដ្ឋព្វៈ និងធម្មារម្មណ៍ជារបស់ក្រៅខ្លួន ប៉ុន្តែវត្ថុទាំង ៦ នេះ កើតចេញពីសន្តានចិត្តខាងក្នុង ដែលធ្វើឱ្យមានការស្រឡាញ់ស្អប់ បង្កប់អាថិកំបាំងថាមានអ្នកដទៃពេញចិត្តខ្លួន ស្អប់ខ្លួនឬក៏បង្កើតការសប្បាយតាមកាមារម្មណ៍ដូចជា បរិភោគអាហារមានរសឆ្ងាញ់នៅតាមផ្ទះឬនៅ

ភោជនីដ្ឋាននិងមើលល្បែងកម្សាន្ត មានការរាំច្រៀងប្រគំតន្ត្រី លេងកីឡាវាយកូនឃ្លី រត់ប្រណាំង ឬក៏ទៅមើលទីកន្លែងដទៃណាផ្សេង ដើម្បីសេចក្តីសប្បាយ នេះឯងជាតួទុក្ខដែលរស់នៅក្នុងការប្រើប្រាស់កម្លាំងធាតុពីកាមតណ្ហាទាំងអស់ ។ អ្វីទៅហៅថាកាម ? ឆ្លើយ : កាមបានដល់ទ្រព្យសម្បត្តិផ្សេងៗ ដែលសត្វលោកត្រូវការចាំបាច់ប្រើប្រាស់ ប្រចាំថ្ងៃដោយសេចក្តីត្រេកត្រអាល ដូចជា ដីស្រែចំការ ចម្ការ មាសប្រាក់ទ្រព្យសម្បត្តិ និងរបស់ប្រើប្រាស់ផ្សេងៗ ជាដើម ។ នៅក្នុងខុទ្ទកនិកាយមហានិទ្ទេស បឋមភាគបិដកលេខ ៦៤/៩ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្តែងឧបមា ធៀបប្រៀបកាម ទៅនឹងរបស់ ផ្សេងៗ មាន ១១ ប្រការ គឺ

១- កាមទាំងឡាយមានឧបមាដូចជារាងឆ្អឹងដោយសេចក្តីថា មានសេចក្តីត្រេកអរតិច

២- កាមទាំងឡាយមានឧបមាដូចដុំសាច់បានសេចក្តីថា ជារបស់សធារណដល់សត្វ មានប្រមាណច្រើន

៣- កាមទាំងឡាយមានឧបមាដូចគប់ភ្លើងស្មៅ ដោយសេចក្តីថា ដុត កំដៅរឿយៗ

៤- កាមទាំងឡាយមានឧបមាដូចរណ្តៅរងើកភ្លើង ដោយសេចក្តីថាមានកិរិយាក្តៅរោលរាលខ្លាំង

៥- កាមទាំងឡាយមានឧបមាដូចយល់សប្តិ ដោយសេចក្តីថាមានកិរិយាតាំងឡើងផ្តេសផ្តាស

៦- កាមទាំងឡាយមានឧបមាដូចរបស់ខ្ចីគេ ដោយសេចក្តីថាជារបស់ប្រព្រឹត្តទៅមួយដងមួយគ្រាប៉ុណ្ណោះ

៧- កាមទាំងឡាយមានឧបមាដូចឈើមានផ្លែ ដោយសេចក្តីថាមានកិរិយាបាក់ខ្ទេចខ្ទី ឬបាក់ដាច់អស់

៨- កាមទាំងឡាយមានឧបមាដូចកាំបិតនិងជ្រុញ ដោយសេចក្តីថាដាច់រេចរិល

៩- កាមទាំងឡាយមានឧបមាដូចមុខលំពែង ដោយសេចក្តីថាចាក់ទម្លុះ

១០-កាមទាំងឡាយមានឧបមាដូចក្បាលពស់វែក ដោយសេចក្តីថា ប្រកបដោយភ័យចំពោះមុខ

១១-កាមទាំងឡាយមានឧបមាដូចគំនរភ្លើង ដោយសេចក្តីថាក្តៅរោលរាលដោយភ្លើងធំ ។

**មើលលោកនេះ គួរប្រញាប់ងកខ្លួនចេញ** កុំនៅក្រាញបេះមិនចេញដូចសត្វជីងចក់តោងជាប់ស្អិតនឹងក្តារ គួររើបម្រះកុំឱ្យជាប់ជំពាក់ដូចស្តរតាំងម៉ែដែលគេកូរឱ្យស្អិតក្នុងខ្ទះ គួរលះបង់ចោល ឬកាត់បន្ថយឬវៀរកាម ដែលគ្រោតគ្រាតចេញដូចមានព្រះគាថាទ្រង់សំដែងទុក :

**យោ កាមេ បរិវជ្ជេតិ សប្បស្សេវ បទា សិរោ**

**សោមំ វិសត្តិកំ លោកេ សតោ សមតិវត្តតិ ។**

ប្រែ : បុគ្គលណាវៀរកាមទាំងឡាយ ដូចបុគ្គលវៀរក្បាលពស់ដោយជើង បុគ្គលនោះជាអ្នកមានសតិរមែងកន្លងវិសត្តិកាតណ្ហានេះក្នុងលោក ។

## ជីវភាពក្នុងសង្គម

**មើលលោកនេះ ដោយការពិចារណាចំពោះសង្គមមនុស្ស** កំពុងរស់នៅសព្វថ្ងៃមានសភាពជ្រួលច្របល់ ដោយអំពើអធម៌ខ្វះសីលធម៌ច្រើនទៅដោយចោរឆក់ ចោរប្លន់ ការកាប់សម្លាប់គ្នាគ្មានត្រាប្រណីនិងការប្រព្រឹត្ត អនាចារ ការរកទទួលទានមិនគោរពតាមធម៌និងប្រព្រឹត្តល្មើសពីច្បាប់រដ្ឋដែលធម្មជាតិមិនទទួលស្គាល់ឡើយ ។ ដើម្បីជួយកែសម្រួលឱ្យសង្គមមានប្រក្រតីធម្មតាឡើងវិញ មានតែនាំគ្នាបដិបត្តិតាមធម៌ព្រះពុទ្ធអង្គ ទើបធ្វើឱ្យមនុស្សទូទៅគ្រប់ប្រភេទមានស្ថិរភាពហ្មឹងហ្មំដូចអរិយប្រទេសចម្រើនជឿនលឿនថ្លៃថ្នូរប្រសើរខ្ពង់ខ្ពស់ មានចរិយាធម៌ មានសីលធម៌ សុជីវធម៌ ប្រព្រឹត្តធ្វើដោយកាយវាចាចិត្ត បានជាប្រយោជន៍ ក្នុងការរស់នៅឈានទៅរកសេចក្តីសុខចាំបាច់ត្រូវមានសីលធម៌ និងវិនយប្បញ្ញត្តិគឺការអប់រំចិត្ត ។

## អ្វីទៅហៅថាសីលធម៌ ?

ពាក្យថា សីលធម៌ កើតចេញពីពាក្យ សភាវធម៌ ដែលមានន័យថា ល្អ ស្អាត បរិសុទ្ធសម្រាប់មនុស្សប្រព្រឹត្តធ្វើដោយកាយវាចាចិត្ត ដើម្បីសេចក្តីសុខចម្រើនក្នុងសង្គមមនុស្ស ។

សីលធម៌ញែកចេញជា ២ ពាក្យ គឺ សីល + ធម៌ ដែលសរសេរនៅក្នុង វ/ក របស់សម្តេចព្រះសង្ឃរាជ ជួន ណាត ជោតញ្ញាណោថា :

* សីលបានដល់ វិរតិចេតនា ដែលវៀរចាកអំពើអាក្រក់, ការកាន់យក ឬប្រព្រឹត្តល្អ ដោយកាយវាចា និងការមិនប្រព្រឹត្តកន្លងសិក្ខាបទ ឬវិនយប្បញ្ញត្តិ ។ ការកាន់យកនូវចរិយាល្អ, ការសង្រួម អង្គនៃចរិយា, ចរិត ចរិយា មារយាទល្អ, សេចក្តីល្អ, គតិ, លក្ខណៈ, និស្ស័យ, អធ្យាស្រ័យ, សភាព, ប្រក្រតី, ទម្លាប់, សណ្តាប់ធ្នាប់, ធម្មជាតិ, ធម្មតា ។

ធម្មៈ ឬធម៌ សំដៅយកអំពើល្អ, មានគុណធម៌ល្អ គឺសីលគុណ សមាធិគុណ បញ្ញាគុណ ឬព្រហ្មវិហារធម៌ ៤ ក៏បាន ។ ដូច្នោះ សីលធម៌ជាធម៌ជួយឧបត្ថម្ភដល់ការរស់នៅក្នុងសង្គមលោកប្រកបដោយកុសលធម៌ ។

* សីលធម៌ជាជំហានដំបូងរបស់មនុស្សរស់នៅប្រចាំថ្ងៃ ដែលជីវិតត្រូវទទួលយកអំពើល្អដើម្បីជួយការពាររារាំងទប់ស្កាត់នូវអំពើអាក្រក់ទាំងឡាយមកបៀតបៀន មកព្យាបាទ ដោយអកុសលវិបាកណាមួយ ។

មនុស្សយើងបានអត្តភាពជាមនុស្សនេះ មានសេចក្តីប្រាថ្នាត្រូវការមិនចេះឆ្អែតព្រោះតណ្ហា (សមុទយទុក្ខ) ។ ដោយសារតែសេចក្តីត្រូវការមិនស្រាកស្រាន្ត ទើបនាំឱ្យមនុស្សមានការប្រណាំងប្រជែង ចង់បាននូវអ្វីៗទាំងឡាយ(បច្ច័យ៤) ដណ្តើមគ្នារស់រៀងៗខ្លួន ជាហេតុធ្វើឱ្យដុះដាលលូតលាស់ចម្រើននូវអកុសលធមិដូចមានការប្រទូសរ៉ាយ ជាញឹកញាប់ ដោយខ្វះប្រដាប់ការពារគឺសីលធមិដែលលោកកំពុងស្រេកឃ្លានពន់ពេកណាស់ ។ ចំណែកទ្រព្យសម្បត្តិមាសប្រាក់ក៏ជាសេចក្តីត្រូវការមួយផ្នែកដែរ កាលបើពុំមានលក្ខណសម្បត្តិគុណគឺសេចក្តីល្អទេ សេចក្តីសុខរបស់ជីវិតពិតជានឹងទទួលទុក្ខទោសគ្រោះថ្នាក់ រហូតដល់អាយុជីវិតជាមិនខាន ។ ព្រោះដូច្នោះបានជាព្រះពុទ្ធអង្គជ្រាបច្បាស់នូវហេតុនោះព្រះអង្គទ្រង់ប្រទានធម្មវិសេសទេសនាឱ្យមនុស្សទាំងឡាយ វៀរនូវអំពើអាក្រក់សាងកម្មល្អ មានកុសលកម្មបថជាដើម គឺកាយកម្ម ៣, វចីកម្ម ៤ មនោកម្ម ៣ របស់កុសលកម្មបថ ១០ តែក្នុងទីនេះសំដៅទៅលើកម្មបថ ៧ ជាតួចេតនាសីលដូចតទៅនេះ ÷

១- កាយកម្ម ៣ ជាកុសលកម្មបថ ៣ បានដល់ៈ

- វៀរចាកការសម្លាប់សត្វ

- វៀរចាកការកាន់យកទ្រព្យរបស់អ្នកដទៃ ដែលគេមិនបានឱ្យ ដោយកាយ ឬដោយវាចា

- វៀរចាកការប្រព្រឹត្តខុសក្នុងកាមទាំងឡាយមានប្រពន្ធកូន អ្នកដទៃ ជាដើម ។

២ - វចីកម្ម ៤ ជាកុសលកម្មបថ ៤ បានដល់ :

- វៀរចាកការនិយាយពាក្យកុហក

- វៀរចាកការនិយាយពាក្យគំរោះគំរើយ

-វៀរចាកការនិយាយពាក្យបញ្ចិតបញ្ចៀងចាក់ដោត នាំឱ្យអ្នកដទៃ មិនសប្បាយក្តៅក្រហាយចិត្ត

-វៀរចាកការនិយាយលេងឥតប្រយោជន៍ ត្រូវនិយាយតែពាក្យណាត្រឹមត្រូវ និងមានប្រយោជន៍ ។

* សីលធម៌ក្នុងសង្គម ធ្វើមនុស្សឱ្យចេះរួមរស់ប្រកបដោយសាមគ្គីធម៌ មិនចេះមើលបណ្តាំគ្នា គិតតែប្រឹងបំពេញភារកិច្ចរៀងខ្លួន ដើម្បីសាងសុភមង្គលក្នុងគ្រួសារ ក្នុងប្រទេសនីមួយៗ ក៏រអិលទៅដល់សុខសន្តិភាពនៃសង្គមលោកទូទាំងប្រទេសទៀតផង ។

កាលណាគេនិយាយពីសីលធម៌ ក៏គេរាប់បញ្ចូលនូវសុជីវធម៌ និងចរិយាធម៌ផងព្រមទាំងវិនយប្បញ្ញត្តិ ព្រោះសីលធម៌ជាសភាវធម៌ធ្វើឱ្យកុសលផ្នែកដទៃៗទៀតចម្រើនឡើងព្រោងព្រាតជួយជ្រោមជ្រែងកុសលធម៌ទាំងឡាយរបស់សីលធម៌, របស់អរិយធម៌ឱ្យមានថាមពលខ្លាំងក្លាក៏ក្នុងន័យកសាងសុភមង្គលរបស់សង្គមមនុស្ស ដូចជាមាតាបិតានិងបុត្តសង្គ្រោះគ្នាទៅវិញទៅមក លោកគ្រូអ្នកគ្រូនិងសិស្ស, ស្វាមីនិងភរិយា សមណព្រាហ្មណ៍ មិត្តអាមាត្យ កម្មករ ក៏ត្រូវមានសង្គហធម៌ អនុគ្រោះទៅវិញទៅមក ដូចគ្នា ។ ដទៃក្រៅពីនេះ សីលធម៌ក៏ជាផ្នែកមួយក្នុងការសមាទាន និច្ចសីល ដូច សីល ៥ ផងដែរ ព្រោះសីលធ្វើឱ្យមនុស្សមានវិន័យថ្លៃថ្នូរ រីកចម្រើនទៅដោយវត្ថុ សម្ភារផ្សេងៗទាំងធ្វើឱ្យលោកបានសុខដែលមនុស្សត្រូវកសាងពូជមនុស្សដោយសមាទានសីល ៥ ជាឫសគល់នៃ ជីវិតមនុស្សជាតិ ។

* សីលធម៌ បើពោលឱ្យត្រូវ គឺការសំអាតកាយ សំអាតវាចា សំអាតចិត្ត ឱ្យបានល្អប្រកបដោយសុចរិតធម៌ ក្នុងកុសលកម្មបថ ១០ ដូចពោលខាងលើរួចហើយ គ្រាន់តែលើកចំណុចតូចៗ ខ្លះទៀតមកបញ្ចូលរួមផ្សំជាមួយជីវិតប្រចាំថ្ងៃ ដែលត្រូវជួបប្រទះតាមរយៈរូប តាមរយៈសំឡេង តាមរយៈក្លិន តាមរយៈរសអាហារ តាមរយៈផោដ្ឋព្វៈ តាមរយៈ

ធម្មារម្មណ៍ដែលសំខាន់រួមផ្សំជាមួយអបចាយនធម៌ គឺការគោរពឱនលំទោនដល់ចាស់ព្រឹទ្ធាចារ្យ និងមនុស្សទូទៅតាមលំដាប់ថ្នាក់ក្នុងសង្គម ។

* សីលធម៌ ជាសភាវកើតឡើងស្អាតពីកំណើតរបស់គេ មានវិនយប្បញ្ញត្តិ អបចាយនៈ និងសុជីវធម៌ជាឧបការៈក្នុងជីវភាពប្រចាំថ្ងៃធ្វើឱ្យមនុស្ស ស្រឡាញ់រាប់អានគ្នា ស្មោះត្រង់នឹងគ្នា ពោលពាក្យល្អសុភាពរាបសា មិនពោលពាក្យទ្រគោះបោះបោកដែលនាំឱ្យខូចទឹកចិត្តគិតចងគំនុំសងសឹក រហូតដល់ទៅវាយប្រហារគ្នាមិនចេះចប់ ។

*សីលធម៌រស់នៅក្នុងសង្គមនាំឱ្យមនុស្សចេះគោរពគ្នា (អបចាយនៈ) ចេះគួរសមគ្នា (សុជីវធម៌) ចេះជួយសន្តោសគ្នា (សង្គហធម៌) ដែលក្នុងការប្រកបអាជីពឬធ្វើដំណើរឆ្ងាយជិត ឬចូលរួមក្នុងទីប្រជុំជន ថ្លែងសុន្ទរកថា ចូលជួបនឹងអ្នកធំ តូច អ្នកមាន បណ្ឌិតសក្តិ ព្រះរាជា ឬធ្វើបដិសណ្ឋារកិច្ចភ្ញៀវក៏ក្នុងអបចាយនធម៌គ្រប់ឥរិយាបថ ៤ នៃរូបរាងកាយទាំងការនិយាយស្តីក៏គួរពោលតែពាក្យពិត ពាក្យមានប្រយោជន៍ដល់អ្នកស្តាប់ដែល ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់សម្តែងមាន ៥ ប្រការ :

១- ត្រូវនិយាយតាមកាលគួរ

២- ត្រូវនិយាយតែពាក្យពិត

៣- ត្រូវនិយាយដោយពាក្យពីរោះផ្អែមល្ហែមឱ្យគេចូលចិត្ត

៤- ត្រូវនិយាយដោយពាក្យមានប្រយោជន៍

៥- ត្រូវនិយាយដោយចិត្តមានមេត្តាករុណា ដល់សត្វទូទៅ ។

**មុននឹងនិយាយត្រូវរិះគិត　　ពោលវាចាពិតមានសិរី**

**ល្អអាក្រក់មកពីសំដី　　ផ្អែមល្ហែមរស់រីកព្រមដែរ។**

ដែលមាននៅក្នុងសង្គមមនុស្សលោកជានិច្ចកាលតាមភារកិច្ច រៀងខ្លួនដូចតទៅនេះ :

**១- សង្គហធម៌រវាងមាតាបិតានិងបុត្រ**

**ភារកិច្ចរបស់បុត្រមាន ៥ :**

មាតាបិតាជាទីសង្ឃឹមក្នុងជីវិតរបស់កូន ដែលកូនត្រូវមានកតញ្ញូកតវេទិតាធម៌ដើម្បីសេចក្តីល្អរបស់កូនក្នុងឋានៈជាអ្នកទទួលនូវកេរមរតក ត្រូវខិតខំកសាងខ្លួនឱ្យបានទៅជាបុត្តមានចរិយាធម៌ សីលធម៌ល្អប្រពៃណីល្អ ដើម្បីជាគំរូដល់បុត្តទាំងឡាយក្នុងគ្រួសារ ហើយក៏ជាជន្ទល់និងជាសសរទ្រូងរបស់ប្រទេសជាតិ កូនត្រូវមានកាតព្វកិច្ចគោរព ចំពោះលោកអ្នកមានគុណនិងជួយទំនុកបម្រុង មិនឱ្យម៉ែឪព្រួយបារម្ភអ្វីទាំងកាយវាចាចិត្ត ប្រព្រឹត្តយ៉ាងសមរម្យឱ្យសមជាកូន មានលក្ខណសម្បត្តិល្អប្រពៃ ដូចដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែងនៅក្នុងទីឃនិកាយ បាដិកវគ្គ ឆដ្ឋភាគ សិង្គាលិកសូត្រទី ៨ បិដក លេខ

១៩/៦៨ អំពីការគោរពគុណមាតាបិតាជាទិសខាងកើតដែលកូនត្រូវទំនុកបម្រុងដោយស្ថានទាំងឡាយ ៥ យ៉ាង គឺ

១- កូនត្រូវតាំងចិត្តថា អាត្មាអញដែលមាតាបិតាចិញ្ចឹមរក្សាមកហើយ នឹងត្រូវចិញ្ចឹមគាត់វិញ ដោយសេចក្ដីថា មាតាបិតាជាអ្នកឱ្យកំណើតចម្រើនទៅដោយសាច់ និង ឈាមទៅដោយអវយវៈតាំងពីនៅបំបៅដោះ ជូតសំបោរ ផ្ទូតទឹកស្លៀកពាក់ មើលថែរក្សាគ្រប់សព្វបែបយ៉ាងដែល យើងជាកូនចាំបាច់ត្រូវចិញ្ចឹមផ្គត់ផ្គង់គាត់វិញ ។

២- ត្រូវជួយធ្វើការងារបម្រើមាតាបិតា ដោយសេចក្ដីថា សុខចិត្តខកខានធ្វើការងាររបស់ខ្លួន ដើម្បីមកជួយធ្វើការបម្រើមាតាបិតាវិញ ។

៣- ត្រូវតម្កល់ចិត្ត រក្សាវង្សត្រកូលឱ្យគង់វង់ ដោយសេចក្ដីថាបុត្តមិនត្រូវប្រើប្រាស់ទ្រព្យមរតកមានមាសប្រាក់ជាដើមឱ្យវិនាស ត្រូវតាំងនៅក្នុងវង្សត្រកូលប្រកបដោយធមិ មិនរាំងស្ទះនូវលាភសក្ការៈ ដែលហូរចូលមកដល់ក្នុងវង្សត្រកូលសូម្បីប្រព្រឹត្តធ្វើអ្វីៗឱ្យខុសពីខ្សែជីវិតវង្សត្រកូលក៏ពុំមានដែរ ។

៤- ប្រតិបត្តិឱ្យជាអ្នកសមគួរនឹងទទួលទ្រព្យមរតក ដោយសេចក្តីថា មាតាបិតាមានទ្រព្យតិច ឬច្រើនយ៉ាងណាទុកចែកឱ្យតែកូនគ្មានទុកឱ្យអ្នកដទៃណាឡើយ ចូរកូនប្រព្រឹត្តល្អ ចំពោះមាតាបិតាកុំប្រព្រឹត្តខុសនាំឱ្យទាស់ចិត្តគាត់ ព្រោះនៅក្នុងនោះមានធម៌អាចិកំបាំងគឺទឹកចិត្ត ព្រហ្មវិហារធម៌ ៤ ចំពោះកូនប្រុសស្រី ។

៥- ឧទ្ទិសទក្ខិណាទានដល់មាតាបិតា ដែលធ្វើកាលកិរិយាទៅកាន់បរលោក ដោយសេចក្តីថា យើងនឹងធ្វើបុណ្យឱ្យដល់លោកទាំងនោះ ហើយនឹងផ្តើមធ្វើទានឧទ្ទិសជូនទៅលោកអ្នកមានគុណចាប់តាំងពីពេលនេះតទៅ ដែលមានព្រះសង្ឃសាវកទ្រទ្រង់សីលជាប្រធានដូចមានព្រះគាថាទ្រង់ត្រាស់សម្តែងនៅក្នុងសុត្តន្តបិដក ខុទ្ទកនិកាយ ខុទ្ទកបាឋ ភាគ ៥២/៤៥ ដូចតទៅនេះ :

**អភិវាទនសីលិស្ស និច្ចំ វុឌ្ឍាបចាយិនោ**

**ចត្តារោ ធម្មា វឌ្ឍន្តិ អាយុ វណ្ណោ សុខំ ពលំ ។**

ប្រែ : ធម៌គឺពរទាំងឡាយ ៤ ប្រការបានដល់ អាយុ ១ ពណ៌ សម្បុរ១ សេចក្តីសុខ ១ កម្លាំង ១ រមែងចម្រើនអស់កាលជានិច្ច ដល់អ្នកដែលមានសេចក្តីឱនកាយថ្វាយបង្គំចំពោះគុណព្រះរតនត្រ័យជាប្រក្រតី

និងមានសេចក្តីគោរពកោតក្រែងដល់បុគ្គលដែលមានសេចក្តីចម្រើន ដោយគុណមានសីលគុណជាដើម ឬ ចម្រើនដោយវ័យ គឺចាស់ព្រឹទ្ធាចារ្យ ។

**ភារកិច្ចរបស់មាតាបិតាមាន ៥ :**

កាលបើឃើញកូនតាំងចិត្តល្អ មានកតញ្ញូកតវេទិតាធម៌យ៉ាងនេះ មាតាបិតាមានសេចក្តីត្រេកអររីករាយជាពន់ពេក ណាមួយស្រឡាញ់ និងអាណិតកូនក៏បានអនុគ្រោះទំនុកបម្រុងតបនូវសេចក្តីល្អដល់កូនប្រុសស្រី ឱ្យសមតាមឋានៈរបស់ខ្លួននូវស្ថាន ៥ យ៉ាងវិញដែរ ។

១- ហាមឃាត់កូនមិនឱ្យប្រព្រឹត្តអំពើអាក្រក់ ដោយសេចក្តីថា មាតាបិតាពោលដល់ទោសដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន និងភពខាងមុខរបស់បាណាតិបាតជាដើម ហើយហាមថាកូនអើយកុំប្រព្រឹត្តធ្វើកម្មដូចយ៉ាងនេះឡើយ ក្នុងគំនិតចង់ប្រាប់កូនដែលបានធ្វើកម្មនេះរួចហើយ ។

២- ទូន្មានប្រាប់កូនឱ្យតម្កល់ចិត្តនៅក្នុងតែអំពើល្អ ដោយសេចក្តីថា មាតាបិតាឱ្យប្រាក់ដល់កូនដូចអនាថបិណ្ឌិកសេដ្ឋី ឱ្យបុត្តតាំងនៅក្នុងការសមាទានសីលជាដើម ។

៣- បង្កលក្ខណៈបរិយាកាស ឱ្យកូនបានចូលទៅសិក្សាសិល្បៈសាស្ត្រវិជ្ជាក្នុងសាលារៀន ដោយសេចក្តីថា មាតាបិតាបាន

ដឹងថាបុត្តតាំងនៅក្នុងឱវាទរបស់ខ្លួនហើយ ទើបញ៉ាំងបុត្តឱ្យសិក្សាសិល្បមានការគិតលេខជាដើមដែលប្រព្រឹត្តតាម វង្សត្រកូល ។

៤- កាលបើកូនធំពេញរូបពេញរាង គួររៀបចំស្ដីដណ្ដឹងកូនប្រសាឱ្យមានគូស្វាមីភរិយាសមរម្យតាមគន្លងប្រពៃណីជាតិ ដោយសេចក្ដីថា គឺសមគួរតាមត្រកូលជាអ្នកមានសីលនិងរូបសម្បត្តិសមរម្យជាដើម ។

៥- ចែកទ្រព្យសម្បត្តិដល់កូនប្រុសស្រីតាមសម័យដ៏សមគួរ គឺនិច្ចសម័យ និងកាលសម័យ ។ ម្នាលគហបតិបុត្តមាតាបិតាជាទិសខាងកើតដែលកូនទំនុកបម្រុងយ៉ាងនេះឯង រមែងអនុគ្រោះកូនដោយស្ថាន ៥ យ៉ាងជាទីមានសេចក្ដីក្សេមឥតមានភយន្តរាយអ្វីឡើយ ។ ដោយសេចក្ដីថា ក្នុងបទនោះសម័យមាន ២ យ៉ាងគឺ និច្ចសម័យ និងកាលសម័យ ។ និច្ចសម័យ គឺឱ្យជានិច្ចកាលក្នុងការចាយវាយផងនិងធ្វើបុណ្យទានផង ឯកាលសម័យបានដល់ ពេលកូនប្រុសស្រីមានប្ដីប្រពន្ធ ត្រូវចែកទ្រព្យផ្សេងនៅពេលដឹងថាខ្លួនជិតស្លាប់ ។

មាតាបិតាស្រឡាញ់កូនពិត មានធម៌ប្រណីតទុកចែកកូនស្ងួន
អនុគ្រោះប្រណីសម្តី ៤ កាយគ្រប់ចំនួនបីនៅក្នុងចិត្ត ។

កូនសន្សំទុកពាក្យអ្នកមានគុណ បានធ្វើដើមទុនសិក្សាលំអិត
គោរពប្រតិបត្តិសាងសុចរិត យកបណ្តាំពិតសណ្ឋិតជាស្នូល ។

ពាក្យពេចន៍ម៉ែឪស្រដីមិនខុស កូនចៅស្រីប្រុសចាំទុកជាគោល
អប់រំភាវនាកុសលហូរចូល សន្សំប្រមូលទុកក្នុងសន្តាន ។

**ម៉ែឪមានគុណធ្ងន់ខ្លាំងអនេក ទោះបីទូលរែកលើកចេញមិនបាន**
**យកអ្វីមកប្រៀបក្រៅពីខ្លួនប្រាណ ទោះធំប៉ុន្មានក៏នៅមិនស្មើ ។**

**ព្រោះម៉ែឪនេះជាបុព្វាចារ្យ ថ្នាក់ថ្នមរក្សាមិនទាន់ចេះដើរ**
**បំបៅដោះកូនលាងអាចម៍បម្រើ ធំនាំបណ្តើរទៅរៀនសាលា ។**

**ទី២ម៉ែឪជាព្រហ្មមុខបួន ធម៌នៅក្នុងខ្លួនដូចពួកទេព្តា**
**មេត្តាអាណិតចិត្តទន់ស្នេហា ដោយឧបេក្ខាទ្រទ្រង់ចិត្តស្ងប់ ។**

**ទី៣ម៉ែឪជាអាហុណេយ្យ ពុំមានឧបមេយ្យដូចសោឡសចប់**
**កូនត្រូវផ្គត់ផ្គង់ចិញ្ចឹមផ្គុនផ្គាប់ ទុកជាទម្លាប់សំពះរាល់ថ្ងៃ ។**
**កូនណាដឹងគុណមាតាបិតា ធម្មជាតិប្រាប់ថាប្រសើរពេកក្រៃ**
**បុណ្យជួយស្រោចស្រង់ស្រណោះអាល័យ នៅពេលក្សិណក្ស័យរីករាយក្នុងសុគតិ ។**

ការដឹងគុណនាំមកនូវសេចក្តីសុខចម្រើន ។

## ២- សង្គហធម៌រវាងលោកគ្រូនិងសិស្ស

### ភារកិច្ចសរបស់សិស្សមាន ៥ :

ចំណែកលោកគ្រូអាចារ្យឬអ្នកគ្រូក៏មានតួនាទីសំខាន់ក្នុងការបំពេញភារកិច្ចទទួលខុសត្រូវទាំងស្រុង ដល់ការកសាងធនធានមនុស្សបន្ទាប់ពីមាតាបិតា និងផ្សព្វផ្សាយចំណេះដឹងលើកតម្កើងវប្បធម៌ប្រពៃណីជាតិក្នុងសង្គម ដល់សិស្សានុសិស្សសម្រាប់ជាសសរទ្រូងរបស់ប្រទេសជាតិ ក៏ត្រូវមានគុណធម៌សមស្រប ជាអ្នកមានឱវាទថ្លៃថ្នូរគួរគោរពលើកតម្កើងដែលសិស្សពេញចិត្តធ្វើសក្ការះរាប់ អាន និងប្រតិបត្តិដោយស្ថាន ៥ យ៉ាង :

១- សិស្សត្រូវក្រោកទទួលលោកអាចារ្យឬលោកគ្រូអ្នកគ្រូ ដោយសេចក្តីថា ក្រោកឈរឡើងកាលបើឃើញលោកគ្រូដើរចូលមកជិត ត្រូវទទួលយករបស់ពីដៃ ក្រាល អាសនៈ បក់ផ្លិត លាងជើង ជូតជើង ជាដើម ។

២- សិស្សត្រូវតែមានការគាល់បម្រើ ឬជួយធ្វើកិច្ចការខ្លះៗជូនលោកគ្រូតាមមុខនាទីរៀងៗខ្លួន ដោយសេចក្តីថា ទៅជួយធ្វើការងារជូនលោកគ្រូឱ្យហ្មត់ចត់ពិតប្រាកដ ។

៣- សិស្សត្រូវជឿស្តាប់ពាក្យទូន្មានរបស់លោកអាចារ្យ ឬលោកគ្រូអ្នកគ្រូយ៉ាងរីករាយពេញចិត្ត ដោយសេចក្តីថា បើសិស្ស

មិនជឿស្តាប់លោកគ្រូអាចារ្យទេក៏រមែងមិនចម្រើនក្នុងសិល្បសាស្ត្រ និងមិនបានសម្រេចគុណវិសេសអ្វីឡើយ ។

៤- ដោយការបម្រើតូចៗ ( មានការជូនទឹកលុបមុខ និងឈើស្ទន់ជាដើម) ដោយសេចក្តីថា ទោះបីការងារតូចតាចយ៉ាងណាក៏មិនត្រូវឱ្យលោកគ្រូធ្វើដោយខ្លួនឯងដែរ ។ ការជ្រោមជ្រែង ការគាំទ្រ និងសម្តែងការគោរពដោយធ្វើការងារ ជាការអនុមោទនាចំពោះគុណដែលជាការបម្រើដ៏ប្រសើរក្រៃលែង ។

៥- សិស្សត្រូវសិក្សារៀនសូត្រនូវសិល្បសាស្ត្រមុខវិជ្ជាយ៉ាងគោរព ដោយសេចក្តីថា សិក្សារៀនសូត្រឱ្យហ្មត់ចត់ត្រឹមត្រូវល្អ សូម្បីមួយបទក៏គួរឱ្យដឹងពិតប្រាកដឈ្មោះថា រៀនដោយការគោរព ។

**ភារកិច្ចរបស់លោកគ្រូអាចារ្យមាន ៥ :**

ចំពោះលោកអាចារ្យ ឬលោកគ្រូអ្នកគ្រូកាលបើឃើញសិស្សយកចិត្តទុកដាក់ចំពោះខ្លួនក៏ខំផ្សាយចំណេះដឹងដល់សិស្សទាំងឡាយមិនលាក់លៀមទុក និងរកវិធីសាស្ត្រ ( របៀប បង្រៀន) យ៉ាងប្លែកៗ ដោយមានការប្រជុំដោះស្រាយគ្នាដើម្បីធ្វើឱ្យសិស្សងាយយល់បានសម្រេចប្រយោជន៍ តែងមានមេត្តាករុណាធម៌ប្រោសប្រណីដល់សិស្ស

ដោយទឹកចិត្តល្អយ៉ាងត្រជាក់ក្នុងការឱ្យឱវាទអនុគ្រោះនូវស្ថាន៥យ៉ាងទៅវិញដែរ :

១- ដឹកនាំបង្រៀនសិស្សឱ្យបានល្អមានសីលធម៌ល្អ ដោយសេចក្ដីថា លោកគ្រូអាចារ្យរមែងឱ្យសិស្សសិក្សាគឺណែនាំនូវអាកប្បកិរិយាមារយាទថា អ្នកគួរអង្គុយយ៉ាងនេះ គួរឈរយ៉ាងនេះ គួរដើរយ៉ាងនេះ គួរទំពាយ៉ាងនេះ គួរបរិភោគយ៉ាងនេះ គួរវៀរ មិត្រអាក្រក់ គួរគប់មិត្តល្អ ។

២- ធ្វើយ៉ាងណាបង្ហលក្ខណៈឱ្យសិស្សបានរៀនល្អ ដោយសេចក្ដីថា លោកគ្រូអាចារ្យ ជម្រះអត្ថនិងព្យញ្ជនៈប្រយោគ រួចហើយឱ្យសិស្សរៀនដោយអាការៈដែលសិស្សនឹងរៀនបានល្អ ។

៣- ប្រៀនប្រដៅសិស្សឱ្យបានចេះដឹងត្រឹមត្រូវក្នុងសិល្បសាស្ត្រសព្វគ្រប់ តាមសមត្ថភាពរបស់ខ្លួន ។

៤- បើមានសិស្សល្អតែងលើកតម្កើងសរសើរនៅក្នុងទីប្រជុំសិស្សទាំងឡាយក្នុងសាលា ដោយសេចក្ដីថា លោកគ្រូអាចារ្យទាំងឡាយ ពោលដល់គុណរបស់សិស្សយ៉ាងនេះថា សិស្សរបស់យើងម្នាក់នេះឆ្លាតពូកែ ជាពហុស្សូត (ចេះ ចាំច្រើន) ស្មើនឹងយើង អ្នកទាំងឡាយចូរសម្គាល់នូវសិស្ស នេះចុះ ។

៥- ធ្វើសេចក្ដីការពារក្នុងទិសទាំងឡាយ ដោយសេចក្ដីថា ឱ្យសិក្សាប្រុងប្រយ័ត្នខ្ពស់គ្រប់ទីទាំងពួង ព្រោះលាភសក្ការៈរមែង កើតដល់សិស្សក្នុងទិសទាំងឡាយជាពិសេស ជួយការពារនូវភយន្តរាយទាំងឡាយ ដែលនឹងត្រូវកើតឡើងពីសត្រូវ គឺពួកមនុស្សអាក្រក់ អមនុស្ស ឬសត្វតិរច្ឆានកាចៗ ដោយការសង្រួមឥន្ទ្រិយ៍ស្រង់យកមហាកុសលជំនួសអកុសលដែលកើតឡើងពីតណ្ហា ។

សម្លឹងមើលលោកដោយចិត្តមេត្តា លោកគ្រូអាចារ្យតែងអនុគ្រោះ
ប្រាប់នូវវិជ្ជាដល់សិស្សទាំងអស់ ពោលពាក្យពីរោះមានអត្ថខ្លឹមសារ ។
សិស្សស្ដាប់ងាយយល់សាងមេរៀនទុក សិក្សាបានសុខព្យាយាមឧស្សាហ៍
គោរពប្រតិបត្តិដោយចិត្តជ្រះថ្លា ធម៌ល្អអស្ចារ្យកម្របានជួប ។

គុណគឺសេចក្ដីល្អរមែងមានចំពោះសិស្សល្អ ។

## ៣- សង្គហធម៌រវាងស្វាមីនិងភរិយា

រវាងស្វាមីភរិយា មានគុណបំណាច់ដល់លោកនេះយ៉ាងច្រើន ព្រោះ បានឱ្យកំណើតបុត្តទុកបន្តពូជពង្សវង្សត្រកូល ក្នុងសង្គមគ្រួសារ សម្រាប់អនាគតប្រទេសជាតិនីមួយៗលើសាកលលោកដែលជាជំហាន ដំបូងក្នុងការកសាងធនធានមនុស្ស ។ លោកគ្រូអ្នកគ្រូបានទទួលការ អប់រំបង្រៀនសិស្ស ព្រោះជាកុលបុត្រប្រសូតចេញពីមាតាបិតា។ បុគ្គលិក រាជការ អ្នកតូចអ្នកធំមានឋានន្តរសក្តិ ប្រភេទណា ក៏ជាបុត្ររបស់មាតា បិតាដូចគ្នា ពុំមានមនុស្សណាម្នាក់កើតមកហើយគ្មានមាតាបិតាជាអ្នកឱ្យ កំណើតគ្រប់គ្រងថែរក្សា លើកលែងតែក្នុងសម័យពុទ្ធកាលមាន ឧបបាតិកកំណើត គឺកំណើតពុំមានមាតាបិតា ជាអ្នកសម្រេចកិច្ចឱ្យ ។

ចំពោះមាតាបិតា ក៏ឈ្មោះថាស្វាមីភរិយាដែរ គ្រាន់តែមានបុត្រ ឯភរិយាស្វាមីជាមនុស្សមិនទាន់មានបុត្រ ហើយក៏គង់នឹងមានបុត្រនៅ ពេលអនាគតនឹងក្លាយទៅជាមាតាបិតាដូចគ្នា ព្រោះហេតុដូច្នេះបាន ជាមានពាក្យគេនិយាយថា "ស្ត្រីជាមាតាពិភពលោក" ព្រោះជាអ្នកបង្កើត បុត្ររបស់មនុស្សលោកទៅតាមនិយាមធម្មជាតិ មិនអាចមានអ្នកណា មកប្រែក្រឡាស់ឱ្យខុសពីការពិតនេះបានឡើយ ។ ព្រោះតែមាតាជាអ្នក បង្កើតលោក បានជាគេលើកស្ត្រីឱ្យមានសិទ្ធិសេរីភាពដូចបុរសដោយការ ទាមទារសិទ្ធិដែលប្រារព្ធធ្វើពិធីបុណ្យខួបកំណើតទិវានារីអន្តរជាតិកំណត់ យក **ថ្ងៃទី ០៨ ខែ មិនា** រៀងរាល់ឆ្នាំ ដែលស្ត្រីបានចូលរួមការងារជាមួយ បុរសធ្វើកិច្ចការអ្វីដទៃ ដូចបុរស ទាំងផ្នែកកសិកម្ម ពាណិជ្ជកម្ម បុគ្គលិក

កម្មករ អ្នករាជការ តូចធំ រហូតបានចូលកាន់មុខតំណែងធំៗ នាសម័យសព្វថ្ងៃនេះយ៉ាង ជាក់ស្ដែងមែន ។

ម្យ៉ាងទៀត ស្ត្រីមានតួនាទីជាអ្នកជួយរៀបចំចាត់ចែងការងារជាមួយបុរសក្នុងដំណើរការណ៍ ស្ថាបនាលោកឱ្យបានទៅជាលោកមានអារ្យធម៌ សម្បូណ៌ជឿនលឿនទាំងផ្នែកចរិយាធម៌ សីលធម៌ ប្រពៃណី វប្បធម៌ សាសនា សមស្របតាមស្ថាប័នសង្គមចាំបាច់ ត្រូវអាស្រ័យពីធម្មៈ ដែលមានព្រះពុទ្ធសាសនាជាគោលឬជាគ្រឹះ ។ លទ្ធផលការងារទាំងអស់នេះ មិនមែនសម្រេចនៅត្រឹមតែលើកស្ត្រីជាមាតាពិភពលោកប៉ុណ្ណោះទេ ត្រូវអាស្រ័យពីហេតុប្បច្ច័យដទៃទៀតយ៉ាងច្រើន សំខាន់ត្រូវមានសុចរិតកម្ម ព្រោះអ្វីកើតឡើងមិនមែនសុទ្ធតែកើតពីស្នាដៃមនុស្សសុទ្ធសាធ ជាការរួមផ្សំនឹងធាតុដទៃៗសម្រេចពីតួចេតនាកម្ម សំដៅទៅលើគុណធម៌ ដែលជាអ្នកមានសមត្ថភាពគ្រប់គ្រាន់ហើយក៏មិនមែនឱ្យឈ្មោះថាស្ត្រីក៏សុទ្ធតែត្រូវបានគេទទួលស្គាល់នោះទេ តែទោះជាយ៉ាងណា ការងាររបស់ស្ត្រីមានប្រសិទ្ធភាពច្រើនជាមួយបុរស ដូចជាចូលរួមការងារបម្រើលោក ចូលរួមធ្វើបុណ្យទានខាងផ្នែកព្រះពុទ្ធសាសនានិងជាលំអនៅក្នុងគ្រួសាររបស់លោក ព្រមទាំងមានស្វាមីជាអ្នកគ្រប់គ្រងថែរក្សាចិញ្ចឹម ដែលព្រះសម្មាសម្ពុទ្ធទ្រង់មានព្រះទ័យសន្ដោសប្រោសប្រណីប្រទាននូវឱវាទដល់អ្នកទាំងពីរសូមឱ្យ ទទួលបាននូវសេចក្ដីសុខប្រាស់ចាកទុក្ខកុំបីអាក់ខានឡើយ ព្រោះ

ការរស់នៅជាមួយគ្នារវាងគូស្វាមីភរិយា តែងមានការទាស់ខុសប្រែប្រួលមិនខាន មិនតែប៉ុណ្ណោះ ស្ត្រីបានចូលមកទ្រង់ព្រះផ្នួសបួសជាភិក្ខុនីទ្រទ្រង់នូវគុណ ក្នុងសាសនាព្រះដ៏មានព្រះភាគធ្វើកិច្ចបដិបត្តិធម៌ដ៏សមគួរតាមធម៌ បានសម្រេចមគ្គផលច្រើនរាប់មិនអស់នាសម័យពុទ្ធកាល ហើយក៏ជាចំណែកមួយនៃការកសាងខ្លួនឱ្យបានល្អក្នុងសម័យបច្ចុប្បន្ននេះដែលស្ត្រីមានតួនាទី ចូលរួមជួយកសាងលោកផង និងស្វែងយល់ពីការសិក្សាព្រះធម៌ក្នុងព្រះពុទ្ធសាសនាក្នុងឋានៈជាឧបាសិកាមានចំនួនច្រើនដូចគ្នាព្រោះឧបនិស្សយប្បច្ច័យ ។

ដើម្បីជួយសម្របសម្រួលដល់អ្នកទាំងពីរឱ្យមានសុភមង្គលសម្រេចប្រយោជន៍ក្នុងស្ថាប័នគ្រួសារ ព្រះអង្គទ្រង់លើកឡើងនូវសង្គហធម៌អនុគ្រោះជួយគ្នាដូចតទៅ :

### ភារកិច្ចរបស់ស្វាមីមាន ៥

ចំពោះស្វាមីជាទិសខាងលិច ត្រូវទំនុកបម្រុងភរិយាដោយស្ថាន ៥ យ៉ាង :

១- ស្វាមីត្រូវរាប់អានភរិយាឱ្យពេញច្បាប់ ដោយសេចក្តីថា ពោលពាក្យល្អ យ៉ាងពីរោះទៅរកភរិយាមិនឱ្យទាស់ចិត្ត ។

២- ស្វាមីមិនត្រូវមើលងាយភរិយាឡើយ ដោយសេចក្តីថា មិនមើលងាយដោយពាក្យគំរោះគំរើយប្រៀបដូចពោលពាក្យជាមួយនឹងទាសៈកម្មករ ជាដើមទៅរកភរិយា ។

៣- ស្វាមីមិនត្រូវប្រព្រឹត្តក្បត់ចិត្តភរិយាទៅមានស្ត្រីដទៃ ដោយសេចក្តីថា ស្វាមីមិនមានស្ត្រីដទៃជាភរិយា ។

៤- ស្វាមីត្រូវប្រគល់ឥស្សរភាព (តួនាទីដល់ភរិយា) ឱ្យជាធំក្នុងការរៀបចំផ្ទះ ដោយសេចក្តីថា ភរិយាត្រូវទទួលមុខនាទីធំក្នុងការងារផ្ទះដែលជាកិត្តិយសមួយរបស់ស្ត្រីមានស្វាមីចិញ្ចឹម ទោះបីមិនមានទ្រព្យ ឬក្រខ្សត់យ៉ាងណា ឱ្យតែបានទទួលនូវកិត្តិយសមុខមាត់ល្អយ៉ាងនេះក៏ភរិយារីករាយសប្បាយចិត្តដែលជាសុភមង្គលក្នុងជីវិតគ្រួសារ ។

៥- ស្វាមីត្រូវជូនគ្រឿងអលង្ការសម្រាប់តុបតែងខ្លួនដល់ភរិយា ដោយសេចក្តីថា ឱ្យគ្រឿងប្រដាប់អលង្ការដ៏សមគួរដល់ភរិយា ព្រោះគ្រឿងអលង្ការជាលំអមួយរបស់ស្ត្រី ដល់ការតំណាងទឹកចិត្តដ៏បរិសុទ្ធរបស់ស្វាមីជូនភរិយា សម្រាប់ជាគ្រឿងលួងលោមចិត្ត និងជាបណ្ណាការមានតម្លៃខ្ពស់របស់ស្ត្រីគ្រប់រូបទាំងអស់ក្នុងលោកដែលធ្វើឱ្យនាងជាភរិយាជាប់ចិត្តស្រឡាញ់ស្មោះអស់ពីដួងចិត្តទៅលើស្វាមី តែរបស់ទាំងនេះមិនមានតម្លៃដូចទឹកចិត្តឡើយ ។

**ភារកិច្ចរបស់ភរិយាមាន ៥ :**

ដើម្បីឆ្លើយតប នូវអំពើល្អរបស់ស្វាមីដ៏កម្រក្នុងលោក ភរិយាជាទិសខាងលិចក៏មានធម៌ជួយទំនុកបម្រុងអនុគ្រោះស្វាមី ដោយស្ថានទាំងឡាយ ៥ យ៉ាងវិញដែរ ។

១- ភរិយាត្រូវចាត់ចែងការងារដោយល្អ ដោយសេចក្ដីថា ភរិយាមិនលះបង់ការដណ្ដាំស្លធ្វើម្ហូបអាហារជូនស្វាមីទោះបីមានមុខនាទីសំខាន់ក្នុងរាជការឬជាប់រវល់អ្វីៗយ៉ាងណាក៏ដោយ ។

២- ភរិយាត្រូវសង្គ្រោះសាច់ញាតិទាំងពីរខាងដោយល្អ ដោយសេចក្ដីថា ធ្វើការរាប់អានជូនដំណើរទៅវិញទៅមកជាដើម ។

៣- ភរិយាមិនប្រព្រឹត្តក្បត់ចិត្តស្វាមីទៅរកប្រុសដទៃផ្សេង ដោយសេចក្ដីថា មិនលះបង់ស្វាមីទៅមានប្រុសដទៃឡើយ ។

៤- ភរិយាត្រូវថែទាំទ្រព្យសម្បត្តិដែលស្វាមីខំស្វែងរកបាន ដោយសេចក្ដីថា ទ្រព្យដែលស្វាមីរកបានពីកសិកម្ម ពាណិជ្ជកម្ម ត្រូវរក្សាទុកយ៉ាងល្អកុំឱ្យបាត់បង់ ព្រោះស្វាមីជាម្ចាស់លើជីវិត បើចង់ចាយវាយប្រើប្រាស់ត្រូវសួរសុំរកពីស្វាមី និងជាអ្នកខែងរែងដល់ការងារធ្វើម្ហូបអាហារក្នុងគ្រួសារ ។

៥- ភរិយាឈ្លាសវៃមិនខ្ជិលច្រអូសក្នុងកិច្ចការសព្វគ្រប់ ដោយសេចក្ដីថា ភរិយាមិនដូចស្ត្រីខ្ជិលដទៃ តែងខិតខំធ្វើសេចក្ដីល្អដែលខ្លួនធ្លាប់បានធ្វើ បើមានការខ្វះខាតចន្លោះគួរបំពេញ

ឡើងវិញ ។ ការងារល្អរបស់ស្ត្រីជាមង្គលដ៏ឧត្តមនៅក្នុងគ្រួសារ ។ ស្ត្រីជាម្ចាស់ផ្ទះត្រូវចេះគួរសម និងមានវាចា ទន់ភ្លន់ពីរោះផ្អែមល្ហែមដោយបិយវាចាគួរជាទីស្រឡាញ់រាប់អានពីអ្នកដទៃ និងក្នុងគ្រួសារ ។

ភរិយាដែលបានស្វាមីស្រឡាញ់ស្មោះត្រង់ចំពោះខ្លួន ដូចបានជម្រាបជូនមកនោះ សុខចិត្តលះបង់អ្វីៗទាំងអស់ ដើម្បីស្វាមីដោយភក្តីភាព មិនហ៊ានប្រព្រឹត្តទាស់ចិត្តប្ដី ដោយខំរក្សាការស្រឡាញ់ពេញចិត្តស្វាមីនោះ ឱ្យមានស្ថិរភាពរៀងរហូតអស់មួយជីវិត ទុកបន្តពូជពង្សវង្សត្រកូលដល់អនាគតកូនសម្រាប់មាតាមានព្រហ្មវិហារធម៌មួយ ក្នុងសង្គម និងជាគំរូដល់គ្រួសារជិតខាងរបស់ប្រទេស ។

☛ ភរិយាជំពូកនេះជាស្ត្រីជួយលោកដែលគេចាត់ទុកថា ជាមាតាពិភពលោក ព្រោះប្រតិបត្តិត្រឹមត្រូវតាមធម៌ ដែលលោកនឹងទទួលបាននូវសេចក្ដីសុខរីកចម្រើនដល់សង្គមគ្រួសារអាចនឹងឈានឡើងទៅដល់អារ្យប្រទេស មានភាពរុងរឿងគ្រប់វិស័យ ដោយសីលគុណដូចប្រការខាងលើរបស់ធម្មៈជាក់ជាមិនខាន ។

☛ ស្វាមីមានចិត្តស្រឡាញ់ភរិយា ទ្រព្យធននានាប្រគល់ឱ្យស្ត្រី
ទុកជាមេផ្ទះសាងជីវិតថ្មី ទាស់ខុសអ្វីៗភក្ដីករុណា ។

☛ ភរិយាចំណាប់ជាត្រួយជីវិត សួស្តីមានពិតនៅក្នុងគ្រួសារ
ជួយលើកមុខប្តីទឹកចិត្តស្នេហា គ្រប់ពេលឧស្សាហ៍កិច្ចការជាស្ត្រី ។
☛ ស្វាមីប្រឹងប្រែងបម្រើការងារ នឹកដល់ភរិយាធ្វើម្ហូបចំណី
មើលរៀបចំផ្ទះបន្ទប់សិរី ទុកជូនលោកប្តីឱ្យរីករាយចិត្ត ។

ការប្រព្រឹត្តល្អនាំមកនូវសុភមង្គលក្នុងគ្រួសារ ។

# អរិយធម៌

**អ្វីទៅហៅថា អរិយធម៌ ឬអារ្យធម៌ ?**

ឆ្លើយ : អរិយធមិ ឬអារ្យធមិ ជាធម្មជាតិប្រសើរខ្ពង់ខ្ពស់ឧត្តុង្គឧត្តមក្រៃលែងសម្រាប់ស្រុកនិគម ខេត្តដែនរបស់ប្រទេសនិមួយៗទៅតាមអធ្យាស្រ័យរបស់សង្គមធ្លាប់និយមចូលចិត្តពេញចិត្តរបៀបរបបរស់នៅយ៉ាងណា ក៏នៅលើសេចក្តីត្រូវការនៃប្រជាជនក្នុងទីកន្លែងនិមួយៗដែលប្រព្រឹត្តធ្វើអំពើបែបនោះៗ ដើម្បីកែច្នៃតំបន់ឱ្យមានអភិវឌ្ឍនាការចម្រើនរុងរឿងដើរទាន់សម័យរបស់អរិយប្រទេសក្នុងសាកលលោក ។

នៅក្នុងវចនានុក្រមសម្តេចព្រះសង្ឃរាជ **ជួន ណាត** បានសរសេរប្រាប់ថា : អរិយៈ ភាពប្រសើរ, ត្រឹមត្រូវ, សុភាព, រៀបរយ, មានបែបបទល្អ, ស្អាតត្រង់ដែលឥតទោស ។ មានន័យមួយទៀតនៅក្នុងគម្ពីរព្រះពុទ្ធសាសនាថា: អរិយមាន ៤ ពួក គឺ ÷

១- អចារអរិយៈ ឬអាចារិយៈ អ្នកដែលមានមារយាទត្រឹមត្រូវល្អ ។

២- ទស្សនអរិយៈ ឬទស្សនារិយៈ អ្នកដែលមានរូបឆោមលោមពណ៌ល្អ មានឥរិយាបថ ស្រគត់ស្រគំ សមរម្យ គួរឱ្យចង់ឃើញចង់មើល ។

៣- លិង្គអរិយៈ ឬលិង្គារិយៈ បព្វជិតដែលល្អតែភេទ គឺអ្នកបួសដែលផ្ចិតផ្ចង់ប្រុងប្រយ័ត្នតែការស្លៀកដណ្តប់ឱ្យត្រឹមត្រូវតាមបែបបទជាសមណៈ ប៉ុន្តែជាមនុស្សទ្រុស្តសីល ។

៤- បដិវេធអរិយៈ ឬបដិវេធារិយៈ គឺលោកអ្នកបានសម្រេចលោកុត្តរធម៌ (ពុទ្ធាទិ បណ្ឌិត) ។ អាចប្រើពាក្យ "អារ្យ" សរសេរសម្រួលថា អារ្យផ្លាស់ប្តូរគ្នាក៏បាន ដូចអរិយជន ឬអារ្យជន គឺជនពួកអារ្យៈ ជាជន មានរបៀបបែបបទទំនៀមសណ្តាប់ធ្នាប់ល្អ នាំឱ្យមានសេចក្តីចម្រើន ។ អរិយជាតិ ឬអារ្យជាតិ គឺមានជាតិជាអរិយជន, ជាតិជនអ្នកមាន

អារ្យធម៌ ។ អរិយទ្រព្យ, អរិយធន ឬអារ្យទ្រព្យ គឺទ្រព្យប្រសើរ, ទ្រព្យរបស់អរិយជន (ក្នុងព្រះពុទ្ធសាសនាសំដៅយកធម៌ ៧ យ៉ាង គឺ សទ្ធា, សីល,ហិរិ, ឱត្តប្បៈ, សុតៈ, ចាគៈ, បញ្ញា ហៅថា អរិយទ្រព្យ) ព្រះពុទ្ធប្រទាន ឱវាទហៅថា ទ្រព្យប្រសើរក្រៃលែង ។ ជនណាមាន ទ្រព្យនេះ ជននោះឯងព្រះចមត្រៃ ប្រទានឱវាទថ្លៃថា ពុំមែនជាអ្នកទីទ័លក្រឡើយ ។ អរិយធម៌ ឬអារ្យធម៌ គឺធម៌ដែលនាំឱ្យកើតសេចក្ដីសុខចម្រើន, ធម៌របស់អរិយជន ទំនៀមសណ្ដាប់ធ្នាប់ល្អ, ឬបែបបទរៀបរយ ។ ចំណែកព្រះអរិយបុគ្គលមាន ៨ ពួក រាប់តាំងពីបានសម្រេច សោតាបត្តិមគ្គរហូតដល់បានសម្រេចអរហត្តផល ។

ពាក្យថា អរិយធម៌នេះកើតឡើងដោយឫសគល់ ៥ ប្រការ :

១- សីលធម៌ : ហេតុនាំឱ្យចៀសវាងនូវអំពើអាក្រក់កសាងតែអំពើល្អតាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធសាសនា ធ្វើឱ្យមនុស្សមានមេត្តា ករុណា ស្រឡាញ់រាប់អានគ្នាមិនមានការព្យាបាទបៀតបៀនគ្នា ។

២- មនុស្សធម៌ ៖ វិនយប្បញ្ញត្តិ ធ្វើឱ្យមនុស្សប្រព្រឹត្តត្រឹមត្រូវតាមឋានៈជាមនុស្ស ដែលមានគុណតម្លៃប្រសើរខ្ពង់ខ្ពស់ ។

៣- សុជីវធម៌ ៖ ច្បាប់រស់នៅសមរម្យតាមមុខនាទីរបស់មនុស្ស ស្គាល់ហេតុផល គួរឬមិនគួរ ស្គាល់ឋានៈខ្លួន នឹងអ្នកដទៃ ស្គាល់ប្រមាណក្នុងជីវភាពរស់នៅ ស្គាល់កាលសម័យ, ស្គាល់មិត្ត និងអមិត្ត ។

៤- វប្បធម៌ ៖ ការផ្សាំបណ្តុះចរិយាមារយាទ និងចំណេះវិជ្ជាទាំងប្រាជ្ញាស្មារតីឱ្យបានចម្រើនលូតលាស់ ។

៥- វឌ្ឍនធម៌ ៖ ភារៈនៃសេចក្តីចម្រើនគ្រប់ផ្នែកក្នុងសង្គម ។ (ដកស្រង់ពីក្នុងសៀវភៅចលនាអរិយធម៌របស់លោក សុង ស៊ីវ) ។

សីលធម៌អប់រំ សាមគ្គីគ្នារស់
អរិយធម៌ខ្ពស់ រុងរឿងលោកា
ទេវតាមារព្រហ្ម មានឫទ្ធិយ៉ាងណា
ជួយថែរក្សា មនុស្សមានសីលគុណ ។

# សេចក្ដីអធិប្បាយ

កាលណាគេនិយាយពីអារ្យធម៌ ត្រូវតែយកសីលធម៌ ចរិយាធម៌ ដែលជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធអង្គ មកជាគោលមុនដំបូង ដើម្បីធ្វើឱ្យសង្គមមានភាពថ្លៃថ្នូរប្រកបដោយសេចក្ដីសុខចម្រើន ជាភិយ្យោភាព។ មនុស្សមានចរិយាធម៌ល្អមារយាទប្រកបដោយអត្តចរិតសមរម្យ រស់នៅក្នុងសង្គមមានអបចាយនធម៌ ជាអ្នកគោរពគ្នាទៅវិញទៅមក តាមតួនាទីរៀងខ្លួន មិនឈ្លោះទាស់ទែងគ្នា ស្រឡាញ់រាប់អានគ្នាជាមិត្តមិនទុកជាសត្រូវបាន ជាឧបការៈដល់ការរីកចម្រើនខាងផ្លូវបញ្ញា ស្មារតីទាំងខ្លួនឯងនិងអ្នកដទៃ ធ្វើឱ្យអ្នកទាំងពីរចាប់ដៃគ្នាជាភាតរភាព ព្រមទាំងទុកជាការជួយកសាងសន្សំបារមីសម្រាប់ឆ្លងចាកលោកទៀតផង។ សីលធម៌នាំឱ្យមនុស្សបានសុខស្ងប់ ព្រោះពុំមានការរង្កៀសសង្ស័យត្រេកអរតែពីការងារល្អៗ ចូលចិត្តកសាងអំពីបុណ្យផ្សេងៗ តែងចូលរួមគ្រប់ពិធីបុណ្យក្នុងព្រះពុទ្ធសាសនា ដូចជាការកសាងសន្សំកុសលតាមពេលវេលាមានរដូវបុណ្យចូលវស្សា អសាឡ្ហបូជា បុណ្យចេញវស្សា រដូវកាលនៃអង្គកឋិនទាន បុណ្យវិសាខបូជា ក្នុងថ្ងៃ ១៥ កើត ខែ ពិសាខជាថ្ងៃដែលព្រះសម្មាសម្ពុទ្ធឧប្បត្តិកឡើងក្នុងលោក ថ្ងៃត្រាស់ដឹងធម៌ និងថ្ងៃបរិនិព្វាន របស់ព្រះដ៏មានព្រះភាគ ។

ក្នុងសង្គមមនុស្សធម៌ មនុស្សពុំសូវមានការព្រួយបារម្ភពីអំពើចោរកម្មផ្សេងៗ រស់នៅយ៉ាងស្រណុកសុខស្រួល មានជីវភាពសមរម្យតាមឋានៈរបស់ខ្លួន និងមានការទទួលខុសត្រូវយ៉ាងកក់ក្ដៅពីរាជការ ឬរាជរដ្ឋាភិបាល ដូចជាធ្វើការងារតាមកាលកំណត់ ជួយទំនុកបម្រុងឧបត្ថម្ភ ដល់មនុស្សតាមកម្លាំងពលកម្ម ។

ជាប្រយោជន៍យ៉ាងសំខាន់ មនុស្សរស់នៅក្នុងសង្គម ត្រូវមានសុជីវធម៌ (ជីវិតរស់នៅមានវិន័យល្អ សណ្ដាប់ធ្នាប់ ដោយអាកប្បកិរិយាជាមនុស្សឧត្តុង្គឧត្ដម)ចេះទទួលស្គាល់តម្លៃរបស់មនុស្ស ថាតើត្រូវបំពេញតួនាទីកាតព្វកិច្ចយ៉ាងណា ដូចជា មាតា បិតា មានព្រហ្មវិហារធម៌ ៤ ចំពោះកូនប្រុសស្រី គឺស្រឡាញ់រាប់អានស្មោះស្មើទៅលើកូន មានការប្រៀនប្រដៅអប់រំកូនឱ្យបានទៅជាមនុស្សល្អ កាលបើឃើញកូនធ្វើខុសដោយប្រការណានីមួយ ។ ដទៃក្រៅពីនេះអរិយធម៌គឺ ជួយស្ថាបនាលោកទៅរកសេចក្ដីសុខចម្រើនតែម្យ៉ាង ព្រោះលោកកំពុងមានទុក្ខគ្របសង្កត់ ហើយក៏ពុំមានអ្នកណាក្រៅពីព្រះសម្ពុទ្ធអាចមានឥទ្ធិពលមកជួយរំដោះសត្វលោកកុំឱ្យមានទុក្ខ គឺ ជាតិ ជរា ព្យាធិ មរណៈបានឡើយដែលជាធម្មនិយាមចាំបាច់ត្រូវមានព្រះសម្មាសម្ពុទ្ធមួយអង្គត្រាស់ដឹងឡើងក្នុងលោក ។

ពាក្យប្រៀនប្រដៅរបស់ព្រះអង្គ មានអត្ថន័យខ្លឹមសារយ៉ាងជ្រាលជ្រៅ សំដៅដល់ប្រយោជន៍សត្វ ៣ យ៉ាងដូចតទៅ ៖

* **ទិដ្ឋធម្មិកត្ថប្រយោជន៍** (ប្រយោជន៍ក្នុងបច្ចុប្បន្ន) សម្រាប់គ្រហស្ថអ្នកគ្រប់គ្រងផ្ទះត្រូវធ្វើការងាររកទ្រព្យសម្បត្តិមកចិញ្ចឹមមាតា បិតា បុត្រ ភរិយា និងសមណព្រាហ្មណ៍ មាន ៤ ប្រការ ៖

១- **ឧដ្ឋានសម្បទា** ការដល់ព្រមដោយសេចក្តីព្យាយាម គឺប្រឹងប្រែងក្នុងកិច្ចការគ្រប់យ៉ាង ដើម្បីរកទ្រព្យសម្បត្តិ

២- **អារក្ខសម្បទា** ការដល់ព្រមដោយកិច្ចថែរក្សាទ្រព្យសម្បត្តិដែលរកបានហើយ

៣- **កល្យាណមិត្តតា** ភាពជាអ្នកសេពគប់មិត្តល្អ គឺសប្បុរស

៤- **សមជីវិតា** ភាពជាអ្នកមានជីវិតរស់នៅប្រកបដោយចិត្តស្មើល្អ ចៀសវាងពីការចិញ្ចឹមជីវិតខុសគឺមិច្ឆាជីវៈ ៥ ប្រការ។

ធម៌ទាំង ៤ យ៉ាងនេះជាធម៌ជួយបម្រើលោកទៅរកភាពសម្បូណ៍ សប្បាយរុងរឿងប្រយោជន៍ឱ្យបានសុខស្ងប់ដូចអារ្យប្រទេស សរសេរអក្សរកាត់ (ឧ.អា.ក.ស.) ដែលក្នុងសម័យពុទ្ធកាល ប្រទេសភាគច្រើនបានទទួលនូវភាពរីកចម្រើនខ្ពង់ខ្ពស់ មានទ្រព្យសម្បត្តិច្រើនរាប់មិនអស់ធ្វើជាមហាសេដ្ឋី

រហូតមានភ្នំមាសដុះក្នុងផ្ទះទៀតផង ព្រោះធម៌ ៤ ប្រការនេះឯង ។

* **សម្បរាយិកត្ថប្រយោជន៍** (ប្រយោជន៍ក្នុងបរលោក) ជាប្រយោជន៍ដែលបុគ្គលគួរបំពេញទុកជាបុញ្ញនិធិ គឺកំណប់បុណ្យទៅក្នុងលោកខាងមុខ មាន សុគតិភពជាដើម ចងក្រងនូវធម៌ ៤ ប្រការ គឺ

១- **សទ្ធាសម្បទា** ដល់ព្រមដោយសទ្ធា

២- **សីលសម្បទា** ដល់ព្រមដោយសីល

៣- **ចាគសម្បទា** ដល់ព្រមដោយការបរិច្ចាគទាន

៤- **បញ្ញាសម្បទា** ដល់ព្រមដោយបញ្ញា ។

ជាមហាកុសលញាណសម្បយុត្តជួយរុញច្រានសត្វទទួលបាននូវសេចក្ដីសុខនិងជួយបន្តរហូតដល់ព្រះនិព្វាន សរសេរអក្សរកាត់ (ស.សី.ចា.ប.) ។

* **បរមត្ថប្រយោជន៍** (ប្រយោជន៍ព្រះនិព្វាន) ជាឈ្មោះនៃសេចក្ដីសុខដ៏កំពូល និងលោកជីវិតចុងក្រោយបង្អស់ ដែលជាការសិក្សា ពីចិត្ត ចេតសិករូបក្នុងព្រះអភិធម្ម គឺជីវិតប្រចាំថ្ងៃរបស់សតិប្បដ្ឋាន វិបស្សនា ។

(ក្នុងសៀវភៅប្រយោជន៍ ៣ ប្រការ រៀបរៀងដោយ ភិក្ខុ វជិរប្បញ្ញោ សាន សុជា)

ដូចបានជម្រាបជូនមកនេះ, ព្រះពុទ្ធជាម្ចាស់មានធម៌ខ្វាក់ចេញពីដួងហឫទ័យសង្គ្រោះសត្វលោក គិតគូរពីប្រយោជន៍ ធ្វើឱ្យសត្វលោកបានទទួលនូវសេចក្តីសុខចម្រើនតាមបំណងប្រាថ្នានិងលះបង់នូវកិលេសដែលកើតជាមួយអកុសលចិត្ត ទាំង ១២ ដើម្បីសុភមង្គលក្នុងបច្ចុប្បន្នហើយក៏ទ្រង់មិនបណ្តោយឱ្យនៅកំព្រាគ្មានទីពឹង ទ្រង់បង្ហាញពីសេចក្តីសុខក្នុងទេវលោក ដែលជាសេចក្តីសុខទិព្វជាងសុខក្នុងបច្ចុប្បន្នក៏នៅក្នុងទុក្ខដដែល ព្រោះនៅប្រែប្រួល ។ ដើម្បីឱ្យរួចពីទុក្ខទាំងអស់នេះ ព្រះអង្គលើកឡើងពីបរមត្ថប្រយោជន៍ គឺប្រយោជន៍ក្នុងការសិក្សាពីចិត្ត ចេតសិក រូបរបស់ព្រះអភិធម្មសម្រាប់ឆ្លងចាកលោក ហៅថាព្រះនិព្វាន មានសតិប្បដ្ឋាន ៤ ជាប្រធាននាំមុខ ។

ម្យ៉ាងទៀតក្នុងសម័យសព្វថ្ងៃនេះ ប្រជាជនមួយចំនួន នៅតាមបណ្តាប្រទេសលើសាកលលោក មានការភ្ញាក់ផ្អើលប្រែប្រួលវិលមកកាន់ព្រះពុទ្ធសាសនាភាគច្រើន ដូចជា ប្រទេសឥណ្ឌាដែលជាដើមកំណើតរបស់ព្រះសម្ពុទ្ធទ្រង់ប្រសូតនិងត្រាស់ដឹងក៏បានបោះបង់ព្រហ្មញ្ញសាសនាត្រឡប់មកកាន់ព្រះពុទ្ធសាសនា ដោយគេបានធ្វើពិធីបុណ្យមួយយ៉ាងធំនៅទីក្រុងបុំបៃ មានពុទ្ធបរិស័ទចូលរួមរាប់សែននាក់ដើម្បីប្រកាសយ៉ាងឧឡារិកលែងទទួលស្គាល់ "លទ្ធិព្រហ្មញ្ញសាសនា" វិលមកកាន់

ព្រះពុទ្ធសាសនាវិញ ។ ទ្រង់សម្តែងដោយ **ព្រះភិក្ខុចិត្តរក្ខិតោ សំ-សម្បត្តិ** នាពិធីបុណ្យក្នុងឱកាសបញ្ចុះបឋមសិលា នៅវត្តសុវណ្ណបុទុម ។

សេចក្តីនេះ លើកយកប្រទេសឥណ្ឌាមកជម្រាបជូនថា នាសម័យសព្វថ្ងៃប្រទេសនេះ ត្រូវធ្លាក់ចុះឱនថយយ៉ាងខ្លាំង. ប្រជាជនមានការរស់នៅដោយលំបាកជួបនឹងភាពអត់ឃ្លាន ខ្វះសុខភាព ព្រោះតែបោះបង់ព្រះពុទ្ធសាសនាទៅកាន់លទ្ធិសាសនាដទៃ ដូចជា ព្រហ្មញ្ញសាសនាជាដើម (សាសនាបួងសួង) គ្មានហេតុផលពិតប្រាកដ មិនដូចកាលពីសម័យពុទ្ធកាល ដែលប្រទេសនេះមានភាពរុងរឿងជឿនលឿនខ្លាំងមានអំណាចគ្របដណ្តប់លើប្រទេសឯទៀត១ផងក្នុងសម័យព្រះបាទអសោក ជាស្តេចចុល្លចក្រគ្រប់គ្រងអំណាចក្នុងជម្ពូទ្វីបទាំងមូលយកប្រទេសឥណ្ឌាធ្វើជាព្រះរាជធានី ដែលផ្សព្វផ្សាយអំណាចទៅទិសខាងលើ និងខាងក្រោម ប្រមាណ ១ យោជន៍ ។

**មើលលោកនេះ ក្នុងគំនិតជួយបណ្តុះពូជល្អដល់បុត្ត** កាលណាសង្គមមានអារ្យធម៌គ្រប់គ្រាន់ ការប្រព្រឹត្តធ្វើអ្វី១បានសុខស្រួលគ្មានទំនាស់ខ្វែងគំនិតគ្នាប្រកបដោយសីលធម៌ ដែលជាហេតុធ្វើឱ្យមនុស្សភាគច្រើនចូលចិត្តសាងអំពើល្អ ចៀសវាងពីអំពើអាក្រក់ផ្សេង១ និងមានឥទ្ធិពលផ្សាយទូទៅអាចទទួលស្តាប់នូវឱវាទល្អ១របស់អ្នកប្រាជ្ញ មានព្រះសម្មាសម្ពុទ្ធជាដើម យកមកទុកក្នុងខ្លួន ដូចជាសុភមង្គលរបស់គ្រួសារ

នីមួយៗ ដែលមាតាបិតាចង់ធ្វើការអប់រំបុត្រ នឹងបានសម្រេចលទ្ធផលល្អ ដោយងាយ **សោវចស្សតា** ជាក់ជាមិនខាន ព្រោះកូនស្តាប់បង្គាប់ម៉ែឪណាស់ មើលតម្រាប់ម៉ែឪគ្រប់ពេល។ ម៉ែឪខ្លះមិនដឹងថាកូនឃ្លាំលួចចាំមើលបំណាំក៏ចូលចិត្តប្រព្រឹត្តខុសឆ្គងក្នុងសីលធម៌ផ្សេងៗ រីករវរដល់សង្គមគ្រួសារ មានការចាយវាយផ្តេសផ្តាស ប្រព្រឹត្តអំពើពាលាអាវាសែ ដែលជាហេតុ ទូន្មានកូនមិនបាន ព្រោះកូនមិនស្តាប់បង្គាប់ ក៏ពោលទោសដល់អ្នកដទៃ ។

តាមព្រះពុទ្ធដីការបស់ព្រះជិនស្រីថា កូននៅក្នុងលោកនេះមាន ៣ ជំពូក :

១- កូនណាដែលមានសេចក្តីថ្លៃថ្នូរ ចេះគោរពម៉ែឪ ចាស់ព្រឹទ្ធចារ្យ ជួយម៉ែឪ មានសន្តានចិត្តល្អ ស្គាល់ខុសត្រូវយល់ហេតុផលច្បាស់លាស់មានសទ្ធាស្រឡាញ់អ្នកមាន សីលធម៌លើសមាតាបិតាហៅថា **“អតិជាតបុត្រ”** ។

២- កូនណាមានសេចក្តីក្លាហានក្នុងការកសាងអំពើល្អ ចេះគោរពនិងជួយម៉ែឪព្រមទាំងចាស់ព្រឹទ្ធាចារ្យនិងសមណព្រាហ្មណ៍ដូចបុត្រទី១ តែបញ្ញានៅទាបជាងកូនទី១ មានសីលធម៌ស្មើនឹងមាតាបិតា ចេះជួយដឹកនាំម៉ែឪឱ្យទៅរក

ធមិដូចគ្នា ចេះគោរពស្រឡាញ់ព្រះពុទ្ធសាសនា កូននេះហៅថា **"អនុជាតបុត្រ"** ។

៣- កូនណាមិនស្តាប់បង្គាប់ម៉ែឪ ខិលខូចតាំងពីក្មេងចូលចិត្តបំផ្លាញម៉ែឪមិនគោរពចាស់ព្រឹទ្ធាចារ្យ ចូលចិត្តសេពគប់បាបមិត្ត រហូតដល់លួចម៉ែឪខ្លួនឯង ទោះបីនរណានិយាយក៏មិនស្តាប់ នៅក្នុងសាលារៀន លោកគ្រូអ្នកគ្រូបោះបង់ចោលមិនសូវរាប់អាន ព្រោះអប់រំទូន្មានមិនស្តាប់ កូននោះ ហៅថា **"អវជាតបុត្ត"** ។

ការអប់រំបុត្តទាំងឡាយ មិនសុទ្ធតែបានសម្រេចផលល្អប្រសើរប៉ុន្មានទេ ថ្វីដ្បិតតែមាតាបិតាមានការគ្រប់គ្រងល្អ និងអនុគ្រោះកូនដោយស្ថាន ៥ យ៉ាង ដូចបានជំរាបជូនខាងលើ ព្រោះមានកត្តាច្រើនយ៉ាងទាក់ទងពីអធ្យាស្រ័យរបស់កូន និងហេតុប្បច្ច័យធម្មជាតិ ។ ដោយសេចក្តីថា ក្នុងសម័យបច្ចុប្បន្នរវាងអាយុមនុស្សក្រោម ១០០ ឆ្នាំ ជាពេលវេលានៃការខែចុះរបស់អន្តរកប្បផែនដី ជាកាលវេលាសម្បូណ៌ទៅដោយកិលេស បណ្តាលឱ្យមនុស្សចូលចិត្តប្រព្រឹត្តអំពើខុសឆ្គងខ្វះសីលធមិទូទាំងប្រទេសលើសាកលលោក មានសម្តែងនៅក្នុងសៀវភៅ **"ពុទ្ធព្យាករណ៍"** ដូចជា សម័យពុទ្ធកាលក៏នៅមានការប្រព្រឹត្តខុសយ៉ាង

ច្រើន ទាំងឃរាវាស និង បព្វជិត (**ព្រះសង្ឃ**) ដែលបានចូលមកថ្វាយខ្លួនបួស ជាភិក្ខុ ភិក្ខុនី ចំពោះព្រះដ៏មានព្រះភាគក៏នៅតែប្រព្រឹត្តខុសឆ្គងយ៉ាង ច្រើនរាប់មិនអស់ដែលជាហេតុធ្វើឱ្យព្រះសម្មាសម្ពុទ្ធទ្រង់បញ្ញត្តព្រះវិន័យ មានសិក្ខាបទ ២២៧ សម្រាប់ភិក្ខុ និងភិក្ខុនីចំនួន ៣១១ មានទាំងគរុធម៌ ៨ ប្រការផង ។ ម្យ៉ាងទៀតទាក់ទងពីបច្ច័យដទៃទៀតយ៉ាងច្រើន ដូចជាអធ្យាស្រ័យធាតុ ក្នុងសង្គមនិងក្នុងកាលៈទេសៈប្រទេសជាតិជួប ប្រទះនឹងគ្រោះមហន្តរាយជាយថាហេតុ គឺប្រទេសមានសង្គ្រាម គ្រោះទុរ្ភិក្សអត់ឃ្លាន ក៏នាំឱ្យមានអំពើចោរកម្មផ្សេងៗ ជាបរពោឃោសៈ ក៏មិនងាយនឹងអប់រំទូន្មានកូនឱ្យបានល្អដែរ ។ តែទោះបីយ៉ាងនេះក៏មាន កូនខ្លះគេអប់រំបានល្អ ព្រោះអាស្រ័យពីការសេពគប់ក្នុងសង្គម បើការសេពគប់មិត្តល្អ (**កល្យាណមិត្ត**) តែងនាំមកនូវសេចក្ដីសុខចម្រើន ដែលព្រះសម្មាសម្ពុទ្ធ ទ្រង់សម្ដែងព្រះគាថាទុកនៅក្នុងមង្គលសូត្រថា :

**អសេវនា ច ពាលានំ បណ្ឌិតានញ្ច សេវនា**

**បូជា ច បូជ និយានំ ឯតម្មង្គលមុត្តមំ**

ប្រែថា : កិរិយាមិនសេពគប់នូវបុគ្គលពាលទាំងឡាយ១, កិរិយាសេពគប់នូវបុគ្គលជាបណ្ឌិតទាំងឡាយ១, កិរិយាបូជាដល់បុគ្គលដែលគួរបូជាទាំងឡាយ១, ទាំង ៣ នេះ ជាមង្គលដ៏ឧត្តម ។

# មេរៀនសម្រាប់យុវវ័យ

សូមសិស្សទាំងឡាយ ចូរអ្នកខ្វល់ខ្វាយ ខិតខំសិក្សា
ស្តាប់គ្រូពន្យល់ ពាក្យពេចន៍អក្ខរា មេរៀនវិជ្ជា
ត្រិះរិះក្នុងចិត្ត ។

កុំគិតដើរលេង សប្បាយនឹងភ្លេង ដក់ចិត្តយ៉ាងស្អិត
ខូចការសិក្សា មោហាបាំងបិទ គ្មានចំណេះឋិត
នៅក្នុងខ្លួនឯង ។

មូលហេតុមកពី គប់អ្នកដទៃ ពុំមើលជាក់ស្តែង
នាំដើរផ្លូវខុស មិនចេះកោតក្រែង ទាញបែរបង្វែង
រាំច្រៀងកម្សាន្ត ។

បើខុសហួសហើយ ក៏កុំកន្តើយ អប់រំចិត្តបាន
ឱ្យតែព្រមស្ម័គ្រ សេពគប់កល្យាណ ពិតជាស្រោកស្រាន្ត
ស្បើយទុក្ខតទៅ ។

បើរៀនចេះដឹង កូនកុំស្រើង ភ្លេចម៉ែភ្លេចឪ
គុណគ្រូអាចារ្យ អ្នកបង្ហាញផ្លូវ ភ្លេចមិនត្រឹមត្រូវ
ដុតបំផ្លាញគល់ ។

បើកូនផ្លាស់ប្តូរ មានចិត្តអាសូរ គិតគូររវល់
មាតាបិតា ករុណាជាផល កូនទុកតម្កល់
មិនធ្លាក់អបាយ ។

បើធ្វើដំណើរ យានយន្តឬដើរ ទោះជិត ឬឆ្ងាយ
នឹកគុណម៉ែឪ កុសលទាំងឡាយ ការពារអន្តរាយ
គ្រោះថ្នាក់តាមផ្លូវ ។

ម្យ៉ាងទៀតលោកផ្តាំ សូមកូនចងចាំ កុំជួញសត្រូវ
សាងមិត្តល្អវិញ ចំណេញដឹងត្រូវ នាំដើរឆ្ពោះទៅ
ស្ថានបរមសុខ ។

ធម៌មានតម្លៃ ដាស់តឿនរាល់ថ្ងៃ បំបាត់អផ្សុក
ជម្រះក្លិនស្អាប បន្សាបគ្រប់មុខ រួចផុតចាកទុក្ខ
គ្មានអ្វីបៀតបៀន ។

បើកូនស្ទាក់ស្ទើរ នៅតែភ្លីភ្លើ គេរុញទៅកៀន
រស់ចង្អៀតលោក មិនព្រមចង់រៀន ស្តាប់ធម៌ខ្មាសអៀន
ថាខ្ញុំនៅក្មេង ។

បើកូនធ្វើការ បម្រើរាជការ មានមុខតំណែង
គោរពអ្នកធំ អ្នកតូចកោតក្រែង រាប់អានកូនឯង
ទុកជាកិត្តិយស ។

កូនសាងចិត្តល្អ មិនចេះស្គាល់ក្រ មួយជីវិតរស់
បើចង់សាងគុណ ចូលទ្រង់ព្រះផ្នួស សាងពាក្យពីរោះ
ស្តាប់ធម៌រាល់ថ្ងៃ ។

សម្បត្តិក្នុងលោក មានច្រើនគរគោក ពុំមានតម្លៃ
ប្រៀបនឹងព្រះធម៌ ពុំអាចកាត់ថ្លៃ កូនមាសចរណៃ
ឪផ្តាំទុកកេរ្តិ៍ ។

បើកូនចង់សុខ កុំសាងពូជទុក្ខ ពោលប្រទេចជេរ
វាចាអាក្រក់ ផលមិនភ្លេចទេ មិនដែលទំនេរ
ឱ្យកូនរួចខ្លួន។

បើកូនចង់ឆ្លាត ខិតខំសង្វាត រៀនធម៌មាំមួន
នឹកគុណព្រះពុទ្ធ ព្រះធម៌មគ្គ ៤ មុនពេលដេកពួន
ថ្វាយបង្គំព្រះ ។

ការរមិលគុណនាំមកនូវសេចក្ដីវិនាស

## ៤- សង្គហធម៌រវាងមនុស្សរស់នៅជុំវិញ

### ភារកិច្ចរបស់កុលបុត្តអ្នកគ្រប់គ្រងផ្ទះ មាន ៥ :

មិត្តអាមាត្យ ជាទិសខាងជើងក៏ត្រូវមានការស្រឡាញ់រាប់អានគ្នា ថ្វីដ្បិតតែអ្នកទាំងនោះជាអ្នកដទៃ ក៏មិនមែនមានធមិសម្រាប់តែសុភមង្គលក្នុងសង្គមគ្រួសារមួយយ៉ាងតូចប៉ុណ្ណោះទេ ត្រូវមានធមិអនុគ្រោះដល់គ្នា ដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្ដែង ។

ចំពោះមិត្តអាមាត្យជាទិសខាងជើង កុលបុត្រត្រូវប្រតិបត្តិដោយស្ថាន ៥ យ៉ាងដែរ :

១- ដោយការបរិច្ចាគទ្រព្យសម្បត្តិគឺឱ្យរបស់

២- ដោយការនិយាយតែពាក្យគាប់ចិត្ត

៣- ដោយការប្រព្រឹត្តឱ្យជាប្រយោជន៍

៤- ដោយការប្រព្រឹត្តខ្លួនស្មើ ( មិនប្រកាន់)

៥- ដោយការមិនពោលពាក្យកុហកបោកប្រាស់ ។

ព្រោះអ្នកនៅជុំវិញ រួមរស់ក្នុងសង្គមទុកដូចជាញាតិតែមួយដែលមិនត្រូវប្រព្រឹត្តអំពើអ្វីៗ មិនសមហេតុផលដោយអ្នកនេះ ជាអ្នកជួយរកប្រយោជន៍ឱ្យយើង ស្រឡាញ់យើង ជួយថែរក្សាការពារក្នុងគ្រាមានអាសន្នម្ដងម្កាល តាមពេលវេលា ។

## ភារកិច្ចរបស់មិត្តអាមាត្យ មាន ៥ :

ដូច្នេះឯងហើយ បានជាមិត្តអាមាត្យត្រូវសង្គ្រោះអ្នក ដោយស្ថាន ៥ យ៉ាងដែរ ព្រោះសម្លឹងឃើញសេចក្ដីល្អដែលមិនអាចរអត់ទ្រាំនៅស្ងៀមថា នឹងមិនបំពេញកតញ្ញូតបរិញ្ញពុំបាន ។

១- ជួយថែរក្សាមិត្តក្នុងពេលមានការភ្លាំងភ្លាត់ធ្វេសប្រហែស

២- ជួយថែរក្សាទ្រព្យសម្បត្តិរបស់មិត្ត ដែលធ្វេសប្រហែស

៣- ជាទីពឹងរបស់មិត្តនៅពេលមានភ័យកើតឡើង

៤- មិនបោះបង់គ្នាក្នុងគ្រាមានវិបត្តិអាសន្ន

៥- រាប់អានរហូតដល់ផៅពង្សរបស់មិត្ត ។

ដែលសង្គមមួយមានថាមពលខ្លាំងក្លាប្រកបដោយសីលធម៌ មិនសង្កត់សង្កិនរំលោភសិទ្ធិគ្នា រស់នៅប្រកបដោយភាពស្រុះស្រួលមិនប្រកាន់ និងចេះគោរពគ្នាធ្វើឱ្យមានសេចក្ដីសុខយ៉ាងក្រៃលែង ។

| | | |
|---|---|---|
| មនុស្សរស់នៅ | ជុំវិញខ្លួន | គេអប់រំ |
| ចិត្តបន្ទុំ | ឱ្យមេត្តា | គ្រាប្រណី |
| ជួយសន្តោស | ទុករាប់អាន | មានមេត្រី |
| ទោះពោលស្ដី | ជាមួយគ្នា | ដោយញញឹម ។ |

មនុស្សល្អមានពន្លឺបញ្ញាជាពូជ ។

## ៥- សង្គហធម៌រវាងទាសៈនិងកម្មករ

### ភារកិច្ចរបស់ចៅហ្វាយនាយមាន ៥ :

កាលបើអ្នកនៅរួមរស់ជាមួយ មានធម៌សង្គ្រោះដោយទឹកចិត្តមេត្តាគ្នាជាធ្លុងមួយយ៉ាងនេះ សត្រូវពីខាងក្រៅក៏មិនអាច លូកដៃចូលមកខាងក្នុងបានដោយងាយ មានតែជួយការពារស្រឡាញ់រាប់អានថែមទៀត ដែលជាហេតុនាំមកនូវសេចក្ដីសុខសប្បាយជាអតិបរមា ព្រោះហេតុនោះ ទើបព្រះសម្មាសម្ពុទ្ធ ទ្រង់លើកយកពីទាសៈនិងកម្មករជាទិសខាងក្រោមមកសម្ដែងប្រាប់ទៀត ។

ទាសៈនិងកម្មករជាទិសខាងក្រោម ចៅហ្វាយនាយត្រូវទំនុកបម្រុងដោយស្ថាន ៥ យ៉ាងផ្សេង :

១- ដោយការចាត់ចែងការងារសមគួរតាមអត្ថភាព ដោយសេចក្ដីថា មិនយកការងាររបស់មនុស្សក្មេងឱ្យមនុស្សចាស់ធ្វើ ឬឱ្យការងារក្មេងធ្វើការងារមនុស្សចាស់ មិនឱ្យការងារមនុស្សប្រុសដល់មនុស្សស្រីធ្វើ ឬមិនឱ្យការងារមនុស្សស្រីមកបុរសធ្វើវិញ ដោយចាត់ចែងការងារតាមកម្លាំងសមត្ថភាពរបស់ខ្លួន ។

២- ដោយការឱ្យនូវភត្តាហារ និងថ្លៃឈ្នួលសមល្មម តាមកម្លាំងពលកម្ម ដោយសេចក្តីថា ឱ្យថ្លៃឈ្នួលតាមកម្លាំងការងារ គឺក្មេងតាមក្មេង ចាស់តាមចាស់ មិនច្រឡូកច្របល់គ្នា ។

៣- ជួយថែរក្សាព្យាបាល ក្នុងវេលាមានជំងឺឈឺថ្កាត់ ដោយសេចក្តីថា ឱ្យឈប់សម្រាកក្នុងវេលាមានជំងឺ ឱ្យថ្នាំព្យាបាល ឬនាំទៅមន្ទីរពេទ្យ ។

៤- ដោយការចែករំលែកនូវរបស់មានរសត្រកាលចម្លែក ដោយសេចក្តីថា ពេលបានចំណីអ្វីមានរសឆ្ងាញ់ពិសារប្លែកៗ មិនបរិភោគតែម្នាក់ឯង តែងតែរំលែកចែកដល់អ្នកទាំងនោះ ។

៥- មានការអនុគ្រោះឱ្យឈប់សម្រាកក្នុងសម័យដ៏គួរ ដោយសេចក្តីថា អនុគ្រោះក្នុងនិច្ចសម័យ និងកាលសម័យ គឺ

- និច្ចសម័យ : ទាសៈ និងកម្មករ ធ្វើការងារពេញមួយថ្ងៃរមែងនឿយហត់អស់កម្លាំង ដូច្នោះត្រូវមានពេលឈប់សម្រាកដើម្បីកុំឱ្យនឿយហត់បាក់កម្លាំង ។

- កាលសម័យ : ការឱ្យគ្រឿងតាក់តែងកាយ និងអាហារពិសេសជាដើម ក្នុងថ្ងៃបុណ្យសំខាន់ៗ ប្រចាំសាសនា ឬថ្ងៃបុណ្យប្រពៃណីជាតិ កំណត់ឱ្យសម្រាក ពីការងារ ។

## ភារកិច្ចរបស់ទាសៈនិងកម្មករ មាន ៥ :

ចៅហ្វាយនាយមានធម៌ជួយអនុគ្រោះ ដល់ការរស់នៅរបស់ខ្លួន ជួយទំនុកបម្រុងនិងមិនប្រើហិង្សាដឹងសុខដឹងទុក្ខយ៉ាងនេះ ធ្វើឱ្យកម្មករជាទិសខាងក្រោម ពេញចិត្តស្រឡាញ់គោរពរាប់អានដល់ចៅហ្វាយនាយវិញ ដោយខំបម្រើធ្វើការងារមិនខ្លាចនឿយហត់ ទោះយប់ថ្ងៃក្តីក៏សប្បាយរីករាយចូលរួមយ៉ាងសស្រាក់សស្រាំ មិនឱ្យចៅហ្វាយនាយឃ្នើសចិត្តព្រួយលំបាក ដោយព្រះសម្មាសម្ពុទ្ធលើកឡើងពីស្ថាន ៥ យ៉ាងដែរ :

១- ក្រោកឡើងមុនធ្វើការងារបម្រើចៅហ្វាយនាយ

២- ឈប់សម្រាកធ្វើការងារក្រោយចៅហ្វាយនាយ

៣- កាន់យកតែរបស់ដែលចៅហ្វាយឱ្យ

៤- ធ្វើការងារបម្រើឱ្យចៅហ្វាយនាយយ៉ាងយកចិត្តទុកដាក់ ដោយសេចក្តីថា មិនសម្លឹងទោស គិតតែពីធ្វើការងារ ដែលចៅហ្វាយប្រគល់ឱ្យតាមមុខនាទីដោយរីករាយ

៥- នាំកិត្តិគុណរបស់ចៅហ្វាយនាយ ទៅថ្លែងក្នុងទីនោះៗ ដោយសេចក្តីថា នាំសេចក្តីល្អរបស់ចៅហ្វាយទៅលើកសរសើរគុណក្នុងទីប្រជុំកណ្តាលបរិស័ទ ដែលធ្លាប់អនុគ្រោះខ្លួន ។

នេះជាស្នាដៃសុជីវធម៌ក្នុងសង្គហធម៌របស់ធម្មៈពិត ដែលមិនមែនមានច្បាប់ឯណា ក្រៅពីបញ្ញាបារមីរបស់ព្រះពុទ្ធអង្គជួយស្រោចស្រង់សត្វ ទ្រង់ប្រសូតនូវស្ថានប្រាំយ៉ាង ទុកបន្តវង្សព្រះពុទ្ធសាសនា ។

បើមានមនុស្ស រស់ជាមួយ នៅក្នុងផ្ទះ
វៀរស្រឡះ ភាពមិនល្អ កម្រផ្កាច់
ត្រូវគិតគូរ អាសូរគ្នា ជួយសម្រេច
កុំប្រចាច់ កៀបសង្កត់ ផ្លូវចិត្តឡើយ ។

គ្មានអ្វីប្រសើរជាងការជួយសង្គ្រោះអ្នកដទៃ ។

## ៦- ការបដិបត្តិរវាងគ្រហស្ថនិងសមណព្រាហ្មណ៍

### ភារកិច្ចរបស់គ្រហស្ថមាន ៥ :

តាមធម្មតានៅក្នុងសង្គមនីមួយៗ គេមិនគិតគួរត្រឹមរឿងក្នុងគ្រួសារមួយប៉ុណ្ណោះទេក៏គួរយកចិត្តទុកដាក់ដល់អ្នកដទៃផ្សេងៗទៀត ព្រោះថា ការធ្វើល្អនាំមកនូវផលល្អ ដោយកុំគិតតែពីចំណូលចំណេញច្រើនពេក បើពុំមានបញ្ចេញនូវកាកសំណល់ខ្លះៗ ចំណូលក៏មិនសូវសម្បូណ៌យ៉ាងណា ក្នុងរូបរាងកាយនៃយើងម្នាក់ៗ បើគិតតែពីបរិភោគអាហារពុំមាន ការបន្ទោបង់ឧច្ចារបស្សាវៈ សុខភាពផ្លូវកាយក៏មិនសូវស្រួលដែរ ។

ម្ល៉ោះហើយកុលបុត្រត្រូវប្រតិបត្តិចំពោះសមណព្រាហ្មណ៍ក្នុងព្រះពុទ្ធសាសនា ជាទិសខាងលើដោយស្ថាន ៥ យ៉ាងទៀត ទើបកសាងបានជាមនុស្សល្អរស់នៅក្នុងសង្គមទៅបាន ។ ធម៌ក្នុងចំណែក ៥ យ៉ាងនោះគឺ

១- កាយកម្មប្រកបដោយមេត្តា

២- វចីកម្មប្រកបដោយមេត្តា

៣- មនោកម្មប្រកបដោយមេត្តា

៤- ជាអ្នកមិនបិទទ្វារផ្ទះទេ (ឱ្យទានជានិច្ច)

៥- ដោយកិរិយាឱ្យអាមិសទាន ។

បើចង់ចំណេញត្រូវហ៊ានចំណាយ លះបង់កុំស្ដាយមិនបង្អង់យូរ
ការពាររូបកាយដោយការតស៊ូ យកទ្រព្យដោះដូរការពារជីវិត ។
ចង់រស់មានខ្លឹមខិតខំដោះស្រាយ កុសលទាំងឡាយសន្សំទុកពិត
ចំណាយខ្លួនប្រាណបូជាជីវិត យកធម៌ប្រណីតតោងព្រះនិព្វាន ។

ការបូជាគុណព្រះរតនត្រៃនាំមកនូវសេចក្ដីសុខចម្រើន ។

## ភារកិច្ចរបស់សមណព្រាហ្មណ៍មាន ៦ :

កាលបើ កុលបុត្តគោរពដល់សមណព្រាហ្មណ៍ដោយទឹកចិត្តជ្រះថ្លា យ៉ាងនេះហើយ សមណព្រាហ្មណ៍ជាទិសខាងលើតែងមានមេត្តាករុណា គុណដល់ទាយកដោយស្ថាន ៦ យ៉ាងទៅវិញ

១- ហាមឃាត់កុលបុត្តចាកអំពើអាក្រក់
២- ឱ្យតាំងនៅក្នុងអំពើល្អ
៣- អនុគ្រោះដោយចិត្តដ៏ល្អ
៤- ឱ្យបានស្ដាប់ពាក្យដែលមិនធ្លាប់ស្ដាប់
៥- បំភ្លឺសេចក្ដីដែលធ្លាប់ស្ដាប់ហើយ
៦- ប្រាប់ផ្លូវសួគ៌ ។

ព្រះសង្ឃសាវ័កទ្រទ្រង់ធម៌ មានសីលស្អាតល្អពោលពាក្យពិត
មិនបៀតបៀនសត្វជួយជីវិត ឱ្យឋិតនៅក្នុងភាពសុខសាន្ត ។
កូនត្រូវចិញ្ចឹមតបសងគុណ ទុកជាស្រែបុណ្យបំពេញទាន
លះចិត្តកំណាញ់ទ្រព្យធនមាន ដូរព្រះនិព្វានចេញចាកលោក ។
គ្មានអ្វីក្រៃលែងជាងបម្រើ ព្រះសង្ឃប្រសើរគ្មានសំយោគ
បុណ្យច្រើនឱ្យផលត្រជាក់ល្អក ព្រះដ៏មានជោគទ្រង់ពោលទុក ។
បើកូនខ្ជិលមិនព្រមស៊ូគ្រស្មោះ បម្រើឡេះឡោះលួចហូបចុក
ម្ហូបម្ហាបម្រុងច្រើនគ្រប់មុខ កូនមិនបានសុខធ្លាក់អបាយ ។
ព្រះសង្ឃដូចភ្លើងដុតឆេះព្រៃ កិលេសចង្រៃជ្រុះពីកាយ
ដោយវិបស្សនាជាឧបាយ ដែលទ្រង់ត្រួសត្រាយតាមធម្មា ។

មាតាបិតាជាទិសខាងកើត អាចារ្យជាទិសខាងត្បូង កូនប្រពន្ធជាទិសខាងលិច មិត្តជាទិសខាងជើង ទាសៈនិងកម្មករជាទិសខាងក្រោម សមណព្រាហ្មណ៍ជាទិសខាងលើ គ្រហស្ថក្នុងត្រកូលដែលអាចគ្រប់គ្រងផ្ទះ គប្បីនមស្ការទិសទាំងឡាយនុះ ។ បណ្ឌិតបរិបូរដោយសីលមានវាចាពីរោះ មានប្រាជ្ញាវាងវៃ មានកិរិយាប្រព្រឹត្តឱនលំទោនជាប្រក្រតី មិនរឹងត្អឹង បុគ្គលមានសភាពដូច្នោះរមែងបានយស បុគ្គលមានព្យាយាមរវៀសរវៃ មិនខ្ជិលច្រអូសរមែងមិនញាប់ញ័រក្នុងអន្តរាយទាំងឡាយ

បុគ្គលមានកិរិយាប្រព្រឹត្តឥតចន្លោះ មានប្រាជ្ញាវាងវៃ រមែងបានយស ។ បុគ្គលមានសេចក្ដីសង្គ្រោះ ជាអ្នកចងមិត្ត ជាអ្នកដឹងដំណើរពាក្យ ប្រាស ចាកការកំណាញ់ដឹកនាំពន្យល់ការណ៍ផ្សេងៗ ជាអ្នកណែនាំរឿយៗ រមែង បានយស ។ ទាន ១ ពាក្យពីរោះ ១ សេចក្ដីប្រព្រឹត្តជាប្រយោជន៍ ក្នុង លោកនេះ ១ ភាវៈ ជាអ្នកមានចិត្តស្មើ ( មិនប្រកាន់) ក្នុងធម៌ទាំងឡាយ ដល់បុគ្គលនោះ ៗ តាមសមគួរ ១ ។ សង្គហធម៌ទាំងនេះ ( មានក្នុងលោក ទើបលោកប្រព្រឹត្តទៅបាន) ដូចជា រថមានប្រែកទប់ដូច្នោះឯង បើ សង្គហធម៌ទាំងនេះមិនមានហើយ មាតាក្ដី បិតាក្ដី ក៏មិនបាននូវសេចក្ដី រាប់អាននិងការបូជាអំពីកិច្ចដែលកូនត្រូវធ្វើ ។ ព្រោះហេតុ តែអ្នកប្រាជ្ញ ទាំងឡាយសម្លឹងឃើញសង្គហធម៌ទាំងនោះដោយប្រពៃ ហេតុនោះបាន ជាលោកដល់នូវភាវៈជាធំជាង គួរគេសរសើរផង ។

សេចក្ដីនេះមានយ៉ាងណា កាលព្រះមានព្រះភាគទ្រង់ទតឃើញ សិង្គាលកគហបតិបុត្ត ក្រោកឡើងអំពីព្រឹក មានសំពត់ស្លៀកដណ្ដប់ទទឹក និងសក់ក៏ទទឹកចេញពីក្រុងរាជគ្រឹះ កំពុងផ្គងអញ្ជលីថ្វាយបង្គំនូវទិសទាំង ឡាយច្រើន គឺទិសខាងកើត ខាងត្បូង ខាងលិច ខាងជើង ខាងក្រោម និងទិសខាងលើ ទើបទ្រង់ត្រាស់សួរសិង្គាលកគហបតិបុត្ត ដូច្នេះថា នែ! គហបតិបុត្ត ហេតុអ្វីទើបអ្នកក្រោកអំពីព្រឹក ចេញពីក្រុងរាជគ្រឹះផ្គង អញ្ជលី ថ្វាយបង្គំទិសទាំងឡាយច្រើនដូច្នោះ ។ សិង្គាលកគហបតិបុត្ត

ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន កាលបិតារបស់ខ្ញុំព្រះករុណាហៀបនឹងធ្វើមរណកាល បានផ្តាំនឹងខ្ញុំព្រះអង្គយ៉ាងនេះថា ហៃ! បាអ្នកត្រូវតែថ្វាយបង្គំ ទិសទាំងឡាយ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនោះធ្វើសក្ការៈគោរព រាប់អានបូជា នូវពាក្យរបស់បិតា ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា នែគហបតិបុត្ត ក្នុងវិន័យរបស់ព្រះអរិយៈ គេមិនត្រូវថ្វាយបង្គំទិសទាំង ៦ យ៉ាងដូច្នេះទេ ។ ម្នាលគហបតិបុត្ត អ្នកត្រូវដឹងទិសទាំង ៦ ដូច្នេះ គឺ មាតាបិតា អ្នកត្រូវដឹងថាទិសខាងកើត ១, អាចារ្យអ្នកត្រូវដឹងថាទិសខាងត្បូង ១, កូននិងប្រពន្ធអ្នកត្រូវដឹងថាទិសខាងលិច ១, មិត្តអាមាត្យ អ្នកត្រូវដឹងថាទិសខាងជើង ១, ទាសៈ និងកម្មករអ្នកត្រូវដឹងថាទិសខាងក្រោម១, សមណព្រាហ្មណ៍អ្នកត្រូវដឹងថាទិសខាងលើ១, ។ ចំពោះទិសនីមួយៗទាំងនេះក៏មិនមែន ត្រឹមតែថ្វាយបង្គំប្រណម្យអញ្ជលីដោយពុំដឹងអ្វីសោះនោះទេ ព្រោះអ្វីៗ កើតឡើងសុទ្ធតែមានហេតុប្បច្ច័យយ៉ាងណា ការថ្វាយបង្គំទិសនោះ ត្រូវមានការគោរពបដិបត្តិឱ្យបានត្រឹមត្រូវ តាមធម៌ដូចដែលតថាគត សម្តែងនោះឯងឈ្មោះថាថ្វាយបង្គំ គឺសំដៅយកការសង្គ្រោះដោយធម៌ ៥ យ៉ាងទៅវិញទេ ទើបបានសម្រេចប្រយោជន៍ បើគ្រាន់តែថ្វាយបង្គំទទេគ្មានដឹងគ្មានយល់អ្វីសោះនោះ តើអត្ថន័យខ្លឹមសារនៃជីវិតនៅត្រង់ណាដូចជារាល់ថ្ងៃពុទ្ធបរិស័ទមួយចំនួនតែងតែនមស្ការថ្វាយបង្គំព្រះរតនត្រ័យ

តើខ្លឹមសារដែល ត្រូវប្រតិបត្តិនោះ នៅកន្លែងណាដូចគ្នា ប្រការទាំងនេះក៏គួរពិចារណា ឱ្យបានល្អិតល្អន់ក្នុងការបានអត្តភាពជាមនុស្ស, ជាការកម្រយ៉ាងក្រៃលែង ។ តែបើខ្វះការសិក្សាឱ្យបានយល់ដឹង មុខជានឹងភ្លាត់វង្វេងទៅរកការប្រព្រឹត្តខុស រហូតដល់ជីវិតចុងក្រោយគ្មានបានអ្វីសោះយកទៅជាមួយ បើត្រឹមតែសូត្រ ដូចជា សិង្គាលកគហបតិបុត្ត ប្រសិនបើពុំបានជួបនឹងព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ដឹងឡើងក្នុងលោក ការមិនដឹងនេះនៅជាប់រហូត ទោះបីទេវតាមារព្រហ្មជាដើម ក៏ពុំដឹងដែរ រឿងមានកន្លងមកហើយ ក្នុងមង្គលសូត្រ ៣៨ ប្រការនោះដូចទិសទាំង ៦ ដែលត្រូវបិទបាំងដោយអរិយសាវក យ៉ាងនេះឯង ។

## ហេតុនាំឱ្យមានការថ្វាយបង្គំទិសទាំងឡាយ

នៅក្នុងអដ្ឋកថា ទីឃនិកាយ បាដិកវគ្គ លេខ ១៩/៩៤ ទ្រង់ត្រាស់សម្ដែងថា : សម័យថ្ងៃមួយ ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់និមន្តយាងទៅកាន់ក្រុងរាជគ្រឹះ បានប្រថាប់នៅក្នុងព្រះវិហារវត្តវេឡុវ័ន ជាកន្លែងប្រទានអាហារដល់សត្វកន្លឹក ក្នុងសួនឧទ្យាននោះ ។ គ្រានោះមានសេដ្ឋីម្នាក់ឈ្មោះ គហបតិមហាសាល មានទ្រព្យសម្បត្តិ ៤០ កោដិ និងមានកូនប្រុសម្នាក់ឈ្មោះ គហបតិបុត្រ ជាអ្នកមិនមានសទ្ធា ចំណែកមាតាបិតាវិញជាអ្នកមានសទ្ធា ជឿមាំក្នុងគុណព្រះពុទ្ធសាសនា ជាឧបាសក អ្នកបានសម្រេច សោតាបន្នទាំងពីរនាក់ប្ដីប្រពន្ធ កំពុងមាន

ការព្រួយបារម្ភយ៉ាងខ្លាំងចំពោះ កូនប្រុសរបស់គាត់ ដែលមិនជ្រះថ្លាក្នុងគុណព្រះពុទ្ធព្រះធម៌ព្រះសង្ឃ ។ គ្រានោះមាតាបិតាតែងអប់រំទូន្មានកូនជារឿយៗយ៉ាងនោះថា នែ៎ កូន អ្នកចូរទៅគាល់ព្រះសាស្តា ចូល ទៅរកព្រះធម្មសេនាបតីសេរីបុត្រ ព្រះមហាមោគ្គល្លាន ព្រះមហាកស្សបៈ ព្រះមហាសាវក ៨០ អង្គ ។ ពេលនោះបុត្តក៏ពោលឡើងថា : កាលបើចូលទៅរកព្រះសមណៈទាំងឡាយ របស់ព្រះមាតាបិតា រមែងមិនមានដល់ខ្ញុំទេ ព្រោះការចូលទៅនោះ ត្រូវសំពះឱនចុះក្រោមជាហេតុនាំឱ្យរោយខ្នង ត្រូវអង្គុយនៅលើដី ធ្វើឱ្យសំពត់ប្រឡាក់ដីសឹករេចចាស់ និងមានការសន្ទនាស្និទ្ធស្នាល ឬក៏ត្រូវនិមន្ត ដើម្បីធ្វើបុណ្យទានយ៉ាងណានឹងប្រគេនទេយ្យធម៌មានត្រៃចីវរនិងអាហារបិណ្ឌបាតជាដើម ដែលនាំឱ្យខូចប្រយោជន៍ គឺអស់ទ្រព្យសម្បត្តិទៀតផង ។ មាតាបិតាមិនអាចដឹកនាំកូនបាន នៅពេលសម្រាកលើគ្រែជិតនឹងធ្វើមរណកាលក៏ត្រិះរិះគិតថា នឹងឱ្យឱវាទកូនដោយឱ្យកូនគោរពថ្វាយបង្គំនូវទិសទាំងឡាយរាល់ព្រឹកចុះ ព្រោះពេលកំពុងថ្វាយបង្គំនោះប្រាកដជានឹងបានជួបព្រះសាស្តាឬព្រះសង្ឃសាវកទាំងឡាយអង្គណាមួយមិនខានដែលអាចទូន្មានបុត្តរបស់យើងឱ្យមានសទ្ធាជឿគុណ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ និងបានធ្វើបុណ្យទានតទៅ ។

ដោយហេតុនេះ បានជាកូនគហបតីមហាសាលឈ្មោះ គហបតីបុត្ត ត្រូវក្រោកពីព្រឹកថ្វាយបង្គំនូវទិសទាំងឡាយនោះ តាមពាក្យបណ្តាំ របស់ **បិតាមាតា** ព្រោះទិសទាំងឡាយមានអត្ថន័យជ្រាលជ្រៅល្អិតល្អន់ ដែលមានតែព្រះសម្មាសម្ពុទ្ធឬព្រះសង្ឃសាវក ទើបអាចជ្រាបដឹងនូវអត្ថន័យនោះបាន ។

**អត្ថន័យរបស់ទិសទាំង ៦ មានដូចតទៅ :**

១- មាតាបិតាជាទិសខាងកើត ហៅថា(ទិសខាងមុខ) ព្រោះជាអ្នកមានឧបការៈមុន ។

២- លោកគ្រូអាចារ្យជាទិសខាងត្បូងហៅថា (ខាងស្តាំ) ព្រោះជាអ្នក គួរដល់ទក្ខិណា ។

៣- បុត្តភរិយាជាទិសខាងលិចហៅថា (ខាងក្រោយ) ដោយអំណាច នៃការគិតតាមក្រោយ ។

៤- មិត្តសម្លាញ់ជាទិសខាងជើង ព្រោះកុលបុត្តទាំងនោះអាស្រ័យមិត្ត និងសំឡាញ់ ទើបរួចផុតចាកទុក្ខទៅបាន ។

៥- ទាសៈនិងកម្មករ ជាទិសខាងក្រោម ដោយការតាំងនៅក្បែរជើង ។

៦- សមណព្រាហ្មណ៍ ជាទិសខាងលើ ព្រោះតាំងនៅដោយ គុណធម៌ទាំងឡាយ ។

កាលបើស្វែងរកសុខ ក៏គួរឆ្លងកាត់នូវការប្រតិបត្តិតាមទិសទាំង ៦ នេះ ទើបរួចផុតចាកទុក្ខដែលព្រះអរិយៈទាំងឡាយលោកបានដល់ត្រើយ គឺ ព្រះនិព្វាន ព្រោះតែនមស្ការថ្វាយបង្គំយ៉ាងដូច្នេះឯង ។

## បណ្តាំម៉ែឪ

កូនល្អស្តាប់ម៉ែឪ ជាពន្លឺដល់ពូជពង្ស
សំអាតចិត្តស្មោះត្រង់ ជួយស្រោចស្រង់ពួកញាតិមិត្ត ។
កុំលេងល្បែងភ្នាល់ នាំកង្វល់ព្រួយរិះគិត
ល្បែងនេះមិនដែលពិត គេជីវិតយកតែប្រាក់ ។
ចាញ់ល្បែងខាតអស់ទ្រព្យ តែកុំឡប់ស្មារតីភ្នាក់
សទ្ធាបានជឿជាក់ មិនឱ្យអ្នកនៅកំព្រា ។
យូរឆាប់គង់ស្រោកស្រាន្ត កុសលមានព្រោះឧស្សាហ៍
រៀនគិតពិចារណា មិនមុសាចៀសសម្លាប់ ។

ឆ្លងផ្លូវត្រូវមើលស្តាំ ឆ្វេងចំណាំកុំចង់ឆាប់
លឿនពេកប្រយ័ត្នស្លាប់ ឡានបុកងាប់កណ្តាលផ្លូវ ។
បើចេញពីសាលា លាអាចារ្យឱ្យត្រឹមត្រូវ
គុណគ្រូជួយបំភ្លឺ នាំកូនទៅកន្លែងសុខ ។
ពួកជនដែលខិលខូច ធំ ឬតូចមិនអុកឡុក
ម៉ូតូមិនហ៊ានបុក ឡានពីមុខគេចចេញបាន ។
កូនល្អស្តាប់ម៉ែឪ យល់ដឹងត្រូវបានសុខសាន្ត
គុណគ្រូទាំងប៉ុន្មាន កូនកុំប្រមាថគួរគោរព ។

មិនអាចវិចិត្រមនុស្សឱ្យដូចជាចិត្តខ្លួនឯងឡើយ ។

# អំពីការសេពគប់

**មើលលោកនេះ** ក្នុងការទំនាក់ទំនងដោយការពិចារណាទៅលើជីវិតរស់នៅក្នុងសង្គម ដែលមានការទាក់ទងគ្នា មិនរវាទឃ្លាតពីចរន្តនៃការប្រព្រឹត្តធ្វើការងារផ្សេងៗ ទាំងផ្នែកលោកីយ៍និងទិសដៅស្វែងរកគុណធម៌ឆ្លងចាកលោក តែងតែមានការជួបប្រាស្រ័យពិភាក្សាពីគ្នាទៅវិញទៅមកយ៉ាងណា ត្រូវសម្លឹងពិនិត្យឱ្យបានល្អិតល្អន់ហ្មត់ចត់ត្រឹមត្រូវ ព្រោះការសេពគប់ ក៏ជាជីវិតមួយស្វែងរកសុភមង្គលដែរ តែបើសេពគប់ខុស នឹងនាំឱ្យវិនាសខ្លួនប្រាណរហូតដល់ធ្លាក់អបាយភូមិ ព្រោះមិត្តអាក្រក់ដឹកនាំឱ្យដើរទៅរកតែអំពើមិនល្អ ចំណែកកល្យាណមិត្តតែងដឹកនាំទៅរកអំពើល្អ ដូចជា ការសន្សំកុសលដោយការធ្វើបុណ្យទានស្តាប់ធម្មទេសនា សមាទានសីល ធ្វើសមាធិ និងចម្រើនបញ្ញា ។

**១-<u>ការសេពគប់មិត្តល្អ</u> :**

នៅក្នុងសិង្គាលកសូត្រ ទីឃនិកាយបដិកវគ្គភាគ១៩/៨២ ព្រះសម្មាសម្ពុទ្ធទ្រង់បង្ហាញប្រាប់ថា :

ម្នាលគហបតីបុត្តមនុស្ស ៤ ពួក អ្នកត្រូវដឹងថាជាមិត្តមានសន្តានល្អ គឺ មិត្តមានឧបការៈ ១ មិត្តរួមសុខរួមទុក្ខអ្នកត្រូវដឹងថាជា មិត្តមានសន្តានល្អ ១ មិត្តប្រាប់ប្រយោជន៍ អ្នកត្រូវដឹងថាជាមិត្តមាន សន្តានល្អ ១ មិត្តមានសេចក្តីឈឺឆ្អាល អ្នកត្រូវដឹងថាជាមិត្តមាន សន្តានល្អ ១ ។

* មិត្តមានសន្តានល្អគឺមិត្តមានឧបការៈ អ្នកត្រូវដឹងដោយស្ថាន ៤ យ៉ាង :

១- រក្សាមិត្តដែលវង្វេងភ័ន្តច្រឡំធ្វេសប្រហែស

២- រក្សាសម្បត្តិរបស់មិត្តដែលធ្វេសប្រហែស

៣- ជាទីពឹងពំនាក់នៃមិត្តដែលមានសេចក្តីភិតភ័យ

៤- កាលបើកិច្ចដែលត្រូវធ្វើកើតឡើងតែងជួយផ្តល់ភោគៈ ជាទ្វិគុណជាងទ្រព្យដែលមិត្តត្រូវការនោះៗ ។ ដោយស្ថានទាំង ៤ ប្រការខាងលើនេះអ្នកត្រូវដឹងថា ជាមិត្តមានឧបការៈមានសន្តានចិត្តល្អ កម្ររកបានក្នុងលោកនាសម័យសព្វថ្ងៃនេះ ។

* មិត្តរួមសុខរួមទុក្ខ អ្នកត្រូវដឹងដោយស្ថាន ៤ យ៉ាង :

១- ប្រាប់នូវអាថិកំបាំងរបស់ខ្លួនដល់មិត្ត

២- ជួយបិទបាំងនូវអាថិកំបាំងរបស់មិត្ត

៣- មិនបោះបង់គ្នា ក្នុងគ្រាមានវិបត្តិ

៤- លះបង់ជីវិតដើម្បីប្រយោជន៍ដល់មិត្ត ( ស៊ូប្ដូរជីវិត) ។

ជាការលះបង់មានជម្រៅខ្លាំងក្លាអស្ចារ្យរបស់មិត្ត ដែលមានភក្តីភាពលើសពីអ្វីៗទាំងអស់ ក្នុងការបង្ហាញពីលក្ខណៈពិសេសរបស់ធម្មជាតិ ដោយព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ត្រាស់សម្ដែងទុក ។

* មិត្តប្រាប់ប្រយោជន៍ អ្នកត្រូវដឹងដោយស្ថាន ៤ យ៉ាង :

១- ហាមមិត្តឱ្យឃ្លាតចាកពីអំពើអាក្រក់

២- ដឹកនាំមិត្តឱ្យតម្កល់តែក្នុងអំពើល្អ

៣- ឱ្យបានឮពាក្យដែលមិនធ្លាប់បានឮ

៤- ប្រាប់ផ្លូវទៅឋានសួគ៌ ។

ប្រព្រឹត្តល្អបានផលល្អ ឱ្យដូចជាមិត្តនេះពុំមានសោះឡើយ លើកលែងតែអ្នកប្រព្រឹត្តធម៌របស់កល្យាណមិត្តជាដើម ដែលគិតតែពីប្រយោជន៍ជនដទៃពុំគិតប្រយោជន៍ខ្លួន ។ ព្រោះថាការសេពគប់មិត្តបានល្អ ( កល្យាណមិត្ត) ជាបុព្វភាគនៃពោជ្ឈង្គធម៌ ដូចជា អរុណដែលរះឡើងជាបុព្វភាគនៃការមានព្រះអាទិត្យបំភ្លឺលោក ។

* មិត្តមានសេចក្តីឈឺឆ្អាល ជាមិត្តមានសន្តានល្អ អ្នកត្រូវដឹងដោយស្ថាន ៤ យ៉ាង :

១- ជួយព្រួយចិត្ត ពីព្រោះមិត្តមានសេចក្តីវិនាស

២- ជួយត្រេកអរព្រោះមិត្តមានសេចក្តីចម្រើន

៣- ទទឹងទាស់នឹងមនុស្សដែលពោលទោសពីមិត្ត

៤- សរសើរតែមនុស្សដែលពិពណ៌នាគុណមិត្ត ។

| | | |
|---|---|---|
| បើសម្លឹង | ត្រូវខំប្រឹង | ពិចារណា |
| ស្រង់ខ្លឹមសារ | ចិត្តឧស្សាហ៍ | សង្វាតរៀន |
| ដូចបក្សី | ហើរលើដី | មើលជ្រុងកៀន |
| ខ្លាចបៀតបៀន | រកទ្រនំ | មែកឈើខ្ពស់ ។ |

ដោយសេចក្តីរីករាយយ៉ាងក្រៃលែង ដែលបានជួបមិត្តដូចពោលខាងលើនៃស្ថានទាំង៤ យ៉ាងកម្រក្រៅពីបុគ្គលដែលមានគុណធមទុកក្នុងខ្លួនគ្របសង្កត់ជាខណៈៗ នូវ **លោភៈ ទោសៈ មោហៈ** របស់អប្បិច្ឆបុគ្គល (អ្នកប្រាជ្ញាតិច) ទើបស្វែងរកមិត្តយ៉ាងដូច្នេះ អាស្រ័យដោយឧបនិស្ស័យពីអតីត របស់ខ្លួនអាចទទួលផលគ្រប់គ្រាន់ ព្រោះថា

បុថុជ្ជនមិនងាយនឹងធ្វើបានយ៉ាងដូច្នេះដោយនៅមានកិលេសញាប់ញ៉ូវក្នុងសន្ដានយ៉ាងណា បុគ្គលមានធម៌ប្រណីតឧត្ដមទើបកសាងនូវមិត្តភាពនិងជំហានទៅរកសុភមង្គលរបស់ខ្លួននិងអ្នកដទៃ ដូចការគោរពមិត្តយ៉ាងនេះឯង ។

## ២. ការសេពគប់មិត្តអាក្រក់ :

ចំណែកមិត្តអាក្រក់មានធម៌ថោកទាប ម្នាលគហបតីបុត្ត អ្នកត្រូវស្គាល់មនុស្សដែលមិនមែនជាមិត្ត គ្រាន់តែជាមិត្តប្លម ៤ ជំពូក :

មនុស្សគិតយកតែប្រយោជន៍ខ្លួន មិនមែនជាមិត្តគ្រាន់តែជាមិត្តប្លម ១ អ្នកត្រូវស្គាល់មនុស្សល្អតែសម្ដីថា មិនមែនជាមិត្តគ្រាន់តែជាមិត្តប្លម ១ អ្នកត្រូវស្គាល់មនុស្សដែលនិយាយចាក់បណ្ដោយឱ្យគាប់ចិត្តថាមិនមែនជាមិត្តគ្រាន់តែជាមិត្តប្លម ១ អ្នកត្រូវស្គាល់សម្លាញ់ ក្នុងការវិនាសភោគទាំងឡាយ ថាមិនមែនមិត្តគ្រាន់តែជាមិត្ត ប្លម ១ ។

* មនុស្សគិតយកតែប្រយោជន៍ខ្លួន គ្រាន់តែជាមិត្តប្លមនោះអ្នកត្រូវស្គាល់ដោយស្ថាន ៤ យ៉ាង :

១- មិត្តគិតយកតែប្រយោជន៍ខ្លួន

២- មិត្តប្រាថ្នាយករបស់ច្រើន ដោយឱ្យរបស់តិច

៣- ទាល់តែមានភ័យទើបជួយធ្វើកិច្ចការរបស់មិត្ត

៤- សេពគប់មិត្ត ព្រោះតែប្រយោជន៍ ។

* មនុស្សល្អតែសំដី គ្រាន់តែជាមិត្តប្លម អ្នកត្រូវស្គាល់ដោយ ស្ថាន ៤ យ៉ាង :

១- មិត្តចេះទទួលរាក់ទាក់នូវរបស់កន្លងទៅហើយ

២-មិត្តទទួលរាក់ទាក់នូវរបស់ដែលមិនទាន់មានមក

៣- ចេះសង្គ្រោះនូវអំពើឥតប្រយោជន៍

៤- កាលបើកិច្ចទាំងឡាយកើតឡើងភ្លាម១ ក៏សម្តែងអង្គរបស់ខូចខាតបានសេចក្តីថា មិនឱ្យគេពឹងពាក់ខ្លួនបាន ។

* មនុស្សនិយាយចាក់បណ្តោយឱ្យគាប់ចិត្ត គ្រាន់តែជាមិត្តប្លម អ្នកត្រូវស្គាល់ដោយស្ថាន ៤យ៉ាង :

១- បើមិត្តធ្វើអំពើអាក្រក់ក៏យល់ព្រមតាម

២- បើមិត្តធ្វើល្អក៏យល់ព្រមតាម

៣- ពណ៌នាគុណមិត្ត តែក្នុងទីចំពោះមុខ

៤- ចូលចិត្តពោលទោសមិត្ត តែក្នុងទីកំបាំងមុខ ។

* មនុស្សជាសម្លាញ់ក្នុងផ្លូវវិនាស គ្រាន់តែជាមិត្តប្លម អ្នកត្រូវស្គាល់ដោយស្ថាន ៤ទៀតៈ

១- ជាសម្លាញ់ក្នុងកិរិយាប្រកបរឿយ ៗនូវការផឹកទឹកស្រវឹង គឺសុរា និងមេរ័យដែលជាទីតាំងនៃសេចក្ដីប្រមាទ

២- ជាសម្លាញ់ក្នុងការប្រកបរឿយៗនូវការត្រាច់ទៅតាមច្រកល្ហកខុសកាល

៣- ជាសម្លាញ់ក្នុងកិរិយាដើរមើលល្បែងមហោស្រព

៤- ជាសម្លាញ់ក្នុងកិរិយាប្រកបរឿយៗនូវល្បែងភ្នាល់ដែលជាហេតុជាទីតាំងនៃ សេចក្ដីប្រមាទ ។

មើលមនុស្សឱ្យស្គាល់អធ្យាស្រ័យ កុំវាយតម្លៃពីខាងក្រៅ
អាក្រក់ស្អុយក្នុងកាចល្ងង់ខ្លៅ ឆេវឆាវឆេះក្ដៅធំមិនឈប់ ។
មនុស្សល្អសម្ដីវាចាពិត ចេះមានគំនិតឱនគោរព
ចាស់ព្រឹទ្ធាចារ្យទុកជាម្លប់ ដឹងអ្វីសព្វគ្រប់ពិចារណា ។
បើកូននៅក្បែរបានប្រយោជន៍ ជ្រុះក្លិនអសោចិ៍ឆ្អាបមុសា
ស្រង់ក្លិនក្រអូបក្នុងឱរា ចិត្តស្អាតជ្រះថ្លាបុណ្យរាល់ថ្ងៃ ។

លុះព្រះសាស្ដាសម្ដែងសេចក្ដីនេះចប់ហើយ ទើបទ្រង់សម្ដែងគាថាព័ន្ធតទៅទៀតថា:

បុគ្គលដែលជាមិត្តគិតយកតែប្រយោជន៍ខ្លួន ១ បុគ្គលដែលជាមិត្តល្អតែសំដី ១ បុគ្គលនិយាយចាក់បណ្ដោយឱ្យគាប់ចិត្ត ១ បុគ្គលដែលជា

សម្លាញ់ក្នុងផ្លូវវិនាស ១ ទាំង ៤ ពួកនេះបណ្ឌិតទាំងឡាយជ្រាបដឹងថា មិនមែនជាមិត្ត គប្បីចៀសវាងឱ្យឆ្ងាយដូចជាអ្នកដំណើរចៀសវាងផ្លូវដែលប្រកបដោយភ័យដូច្នោះ ។

បុគ្គលកាលបើបានជ្រាបសេចក្ដីពិតនៃធម៌សម្រាប់រួមសុខ រួមទុក្ខជាមួយមិត្ត គួរចៀសវាងពីបាបមិត្តឱ្យបានជ្រះស្រឡះកុំគប់រកគ្រាន់តែជួបម្ដងម្កាលទុកជាមនុស្សដទៃក្រៅខ្លួន និងប្រុងប្រយ័ត្នកុំឱ្យមាន រឿងហេតុផ្សេងៗពីអ្នកដទៃស្រោចមកលើខ្លួន ព្រោះថាមនុស្សដែលមានធម៌ថោកទាប ពុំសូវបានប្រកបនូវសេចក្ដីសុខយូរទេ តែងជួបនូវទុក្ខទោសគ្រោះថ្នាក់ជាញឹកញាប់ដោយអំពើដែលខ្លួនសាង តែត្រូវមានមេត្តាចិត្តអាណិតដល់គ្នា ទើបស្វែងរកសុភមង្គលឱ្យខ្លួនឯងបាន ។

**មើលលោកនេះ ដោយការពិចារណា** នូវសុភមង្គលក្នុងសង្គមគ្រួសារតទៅទៀត ដែលមានស្វាមីភរិយា ជាប្រធានដឹកនាំសង្គមគ្រួសារទៅរកសិរីសួស្ដីរីកចម្រើនជាភិយ្យោភាព ។

ពាក្យថាស្វាមីភរិយា នៅក្នុងវចនានុក្រមរបស់សម្ដេចព្រះសង្ឃរាជ **ជួន-ណាត** ជោតញ្ញាណោ បានសរសេរប្រាប់ថា :

១- ស្វាមី( -មី ) ( សំ.ស្វាមិន៑ , បាលី សាមី ) ម្ចាស់ , ប្ដី ។ សេចក្ដីស្រឡាញ់ស្មោះចំពោះម្ចាស់ ចំពោះចៅហ្វាយនាយ ,សេចក្ដីស្រឡាញ់ស្មោះត្រង់ចំពោះស្វាមី ។ ស្វាមីនិងភរិយា គឺ ប្ដីនិងប្រពន្ធ ។ល។

២- ភរិយា ( បា សំ.ភាយ៌ា ) ស្ត្រីដែលស្វាមីត្រូវចិញ្ចឹម( ប្រពន្ធ) ស្វាមីភរិយា បុត្រភរិយា (ពាក្យកាព្យ) ខ្លែងហើរដ្បិតខ្យល់ នាយថ្កើង ដ្បិតពល រក្សាឱ្យសុខ ទ្រព្យគង់ដ្បិតស្រី ចេះសំចៃទុក ផ្ទះធំស្រណុក ដ្បិតភរិយាជា ។ ( ដកស្រង់ពីសាស្ត្រច្បាប់រាជនេតិ ជាព្រះនិពន្ធនៃព្រះរាជសម្ភារ ) ។

កាលបើអ្នកទាំងពីរស្រុះស្រួលគ្នា ចលនានៃការរៀបចំសុមភង្គល ក៏ត្រូវបានសម្រេច ដែលជាហេតុធ្វើឱ្យសង្គមមនុស្សជួបប្រទះនូវសេចក្តីសុខចម្រើនយ៉ាងទូលំទូលាយជាទូទៅ មិនថាអ្នកមានទ្រព្យ ឬអ្នកក្រកំសត់ ព្រោះសេចក្តីសុខ កើតមានក្នុងចិត្តសន្តាន ដោយមានភរិយាជាស្ត្រីមេផ្ទះចេះចាត់ចែងកិច្ចការ ដោយថាប្រទេសជាតិរីកចម្រើនអាស្រ័យពីស្ថាប័នគ្រួសារជាមុនដូចមានពាក្យកំណាព្យរបស់ព្រះរាជសម្ភារខាងលើនេះ ។

ពិតមែនតែអ្វី១ ក្នុងលោកកើតឡើងព្រោះស្ត្រីជាភរិយាដែលគេចាត់ទុកថា ជាមាតាពិភពលោក ដោយថាស្ត្រីមានកិច្ចរវល់ខ្លាំងណាស់ណាមួយចិញ្ចឹមបុត្រ ថែរក្សាបុត្រដោយផ្ទាល់ខ្លួន. អប់រំបុត្រនៅតាមផ្ទះយ៉ាងសប្បាយរីករាយក្នុងចិត្តនិងខិតខំបំរើស្វាមី ឪពុកម្តាយក្មេកព្រមទាំងធ្វើម្ហូបចំណីគ្រប់សព្វបែបយ៉ាងសម្រាប់គ្រួសារ ។ បើពិនិត្យផ្ទៀងផ្ទាត់មើលលោកនេះ ឃើញថាភរិយាមានកិច្ចការច្រើនជាងបុរស គួរឱ្យតម្លៃខ្ពស់មែន តែបើគិតពីច្បាប់ធម្មជាតិវិញ **ទោះបីស្ត្រីមានឥទ្ធិពល**

**ខ្លាំងយ៉ាងណាអាចគ្របដណ្តប់លើបុរស** តាមរយៈរូប តាមរយៈសំឡេង តាមរយៈក្លិន តាមរយៈរស តាមរយៈផោដ្ឋព្វៈ ក៏កម្លាំងនេះនៅទន់ខ្សោយ មិនអាចយកជ័យជំនះទាំងស្រុងលើបុរសជាស្វាមីបានដែរ ដូចដែលព្រះដ៏មានព្រះភាគ ទ្រង់សម្តែងក្នុងសំយុត្តនិកាយ សឡាយតនវគ្គ មាតុគ្គាមពលវគ្គបិដកលេខ ៣៦/១០១ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាមប្រកបដោយកម្លាំង ៥ ប្រការបង្រ្កាបប្តីដែលនៅគ្រប់គ្រងផ្ទះបាន ។

កម្លាំង ៥ ប្រការនោះគឺ

១- **រូបពលំ** កម្លាំងរូប ២- **ភោគពលំ** កម្លាំងភោគ

៣- **ញាតិពលំ** កម្លាំងញាតិ ៤- **បុត្តពលំ** កម្លាំងកូន

៥- **សីលពលំ** កម្លាំងសីល ។

ចំណែកបុរសវិញ មានកម្លាំងតែមួយអាចគ្របសង្កត់លើមាតុគ្រាមបានគឺ ឥស្សរិយយស មិនចាំបាច់ពឹងកម្លាំងរូប, កម្លាំងភោគ, កម្លាំងញាតិ, កម្លាំងកូន, កម្លាំងសីល ថែមទាំងស្រ្តីជាមន្ទិលក្នុងការប្រព្រឹត្តព្រហ្មចរិយធម៌ទៀតផង ។

ម្យ៉ាងទៀតភរិយាជាមាតានៃលោក ក៏មិនមែនសុទ្ធតែបរិបូរដោយលក្ខណសម្បត្តិភាពជាស្រ្តីល្អស្អាតនូវកាយ នូវវាចា នូវចិត្តទាំង អស់នោះទេ ភរិយាខ្លះមានចិត្តផិតក្បត់មិនស្មោះត្រង់ចំពោះស្វាមី ដែលជាហេតុនាំឱ្យវិនាសដល់សុភមង្គលគ្រួសារបានដែរ ។ ដូចជា នៅក្នុង

អង្គុត្តរនិកាយ សត្តកនិបាតអដ្ឋមភាគបិដកលេខ ៤៧/១៦៨ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ប្រារព្ធចំពោះនាងសុជាតាថា ភរិយារបស់បុរសមាន ៧ ពួកគឺ

១- វធកាសមាភរិយា (ភរិយាស្មើដោយអ្នកសម្លាប់)

២- ចោរីសមាភរិយា (ភរិយាស្មើដោយចោរ)

៣- អយ្យាសមាភរិយា (ភរិយាស្មើដោយម្ចាស់)

៤- មាតុសមាភរិយា (ភរិយាស្មើដោយមាតា)

៥- ភគិនីសមាភរិយា (ភរិយាស្មើដោយប្អូនស្រី)

៦- សខីសមាភរិយា (ភរិយាស្មើដោយសម្លាញ់)

៧- ទាសីសមាភរិយា (ភរិយាស្មើដោយខ្ញុំស្រី) ។

ម្នាលនាងសុជាតា បណ្តាភរិយាទាំង ៧ ពួកនោះ តើនាងជាភរិយាដូចម្តេច ?

## សេចក្តីពិស្តារ

១- ភរិយាដែលស្វាមីលោះមកដោយទ្រព្យ ជាស្ត្រីមានចិត្តប្រទូស្ត (នឹងស្វាមី) មានសេចក្តីមិនអនុគ្រោះនូវប្រយោជន៏ជាអ្នកត្រេកត្រអាលក្នុងបុរសដទៃមើលងាយប្តីខ្វល់ខ្វាយដើម្បីសម្លាប់ (ប្តី) ស្ត្រីណាដែលជាភរិយា នៃបុរសមានសភាពដូច្នេះ ស្ត្រីនោះហៅថា វធកាសមាភរិយា ។

២- ស្វាមីនៃស្ត្រីបាននូវទ្រព្យណា ហើយតម្កល់ទុកដើម្បីធ្វើនូវសិល្បៈក្ដីនូវជំនួញក្ដី នូវកសិកម្មក្ដី ស្ត្រីនោះប្រាថ្នា លួចកិបយកនូវទ្រព្យ សូម្បីបន្តិចបន្តួចអំពីទ្រព្យនោះ ស្ត្រីណាជាភរិយានៃបុរសមានសភាពដូច្នោះ ស្ត្រីនោះ ហៅថា ចោរីសមាភរិយា ។

៣-ស្ត្រីមិនមានសេចក្ដីប្រាថ្នានឹងធ្វើនូវការងារ ជាអ្នកខ្ជិលច្រអូស ស៊ីច្រើនរឹងរូសកាច ពោលនូវពាក្យអាក្រក់ ប្រព្រឹត្តគ្របសង្កត់នូវស្វាមីដែលមានព្យាយាមប្រឹងប្រែង ស្ត្រីណាជាភរិយានៃបុរសមានសភាពដូច្នេះ ស្ត្រី នោះហៅថា អយ្យាសមាភរិយា ។

៤- ស្ត្រីណាមានសេចក្ដីអនុគ្រោះនូវប្រយោជន៍សព្វកាល ចេះរក្សាប្ដី ដូចជាមាតារក្សាកូនទាំងរក្សានូវទ្រព្យដែលស្វាមីរកបាន ស្ត្រីណាជាភរិយា នៃបុរសមានសភាព ដូច្នេះ ស្ត្រីនោះហៅថា មាតាសមា ភរិយា ។

៥- ស្ត្រីណាមានសេចក្ដីគោរពចំពោះស្វាមីរបស់ខ្លួន ដូចប្អូនស្រីគោរពបងប្រុស មានសេចក្ដីអៀនខ្មាសប្រព្រឹត្តទៅ តាមអំណាចនៃភស្ដាស្ត្រីណាជាភរិយានៃបុរសមាន សភាពដូច្នេះ ស្ត្រីនោះហៅថា ភគិនីសមាភរិយា ។

៦- ស្ត្រីណាក្នុងលោកនេះបានឃើញនូវប្ដីហើយក៏រីករាយ ដូចជាសម្លាញ់ បានឃើញសម្លាញ់ដែលបាត់មុខអស់កាលយូរស្ត្រីនោះបរិបូរណ៍

ដោយត្រកូលជាអ្នកមានសីល ជាស្ត្រីមានវត្តប្រតិបត្តិចំពោះប្តី ស្ត្រីណាជាភរិយានៃបុរស មានសភាពដូច្នោះ ស្ត្រីនោះហៅថា សខីសមាភរិយា ។

៧- ស្រីដែលស្វាមីជេរវាយគំរាមដោយដំបងមិនមានចិត្ត ប្រទូស្តវិញ ចេះអត់សង្កត់ដល់ប្តីមិនក្រោធ ប្រព្រឹត្តទៅតាមអំណាចនៃភស្តា ស្ត្រីណាជាភរិយានៃបុរសមាន សភាពដូច្នោះ ស្រីនោះហៅថា ទាសីសមាភរិយា ។

ភរិយាណា ក្នុងលោកនេះ ដែលហៅថា វធកាក្តី ចោរីក្តី អយ្យាក្តី ភរិយាមានសភាពជាស្ត្រីទ្រុស្តសីលរឹងរូស មិនមានសេចក្តីគោរពស្វាមី លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកាន់នរក ។ ភរិយាណាក្នុងលោកនេះដែលហៅថា មាតាក្តី ភគិនីក្តី សខីក្តី ទាសីក្តី ភរិយាទាំងនោះ ជាស្ត្រីសង្រួមអស់កាលជាយូរអង្វែង ព្រោះតាំងនៅក្នុងសីលធម៌ លុះបែកធ្លាយរាងកាយស្លាប់ទៅរមែងទៅកាន់សុគតិភព ។

ម្នាលនាងសុជាតា បណ្តាភរិយាទាំង ៧ ពួកនេះ តើនាងជាភរិយាដូចម្តេច ? បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគ សម្គាល់ទុកនូវខ្ញុំព្រះអង្គថាជាភរិយា ស្មើដោយទាសីរបស់ស្វាមី ។ នាងសុជាតានេះ ជាប្អូនស្រីបង្កើតរបស់នាងវិសាខា ត្រូវជាឃរសុណិសា (កូនប្រសារស្រីក្នុងផ្ទះ) របស់អនាថបិណ្ឌិកសេដ្ឋី ដែលបាននាំមកអំពីត្រកូលស្តុកស្តម្ភ ។ នាងនោះ មិនអើពើនឹងឪពុកក្មេកម្តាយក្មេក មិនអើពើនឹងស្វាមីទាំងមិន

បានធ្វើសក្ការៈមិនបានគោរព មិនបានរាប់អាន មិនបានបូជាព្រះដ៏មានព្រះភាគទេ ។ លុះទ្រង់ជ្រាបភ្លាមព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហៅនាងសុជាតា ដោយទ្រង់សម្តែងអំពីភរិយា ៧ ជំពូកដល់នាង ។ នាងសុជាតា ធ្លាប់ជាមាតារបស់ព្រះអង្គកាលពីអតីតជាតិ ដែលព្រះអង្គធ្លាប់បានជួយសង្គ្រោះ រួចមកហើយ អំពីពាក្យពោលមិនពីរោះ ក៏ជាប់ជាឧបនិស្ស័យ រហូតមក ដល់ជាតិសព្វថ្ងៃនេះ ។

ស្ត្រីជាភរិយាមានការខ្វល់ខ្វាយក្នុងកិច្ចការជាយរាវាសច្រើន ដែលជាកិច្ចការមួយសម្រាប់បម្រើលោក ដើម្បីសេចក្តីសុខសិរីសួស្តី ចម្រើនទៅដោយកិលេស មានលោភៈ (រាគៈ) ទោសៈ (ខឹងក្រោធ) មោហៈ (វង្វេងវិលវល់ក្នុងកាមគុណ) ពុំមានខ្វល់ខ្វាយនៅក្នុងការ កម្ចាត់កិលេសតណ្ហា ឈានទៅរកសុខសន្តិភាពឡើយ ។ ព្រោះហេតុដូច្នោះ បានជាព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សម្តែងនៅក្នុង សំយុត្តនិកាយ សឡាយតនវគ្គបិដកលេខ ៣៦/៨៨ ដូចតទៅនេះ :

មាតុគ្រាមប្រកបដោយធម៌ ៥ យ៉ាង គឺមាតុគ្រាមមិនមានសទ្ធា ១, មិនមានសេចក្តីខ្មាសបាប ១, មិនមានសេចក្តីខ្លាចបាប ១, មានសេចក្តីច្រណែន ១, មិនមានបញ្ញា ១, លុះបែកធ្លាយរាងកាយស្លាប់ទៅរមែងទៅកើតក្នុងតិរច្ឆាន ប្រេត អសុរកាយ នរក ។ នេះជាសេចក្តីទុក្ខនៅក្នុងបរលោកនាយ ចំណែកក្នុងបច្ចុប្បន្នកំពុងរស់នៅមាតុគ្រាមមានទុក្ខ ៥

យ៉ាងទៀត មានសម្ដែងនៅក្នុងសំយុត្តនិកាយ សឡាយតនវគ្គ បិដកលេខ ៣៦/៨៤ ដូតតទៅ :

១- ម្នាលភិក្ខុទាំងឡាយ មាតុគ្រាមក្នុងលោកនេះនៅក្មេងទៅកាន់ត្រកូលប្ដី ប្រាសចាកញាតិទាំងឡាយរបស់ខ្លួន នេះហៅថា ទុក្ខដោយឡែកទី ១ របស់មាតុគ្រាម ដែលទទួលរងផ្សេងអំពីបុរសទាំងឡាយ

២- មាតុគ្រាមមានរដូវ នេះជាទុក្ខដោយឡែកទី ២

៣- មាតុគ្រាមមានគភ៌ នេះជាសេចក្ដីទុក្ខដោយឡែកទី ៣

៤- មាតុគ្រាមសម្រាលបុត្ត នេះជាសេចក្ដីទុក្ខដោយឡែកទី ៤

៥- មាតុគ្រាមចូលទៅបម្រើបុរសជាស្វាមី នេះជាសេចក្ដីទុក្ខទី៥ ។

កាលបើមានសេចក្ដីទុក្ខគ្របសង្កត់គ្រប់ពេលគ្មានស្រាកសាន្តយ៉ាងនេះ ក៏មាតុគ្រាមមិនគួរសំងំស្ងៀមយ៉ាងដូច្នេះ ត្រូវប្រញាប់ស្វែងរកទីពឹងដល់ព្រះរតនត្រៃ គឺព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ទើបទទួលបានសុខចម្រើនក្នុងលោកនេះ និងលោកខាងមុខ ។ ធម៌សម្រាប់ មាតុគ្រាមទីពឹងទីរលឹកមាន ៥ ប្រការ :

១- មានសទ្ធា ២- មានសេចក្ដីខ្មាសបាប

៣- មានសេចក្ដីខ្លាចបាប ៤- មិនក្រោធ ៥- មានបញ្ញា ។

មាតុគ្រាមប្រកបដោយធម៌ ៥ យ៉ាងនេះឯង លុះបែកធ្លាយរាងកាយស្លាប់ទៅតែងទៅកើតក្នុងសុគតិសួគ៌ទេវលោក ។

**មើលលោកនេះ** ដោយការពិចារណាទៅលើសង្ខារទាំងពួងដែលប្រជុំតាក់តែងឡើងពីហេតុប្បច្ច័យ រួចក៏ត្រូវប្រែប្រួលវិនាសទៅវិញជាធម្មតា ។ លោកនៃការរស់នៅនេះសន្សំកម្ម ជាតួចេតនារបស់វេទនាសោយអារម្មណ៍ ល្អអាក្រក់យ៉ាងណា ក៏ជាចំណែកមួយនៃវិបាកឱ្យផលតាមក្រសែជីវិត ដែលជាសភាវៈលោកទុកប្រើប្រាស់តាមតម្រូវការរាល់ថ្ងៃ ប្រមូលគោងយកនូវអារម្មណ៍ទាំងឡាយមកធ្វើជារបស់ខ្លួន រួចក៏ត្រូវយំសោកកន្ទក់កន្ទេញបោកខ្លួន នៅពេលអារម្មណ៍ទាំងនោះស្មារលោត្រឡប់ទៅវិញក្រោមម្លប់ **អនិច្ចំ ទុក្ខំ អនត្តា** ដោយន័យសេចក្ដីថាគ្មានបានអ្វីសោះ ហើយក៏ចេះតែចង់បានមិនស្រាកស្រាន្ត (អូសទាញពីកម្លាំងតណ្ហា) ធ្វើឱ្យសត្វលោកឈ្លក់វង្វេងមិនដឹងខុសត្រូវ ស្រេកឃ្លានក្នុងរបស់គ្មានតម្លៃដែលមួយថ្ងៃទៅមួយថ្ងៃ រីកចម្រើនតែកិលេស កើតទុក្ខព្រួយបារម្ភចង់បានមិនចេះចប់ព្រោះសេចក្ដីល្ងង់ខ្លៅធ្វើឱ្យលោកនេះវិនាសប្រែប្រួលតាមកម្លាំងស្រូបទាញពីផែនដី បង្កើតជាចលនាមួយដល់ពិភពលោកចូលចិត្តសាងលោកទៅតាមការខែចុះនៃអន្តរកប្បរបស់អាយុមនុស្សសត្វ ឱ្យនៅខ្ចីស៊ីដាច់ឬខាតអស់ពីមួយអសង្ខេយ្យឆ្នាំចុះមកនៅត្រឹម ១០០ ឆ្នាំ និងបន្តការខែចុះរហូតត្រឹម ១០ ឆ្នាំ ទើបខែ

ឡើងទៅទល់ និងអាយុមនុស្សមួយអសង្ខេយ្យ ( សូន្យ ១៤០ ) វិញ ។ ទង្វើអធម៌ខ្វះសីលធម៌នេះ មិនមែនមានអ្នកកសាងហេតុបណ្តាល ជាការកើតឡើងពីហេតុប្បច្ច័យរបស់ខន្ធអាយតនធាតុនៃលោកដែលធ្វើឱ្យមនុស្សយើងម្នាក់ៗ ចូលចិត្តប្រព្រឹត្តសាងអំពើថោកទាប នូវអកុសលធម៌ទាំងឡាយ ស្រេកឃ្លានតែពីទ្រព្យសម្បត្តិមាសប្រាក់បុណ្យសក្តិកិត្តិយស នៃលោកធម៌ ៨ យ៉ាង គឺ

| | |
|---|---|
| ១- មានលាភ | ២- អត់លោភ |
| ៣- មានយស | ៤- អត់យស |
| ៥- មានសរសើរ | ៦- មាននិន្ទា |
| ៧- មានសុខ | ៨- មានទុក្ខ ។ |

ទាំងនេះជាធម៌ប្រចាំលោកសម្រាប់សត្វរស់នៅក្នុងលោក គឺសត្វជាប់ចំណងកាមគុណទាំង ៥ ព្រោះលោកធម៌ ៨ នេះឯង ។

សត្វលោកណាមួយដែលថា មិនត្រេកអរ នឹងលាភសក្ការៈ

សត្វលោកណាមួយដែលថា មិនត្រេកអរ នឹងមានយសសក្តិ

សត្វលោកណាមួយដែលថា មិនត្រេកអរ នឹងគេសរសើរ

សត្វលោកណាមួយដែលថា មិនត្រេកអរ នឹងសុខ ( ខ្លើម ទុក្ខ ) ។

នេះជាចំណីឆ្ងាញ់របស់សត្វលោក មនុស្សលោកទាំងអស់ឱ្យតែនៅជាបុថុជ្ជន។ ព្រោះតែការសប្បាយរីករាយនេះហើយ បានជាធ្វើឱ្យ

លោកទ្រេតទ្រោតវិលចុះវិលឡើងម្តងទៅកើតក្នុងឋានសួគ៌ ម្តងទៅកើតជាសត្វតិរច្ឆាន ប្រេតអសុរកាយ នរក ជួនណាមកកើតជាមនុស្សសម្បូណ៌ទ្រព្យសម្បត្តិអាចធ្វើជាគហបតី ជាស្តេចចក្រ ឬក៏ជាអ្នកមានបុណ្យសក្តិខ្ពង់ខ្ពស់ មានមុខមាត់ធំដុំគេទទួលស្គាល់ច្រើន ឬក៏ជាមនុស្សខ្វាក់ខ្វិន គ ថ្លង់ ពិការដៃជើង ខ្វះបុណ្យ ព្រោះជាឧបនិស្សយប្បច្ច័យសន្សំទុកខ្លួនឯងរបស់កម្មមានវិបាកជាសុខ ជាទុក្ខ នៅក្នុងលោកនេះ ។

មនុស្សយើងម្នាក់ៗ ពេញចិត្តណាស់ និងសេចក្តីសប្បាយរីករាយក៏មិនបានដឹងថា សេចក្តីសប្បាយរីករាយនេះ ជាតួទុក្ខកើតពីតណ្ហាជាហេតុ កាលបើសប្បាយខ្លាំងទុក្ខខ្លាំង ស្រឡាញ់ខ្លាំងក៏ទុក្ខនេះជានិយាមធម៌របស់ធម្មជាតិ ។ កាលណាបើគេនិយមចូលចិត្តរបស់ណារបស់នោះតែងផ្តល់នូវសេចក្តីទុក្ខដល់គេវិញ ព្រោះសេចក្តីទុក្ខកើតចេញពីខ្លួនឯង ។ អារម្មណ៍ទាំងអស់ក្នុងលោកគ្មានអ្វីគួរឱ្យយើងស្រឡាញ់ស្អប់ជ្រប់ងប់ជាប់ចិត្តផ្តេកផ្តិត បើមិនមានលោភៈ បើមិនមានទោសៈ បើមិនមានមោហៈ និងមិនមានសេចក្តីប្រកាន់ ក៏មិនមានអ្វីគួរឱ្យទាស់ចិត្តនិងមានបញ្ញាឃើញសច្ចធម៌ ដូចដែលព្រះតថាគតទ្រង់ត្រាស់ សម្តែងថា : **កោធំ ឃត្វា សុខំ សេតិ** ប្រែថា សម្លាប់សេចក្តីក្រោធបានទើបដេកជាសុខ ។ ដូចជានៅក្នុងវិសុទ្ធិមគ្គទ្រង់សម្តែងថា ធម្មជាតិអ្វីមួយដែលកើតឡើងសុទ្ធតែជាទុក្ខទាំងអស់ព្រោះសេចក្តីប្រកាន់ ទុក្ខ

ដោយអត្ថថា បៀតបៀនកៀបសង្កត់ មានបច្ច័យប្រជុំតាក់តែង ក្តៅរោលរាល និង វិនាសប្រែប្រួល ដែលនៅក្នុងព្រះពុទ្ធសាសនាទ្រង់សម្តែងតែពីការកំណត់ដឹងនូវទុក្ខ និងការរំលត់ទុក្ខ នេះជាទិសដៅស្វែងរកធម៌ស្ងប់សុខសន្តិភាព ដែលព្រះជិនស្រីបានកសាងបារមីច្រើនអសង្ខេយ្យកប្បសរុបទាំងអស់ ២០ អសង្ខេយ្យកប្បគឺតាំងព្រះទ័យនឹកគិតមុន ៧ អសង្ខេយ្យកប្ប ចេញវាចា ៩ អសង្ខេយ្យកប្ប, ពុទ្ធព្យាករណ៍ ៤ អសង្ខេយ្យកប្បនិងមួយសែនកប្បទៀត សម្រាប់បញ្ញាធិក ចំណែកសទ្ធាធិក កសាងបារមី ៤០ អសង្ខេយ្យ ១ សែនកប្ប និងវិរិយាធិក ៨០ អសង្ខេយ្យ ១ សែនកប្ប ។

បើសម្លឹងពិនិត្យ អប់រំចិត្តពិចារណា
ស្រង់ស្រូបរសខ្លឹមសារ សច្ចណាទុកក្នុងចិត្ត ។

ស្រឡាញ់អ្វីស្មើដោយស្រឡាញ់ខ្លួនមិនមាន

# អំពីការមិនស្អាត

**មើលលោកនេះដោយការពិនិត្យ** ទៅលើរបស់ដែលសត្វលោកកំពុងប្រើប្រាស់ប្រចាំថ្ងៃ ប្រៀបដូចក្មេងក្មេងលេងដីខ្សាច់ ដែលវាកសាងបានជាកូនផ្ទះតូចៗ មានរូបភាពគួរស្រឡាញ់តាមចំណង់ចំណូលចិត្តដើម្បីសេចក្ដីសប្បាយមួយភ្លែត រួចកម្ទាត់កម្ទាយឈូសចោលនូវកូនផ្ទះ នោះធ្វើឱ្យលេងមិនកើតយ៉ាងណា របស់អ្វីៗក្នុងលោកដែលមនុស្សយើងកំពុងប្រើប្រាស់ប្រចាំថ្ងៃ ជារបស់មានតម្លៃខ្ពង់ខ្ពស់ឧត្ដុង្គឧត្ដម ប្រសើរខ្លាំងណាស់ តែពេលណាឆ្អែតស្អប់ស្អល់លែងត្រូវការ គេក៏បោះបង់ចោល ដូចក្មេងលេងកូនផ្ទះយ៉ាងនោះដែរ ។

ហេតុដូចម្ដេចបានជាត្រូវបោះបង់ចោល ឈូសចោលទៅវិញ ព្រោះរបស់ទាំងនោះជាការប្រជុំរួម ទៅដោយមហាភូតរូប ៤ លាយឡំនូវរបស់មិនស្អាតគឺកិលេសជាតិទាំងឡាយទាំងពួងជាដើម សុទ្ធតែជាអកុសលធម៌ មិនក្រៅអ្វីពីលោភ ៨ ដួង (លោភមូល) ទោស ២ ដួង (ទោសមូល) មោហ ២ ដួង (មោហមូល) ដែលធុំក្លិនអសោចិស្មុយ ព្រោះលោកនេះគេត្រូវការគ្មានស្រាកស្រាន្ត ដូចជាទ្រព្យសម្បត្តិ មាសប្រាក់ ដីស្រែចំការ សំខាន់ គឺបច្ច័យ ៤ ជារបស់ប្រើប្រាស់ប្រចាំថ្ងៃ ដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្ដែងនៅក្នុងអង្គុត្តរនិកាយ ទសកនិបាត

ទ្វារទសមភាគ បិដកលេខ ៥១/១២៣ អំពីការមិនស្អាតប្រាវព្ធចំពោះចុន្ទកុមារបុត្រថា ៖ ម្នាលចុន្ទ ការមិនស្អាតដោយកាយមាន ៣ ប្រការ ការមិនស្អាត ដោយ វាចាមាន ៤ ប្រការ និងការមិនស្អាតដោយចិត្តមាន ៣ ប្រការ ។

## សេចក្តីពិស្តារ

* ការមិនស្អាតដោយកាយមាន ៣ ប្រការ ៖

១- **បាណាតិបាតោ**-ម្នាលចុន្ទ បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ ជាមនុស្សមានចិត្តអាក្រក់ មានដៃប្រឡាក់ឈាម មានចិត្តបោះជាប់ក្នុងការសម្លាប់សត្វ មានចិត្តមិនអាសូរចំពោះពួកសត្វ ។

២- **អទិន្នាទានំ** ជាអ្នកលួចទ្រព្យគេ គឺ ជាអ្នកកាន់យកនូវគ្រឿងឧបករណ៍ជាសម្បត្តិនៃបុគ្គលដទៃដែលគេទុកក្នុងស្រុកក្តី ទុកក្នុងព្រៃក្តី មិនបានហៅឱ្យលួចយក ។

៣- **កាមេសុមិច្ឆាចារោ** ជាអ្នកប្រព្រឹត្តខុសក្នុងកាមទាំងឡាយដែលមានមាតារក្សា បិតារក្សា បងប្អូនប្រុសរក្សា បងប្អូនស្រីរក្សា ញាតិរក្សា ធម៌រក្សា ជាស្ត្រីមានប្តីមានអាជ្ញា (កំណត់ទុក) ដោយហោចទៅ សូម្បីតែស្ត្រីដែលបុរសបំពាក់កម្រងផ្កាឱ្យ សុទ្ធតែជាស្ត្រីដែលមានម្ចាស់របស់គេ ហួងហែងរក្សាទាំងអស់ ។

* ការមិនស្អាតដោយវាចាមាន ៤ ប្រការ :

១- **មុសាវាទោ** ជាអ្នកពោលពាក្យកុហកនៅក្នុងរោងជំនុំក្តី កណ្តាលបរិសទ្យក្តី កណ្តាលញាតិក្តី កណ្តាលសេនីក្តី កណ្តាលរាជត្រកូលក្តី ដែលគេនាំទៅធ្វើជាសាក្សី កាលមិនដឹងក៏និយាយថាបានដឹង កាលដឹងក៏និយាយថាមិនដឹងក៏មាន កាលមិនឃើញនិយាយថាឃើញក៏មាន កាលឃើញនិយាយថា មិនឃើញក៏មាន ព្រោះហេតុតែសំណូកគឺអាមិសៈ បន្តិចបន្តួច ។

២- **បិសុណាវាចោ** ជាអ្នកពោលពាក្យញុះញង់ គឺឮពាក្យអំពីសំណាក់ជននេះហើយនាំទៅប្រាប់ជនឯណោះដើម្បីនឹងបំបែកជនទាំងនេះ ឬឮពាក្យអំពីសំណាក់ជនឯណោះនាំមកប្រាប់ជននេះ ដើម្បីនឹងបំបែកជនឯណោះ ជាអ្នកបំបែកជនដែលព្រមព្រៀងគ្នាផង ជាអ្នកជំរុញពួកជនដែលបែកគ្នាហើយផង ជាអ្នកត្រេកអរតែក្នុងពួកអ្នកមានតម្រេកក្នុងពួកក្រុម ជាអ្នករីករាយតែក្នុងពួកពោលវាចាធ្វើឱ្យប្រកាន់គ្នាដោយប្រការដូច្នេះ ។

៣- **ផរុសវាចា** ជាអ្នកពោលពាក្យអាក្រក់ គឺជាអ្នកពោលវាចាទ្រគោះ បោះបោក ខ្ទោះខ្ទរ រោលរាល ស្ទាក់ដំណើរជនដទៃ ជាវាចាជិតនិងសេចក្តីក្រោធ មិនប្រព្រឹត្តទៅ ដើម្បីសមាធិ ។

៤- **សម្ផប្បលាបោ** ជាអ្នកពោលពាក្យឥតប្រយោជន៍ គឺពោលពាក្យខុសកាល ពោលពាក្យមិនពិត ពោលពាក្យមិនមែនជាអត្ថ មិនមែនជាធម៌ មិនមែនជាវិន័យ ដែលជាពាក្យមិនគួរឱ្យតាំងទុកក្នុងហឫទ័យ ប្រាសចាកគ្រឿងអាង ជាពាក្យមិនមានទីបំផុត និងមិនមានប្រយោជន៍ ។

* ការមិនស្អាតដោយចិត្តមាន ៣ ប្រការ :

១- **អភិជ្ឈា** បុគ្គលខ្លះក្នុងលោកនេះ ច្រើនដោយអភិជ្ឈា ជាអ្នកគយគន់នូវគ្រឿងឧបករណ៍ដែលជាទ្រព្យសម្បត្តិនៃបុគ្គលដទៃណា គ្រឿងឧបករណ៍នោះ គប្បីបានមកអញ ។

២- **ព្យាបាទោ** ជាអ្នកមានចិត្តចងគំនុំព្យាបាទ ជាមនុស្សតម្រិះក្នុងចិត្តដែលទោសប្រទូស្តហើយថា សត្វទាំងឡាយនេះចូរលំបាកខ្លះ ចូរបែកធ្លាខ្លះ ចូរសាបសូន្យទៅខ្លះ ចូរវិនាសទៅខ្លះ កុំបីមានបាន (អ្វីបន្តិចបន្តួច) ឡើយ ។

៣- **មិច្ឆាទិដ្ឋិ** ជាអ្នកមានគំនិតយល់ខុស គឺជាមនុស្សយល់ឃើញនូវសេចក្តីវិបរិតថា ទានដែលបុគ្គលឱ្យហើយមិនមានផល ការបូជា ធំ តូច មិនមានផល, ផលវិបាករបស់កុសល និងអកុសលកម្មដែលសត្វធ្វើល្អ អាក្រក់មិនមាន, លោកនេះនឹងលោកខាងមុខមិនមាន, គុណមាតាបិតាមិនមាន សត្វទាំងឡាយជាឧបបាតិកកំណើតមិនមាន, ពួកសមណព្រាហ្មណ៍

ក្នុងលោកជាអ្នកប្រព្រឹត្តល្អត្រឹមត្រូវធ្វើឱ្យជាក់ច្បាស់នូវលោកនេះនិង លោកខាងមុខដោយប្រាជ្ញាដ៏ឧត្តមរបស់ខ្លួនឯងហើយសម្ដែងប្រាប់ មិនមាន ។

ការមិនស្អាតដោយកាយមាន ៣ ដោយវាចាមាន ៤ ដោយចិត្តមាន ៣ ចាត់ចូលទៅក្នុងអកុសលកម្មបថ ១០ ដែលលោកនេះកំពុងប្រព្រឹត្តរាល់ថ្ងៃដើម្បីសន្សំសេចក្ដីទុក្ខដល់ខ្លួនឯង ដូចបានរៀបរាប់ដោយពិស្ដារនៅខាងដើម លុះបែកធ្លាយរាងកាយបន្ទាប់ពីស្លាប់ទៅរមែងទទួលនូវសេចក្ដីទុក្ខ គឺ នរក តិរច្ឆាន ប្រេត ឬ ទុគ្គតិ ក្រៅពីនេះណាមួយទៀតមិនខាន ។

ផ្ទុយមកវិញការស្អាត ដោយកាយកម្ម ៣ វចីកម្ម ៤ មនោកម្ម ៣ ចាត់ចូលទៅក្នុងកុសលកម្មបថ ១០ ដែលត្រូវទទួលផលល្អសន្សំសុខនៅក្នុងបច្ចុប្បន្នទាំងបរលោក លុះចុតិភ្លាម ទៅកើតក្នុងសុគតិសួគ៌ទេវលោកពិតប្រាកដ ។

## បទពិចារណា

| | | |
|---|---|---|
| កុំស្មុគ្រស្មាញ | សាញគំនិត | ចិត្តមិនដាច់ |
| ឆាប់សម្រេច | ទើបកើតបុណ្យ | ពីការងារ |
| ធ្វើមិនដឹង | តាមធម្មតា | ដូចអ្នកជា |
| មិននិន្ទា | ហ៊ានធានា | ថាបានសុខ ។ |

រៀនពិនិត្យ　　 នូវអារម្មណ៍　　កើតពីចិត្ត
ព្រោះតាមពិត　　ចិត្តកើតក្រោយ　　សន្សំទុក្ខ
ការសេពសោយ　　មិនមែនយើង　　អ្នកចេញមុខ
កុំលើកអុក　　ទៅលើសត្វ　　ជួសវេទនា ។

កុំប្រមាទ　　ថាធម្មជាតិ　　គេមិនដឹង
ទោះខំប្រឹង　　គេចជៀសវាង　　គ្រប់វេលា
ចិត្តកើតឡើង　　ត្រូវរលត់　　តាមធម្មា
ពុំមានគ្នា　　អ្នកសាងហេតុ　　ប្រឌិតថ្មែ ។

រូបរលត់　　កុំរន្ធត់　　ភ្ញាក់ផ្អើលខ្លាំង
កុំភ្លេចភ្លាំង　　ថាទៀងទាត់　　នៅរាល់ថ្ងៃ
ត្រូវយកចិត្ត　　គិតឱ្យយល់　　កុំអាល័យ
សុំតថ្លៃ　　ពេលជិតស្លាប់　　គេមិនឱ្យ ។

ការមិនជ្រកនៅក្នុងសច្ចធម៌ នាំឱ្យរង្មៀសសង្ស័យ

## មើលលោកនេះ ដោយការកសាងធនធានមនុស្សក្នុងសង្គម

ទ្វីបទាំង ៤ មានការរស់នៅខុសៗគ្នា ចំណែកជម្ពូទ្វីបយើងនេះ មុខរបររកទទួលទានចិញ្ចឹមជីវិត ធ្វើកសិកម្មខ្លះ ពាណិជ្ជកម្ម ជំនួញជួញដូរខ្លះ ប្រកបដោយធម៌ខ្លះ មិនប្រកបដោយធម៌ខ្លះ និងអ្នកកាន់សាសនាផ្សេងៗមានព្រះពុទ្ធសាសនាជាដើមសម្រាប់ទ្រទ្រង់ប្រទេសជាតិទុកជាប្រទីបឆ្លុះបញ្ចាំងដល់ជនានុជន ឱ្យប្រតិបត្តិតាមឱវាទានុសាសនី ដើម្បីសុខសន្តិភាពក្នុងប្រទេសនីមួយៗជាទូទៅលើសាកលលោក ។ ការរកទទួលទានប្រកបអាជីព ប្រជាជនតែងទទួលបានផលល្អប្រសើរខ្លះ មិនប្រសើរខ្លះ អាស្រ័យពីធម្មជាតិអំណោយផល មានទឹកភ្លៀងជូនតាមរដូវកាល ព្រោះពុំសូវបានសិក្សាក្រេបជញ្ជក់ចំណេះដឹង ឱ្យយល់ជ្រួតជ្រាបនូវហេតុផលច្បាស់លាស់ពីធម្មជាតិក្នុងគោលបំណងលើកតម្កើង នូវទិន្នផលដំណាំដាំដុះផ្សេងៗ ឱ្យបានដឹងជាក់ច្បាស់ពីកំណើតរុក្ខជាតិទាំងឡាយថា តើត្រូវប្រើធាតុអ្វីខ្លះ ដើម្បីធ្វើឱ្យដំណាំទាំងនោះដុះលូតលាស់ល្អរីកចម្រើនសម្បូណ៌ផលផ្លែផ្កា ដោយគ្រាន់តែយកពូជទៅដោតដាំ រួចរង់ចាំទទួលផលប៉ុណ្ណោះ ។ លុះក្រោយមកមេរៀនជីវិតក៏ត្រូវមានការសិក្សាស្រាវជ្រាវ រិះរករូបមន្តចាំបាច់ទៅលើក្បួនវិទ្យាសាស្ត្រនាសម័យជឿនលឿន យកមករួមផ្សំប្រើប្រាស់ឱ្យសម្រេចទៅតាមធម្មជាតិ ដោយមានការបង្កើតជាសាលារៀន និងបញ្ជូនសិស្សនិស្សិត

ទៅចូលរួមសិក្សាពីកន្លែងមួយទៅកន្លែងមួយ ដើម្បីយកចំណេះដឹងនោះមកអនុវត្តតាមទីកន្លែងរៀងខ្លួន ឃើញថាមានអភិវឌ្ឍន៍ជឿនលឿនតាមតំបន់ តាមស្រុកភូមិប្រទេស ហើយក៏បានផ្លាស់ប្តូរពីភាពទន់ខ្សោយមកជាអ្នកមានទ្រព្យសម្បត្តិធូរធា មានប្រាក់កាសច្រើនសម្រាប់ចាយវាយប្រើប្រាស់ធ្វើអ្វីផ្សេងៗ ដូចជាកសាងសំណង់ធំៗ កសាងអគារផ្ទះល្វែងជាច្រើនខ្នង និងកសាងបាននូវគ្រឿង ឧបភោគបរិភោគប្រណីតៗ សម្រាប់ជាអាហារប្រចាំថ្ងៃដល់ជីវភាពរុងរឿង នៅក្នុងគ្រួសារនីមួយៗ ក៏ដូចជាសង្គមមនុស្សទូទៅលើសាកលលោក ។ ក្រៅពីផ្នែកកសិកម្ម ការរកទទួលទានមុខជំនួញជួញដូរក៏ត្រូវប្រើប្រាស់ផលិតផល កសិកម្មបានមកពីការសម្រិតសម្រាំងច្នៃប្រឌិតរបស់កសិករទំនើប ធ្វើឱ្យការរកទទួលទាននេះប្រែក្លាយទៅជាអ្នកមានភោគសម្បត្តិច្រើនៗដូចគ្នា ព្រោះការប្រកបអាជីព អាស្រ័យពីយើងបានកសាងនូវធនធានមនុស្សជាតិ រួមគួបផ្សំជាមួយបច្ចេកវិទ្យាដែលមានលោកគ្រូអ្នកគ្រូ សាស្ត្រាចារ្យចំណានៗ ចេះអប់រំដល់សិស្សានុសិស្សទាំងឡាយ ឱ្យងាយបានឆាប់យល់ដឹងទៅតាមវិធីសាស្ត្រដែលលោកគ្រូម្នាក់ៗ ធ្លាប់បានទទួលកម្រិតយល់ដឹងពីមជ្ឈដ្ឋាននានា ដែលខ្លួនបានសិក្សារៀនសូត្រប្រមូលយកនូវចំណេះវិជ្ជា ពីប្រទេសជាមិត្ត មកបម្រើក្នុងប្រទេសរបស់ខ្លួនបណ្តាលឱ្យសង្គមពិភពលោកក្លាយទៅជាសង្គមមាន

អារ្យធម៌ជឿនលឿនទាំងផ្នែកកសិកម្ម ទាំងផ្នែក ឧស្សាហកម្ម មានរោងចក្រសហគ្រាសទំនើបៗ ទាំងផ្នែកសីលធម៌ វប្បធម៌ប្រពៃណី ធនធានមនុស្ស និងព្រះពុទ្ធសាសនា ក៏មានការរីកចម្រើនយ៉ាងអស្ចារ្យ ដូចនៅប្រទេសខ្មែរនាសម័យសព្វថ្ងៃនេះ មានដើមព្រះមហាពោធិព្រឹក្ស ពីប្រទេសឥណ្ឌា ប្រទេសសិរីលង្កា ព្រះសារីរិកធាតុ គម្ពីរព្រះត្រៃបិដក ដែលវិនាសអន្តរាយក្នុងសម័យ **ប៉ុលពត អៀង សារី** ត្រូវហូរចូលមកយ៉ាងច្រើន ថែមទាំងរីកដុះដាលពេញពិភពលោក ដោយមានលោកអាចារ្យ និង លោកសប្បុរស ដ៏មានគុណសម្បត្តិគ្រប់គ្រាន់ មកបង្ហាត់បង្រៀនផ្សព្វផ្សាយព្រះពុទ្ធសាសនាតាមក្បួនច្បាប់គម្ពីរព្រះត្រៃបិដក នូវពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធសាសនា ។ ប្រសិនបើលោកគ្រូអាចារ្យ អ្នកបង្ហាត់បង្រៀនខ្វះចំណេះដឹងជ្រៅជ្រះ ពុទ្ធបរិសទ្យ សិស្សនិស្សិត ក៏មិនសូវយល់ជ្រួតជ្រាបបានល្អ ម្ល៉ោះហើយគ្រូអាចារ្យ លោកគ្រូអ្នកគ្រូ សាស្ត្រាចារ្យទាំងនោះត្រូវមានបញ្ញាឆ្លាត វាងវៃក្នុងចំណេះដឹងរបស់ខ្លួន ឱ្យមុតមាំពិតប្រាកដទើបក្លាយជាអ្នកបង្ហាត់បង្រៀនល្អ សម្ដែងធម៌ល្អ ផ្ដល់ជាមតិប្រាប់ដល់សិស្សនិស្សិតបាន ដូចមាននៅក្នុងសៀវភៅសរសេរពីរ ៤ ប្រការរបស់លោកគ្រូអគ្គបណ្ឌិតជាម្ចាស់ ចំពោះបុគ្គលដែលមានតួនាទីជាអ្នកបង្រៀនសិស្ស គប្បីមានគុណសម្បត្តិ ៧ ប្រការដូចតទៅនេះ :

**<u>គុណសម្បត្តិទី១</u>** : **បិយោ** ចេះធ្វើខ្លួនឱ្យជាទីស្រឡាញ់ចូលដល់ក្នុងចិត្តរបស់សិស្ស សាងនូវភាពជិតដិតស្និទ្ធស្នាល ដើម្បីជាប្រយោជន៍ឱ្យសិស្សចង់មករៀនជាមួយ និង ហ៊ានប្រឹក្សាសាកសួរបញ្ហាផ្សេងៗ ។

**<u>គុណសម្បត្តិទី២</u>** : **គរុ** ធ្វើខ្លួនឱ្យថ្លៃថ្នូរ គួរដល់ការគោរព និងកោតសរសើរអំពីសិស្សទាំងឡាយ មានការប្រព្រឹត្តដ៏សមគួរដល់ឋានៈធ្វើឱ្យកើតការកក់ក្តៅបានជាទីពឹង និងបានជាប្រយោជន៍ដល់សិស្សពិតប្រាកដ ។

**<u>គុណសម្បត្តិទី៣</u>** : **ភាវនិយោ** ត្រូវអប់រំខ្លួនឱ្យមានការចម្រើនទៅដោយចំណេះដឹងទ្រទ្រង់នូវភូមិបញ្ញាពិតប្រាកដ (ភារៈទូន្មានខ្លួនជាកន្លែងឱ្យកើតបញ្ញា) ជាអ្នកហ្វឹកហាត់ថែបំប៉នចិត្ត ដោយមានស្មារតីជាអចិន្ត្រៃយ៍គួរជាទីលើកតម្កើង និង ជាទីសង្ឃឹមកក់ក្តៅរីករាយក្នុងចិត្តនៅពេលដែលសិស្សមានការនឹករលឹកដល់លោកគ្រូ ព្រមទាំងយកជាគំរូទៀតផង ។

**<u>គុណសម្បត្តិទី៤</u>** : **វត្តា** ចេះនិយាយឱ្យបានផល គឺចេះពន្យល់ឱ្យសិស្សយល់ដឹងថា ពេលណាគួរនិយាយអ្វី ហើយត្រូវនិយាយយ៉ាងណា និង ព្យាយាមរឿយៗក្នុងការពន្យល់ណែនាំ រំលឹកដាស់តឿនព្រមទាំងជាទីប្រឹក្សាយ៉ាងល្អ ។

**គុណសម្បត្តិទី៥ : វចនក្ខមោ** អត់ធន់ចំពោះពាក្យសម្ដីអ្នកដទៃក្នុងពេលបានស្ដាប់ពាក្យប្រឹក្សាសាកសួរ ឥតប្រយោជន៍ គ្រាន់តែជាការរំខានក្ដី ពាក្យពោលបង្អាប់ ឬចាក់រុកអុជអាលក្ដី សូម្បីពាក្យពោលរំលឹកដាស់តឿនអំពីអ្នកដទៃ ដែលគេបានឃើញនូវកំហុសត្រង់ណាមួយក្ដី រមែងអាចអត់ទ្រាំស្ដាប់បានដោយមិនថ្នាំងថ្នាក់ អត់ធន់ចិត្ត ឬ ខូចចិត្តអ្វីឡើយ និងចេះឃើញ កំហុសរបស់ខ្លួន ចេះសុំខមាទោស ព្រមទាំងចេះកែនូវកំហុសតាមវិស័យនៃអ្នកកសាងខ្លួនទៀតផង ។

**គុណសម្បត្តិទី៦ : គម្ភីរញ្ច កថំ កត្តា** ពោលពាក្យមានជម្រៅជ្រៅក្នុងធម៌ ជ្រៅសេចក្ដី គឺ ពោលចង្អុលធម៌ផ្សេងៗក្នុងជីវិត ឱ្យឃើញមានជម្រៅទៅតាមសេចក្ដីពិត នៃសច្ចធម៌ និងពោលនូវពាក្យណាដែលជ្រៅលំបាកឱ្យមកជារាក់ ដូចបើករបស់ដែលកំបាំង ឬ ផ្ងាររបស់ដែលផ្កាប់ ដើម្បីឱ្យអ្នកស្ដាប់បានយល់ប្រាកដក្នុងចិត្ត ព្រមទាំងពោលតាមលំដាប់មិនស្រូតកាត់ឱ្យខូចសេចក្ដី ជាការជម្រាលសេចក្ដីទៅរកជម្រៅ ទន់ទេរទៅដូចជាច្រាំងនៃមហាសមុទ្រ ។

**គុណសម្បត្តិទី៧ : នោ ចដ្ឋានេ និយោជយេ** បានសេចក្ដីថា មិនដឹកនាំទៅរកផ្លូវនៃសេចក្ដីវិនាស ឬ ផ្លូវដែលមិនមែនជាហេតុនៃសេចក្ដីចម្រើនរបៀបដូចជាអាចារ្យដើម របស់អង្គុលិមាលនោះឡើយ ។

អង្គុលិមាលកាលពីដើមជាទីស្រឡាញ់របស់គ្រូ រហូតដល់សិស្សដទៃមានការច្រណែនហើយបានញុះញង់គ្រូឱ្យ មានការភ័យខ្លាចថា អង្គុលិមាលក្បត់ចិត្ត ។ ហេតុតែគ្រូល្ងង់ខ្លៅខ្វះនូវគុណសម្បត្តិទី ៧ នេះក៏បានដឹកនាំបញ្ឆោត ឱ្យអង្គុលិមាលទៅសម្លាប់មនុស្សមួយពាន់នាក់ ដើម្បីបានប្រកបនូវមន្តវិជ្ជា ពិសេសក្នុងបំណងឱ្យគេសម្លាប់អង្គុលិមាល ដែលជាមនុស្សអាក្រក់បានជា ភ្លេចថា ខ្លួនឯងជាគ្រូដែលប្រព្រឹត្តដូចនេះ វាអាក្រក់ជាងអង្គុលិមាលទៅទៀត ត្រូវទទួលរងទុក្ខទោសព្រោះ អំពើនោះធ្លាក់មកលើខ្លួនឯង ។

ពុទ្ធគាថាអំពីគុណសម្បត្តិរបស់គ្រូ ៧ យ៉ាង ដែលបានអធិប្បាយរួចមកហើយ ។

**បិយោ ច គរុ ភាវនីយោ វត្តា ច វចនក្ខមោ**

**គម្ភីរញ្ច កថំ កត្តា នោ ចដ្ឋានេ និយោជយេ ។**

**ប្រែ** គ្រូអាចារ្យធ្វើខ្លួនឱ្យជាទីស្រឡាញ់ផង គួរគោរពផង គួរសរសើរផង ឧស្សាហ៍ប្រៀនប្រដៅផង អត់ធន់ចំពោះពាក្យផង ជាអ្នកនិយាយពាក្យជ្រៅផង ទាំងមិនដឹកនាំក្នុងហេតុដែលមិនគួរផង ។

គុណធម៌ទាំងនេះមានក្នុងគ្រូអាចារ្យណា ក្នុងលោកនេះគ្រូអាចារ្យនោះជាមិត្តពិតប្រាកដជាអ្នកប្រាថ្នា អនុគ្រោះនូវប្រយោជន៍ ។ បុគ្គលណា

ដែលមានសេចក្ដីត្រូវការចងមិត្ត គួរសេពគប់នូវមិត្តដែលមានសភាពបែប នេះ ទោះបីត្រូវលោកពោលបណ្ដេញដោយប្រការណាក៏ដោយ ។

(គោលធម៌ស្រង់ចាក អង្គុត្តរនិកាយ សត្តកនិបាត ទុតិយសិក្ខាសូត្រ ប្រសូត្រសម្ដែងពីមិត្តសំឡាញ់) ។

ដូច្នោះការអប់រំវិជ្ជាជីវៈ អាស្រ័យពីកត្តាសំខាន់ ៦យ៉ាង ដូចតទៅ :

១-គ្រូត្រូវមានចំណេះដឹងខ្ពង់ខ្ពស់គ្រប់គ្រាន់ ដោយគរុកោសល្យ

២-សិស្សត្រូវមានសមត្ថភាពអាចត្រងត្រាប់ចាប់ យកវិជ្ជាពីលោកគ្រូ តាមនិន្នាការថ្នាក់ៗ

៣-មានរូបមន្តច្បាស់លាស់ត្រឹមត្រូវដកស្រង់ពីក្នុងក្បួនច្បាប់ និង គម្ពីរនានា ដោយការខំស្រាវជ្រាវតាមបច្ចេកវិទ្យា

៤-យកចិត្តទុកដាក់ព្យាយាមអំណត់អត់ធន់ក្នុងគរុជីវៈរបស់ខ្លួន

៥-មានការសប្បាយរីករាយមិនប្រទូស្ត នៅពេលមានសិស្សសាកសួរ សំនួរក្នុងន័យចង់ចេះចង់ដឹង

៦-មានលក្ខណៈស្រឡាញ់រាប់អាន ជាទូទៅដល់សិស្សានុសិស្សគ្រប់ ប្រភេទដោយទឹកចិត្តមេត្តាប្រោសប្រណីអនុគ្រោះដល់សព្វសត្វ ។

# កំណើតរបស់មនុស្សសត្វ

**មើលលោកនេះ ដោយការបញ្ជាក់ពីកំណើតពិតរបស់មនុស្ស** គឺ សម្លឹងឃើញកំណើតរបស់មនុស្សប្រសូតចេញពីប្រភពណា ?

ផែនដីយើងនេះពេលដែលកើតឡើងហើយ ត្រូវវិនាសទៅវិញជាធម្មតាមានចន្លោះអន្តរកប្ប ៤ដង ស្មើនឹង ៦៤អន្តរកប្ប ៦៤ x ៤ ត្រូវជា ២៥៦ អន្តរកប្បទើបផែនដីត្រូវវិនាស ។ នៅពេលដែលកកើតផែនដីជាដំបូងពុំមានមនុស្សរស់នៅទេ មានតែធាតុដីទទេធុំក្លិនក្រអូបឈ្ងុយឈ្ងប់ធ្វើឱ្យពួកព្រហ្ម ចុតិមកចាប់បដិសន្ធិរួចបរិភោគដីជាអាហារ ពុំមានបាយសម្លដូចសព្វថ្ងៃនេះឡើយ ។ មនុស្សក្នុងសម័យបុព្វកាលគ្មានសម្លៀកបំពាក់បិទបាំងខ្លួនប្រាណ ពុំមានជម្រកត្រឹមត្រូវរស់នៅក្រោមម្លប់ដើមឈើកណ្តាលវាលល្ហល្ហេវ លុះក្រោយបន្តិចទើបមានជម្រកបិទបាំង ឬមិនបិទបាំងខ្លះមានសម្លៀកបំពាក់ខ្លះ ឬមិនមានសម្លៀកបំពាក់ខ្លះ ។ ដោយមានការចេះខ្មាសអៀនរវាង បុរស និង ស្ត្រី ធ្វើឱ្យដំណើរជីវិតចម្រើនបន្តិចម្តងៗ នាំឱ្យចេះស្លៀកពាក់ មានស្រូវដុះឯងៗគ្មានម្ចាស់គ្រប់គ្រងជាស្រូវដុះនៅលើដីសាធារណៈទូទៅដល់មនុស្សទាំងឡាយសម្រាប់ជាអាហារ ព្រោះលែងបរិភោគដីដូចពីមុនទៀតឡើយ ។

ពេលមានតម្រេករៀង១ខ្លួន បានរួមរក្សជាមួយគ្នានៅកណ្តាលវាល គ្មានការខ្វាសអៀនអ្វីសោះ ។ លុះក្រោយពីនោះ បាននាំគ្នាធ្វើជម្រកមានបន្ទប់បិទបាំង ដើម្បីការពារកេរ្តិ៍ខ្មាស គឺចេះខ្មាសអៀនក្នុងការរួមរក្សស្នេហាគ្នា ។ ចំពោះស្រូវដែលដុះឯងក៏ត្រឡប់ទៅជាស្រូវមានម្ចាស់ហួងហែងថែរក្សាដោយសម្គាល់ថា កន្លែងនេះជារបស់ខ្លួនកន្លែងនោះជារបស់គេ ។ កាលបើសេចក្តីប្រកាន់មានឥទ្ធពលខ្លាំងឡើង១ ក៏នាំគ្នាទៅបេះ ស្រូវនោះយកមកលាក់ទុកក្នុងលំនៅខ្លួន ចៀសវាងពីការលំបាកទៅបេះ ប្រឡេះស្រូវនៅឯស្រែចំការ ព្រោះកាលពីដើមនៅពេលត្រូវការ ទើបនាំគ្នាទៅប្រឡេះបេះស្រូវនោះយកមកប្រើប្រាស់ត្រឹមតែមួយពេលប៉ុណ្ណោះ ។ ចំណែករុក្ខជាតិទាំងឡាយក៏ដុះលូតលាស់ស្រស់ល្អមានស្លឹកត្រួយខ្ចីចាស់មានផ្លែផ្កាឱ្យផលតាមរដូវកាលមិនបាច់ភ័យព្រួយ ព្រោះដីមានជីជាតិល្អស្រាប់ ថែមទាំងអំណោយផលល្អពីធម្មជាតិមានទឹកភ្លៀងធ្លាក់ជូនតាមរដូវកាល ។ ឯរដូវទាំង ៤ គឺរដូវភ្លៀង រដូវរងា រដូវត្រជាក់ និងរដូវក្តៅក៏ប្រែប្រួលជាធម្មតាតាមឧតុនិយាមធម្មជាតិ ជាឱកាសដល់ សត្វទ្វេបាទសត្វចតុប្បាទ សត្វស្លាប សត្វក្នុងទឹក សត្វក្នុងដី ដូចជាជន្លេន កណ្តៀរសត្វល្អិតតូច១ ដូចជាស្រមើលកើតអំពីមេមាន់ក្រាបពង សត្វល្អិតដទៃ១មានពួកក្អាត់ ឬ សត្វល្អិត១កើតនៅលើស្លឹករុក្ខជាតិ លើដីស្រែចំការ

កើតឡើងពីចលនាផ្សំធាតុនៃអាកាសធាតុបង្កើតជា វិញ្ញាណរស់រវើក អាស្រ័យពីពន្លឺនិងចំហាយព្រះអាទិត្យបំភ្លឺលើផែនដី ហៅ ថា **មនធាតុ** ។

មនុស្សយើងកើតចេញពីផ្ទៃនៃ **ព្រះមាតា** ដោយមាតាបិតាបាន រួមរក្សជាមួយគ្នាប្រកបទៅដោយអង្គទាំង ០៣ ប្រការជាកំណើត **គព្ភសេយ្យកសត្វ** ដែលបានដកស្រង់ពីក្នុងសៀវភៅកំណើត ០៤ រៀបរៀងដោយសម្តេចព្រះពោធិវង្ស **នន្ទ-ខ៊ែត** ព្រះសង្ឃនាយករង ទី១ គណៈមហានិកាយ ដែលព្រះសម្មាសម្ពុទ្ធបរមគ្រូទ្រង់ត្រាស់សម្តែង ឡើងចំពោះភិក្ខុទាំងឡាយថា សត្វដែលចុះមកកាន់គភ៌ព្រះមាតានោះ លុះណាតែប្រកបព្រមនូវអង្គ ទាំង ៣ ប្រការ សាងកំណើតដោយបាន សន្និពន្ធ ឬ សន្និបាតរួមរក្សជា មួយគ្នា :

**១-រាគសន្និបាតតិតា ច មាតាបិតា :** មាតាបិតា ព្រមស្នេហ៍គ្រ សមាគមរួមរក្សជាមួយគ្នាដោយក្តីស្នេហ៍ស្ម័គ្រ ។

**២-មាតា ឧតុនី ច :** មាតាជាស្ត្រីមានរដូវ ។

**៣-គព្ភោ ច បច្ចុប្បដិតោ :** មានសត្វចុះមកចាប់បដិសន្ធិតាំងនៅ ប្រាកដ ។ កាលបើខ្វះអង្គណាមួយ ឬពុំបានធ្វើសន្និពន្ធ ឬ សន្និបាតរួមរក្ស ជាមួយគ្នាប្រកបទៅដោយអង្គទាំង ៣ ប្រការនេះទេ ជាតិកំណើត របស់ **គព្ភសេយ្យកសត្វ** ក៏ពុំមានដែរ ។

បើដូច្នោះសត្វចុះចាប់បដិសន្ធិមាន ៤ កំណើតដែលមានសេចក្តីពិស្តារ ដូចខាងក្រោមនេះ :

**<u>ប្រការ ១ :</u> ជលាព្វុជកំណើត** បានដល់ កំណើតសត្វដែលកើតអំពី **"សុក្កៈ"** ជាគព៌្ភសេយ្យកសត្វ គឺសត្វដែលដេកត្រាំក្នុងផ្ទៃមាតា បានដល់ពួកមនុស្ស និង សត្វតិរច្ឆានមាន គោ ក្របី សេះ ដំរី ឆ្កែ ឆ្មា ចៀម ពពែ ជាដើម ។ល។ ចំពោះមនុស្សសុក្កៈនោះមានស្រោម ស្រោបកូននៅក្នុងផ្ទៃមាតា មានទងសុកជាប់នឹងផ្ចិតកូន ជាផ្លូវជ្រួតជ្រាបនូវរសជាតិអាហារ ធ្វើឱ្យកូនរីកចម្រើនធំធាត់តាមកំណត់ស្ថិតក្នុងស្រោមទឹកភ្លោះ។ ពេលដល់កាលកំណត់ ស្រោមទឹកភ្លោះនោះក៏បែកធ្លាយប្រសូត ចេញកូន មកក្រៅ ក៏គេកាត់ទងសុកនោះឱ្យដាច់ចេញពីផ្ចិតកូន (ដកស្រង់ពីក្នុងដីកាអភិធាន) ។

**<u>ប្រការ ២ :</u> អណ្ឌជកំណើត** បានដល់ កំណើតសព្វសត្វមានបក្សាបក្សី សត្វស្លាបស្រុក : មាន់ ទា ក្ងាន ព្រាប ជាដើម ។ល។ ឯសត្វស្លាបព្រៃវិញមាន : ចាប លលក ត្រួច ក្ងោក ទទា ក្អែកទឹក ស្មោញ កុកក្រសាជាដើម ។ល។ ដែលកើតចេញពីស៊ុតជាមុនរួចបានមេវាក្រាបក្រុងភ្ញាស់ចេញ ជាកូន ឬ ហៅថា **"ទ្វិជកំណើត"** គឺកំណើតពីរដង ។

**ប្រការ ៣ : សំសេទជកំណើត** គឺកំណើតសត្វកើតចេញពីរបស់មិនស្អាត ដូចជាញើសក្អែល ឬទីកន្លែងអាប់អួ ស្មោកគ្រោក ភក់ជ្រាំ គំនរ សំរាម មានសត្វចៃ សង្កើច ស្រមោច និងដង្កូវផ្សេងៗ ជាកំណើតមានទាំងមនុស្ស និង សត្វតិរច្ឆាន ។

**ប្រការ ៤ : ឧបបាតិកកំណើត** ជាកំណើតរបស់ទេវតា និង មនុស្ស ព្រមទាំងសត្វនរកប្រេតជាដើមផងដែរ ។ កំណើតនេះពេលកើតឡើងធំពេញរូបរាងតែម្តងដូចជា **នាងអម្ពបាលី** កើតចេញពីដើមស្វាយ មានមនុស្សខ្លះកើតចេញពីផ្កាឈូកទៀតផងក្នុងសម័យពុទ្ធកាលព្រមទាំងមានអាយុពេញវ័យគ្រប់ ១៦ឆ្នាំគត់ (អដ្ឋកថា សង្គិតិសូត្រ) ។

តាមន័យសេចក្តីដែលបានពិពណ៌នាដូចខាងលើនេះ មនុស្សសត្វទាំងអស់កើតពីកំណើត ៤ ចាប់តាំងពីសម័យបុព្វកាល (បឋមកប្ប) ក៏មិនឃើញថា សត្វតិរច្ឆាន (ស្វា) ជាដើមកំណើតរបស់មនុស្សដូចដែលអ្នកខ្លះលើកឡើងថា "មនុស្សកើតពីសត្វស្វា" នោះទេ ព្រោះមនុស្សកើតមកពីកម្លាំងបុណ្យដោយកុសលវិបាកជាឧបនិស្សយប្បច្ច័យ មានភវង្គជាមនុស្ស រក្សាភពជាតិកំណើតក្នុងមួយអត្តភាព ។ ចំណែកសត្វតិរច្ឆាន

កើតពីអកុសកម្មឱ្យផលជាអកុសលវិបាករបស់សត្វតិរច្ឆាន មានភវង្គទ្រទ្រង់ ភពជាតិកំណើតជាសត្វតិរច្ឆានក្នុងមួយអត្តភាពដូចគ្នា ។

(ដកស្រង់ពីក្នុងគម្ពីរព្រះអភិធម្ម) ។

**នៅក្នុងទីឃនិកាយបាដិកវគ្គ** បិដកលេខ ១៩/១៦៧ ក៏មានសម្តែងពីកំណើត ៤ របស់សត្វទាំងឡាយដូចប្រការខាងលើនេះដែរ ។

**ធម្មតាពួកសត្វមានកំណើត ៤ ត្រឹមត្រូវតាមក្បួនច្បាប់ព្រះធម្មា**
**កើតចេញពីពូជមនុស្សរៀងរាល់គ្នា ស្វាទស្វាទទាកើតតាមខ្សែគេ ។**
**បើពោលមិនពិតហាក់ដូចជាល្បែង គ្មានការជាក់ស្តែងគួរគិតគ្នាន់គ្នេរ**
**មិនដែលមនុស្សណាកើតឡើងទទេ យកស្វាធ្វើមេបង្កើតពូជ ។**

## ការអប់រំចិត្ត

**មើលលោកនេះក្នុងសង្គមដោយការពិចារណាទៅលើចិត្ត** តើត្រូវធ្វើការអប់រំរៀបចំចិត្ត រក្សាចិត្ត គ្រប់គ្រងចិត្ត របៀបណា ដើម្បីឱ្យមានប្រសិទ្ធភាព ក្នុងការអប់រំសម្រេចទៅជាចិត្តល្អមានសីលធម៌ វិន័យ សុជីវធម៌ ព្រមទាំងអបចាយនធម៌ក្នុងសង្គម និងគោលដៅ ។

ចិត្តមានត្រឹមមួយដួងគត់ដែលបំបែកចេញជា ៨៩ ដួង ឬ ១២១ ដួង ដោយពិស្តារបានទៅជាកុសល អកុសល វិបាកនិងកិរិយាដូចបាន

ជម្រាបជូន ពីខាងដើមរួចហើយ ឱ្យក្លាយទៅជាចិត្តល្អមានសោភណភាព ស្អាតបរិសុទ្ធ លុះត្រាតែចិត្តនោះប្រាសចាកគ្រឿងស្មៅហ្មង គឺ កិលេសជាតិ ដេកត្រាំនៅក្នុងសន្តានចិត្តរបស់សត្វទាំងឡាយយូរអង្វែងណាស់មកហើយ ។

ហេតុអ្វីបានជាត្រូវអប់រំចិត្ត ?

**ពាក្យថាចិត្ត** ព្រោះសភាវធម៌ដឹងច្បាស់នូវអារម្មណ៍

**ពាក្យថាចិត្ត** ព្រោះសន្សំសន្តាន ដោយអំណាចជវនវិថី

**ពាក្យថាចិត្ត** ព្រោះសភាវធម៌ដែលកម្មកិលេស សន្សំវិបាក

**ពាក្យថាចិត្ត** សូម្បីគ្រប់ដួងឈ្មោះថាចិត្ត ព្រោះធម្មជាតិវិចិត្រតាមសមគួរដោយអំណាចនៃសម្បយុត្តធម៌

**ពាក្យថាចិត្ត** ដោយអត្ថថាគិត ( ស្រង់ចាកបរមត្ថធម៌សង្ខេបដោយធម្មាចារ្យ រស់ សុផាត)

**ពាក្យថាចិត្ត** បានដល់មនុស្សសត្វទាំងអស់ដែលមានចិត្តជាអ្នកគ្រប់គ្រងតែក្នុងសេចក្តី នេះសំដៅទៅលើមនុស្សតែម្តង ។

**ពាក្យថាមនុស្ស** កើតចេញពី មន + ឧស្ស :

**មន :** បានសេចក្តីថា ចិត្ត + ឧស្ស : ប្រសើរខ្ពង់ខ្ពស់ឧត្តុង្គឧត្តមជាសត្វវិសេសជាងសត្វដទៃ ព្រោះចេះគិតពីពិចារណារកហេតុផល អាចប្រព្រឹត្ត ធ្វើអ្វីតាមរយៈការអប់រំ បានទៅជាមនុស្សល្អមានប្រាជ្ញាភ្លឺថ្លា

ព្រោះមាន ចិត្តជាប្រធានក្នុងការដឹងអារម្មណ៍ទូទៅ ។ ដូច្នោះកាលណាគេនិយាយពី មនុស្ស គេនឹងត្រូវលើកបញ្ជាក់ទៅលើចិត្ត បើចិត្តល្អ មនុស្សក៏ឈ្មោះថា ល្អដូចក្នុងព្រះគាថាធម្មបទ ទ្រង់ត្រាស់ថា :

**មនោបុព្វង្គមា ធម្មា មនោសេដ្ឋា មនោមយា**

**មនសា ចេ បសន្នេន ភាសតិ វា ករោតិ វា**

**តតោ នំ សុខមន្វេតិ ឆាយាវ អនុបាយិនី ។**

**ប្រែ :** ធម៌ទាំងឡាយមានចិត្តជាប្រធាន មានចិត្តប្រសើរបំផុតសម្រេចមកពីចិត្ត បើបុគ្គលមានចិត្តជ្រះថ្លាហើយ ទោះបីនិយាយក្តី ធ្វើក្តីក៏ល្អទាំងអស់ ព្រោះចិត្តជ្រះថ្លានោះឯង សេចក្តីសុខរមែងតាមជាប់បុគ្គលនោះដូចស្រមោលអន្ទោលតាមប្រាណយ៉ាងដូច្នោះឯង ។

បើចិត្តមិនល្អមនុស្សក៏មិនល្អដែរ យ៉ាងណាពាក្យថាការអប់រំចិត្តគឺគេត្រូវអប់រំចិត្តអាក្រក់ឱ្យក្លាយទៅជាចិត្តល្អ មនុស្សល្អ គ្រូល្អ សិស្សល្អអ្នកដឹកនាំល្អ ព្រោះមានចិត្តល្អបានដល់មហាកុសល ៨ដួង ក្នុងចិត្ត ៨៩ដួង ឬ ១២១ដួង នេះឯង ។ ចំណែកចិត្តអាក្រក់ វិញជាចិត្តជ្រោកជ្រាកទៅដោយកិលេសដែលមានស្រាប់នៅក្នុងខ្លួន កើតជាមួយពួកអកុសលចិត្តទាំង ១២ ដួង គឺ លោភមូល ៨ ទោសមូល ២ និងមោហមូល ២ ដូចបានជម្រាប ជូនពីខាងដើមរួចមកហើយដែលចាំបាច់ត្រូវអប់រំ ព្រោះ

មនុស្សយើងកើតមកហើយ នាំយកនូវចិត្តអាក្រក់និងល្អមកជាមួយ ដោយពុំដឹងខ្លួន ហើយក៏ចេះតែប្រព្រឹត្តធ្វើនូវអំពើអ្វីៗ តាមចិត្តប្រកាន់ ស្អិតជាប់ជំពាក់ទៅលើ អារម្មណ៍ផ្សេងៗតាមទ្វារ ៦ ណាមួយរួចក៏ សន្សំទុកនូវអំពើកម្មនោះ ច្របូកច្របល់ ដោយកិលេសសម្រាប់ធ្វើកិច្ច បដិសន្ធិនៅភពខាងមុខតទៅទៀត ។ លុះបានសិក្សាអំពីចិត្ត ចេតសិក រូប និព្វានក្នុងព្រះអភិធម្ម ក៏បានដឹងថា មនុស្សយើងម្នាក់ៗ មានចិត្តជា ប្រធាននាំមុខសម្រាប់ធ្វើការងារផ្សេងៗ ដោយកាយកម្ម វចីកម្ម និងមនោកម្មឱ្យត្រឡប់ទៅជាមនុស្សល្អ រហូតបានសម្រេចអមតធម៌ គឺ ព្រះនិព្វានមិនក្រៅអ្វីពីមនុស្សឡើយ ។ ចំណែកសត្វដទៃពុំមានបញ្ញា កាប់ឆ្ការកិលេសឱ្យបានរួចខ្លួន ទៅជាសត្វ វៀរចាកអំពើបាបទាំងឡាយ ដោយភវង្គជាអង្គភពរបស់ចិត្ត តម្រង់ភពជាតិកំណើតជាសត្វតិរច្ឆាន ដែលមិនអាចប្តូរផ្លាស់មកជា មនុស្សលុះត្រាតែបែកធ្លាយរាងកាយស្លាប់ ទៅទើបបន្តភពថ្មី កើតភវង្គថ្មី សាងសន្សំពូជពីកម្មចាស់ សម្រេចជា ផលវិបាកទុកជាឧបនិស្សយប្បច្ច័យ ធ្វើកម្មថ្មីក្នុងបច្ចុប្បន្នតទៅខាងមុខ ទៀត ។

◈ ការអប់រំចិត្ត ឬ ទូន្មានចិត្ត ឬ គ្រប់គ្រងចិត្តឋិតនៅលើមនុស្សតែ មួយប្រភេទ ឯសត្វដទៃមិនអាចប្រព្រឹត្តទៅបានព្រោះមនុស្សជាអ្នកមាន

បញ្ញាសន្សំទុកមកជាមួយ ចេះអនុគ្រោះអត់ឱនត្រាប្រណី ស្លូតបូតសុភាពរាបសា អត់ធន់ និងមានមេត្តាចិត្តសម្រាប់ជួយស្រោចស្រង់សត្វ ឱ្យរួចពីអន្លង់ភក់ គឺ សេចក្តីទុក្ខដូចជាព្រះសម្មាសម្ពុទ្ធជាដើម ព្រះអង្គឆ្លងផុតដល់ត្រើយ គឺ ព្រះនិព្វាន ដោយការសាងបារមីសន្សំទុកច្រើនកប្បជាតិរហូតបានត្រាស់ដឹងសម្មាសម្ពោធិញ្ញាណ អាស្រ័យបារមីចាស់ក្លា ព្រោះព្រះអង្គមានដើមកំណើតជាមនុស្សហៅថា**និយតពោធិសត្វ** (ក្នុងការកសាងបារមី) ទៀងតែពីបានសម្រេច ។

◊ ការអប់រំចិត្ត សំដៅទៅលើការរំដោះចិត្តចេញពីអន្ទាក់មារ បានដល់កិលេសមារ អភិសង្ខារមារ ខន្ធមារ មច្ចុមារ និង ទេវបុត្រមារឋិតនៅស្ថានសួគ៌ជាន់ទី ៦ ដោយបញ្ញា ។

ពាក្យថាបញ្ញានៅក្នុងព្រះពុទ្ធសាសនា បានន័យថា ធម្មជាតិសម្រាប់ដុតបំផ្លាញកិលេសជាតទង្គប្បហានបន្តិចម្តង១ រហូតជាសមុច្ឆេទប្បហានលះដាច់ស្រឡះ ។ ឯបញ្ញាខាងផ្លូវលោកយើងនេះពុំមែនជាបញ្ញាចេតសិកមានន័យត្រឹមតែមនសិការៈ (ធ្វើទុកក្នុងចិត្ត) ពុំបានបំផ្លាញកិលេសជាតិទេគ្រាន់តែចេះដឹងតាមការសិក្សាស្រាវជ្រាវនូវរូបមន្តយកមកប្រើប្រាស់កសាងលោកសម្ភារៈប៉ុណ្ណោះ ។ កាលណាមានសញ្ញាប័ត្រខ្ពង់ខ្ពស់គឺវិជ្ជាខ្ពង់ខ្ពស់រិតតែធ្វើឱ្យ កិលេសចម្រើន ព្រោះគេចេះប្រើល្បិចច្នៃប្រឌិត

នូវអារម្មណ៍ឱ្យវិចិត្រ ធ្វើឱ្យមនុស្សពេញចិត្ត ត្រេកត្រអាលនៅក្នុងកាមារម្មណ៍ ពុំបានដោះស្រាយនូវអ្វីនោះធ្វើឱ្យមនុស្សនឿយណាយធុញទ្រាន់ចាកលោក ។

◈ ការអប់រំចិត្តបានន័យថា ធ្វើលំនៅឋានសម្រាប់ចិត្តជ្រកសំដៅលើការកសាងមហាកុសលទាំងឡាយមានកុសលថ្នាក់ទាន កុសលថ្នាក់សីល កុសលថ្នាក់សមថៈ និងបញ្ញារបស់មហាកុសល ៨ ដួងណាមួយក្នុងចិត្ត ៨៩ ឬ ១២១ ដួងដោយពិស្តារ ដើម្បីកម្ចាត់បង់នូវអកុសលនីវរណៈមានអកុសលចិត្តទាំង ១២ ដួងគឺលោភមូល ៨ ទោសមូល ២ មោហមូល ២ ជាមេកិលេសឱ្យជ្រុះរបូតចេញពីក្នុងចិត្ត ដូចដែលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សម្តែងនៅក្នុងឱវាទបាដិមោក្ខរបស់គោលព្រះពុទ្ធសាសនា សំខាន់ ៣ យ៉ាង :

១-**សព្វបាបស្ស អករណំ** ហាមមិនឱ្យធ្វើនូវអំពើបាបទាំងពួង

២-**កុសលស្សូបសម្បទា** កសាងសន្សំកុសលធម៌រឿយៗ

៣-**សចិត្តបរិយោទបនំ** ត្រូវសំអាតចិត្តឱ្យស្អាតផូរផង់

**ឯតំ ពុទ្ធានសាសនំ** ទាំងបីនេះជាពាក្យប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធទាំងឡាយគ្រប់ៗព្រះអង្គ គឺធម្មៈ ។

◈ ការអប់រំចិត្ត គឺការដុសខាត់ចិត្តបន្តិចម្តងៗ ជានិច្ចកាល មិនថាពេលសម្រាក ឬ ដេក ដើរ ឈរ អង្គុយ យ៉ាងណាទេ ទោះបីកំពុងបន្ទោបង់ ឧច្ចារៈ បស្សាវៈ ឬ កំពុងទទួលទានអាហារ យ៉ាងណាត្រូវមានស្មារតីភ្ញាក់ នឹករលឹក នូវសភាវធម៌កំពុងប្រាកដតាំងនៅក្នុងកម្មដ្ឋានកុំឱ្យចិត្តប្រែប្រួល ខុសពីពាក្យប្រៀនប្រដៅរបស់ ព្រះពុទ្ធអង្គ ។

◈ ការអប់រំចិត្តជាការហ្វឹកហាត់ចិត្តដោយមហាកុសលចិត្ត តម្រង់ចិត្តឱ្យដើរផ្លូវត្រឹមត្រូវល្អ វៀរចាកដាច់ខាតពីផ្លូវអាក្រក់ ដូចមានព្រះគាថា ទ្រង់ត្រាស់នៅក្នុង ខុទ្ទកនិកាយធម្មបទព្រះគាថាបិដកលេខ ៥២/៣៨ ថា ៖

**ឧទកញ្ហិ នយន្តិ នេត្តិកា**

**ឧសុការា នមយន្តិ តេជនំ**

**ទារុំ នមយន្តិ តច្ឆកា**

**អត្តានំ ទមយន្តិ បណ្ឌិតា ។**

**ប្រែ** ធម្មតា អ្នកបង្ហូរទឹក តែងបង្ហូរទឹកទៅ អ្នកធ្វើព្រួញតែងពត់ព្រួញឱ្យត្រង់ អ្នកចាំងឈើតែងចាំងឈើ ឯបណ្ឌិតទាំងឡាយតែងទូន្មានខ្លួនដូច្នោះដែរ ។

◈ ការអប់រំចិត្ត គឺកសាងសុភមង្គលយ៉ាងល្អឯកលើលោកដែលពុំមានការអប់រំណាដូចព្រះសម្ពុទ្ធបំផុតលោកឡើយ ព្រោះលោកនេះមិនមែនថា គ្មានអ្នកចេះដឹងដឹកនាំឱ្យមានការអប់រំទូន្មានចិត្តទេ តែការអប់រំនោះ ជាការអប់រំតាមទ្រឹស្តីរបស់អ្នកប្រាជ្ញក្នុងលោកជាប់ជំពាក់ដោយកិលេសដែលមិនទាន់បានទៅជាការល្អប្រសើរដូចព្រះពុទ្ធអង្គឆ្លងផុតលោកមិននៅក្នុងលោក ព្រោះទ្រង់សម្តែងប្រាប់នូវអ្វីៗសុទ្ធតែទ្រង់ជ្រាបច្បាស់ដោយព្រះសព្វញ្ញុតញ្ញាណ គ្មាននរណាម្នាក់ប្រៀបផ្ទឹម ព្រះអង្គសូម្បីពួកព្រហ្ម ក៏ចុះមកអារាធនា សូមយាងព្រះអង្គទ្រង់ប្រោសប្រទានធម្មទេសនាដែរ ។

◈ការអប់រំចិត្តជាការសន្សំសេចក្តីល្អយកមកទុកក្នុងខ្លួន សំខាន់គឺ សុចរិតកម្ម ៣ ( កាយកម្ម វចីកម្ម មនោកម្ម) ក្នុងកុសលកម្មបថ ១០ ដូចជាលោកគ្រូអ្នកគ្រូត្រូវមានធម៌ ៥ យ៉ាងដល់សិស្ស សិស្សក៏ត្រូវគោរពដោយធម៌ ៥ យ៉ាងដល់លោកគ្រូ មាតាបិតា មានធម៌ ៥ យ៉ាងដល់កូនប្រុសស្រី កូនប្រុសស្រីក៏ត្រូវគោរពគុណដោយធម៌ ៥ យ៉ាងសង្គ្រោះគ្នាទៅវិញទៅមក ភរិយាស្វាមីក៏មានធម៌ ៥៧ សង្គ្រោះគ្នាទៅវិញដូចគ្នាព្រោះដើម្បីសេចក្តីសុខតែម្យ៉ាងប៉ុណ្ណោះដោយលោកនេះជាជម្រកនៃសេចក្តីទុក្ខស្រាប់ហើយ ប្រសិនបើយើងមិនខំស្វែងរកសេចក្តីសុខ គឺ ទីពឹង

ព្រះធម៌ **តើអ្នកណាឱ្យសុខយើងដែលសុខផ្លូវចិត្តនោះប្រសើរ លើសជាង សេចក្តីសុខអ្វីទាំងអស់ក្នុងលោក** ។ មិនមែនថា ទ្រព្យសម្បត្តិមិនជ ប្រយោជន៍ដល់សេចក្តីសុខរបស់យើងទេ វាឱ្យសុខនៅក្នុងបច្ចុប្បន្ននេះ ពិតមែន តែបើខ្វះបញ្ញា ទ្រព្យសម្បត្តិទាំងនោះប្រែក្លាយ ទៅជារបស់ មានពិសពុលសម្រាប់ដុតខ្លួនឯងទៅវិញ ដូចដើមចេកមានផ្លែ ដើមឫស្ស មានផ្លែសម្លាប់ដើមដូចគ្នា **សក្ការោ កាបុរិសំ ហន្តិ** ។

◈ ការអប់រំចិត្ត គឺការកសាងបញ្ញាដែលមានសម្មាសង្កប្បៈ ជ តួយោនិសោមនសិការៈ និង សតិជាប្រធានសម្រាប់ ប្រតិបត្តិ ដើម្បីរំលះ កិលេសចេញពីខន្ធសន្តានជ្រៅជ្រះ ដោយបញ្ញាថ្នាក់ទានក្តី ថ្នាក់សីលក្ ថ្នាក់សមថក្តី សំខាន់បញ្ញាថ្នាក់សតិប្បដ្ឋានជាបុព្វភាគនៃអរិយមគ្គអង្គ ៨ ត្រាស់ដឹង ដោយព្រះសម្ពុទ្ធទើបបញ្ញានោះ រំលត់កិលេសបាន ឯបញ្ញាដទៃ គ្រាន់តែ ជាជំនួយឧបការៈដល់បញ្ញាថ្នាក់សតិបដ្ឋាន ៤ ប៉ុណ្ណោះ ។ បញ្ញាកើត មកពី វុឌ្ឍិធម៌ ៤ ប្រការៈ ១-សេពគប់សប្បុរស ២-ស្តាប់ធម៌សប្បុរស ៣- មានយោនិសោមនសិការៈ ៤-ធម្មានុធម្មប្បដិបត្តិ គឺបដិបត្តិដល់ធម៌ ដ៏សមគួរតាមធម៌ដោយសតិប្បដ្ឋាន ៤ នេះឯង ។

ចំពោះយោនិសោមនសិការៈ ជាអង្គធម៌សំខាន់ដើរតួជាអ្នកជួយផ្សះ ផ្សារបង្រួបបង្រួមរវាងសត្រូវគឺ អារម្មណ៍ទាំងឡាយជាអនិដ្ឋារម្មណ៍ឱ្

ប្រែមកជាឥដ្ឋារម្មណ៍របស់ចិត្តល្អ (កុសល) ព្រោះយោនិសោមនសិការៈ មានការពិចារណាដោយវិធី ១០ យ៉ាង (ស្រង់ចាកព្រះធម្មបិដក មាតិកា ៦៧៦...៧០៨ ក្នុងបទទី ១៨) ។

១-វិធីគិតពិចារណា តាមបែបការស្រាវជ្រាវរាវរកហេតុរកបច្ច័យ

២-វិធីគិតពិចារណា តាមបែបការរំលែកចែកបំបែកការប្រជុំរួម

៣-វិធីគិតពិចារណា តាមបែបត្រៃលក្ខណ៍

៤-វិធីគិតពិចារណា តាមបែបអរិយសច្ចៈ

៥-វិធីគិតពិចារណា តាមបែបអត្ថធម៌សម្ព័ន្ធ (គោលការណ៍ និងទិសដៅ)

៦-វិធីគិតពិចារណា តាមបែបការឃើញគុណទោស និងការរលាស់ចោល (បែបអស្សាទៈ អាទីនវៈនិងនិស្សរណៈ)

៧-វិធីគិតពិចារណា តាមបែបដឹងនូវរបស់ពិត និងរបស់ក្លែងក្លាយ

៨-វិធីគិតពិចារណា តាមបែបញុំាងនូវគុណធម៌ឱ្យចម្រើន (កុសលភាវនា)

៩-វិធីគិតពិចារណា តាមបែបរស់នៅជាមួយនឹងបច្ចុប្បន្ន

១០-វិធីគិតពិចារណា តាមបែបការចែកធម៌ ។

យោនិសោមនសិការៈ មិនមែនជាតួបញ្ញាទេ តែជាបច្ច័យ ឬ ឧបាយ ឱ្យកើតបញ្ញា គឺ ឱ្យកើតសម្មាទិដ្ឋិ ដូចក្នុងគម្ពីរ **មិលិន្ទបញ្ហា** សម្តែង សេចក្តីផ្សេងរវាងយោនិសោមនសិការៈ ជាមួយបញ្ញាថា : **ប្រការទី១** សត្វតិរច្ឆានទាំងឡាយដូចជា ពពែ សេះ គោ ក្របី អូដ្ឋ ល មានមនសិការៈ (មនសិការៈ មិនមានយោនិសោ គឺមិនមានបញ្ញា) ។

**ប្រការទី ២ :** មនសិការមានលក្ខណៈ គិតពិចារណា ចំណែកបញ្ញា មានលក្ខណៈ លះកាត់ ។ មនសិការៈ រួមជាមួយការគិតធ្វើឱ្យបញ្ញាកម្ចាត់ កិលេសបាន ។

**រូបស័ព្ទ:**ពាក្យថាយោនិសោមនសិការៈ កើតពីពាក្យ យោនិសោ ។ យោនិសោ មកពីពាក្យ " **យោនិ** " ប្រែថា : ហេតុ, តណ្ហា នាំឱ្យកើត បញ្ញា ឧបាយវិធី ។ ចំណែកមនសិការៈ ប្រែថា : ការធ្វើទុកក្នុងចិត្ត ការគិតពិចារណា នឹងដល់ដាក់ចិត្ត ។

### ◈ *លក្ខណៈសម្គាល់នូវប្រយោជន៍ធម៌ :*

ការអប់រំចិត្តត្រូវឱ្យស្គាល់ធម៌ណាជាសត្រូវ ធម៌ណាជាមិត្ត ធម៌ណា មានឧបការៈច្រើន ធម៌ណាគួរចម្រើន ធម៌ណាគួរកំណត់ដឹង ធម៌ណាគួរ លះបង់ ធម៌ណាជាចំណែកនៃសេចក្តីវិនាស ធម៌ណាជាចំណែកវិសេស ធម៌ណាត្រាស់ដឹងបានដោយកម្រ ធម៌ណាគួរឱ្យកើតឡើង ធម៌ណាគួរដឹង

ច្បាស់ ធម៌ណាគួរធ្វើឱ្យជាក់ច្បាស់ដែលសម្ដែងនៅក្នុងទីឃនិកាយ បាដិកវគ្គ ឆដ្ឋភាគ ទសុត្តរសូត្រ បិដកលេខ ១៩/២៩៥ មានជាអាទិថា :

**១-ធម៌មានឧបការៈច្រើន** បានដល់ អប្បមាទោ សេចក្ដីមិនប្រមាទក្នុងធម៌ទាំងឡាយជាកុសល ១ សតិ១ សម្បជញ្ញៈ ១ (ការរលឹកដឹងខ្លួន)១ សប្បុរិសូបសំសេវោ (ការសេពគប់នឹងសប្បុរស) ១ សទ្ធម្មស្សវនំ (ការស្ដាប់ធម៌របស់សប្បុរស)១ ធម្មានុធម្មប្បដិបត្តិ (ការបដិបត្តិធម៌ សមគួរ ដល់ធម៌)១ ការនៅក្នុងប្រទេសដ៏សមគួរ១ ការតាំងខ្លួនប្រពៃ១ ភាពជាអ្នកបានធ្វើបុណ្យទុកក្នុងកាលមុន១ អង្គនៃសេចក្ដីព្យាយាម ៥ប្រការ ។ សារាណីយធម៌ ៦ អរិយទ្រព្យ ៧ យោនិសោមនសិការៈមានឫសគល់ ៩ យ៉ាង គឺការធ្វើទុកដោយ ឧបាយនៃប្រាជ្ញានាំឱ្យមានសេចក្ដីត្រេកអរទន់ (បាមោជ្ជ) ក៏កើតឡើង ១ សេចក្ដីឆ្អែតចិត្ត (បីតិ) ក៏កើតឡើង១ កាយស្ងប់រម្ងាប់១ សេចក្ដីសុខ១ ចិត្តតាំងនៅមាំ១ បានឃើញជាក់ច្បាស់ តាមសភាវៈពិត១ ចិត្តនឿយណាយដោយខ្លួនឯង ១ ប្រាសចាកតម្រេកុតស្រឡះ ១ ។ នាថករណធម៌ ១០ ។

**២-ធម៌គួរចម្រើន** បានដល់ កាយគតាសតិ១ សមថៈ១ វិបស្សនា១ សមាធិ ៣ យ៉ាង គឺ សមាធិដែលមានវិតក្កៈទាំងវិចារៈ១ សមាធិដែលគ្មាន

វិតក្កៈ មានវិចារៈ១ សមាធិដែលគ្មានវិតក្កៈ គ្មានទាំងវិចារៈ១ ។ សតិប្បដ្ឋាន៤ ការតាំងចិត្តប្រពៃប្រកបដោយអង្គ៥ គឺការផ្សាយទៅនៃបីតិ១ សេចក្តីសុខ១ ចិត្ត១ ពន្លឺ១ និមិត្តនៃការពិចារណា១ ។ អនុស្សតិដ្ឋាន (ហេតុជាទីតាំងនៃ សេចក្តីរលឹករឿយៗ) ៦ យ៉ាង ការរលឹកដល់ព្រះពុទ្ធ១ ព្រះធម៌១ ព្រះសង្ឃ១ គុណនៃសីល១ ទានដែលបាន បរិច្ចាគ១ ធម៌ទេវតា ១ សម្ពោជ្ឈង្គធម៌៧ ប្រការ អរិយមគ្គប្រកបដោយអង្គ ៨ ប្រការ អង្គនៃសេចក្តីព្យាយាម ដើម្បីសេចក្តីបរិសុទ្ធ ៩ យ៉ាងគឺ សីលវិសុទ្ធិ១ ទិដ្ឋិវិសុទ្ធិ១ កង្ខាវិតរណវិសុទ្ធិ១ មគ្គាមគ្គញ្ញាណទស្សនវិសុទ្ធិ១ បដិបទាញាណ ទស្សនវិសុទ្ធិ១ ញាណទស្សនវិសុទ្ធិ១ បញ្ញាវិសុទ្ធិ១ និងវិមុត្តិវិសុទ្ធិ ១ ។

**៣-ធម៌ដែលគួរកំណត់ចាំ** បានដល់ ផស្សៈ១ នាម១ រូប១ វេទនា ៣ ប្រការ ១ អាហារ ៤ យ៉ាង ១ ឧបាទានក្ខន្ធប្រាំ១ អាយតនៈខាងក្នុង៦ វិញ្ញាណដ្ឋិតិ ៧ លោកធម៌៨ សត្តាវាសៈ៩ អាយតនៈ១០ ។

**៤-ធម៌ដែលគួរលះបង់** បានដល់ អស្មិមានៈ (សេចក្តីប្រកាន់) តណ្ហា ៣ ប្រការ, អន្លង់៤, នីវរណៈ៥, តណ្ហា៦, អនុស័យ៧, សភាពដែលខុស៨ យ៉ាង គឺ ការឃើញខុស១ ត្រិះរិះខុស១ ពោលពាក្យខុស១ ធ្វើការងារ ខុស១ ចិញ្ចឹមជីវិតខុស១ ព្យាយាមខុស១

ការរលឹកខុស១ ការតាំងចិត្ត ខុស១ ។ ធម៌ដែលមានតណ្ហាជាឫសគល់ ៩ យ៉ាង : ការអាស្រ័យតណ្ហា ទើបមានការស្វែងរក១ កើតលាភ១ កើតសេចក្ដីត្រិះរិះ១ សេចក្ដីប្រាថ្នា សេចក្ដីត្រេកអរ១ កើតការជឿស៊ប់១ ទើបកើតការហួងហែងទុក១ ទើប កើតសេចក្ដីកំណាញ់១ កើតការរក្សាទុក១ ទើបអកុសលធម៌ទាំងឡាយ ដ៏លាមកជាច្រើន គឺការកាន់ដំបង់កាន់គ្រឿងសស្ត្រាវុធ ឈ្លោះទាស់ទែង ជជែកគ្នាឯងទាំងនិយាយញុះញង់ និយាយកុហកប្រព្រឹត្តទៅ១។ សភាព ដែលខុស១០ (៨+២) គឺថែមការដឹងខុស១ ការរួចខុស១ ។

**៥-ធម៌ជាចំណែកនៃសេចក្ដីវិនាស** បានដល់អកុសលកម្ម ១០យ៉ាង អាឃាតវត្ថុ (ហេតុនៃការចងគំនុំ) ៩ យ៉ាង កុសីតវត្ថុ (ហេតុនៃបុគ្គលខ្ជិល) ៨យ៉ាង អសទ្ធម្ម (ធម៌របស់អសប្បុរស) ៧យ៉ាង គឺ គ្មានសទ្ធា១ មិនខ្មាសបាប១ មិនខ្លាចបាប១ចេះដឹងតិច១ ខ្ជិលច្រអូស១ ភ្លេចស្មារតី១ ឥតប្រាជ្ញា១ ។ សេចក្ដីមិនគោរព ៦យ៉ាងបានដល់ការមិនគោរពដល់ព្រះសាស្ដា មិនគោរពដល់ព្រះធម៌ ១ មិនគោរពដល់ព្រះសង្ឃ ១ មិនគោរពសិក្ខា ១ មិនគោរពដល់អប្បមាទធម៌ ១ មិនគោរពដល់ការបដិសណ្ឋារៈ ១ ។ សេចក្ដីរឹងត្អឹងនៃចិត្ត ៥ យ៉ាងបានដល់ មិនជ្រះថ្លាក្នុងព្រះសាស្ដា១ មិនជ្រះថ្លាក្នុងព្រះធម៌ ១ មិនជ្រះថ្លាក្នុង

ព្រះសង្ឃ ១ សង្ស័យក្នុងសិក្ខា ១ មានចិត្តចងគំនុំចំពោះសព្រហ្មចារី ១ យោគៈ ៤យ៉ាង (គ្រឿងប្រកប) អកុសលមូល ៣យ៉ាង (ភាពជាអ្នកអាក្រក់) និង អយោនិសោមនសិការៈ ។

**៦-ធម៌ជាទីណែកវិសេស** បានដល់ យោនិសោមនសិការៈ សោវចស្សតា (ភាវៈដែលគេប្រដៅបានដោយងាយ) កល្យាណមិត្តតា (ភាវៈជាអ្នកគប់មិត្តល្អ) កុសលមូល ៣ប្រការ វិសំយោគោ (ប្រាសចាកគ្រឿងប្រកប៤) ឥន្ទ្រិយ៥ (ធម្មជាតិដែលជាធំ) ព្រះសទ្ធម្ម (ធម៌របស់សប្បុរស) ៧យ៉ាង បានដល់ សទ្ធា១ ហិរិ១ ឱត្តប្បៈ១ ពហុស្សុតា១ (ចេះដឹងច្រើន) អារទ្ធវិរិយោ១ (មានព្យាយាម) ឧបដ្ឋិតស្សតិ១ (ស្មារតីតម្កល់ខ្ជាប់) បញ្ញា១ ។ អារព្ភវត្ថុ (ហេតុនៃការប្រារព្ធសេចក្តីព្យាយាម) ៨យ៉ាង អាឃាតប្បដិវិន័យ (ហេតុសម្រាប់កំចាត់បង់គំនុំ) ៩យ៉ាង គន្លងនៃកុសលកម្មបថ១០ ។

**៧-ធម៌ដែលត្រាស់ដឹងបានដោយក្រ** បានដល់ ធម៌នៅអាស្រ័យ និង ព្រះអរិយ ១០យ៉ាង ខណៈមិនគួរ និង សម័យមិនគួរមាន៨យ៉ាង សប្បុរិសធម៌ ៧យ៉ាង បានដល់ធម្មញ្ញូ១ (ដឹងធម៌) អត្ថញ្ញូ១ (ដឹងអត្ថ) អត្តញ្ញូ១ (ដឹងខ្លួន) មត្តញ្ញូ១ (ដឹងប្រមាណ) កាលញ្ញូ១ (ដឹងកាល) បរិសញ្ញូ១ (ដឹងបរិស័ទ) បុគ្គលបរោបញ្ញូ១ (ដឹងបុគ្គលដែល

គួរសេពគប់) ។ សមាធិ៤ គឺសមាធិដែលជាចំណែកនៃសេចក្តីវិនាស១ សមាធិដែលជាចំណែកនៃការឋិតថេរ១ សមាធិជាចំណែកវិសេស១ សមាធិដែលជាចំណែកនៃការទម្លាយនូវកិលេស១ ។ និស្សារណិយធាតុ (ធាតុដែលគួររលាស់ចេញ) ៣ប្រការ គឺ នេក្ខម្ម អរូបជ្ឈន និរោធ ។ ហេតុនឹងបច្ច័យអនន្តរិកចេតោសមាធិ (សមាធិជាលំដាប់នៃវិបស្សនា) ។

**៤-ធម៌ដែលគួរឱ្យកើតឡើង** បានដល់ ញាណដែលមិនកម្រើក គឺ បច្ចវេក្ខណបញ្ញា ខយេ ញាណំ (ការដឹងក្នុងរបស់អស់ទៅ) អនុប្បាទេ ញាណំ (ការដឹងក្នុងរបស់មិនទាន់កើតឡើង) ញាណបី (អតីត អនាគត បច្ចុប្បន្ន) ញាណ ៤ គឺធម្មជាតិដឹងក្នុងធម៌១ ដឹងក្នុងការយល់១ ដឹងក្នុងការកំណត់១ ដឹងក្នុងការសម្មតិ១ ។ ប្រាជ្ញាដឹងខុសក្នុងបច្ចុប្បន្ន សមាធិមិនប្រកបដោយអាមិសៈ សមាធិដោយសង្ខារ ដឹងក្នុងការចូលនឹងការចេញសមាធិ ។ សតតវិហារធម៌ (ធម៌ជាគ្រឿងនៅមិនដាច់នៃព្រះខីណាស្រព) ៦ យ៉ាង គឺរូប សំឡេង ក្លិន រស ផោដ្ឋព្វៈ និងធម្មារម្មណ៍ ជាអ្នកមិនមាន សោមនស្សទោមនស្ស ព្រងើយកន្តើយ ប្រកបដោយស្មារតី និង បញ្ញា ។ សេចក្តីត្រិះរិះរបស់មហាបុរស ៨យ៉ាង គឺ សេចក្តីប្រាថ្នាតិច សន្តោស មានសេចក្តីស្ងប់ស្ងាត់ មិនត្រេកអរក្នុងពួកក្រុម សេចក្តីព្យាយាម មានស្មារតីខ្ជាប់ខ្ជួនមានចិត្តតាំងមាំ មានបញ្ញា ។

សេចក្ដីសម្គាល់ ៩ យ៉ាង គឺ សម្គាល់ថាមិនល្អ១ សម្គាល់ដោយមរណានុបស្សនាញាណ១ សម្គាល់ក្នុងអាហារ ថា ជារបស់គួរខ្ពើម១ សម្គាល់ថាមិនគួរត្រេកអរក្នុងលោកទាំងពួង១ សម្គាល់ថាមិនទៀង១ សម្គាល់ថាជាទុក្ខ១ សម្គាល់ថាមិនមែនខ្លួន១ សម្គាល់នូវរបស់ដែលត្រូវលះបង់១ សម្គាល់ថាគួរនឿយណាយ១ និង សម្គាល់ថា រលត់ទៅនៃទុក្ខទាំងពួង១ ។

**៩-ធម៌ដែលគួរដឹងច្បាស់** បានដល់ ហេតុនៃសេចក្ដីសាបសូន្យ ១០ យ៉ាង អភិភាយតនៈ ៨យ៉ាង និទ្ទសវត្ថុ៧ អនុត្តរិយៈ (ធម្មជាតិប្រសើរ) ៦ យ៉ាងគឺ ឃើញប្រសើរ១ ស្ដាប់ប្រសើរ១ បានប្រសើរ១ សិក្សាប្រសើរ១ បម្រើប្រសើរ១ ការរលឹកប្រសើរ១ ។ វិមុត្តាយតនៈ (ហេតុជាគ្រឿងរួចស្រឡះ) ៥ យ៉ាង អរិយសច្ចៈ ៤ ធាតុ ៣ យ៉ាង គឺ កាមធាតុ រូបធាតុ និង អរូបធាតុ ធាតុ ២យ៉ាង គឺ ធាតុដែលមានបច្ច័យតាក់តែង និងធាតុដែល គ្មានបច្ច័យតាក់តែង ។ **សព្វេ សត្តា អាហារដ្ឋិតិកា** (ពួកសត្វ ទាំងឡាយ រស់បានដោយសារអាហារ) ។

**១០-ធម៌ដែលគួរធ្វើឱ្យជាក់ច្បាស់**បានដល់ អកុប្បាចេតោវិមុត្តិ (អរហត្តផល) វិជ្ជា និង វិមុត្តិ វិជ្ជា៣ គឺ **បុព្វេនិវាសានុស្សតិញ្ញាណ ចុតូបបាតញ្ញាណ, អាសវក្ខយញ្ញាណ** ។ សាមញ្ញផល ៤ គឺ សោតាបត្តិ

ផល សកទាគាមិផល អនាគាមិផល អរហត្តផល ។ ធម្មក្ខន្ធ ៥ គឺ សីលក្ខន្ធ សមាធិខន្ធ បញ្ញាខន្ធ វិមុត្តិខន្ធ វិមុត្តិញាណទស្សនក្ខន្ធ ។ អភិញ្ញា៦ **ឥទ្ធិវិធ ១ (ឫទ្ធិ) ត្រចៀកទិព្វ ១ ចេតោ បរិច្ច ជានាតិ ១** (កំណត់ដឹងចិត្តអ្នកដ៏ទៃបាន) **បុព្វេនិវាសានុស្សតិ** ១ (រលឹកជាតិបាន) **ទិព្វចក្ខុ** ១ **អាសវានំ ខយេ** ឬ **អាសវក្ខយវិជ្ជា** (ធ្វើឱ្យអស់អាសវៈ) ១ ។ កម្លាំងរបស់ព្រះខីណាស្រពទាំង ៧ វិមោក្ខ៨ ប្រការ (ចូរមើលក្នុង មហានិទានសូត្រ ទីឃនិកាយមហាវគ្គ) ។ អនុបុព្វនិរោធ (ធម៌ជាគ្រឿង រលត់តាមលំដាប់ ៩យ៉ាង ធម៌ជា របស់អសេក្ខ ១០យ៉ាង គឺ សម្មាទិដ្ឋិជា របស់អសេក្ខ សម្មាសង្កប្ប សម្មាវាចា រហូតសម្មាញាណ និង សម្មាវិមុត្តិ របស់អសេក្ខ) ។

◊ ការអប់រំចិត្តប្រព្រឹត្តទៅចាប់តាំងពីនៅវ័យក្មេងដឹងក្តីរហូតដល់ វ័យចាស់ស្លាប់ ព្រោះមានអ្នកខ្លះយល់ថា ចាស់ហើយមិនចំបាច់រៀនសូត្រ អ្វីទេ ។

បើខ្វះការអប់រំចិត្ត មនុស្សយើងនឹងប្រែក្លាយទៅជាចិត្តមិនល្អ ពិត មែនតែរូបរាងជាមនុស្សតែចិត្តមិនមែនជាមនុស្ស ព្រោះមនុស្សត្រូវមាន សញ្ញាប័ត្រមនុស្សគឺសីល ៥ ប្រកបដោយគុណសម្បត្តិដទៃទៀត ដូចជា **សទ្ធា សីល សតិ ហិរិ ឧត្តប្បៈ ចាគៈ និង បញ្ញា ។** ការសន្សំបុណ្យដោយ

កុសលថ្នាក់ទាន កុសលថ្នាក់សីល កុសលថ្នាក់សមថៈ មានអំណាចត្រឹម សោយសុខនៅក្នុងលោក លុះត្រាថែមកុសលថ្នាក់សតិប្បដ្ឋាន ទើប បានដល់ព្រះនិញ្វនព្រោះកាមាវចរមហាកុសល ៨ ជាកុសលថ្នាក់ សតិប្បដ្ឋានឧបការៈដល់ មហគ្គតកុសលនិងលោកុត្តរកុសល រហូតដល់ អរហត្តផលទើបលែងប្រើប្រាស់ហៅថា សោឡសកិច្ច គឺ កិច្ចទាំង ១៦ បានចប់សព្វគ្រប់បរិបូណ៌។ ចំណែកចិត្តដទៃ ដូចជាវិបាកជា ផលបានមកពី កុសលនិងអកុសល ឯកិរិយាជាតិសម្រាប់ព្រះខីណាស្រពប៉ុណ្ណោះ មិនមែន ជាចិត្តត្រូវអប់រំទេតែងកើតឡើង អាស្រ័យពី មហាកុសលដែលជាផលកើត ឡើងពីហេតុប្បច្ច័យ ។

មើលលោកនេះ ឆ្លុះបញ្ចាំង ក្នុងសង្គម

ចេះគួរសម ព្រោះសីលធម៌ មិនគួរភ្ញាក់

ជួបសុខទុក្ខ ស្រឡាញ់ស្អប់ ទាញកន្ត្រាក់

ឱ្យញ័ររញ្ជាក់ ដោយលោភៈ ស្រវឹងងុប ។

សេចក្តីប្រកាន់នាំឱ្យមានទុក្ខកង្វល់ ។

# អធ្យាស្រ័យធាតុ

**មើលលោកនេះដោយភាពសាមគ្គី** តើមនុស្សរួមរស់នៅជាមួយគ្នាព្រោះអាស្រ័យពីអ្វី?

◈ការអប់រំចិត្ត ត្រូវដឹងនូវអធ្យាស្រ័យរបស់ធាតុនីមួយៗ ថាតើមនុស្សយើងមានធាតុចិត្តដូចម្ដេចខ្លះ ព្រោះបើអធ្យាស្រ័យដូចគ្នា អាចរស់នៅជាមួយគ្នាបាន ប្រសិនបើអធ្យាស្រ័យមិនដូចគ្នា ការរស់នៅជាមួយគ្នាមិនបានសុខយ៉ាងណា ព្រះមានព្រះភាគទ្រង់ត្រាស់សម្ដែងនៅក្នុងសំយុត្តនិកាយនិទានវគ្គបិដកលេខ ៣២/៣៩ ថា :

ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយត្រូវគ្នា សមគ្នា ដោយធាតុ គឺពួកជនមិនមានសទ្ធាត្រូវគ្នាសមគ្នាជាមួយនឹងពួកជនមិនមានសទ្ធា ពួកជនមិនខ្មាសបាបខ្លាចបាបត្រូវគ្នានិងពួកជនមិនខ្មាសបាបខ្លាចបាប ពួកជនខ្ជិលច្រអូសមិនចេះមិនដឹង វង្វេងស្មារតី មិនមានបញ្ញា ត្រូវគ្នា សមគ្នាជាមួយពួកជនទាំងនោះ ។ សេចក្ដីនេះបង្ហាញប្រាប់ពីការរស់នៅជាមួយគូស្វាមីភរិយាអស់មួយជីវិតដែលត្រូវរើសគូស្រករយកមកធ្វើជាមនុស្សរស់នៅក្នុងគ្រួសារសម្រាប់បន្តវង្សត្រកូល ត្រូវគិតពិចារណាឱ្យបានល្អិតល្អន់ហ្មត់ចត់កុំចេះតែព្រមល្មមទៅតាមការអង្វរអង្វែងដោយកម្លាំង

តណ្ហាដឹកនាំខ្លាំងពេក គួរទប់ស្មារតីខ្លះៗ នៅពេលដែលឃើញ សម្រស់រូបរាងកាយសល្អឆើត។ នៅក្នុងខុទ្ទកនិកាយជាតកទសមភាគអសីតិនិបាតកុណាលជាតកបិដកលេខ ៦១/១៧៥ ព្រះសមាសម្ពុទ្ធទ្រង់ត្រាស់ថា : បុរសមិនត្រូវទៅសេពគប់ចំពោះស្ត្រី ៥ ជំពូក :

១- ពួកស្ត្រីមានពណ៌សម្បុរល្អ លើសលុបពេក

២- ស្ត្រីជាទីស្រឡាញ់ពេញចិត្តរបស់ពួកជនច្រើន

៣- ស្ត្រីឆ្លៀវឆ្លាសក្នុងការរាំ និង ច្រៀង

៤- ស្ត្រីមានស្វាមី ( ប្រពន្ធ) ហួងហែងថែរក្សា

៥- ព្រោះហេតុនៃទ្រព្យ ។

ព្រោះមនុស្សខ្លះល្អមែនពីខាងក្រៅ តែចិត្តខាងក្នុងមិនល្អហៅថា មនុស្សមានចិត្តអាក្រក់ ស្មើគ្នានឹង **មនុស្សតិរច្ឆានោ** មនុស្ស **នេរយិកោ** **មនុស្សបេតោ** ។ មនុស្សខ្លះទៀតមើលរូបរាងពីខាងក្រៅមិនសូវល្អស្រស់ទេ តែចិត្តខាងក្នុងល្អ ហៅថា **មនុស្សទេវោ** ឬ **មនុស្សមនុស្សោ** ដែលពួកជនទាំងឡាយគេរាប់អានស្រឡាញ់ចូលចិត្ត ។ ដូច្នោះកិច្ចការនេះត្រូវទុកភារៈឱ្យសាមីខ្លួនរបស់គេជ្រើសរើសគូជាមុន ដើម្បីសម្រួលតាមអធ្យាស្រ័យធាតុ បន្ទាប់មកទើបមាតាបិតាជួយរៀបចំផ្សំផ្គុំជាក្រោយ ប្រសិនបើពិនិត្យទៅឃើញថាល្អ ក៏គួររៀបចំទុកដាក់តាមប្រពៃណីជាតិ

តែបើមិនល្អក៏គួរហាមកូនកុំឱ្យរៀបអាពាហ៍ពិពាហ៍ កាលបើហាមឃាត់មិនស្តាប់ត្រូវបណ្តោយតាមរឿងនោះចុះ ។ ការមានគូស្វាមីភរិយា ជាសុភមង្គលមួយ សម្រាប់កូនប្រុសស្រី ដែលមិនអាចហាមឃាត់យ៉ាំងកូនព្រោះទំនាស់ នឹងច្បាប់ប្រទេសជាតិព្រមទាំងច្បាប់ធម្មជាតិទៀតនៅពេលណាកូនប្រុសស្រីដល់វ័យកំលោះក្រមុំហើយ ប្រសិនបើកូនប្រុសស្រីនោះមិនព្រមចង់មានស្វាមីភរិយា ម៉ែឪក៏មិនត្រូវ បង្ខិតបង្ខំចិត្តឡើយ ។ ការរស់នៅជាមួយគ្នាស្រឡាញ់គ្នាណាស់មុនដំបូង តែកុំភ្លេចថាថ្ងៃណាមួយនឹងត្រូវបែកបាក់គ្នាទៅវិញ ប៉ុន្តែបើរស់នៅជាមួយគ្នា រហូតដល់ចាស់រឹតតែល្អណាស់ ព្រោះការព្រាត់ប្រាសនោះក៏មិនមែនយើងចង់បែកបាក់ នេះជាធម្មជាតិមិនទៀងបើចង់កុំឱ្យព្រាត់លុះត្រាតែកុំឱ្យជួប ។ ការជួបជុំគ្នារវាងប្តីប្រពន្ធមិនសុទ្ធតែបានសុខរហូត សំខាន់ត្រូវមានធម៌ប្រាំ៧ សង្គ្រោះគ្នាដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែង ។ ពេលណាសេចក្តីស្រឡាញ់រលត់អស់ទៅ សេចក្តីស្អប់ជាទុក្ខសោកនឹងមកជំនួសយ៉ាងប្រាកដដល់បុរសស្ត្រី ម៉្លោះហើយត្រូវមានមេត្តាចិត្តអាណិតអាសូរគ្នាកុំខានឱ្យសោះមកដូរវេនសេចក្តីស្រឡាញ់ នេះជាសុភមង្គលមួយក្នុងជីវិតមិនទៀង ដែលទាក់ទងតាំងពីធាតុអធ្យាស្រ័យពីធម៌៥៧ និង

បញ្ញាមួយទៀតដែលឃើញទោសក្នុងបញ្ចក្ខន្ធ តែបើលើសពីនេះសេចក្តីសុខ គឺ សួស្តីទាំងឡាយរបស់សត្វមិនក្រៅអ្វីពី :

**នាញ្ញត្រ ពោជ្ឈង្គតបសា**

**នាញ្ញត្រ ឥន្ទ្រិយសំវរា**

**នាញ្ញត្រ សព្វនិស្សគ្គា**

**សោត្ថឹ បស្សាមិ បាណិនន្តិ ។**

**ប្រែ :** ព្រះតថាគតមិនឃើញសួស្តីរបស់ពួកសត្វ ក្រៅអំពីពោជ្ឈង្គ និងតបោគុណ ក្រៅពីការសង្រួមឥន្ទ្រិយ ក្រៅពីការលះបង់កិលេសទាំងអស់ទេ ដែលទ្រង់ត្រាស់នៅក្នុងសំយុត្តនិកាយ សគាថវគ្គភាគ ២៩/១៤២ នេះជាសេចក្តីសុខប្រណីតរបស់សត្វ បានមកពីការអប់រំចម្រើនសតិប្បដ្ឋាន បាននូវពោជ្ឈង្គធម៌របស់បញ្ញា ក្នុងពោធិបក្ខិយធម៌ ៣៧ ប្រការពីក្នុងចិត្តសន្តាន ។

◊ ការអប់រំចម្រើនបញ្ញាតាមផ្លូវដ៏ត្រឹមត្រូវត្រង់ (អរិយមគ្គអង្គ ៨) នេះនាំឱ្យបានសុខពិសេសជាងអ្វីៗទាំងអស់ ព្រោះមិនសូវញាប់ញ័រ និង លោកធម៌ ៨ ដែលសម្បូណ៌ទៅដោយសម្ភារប្រើប្រាស់យ៉ាងទំនើបៗ ដូចជាមានប្រាក់កាសច្រើនៗមានអគារធំល្វឹងល្វើយ មានរថយន្ត ម៉ូតូ សម្លៀកបំពាក់ ល្អស្អាតប្រកបដោយសាច់ហ្មត់ល្អរំលេចដោយម៉ូដផ្សេងៗ

គ្រឿងអលង្ការ គ្រឿងក្រអូប ម្ហូបអាហារប្រណីតនិងមានទីកន្លែងលេងសប្បាយស្រីស្អាតប្រុសស្អាត សម្រាប់កំដរបរិយាកាសកម្សាន្តនាពេលរាត្រីដែលមានឥទ្ធិពលខ្លាំងលើសលុបក្នុងលោកដោយអំណាចតណ្ហា ធ្វើឱ្យឈ្លក់វង្វេងក្នុងកាមារម្មណ៍ ដែលមានតែបញ្ញាចេតសិកមួយប៉ុណ្ណោះទើបទប់ទល់មិនញាប់ញ័រនឹងលោកធម៌ទាំងនោះបាន **សុខោ បញ្ញា បដិលាភោ** ការមាន បញ្ញាជាលាភ នាំមកនៅសេចក្តីសុខយ៉ាងក្រៃលែង ។

## សីលគុណអប់រំ

**មើលលោកនេះដោយ កម្មដ្ឋាន :**

❖ ការអប់រំ គេបន្ទុំ ចិត្តឱ្យស្អាត
ត្រូវឱយឆ្លាត លះបង់បាប ពីសន្តាន
កុំបៀតបៀន សត្វដទៃ ទាំងតិរច្ឆាន
កុំចង់បាន ទ្រព្យគេព្រួយ ដោយសារយើង ។

❖ ការអប់រំ គេបន្ទុំ វាចាស្អាត
ឱ្យឱវាទ កុំធ្វើឫក ឆ្មើងកន្ទ្រើង
និយាយពាក្យ មុសាវាទ គាស់រំលើង
ដូចដុតភ្លើង នាំឱ្យគេ ខូចទឹកចិត្ត ។

❖ ការអប់រំ　គេបន្ទំ　កាយឱ្យស្អាត
ការប្រមាទ　សម្លាប់សត្វ　កុំប្រព្រឹត្ត
ទោះរកស៊ី　ធ្វើការងារ　ទៀងត្រង់ពិត
សាងសុចរិត　លះកាមេ　លះលួចទ្រព្យ ។

❖ ការអប់រំ　ធ្វើឱ្យមនុស្ស　បានថ្លៃថ្នូរ
ត្រូវអាសូរ　លក់ជួញដូរ　កុំទម្លាប់
បំបាត់គេ　បោះបង់ចោល　ឱ្យសមស្រប
ប៊ិនប្រសប់　ប្រឹងធ្វើការ　ប្រឌិតច្នៃ ។

❖ ការអប់រំ　ជួយខ្លួនឯង　អ្នកដទៃ
កុំរំពៃ　សម្លឹងទោស　កើតចង្រៃ
សន្សំទុក　នាំសៅហ្មង　អស់តម្លៃ
តាមសម័យ　គេកែប្រែ　ល្អពេកពន់ ។

❖ បើស្រឡាញ់　កុំតែក្នាញ់　អន្ទះសា
ចិត្តស្នេហា　គ្មានស្គាល់ខុស　ល្មោភលោភលន់
ឱ្យតែបាន　ចាយប៉ុន្មាន　ដូចទឹកជន់
រឹងមិនទន់　ទៅនរក　ជួយពុំរួច ។

❖ ការអប់រំ គេនិយម ធ្វើបុណ្យទាន

ខ្សត់ឬមាន គេមិនថា ចិត្តឱ្យស្រួច

យកសទ្ធា ដុះជាពូជ ទើបចេញរូប

ព្រោះមិនលួច ទ្រព្យគេមាន សាងកុសល ។

❖ ការអប់រំ គេបន្ទំ ប្រើចិត្តសាស្ត្រ

សម្គាល់ច្បាស់ ដោយវិធី សួរយោបល់

សម្លឹងគិត ស្ទង់ជម្រៅ ឱ្យបានយល់

រហូតពាល់ ដល់សច្ចៈ ទើបសម្រេច ។

❖ ការអប់រំ គេសន្សំ បន្តិចម្តង

បារមីឆ្លង ភពទាំង៣ បានកាច់ផ្តាច់

លែងវិលវល់ អន្ទោលទៅ មិនចេះដាច់

ពុំមានសាច់ ឆ្អឹងសរសៃ រឹងស្ងួតអស់ ។

❖ ការអប់រំ សំអាតចិត្ត ឱ្យផូរផង់

ត្រូវលះបង់ សត្វបុគ្គល កុំស្រណោះ

គិតប្រយោជន៍ អ្នកដទៃ ជួយរំដោះ

កុំជំទាស់ ច្បាប់ធម្មា ព្រះពុទ្ធអង្គ ។

❖ សេចក្ដីសុខ តែងប្រែប្រួល មិនទៀងទាត់
លោកនេះក្បត់ រត់រកទុក្ខ លែងស្មោះត្រង់
ការសិក្សា អប់រំចិត្ត រៀរចំណង់
ការលះបង់ ទុកជាទាន បានបុណ្យច្រើន ។

❖ កូនត្រូវចេះ ជួយរក្សា ញាតិជិតខាង
មានទីអាង ពឹងពំនាក់ ជួយដាស់តឿន
គ្រាអាសន្ន មិនកំណត់ យឺតឬលឿន
សាងមិត្តភឿន សាមគ្គីគ្នា ជាកម្លាំង ។

❖ ការរស់នៅ ជួបសុខទុក្ខ ជាធម្មតា
កុំប្រាថ្នា ឱ្យខុសហេតុ នាំភ្លេចភ្លាំង
យកបញ្ញា មកកាប់ឆ្ការ ដូចភ្លៀងរាំង
តតាំងច្បាំង ទើបយកឈ្នះ លើកិលេស ។

❖ កូនត្រូវមាន ស្មារតីភ្ញាក់ រៀនឱ្យជាក់
កុំទម្លាក់ ទោសដាក់គេ ថាខ្លួនចេះ
អំពើបាប ដូចដុតរោល ក្ដៅផ្ទុះប្រេះ
កុំចង់ចេះ មិនទាន់រៀន ស្គរប្រហោង ។

❖ រៀនអ្វីក៏ រៀនទៅចុះ ឱ្យកូនប្រុស
យល់មិនខុស មិនច្រឡំ ត្រង់មិនកោង
វិជ្ជាពិត មានប្រយោជន៍ តាមសណ្ដាង
ជួយយឹតយោង មិនរហាម មានមុខមាត់ ។

❖ បើចេះអ្វី ចេះប្រាកដ កើតសម្បត្តិ
មិនរសាត់ បាត់ពីប្រាណ មិនក្រខ្សត់
ក្នុងការងារ មានព្យាយាម យ៉ាងហ្មត់ចត់
ផលទៀងទាត់ កើតពីហេតុ មិនចេះភ្លេច ។

❖ មួយអត្តភាព កូនប្រុសស្រី ត្រូវអប់រំ
ចិត្តបន្ទំ ស្រង់ក្លិនល្អ លះកម្ទេច
សំរាមស្អុយ ដែលគេចោល គ្រឿងគគ្រិច
កុំបំភ្លេច ចិត្តខ្លួនឯង ឱ្យទុព្វល ។

❖ ចិត្តភង្គៈ មួយជីវិត ត្រូវបែកធ្លាយ
កុំគិតងាយ ថាជីវិត ជាឫសគល់
រស់នៅយូរ មួយខណៈ ខ្ចីមិនយល់
កុំរវល់ ខ្លាំងញាប់ពេក បាត់ស្មារតី ។

❖ កុំវង្វេង ថាមាសប្រាក់ ជួយជីវិត
ឱ្យរស់ពិត តាមធម្មៈ បុណ្យលោកិយ
ពីអតីត រួមផ្សំគ្នា ជាមេត្រី
ចេះប្រណី សម្ពន្ធគ្នា កើតកុសល ។

❖ ការអប់រំ គេបន្ទំ ឱ្យស្គាល់ផ្លូវ
មគ្គត្រឹមត្រូវ អង្គប្រាំបី ដើរបានដល់
សតិប្បដ្ឋាន ចម្រើនចិត្ត លែងកង្វល់
ទុកតម្កល់ ពោធិត្រាស់ ព្រះនិព្វាន ។

❖ ពេលជិតស្លាប់ កុំទម្លាប់ ជាប់រវល់
នាំអំពល់ ធ្លាក់អបាយ ខានធ្វើទាន
សំអាតចិត្ត កុំនឹកនា ទ្រព្យធនមាន
មិនមែនស្ពាន ចម្លងអ្នក ទៅត្រើយនាយ ។

❖ បើចិត្តស្ងប់ មរណាសន្ន ជួយឧបត្ថម្ភ
នូវបណ្តាំ ព្រះជិនស្រី ដែលវេចស្លាយ
បុណ្យរុញច្រាន កន្លងផុត ហួរទម្លាយ
មិនរាយមាយ ជនកៈ កម្មសុគតិ ។

# **សតិប្បដ្ឋាន** (ជំហានទី ៥)

**មើលលោកនេះដោយវិចារណា** ទៅលើការអប់រំបញ្ញា គឺការអប់រំសតិប្បដ្ឋាន ឯការចម្រើនសតិ គឺការចម្រើនបញ្ញាដែលមានសតិប្បដ្ឋាន៤បានដល់ ពួកកាយ ពួកវេទនា ពួកចិត្ត និង ពួកធម៌ក្នុងបញ្ចក្ខន្ធតាមព្រះដ៏មានព្រះភាគ។ ចំណែកភូមិបញ្ញាមានអារម្មណ៍ ៧៣ គឺ ខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ ឥន្ទ្រិយ ២២ បដិច្ចសមុប្បាទ ១២ និង សច្ចៈ ៤ ជាបរមត្ថសុទ្ធដែលសតិប្បដ្ឋានភាវនាអប់រំរលឹកនូវអារម្មណ៍ទាំងនេះធ្វើឱ្យតណ្ហាជ្រុះបន្តិចម្តងៗជាតទង្គប្បហានទៅជាលោកិយ ។

ការចម្រើន សតិ គឺចម្រើន ពួកកាយ

ការចម្រើន សតិ គឺចម្រើន ពួកវេទនា

ការចម្រើន សតិ គឺចម្រើន ពួកចិត្ត

ការចម្រើន សតិ គឺចម្រើន ពួកធម៌មានវីរិយៈ ជាអ្នកជួយអុំជួយចែវដល់បញ្ញាផង ។

**<u>សារៈសំខាន់របស់សតិប្បដ្ឋាន</u>** សតិប្បដ្ឋានមានការរលឹកទៅលើ សភាវធម៌កំពុងប្រាកដ (ភ្លាមៗ) ជាអារម្មណ៍បរមត្ថដែលមានពិត ។ ពាក្យថា បរមត្ថធម៌ចេញមកពីពាក្យថា បរម + អត្ថ + ធម៌ ។ អត្ថមាន លក្ខណៈជារបស់មិន

មានអ្នកណាអាចនឹងផ្លាស់ប្តូរបាន ជាសភាវធម៌ដែលមានពិតក្នុងលោក ក្នុងចក្រវាលទាំងអស់ មិនផុតពីចិត្ត១ ចេតសិក១ រូប២៨ ។ ម្យ៉ាងទៀតព្រះនិព្វាន ក៏មិនកើតឡើងផ្ទុយពីចិត្ត ចេតសិក រូបនេះដែរ ហើយក៏ត្រូវរលឹកត្រឹមតែធម៌ ៤ប៉ុណ្ណោះ ដទៃក្រៅពីនេះមិនជាសតិប្បដ្ឋាន ។

## អង្គធម៌របស់សតិប្បដ្ឋាន ៤ :

**១-កាយានុបស្សនាសតិប្បដ្ឋាន** សតិដែលតាំងមាំនៅក្នុងការពិចារណារឿយៗនូវពួកកាយ គឺ រូបក្ខន្ធ មានខ្យល់ចូលចេញ ឥរិយាបថធំ ឥរិយាបថតូចជាដើម អង្គធម៌បានដល់ សតិចេតសិក នៅក្នុងមហាកុសល ៨ មហាកិរិយា ៨ អប្បនាជវន ២៦ ។

**២-វេទនានុបស្សនាសតិប្បដ្ឋាន** សតិដែលតាំងមាំនៅក្នុងការពិចារណារឿយៗនូវពួកវេទនា អង្គធម៌បានដល់ សតិចេតសិក នៅក្នុងមហាកុសលចិត្ត ៨ មហាកិរិយា ៨ អប្បនាជវន ២៦ ។

**៣-ចិត្តានុបស្សនាសតិប្បដ្ឋាន** សតិដែលតាំងមាំនៅក្នុងការពិចារណារឿយៗនូវពួកចិត្ត មានលោភចិត្ត អលោភចិត្ត ទោសចិត្ត អទោសចិត្ត មោហចិត្ត អមោហចិត្ត ជាដើម អង្គធម៌បានដល់ សតិចេតសិកដែលនៅក្នុងមហាកុសលចិត្ត ៨ មហាកិរិយា ៨ អប្បនាជវន ២៦ ។

**៤-ធម្មានុបស្សនាសតិប្បដ្ឋាន** សតិដែលតាំងមាំនៅក្នុងការពិចារណារឿយៗ នូវសភាពជា លោភៈ ទោសៈ មោហៈ ជាដើម អង្គធម៌បានដល់សតិចេតសិក នៅក្នុងមហាកុសលចិត្ត ៨ មហាកិរិយា ៨ អប្បនាជវន ២៦ ។ (ដកស្រង់ពីក្នុងបរមត្ថជោតិកៈ)

## សេចក្តីពិស្តារ

**១-ឥធ ភិក្ខុ កាយេ កាយានុបស្សី** បានសេចក្តីថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញកាយក្នុងកាយដោយសម្លឹងឃើញកាយក្នុងកាយថាជាកាយ សម្លឹងឃើញកាយតាមសភាវៈដែលជាទីប្រជុំ ឬ ប្រកបចូលគ្នានៃចំណែកប្រកប គឺ អវយវៈតូចធំផ្សេងៗ មិនមែនសម្លឹងឃើញថាគេ ថាយើង ថាអ្នកប្រុសអ្នកស្រី ថារបស់ខ្ញុំរបស់អ្នកនោះ ឬ អ្នកនេះក្នុងសក់រោមក្រចកជាដើម ដោយសេចក្តីថា ឃើញត្រង់តាមសេចក្តីពិតត្រង់តាមសភាវៈនូវរបស់ដែលឃើញ គឺមើលកាយត្រូវឃើញត្រឹមតែកាយ មិនមែនមើលកាយ បែរទៅជាឃើញសត្វ ឬឃើញរបស់ជាទីពេញចិត្តទៅវិញទេដូចព្រះគាថាទ្រង់ត្រាស់សម្តែង :

**យំ បស្សតិ ន តំ ទិដ្ឋំ យំ ទិដ្ឋំ ន តំ បស្សតិ**
**អបស្សំ ពជ្ឈតេ មូឡ្ហោ ពជ្ឈមានោ ន មុច្ចតិ ។**

**ប្រែថា :** បុគ្គលឃើញរបស់ណា, របស់នោះក៏មិនបានឃើញ, របស់ណាត្រូវឃើញ ក៏មិនឃើញរបស់នោះទៅវិញពេលមិនឃើញក៏វង្វេងរកនឹកគិតមិនបាន ។

**២-អាតាបី សម្បជានោ សតិមា ប្រែថា :** មានសេចក្តីព្យាយាម មានសម្បជញ្ញៈ មានសតិបានដល់ មានសម្មាវាយាម សម្មាទិដ្ឋិ និង សម្មាសតិ ដែលជាអង្គមគ្គ ៣ ត្រូវប្រកបជាមួយអង្គមគ្គទាំងឡាយ ។ សេចក្តីព្យាយាមតែងដាស់តឿនចិត្ត មិនឱ្យបង្អង់ មិនឱ្យរង់ចាំ មិនឱ្យថយក្រោយ មិនបើកឱកាសឱ្យអកុសលធម៌កើតឡើងជាកម្លាំង ឱ្យចិត្តរុលទៅមុខដើម្បីធ្វើឱ្យកុសលធម៌ផ្សេងៗ ចម្រើនឡើងដែលមានសម្បជញ្ញៈដើរតួជាបញ្ញាពិចារណាដឹងនូវអារម្មណ៍ដែលសតិកំណត់ទុកមិនឱ្យវង្វេង និងយល់ត្រូវត្រង់តាមសភាវពិត ។ សតិជាអ្នកចាប់អារម្មណ៍ទុកធ្វើឱ្យដឹងភ្លាមៗគ្រប់ខណៈចិត្តមិនធ្វេសប្រហែស ។

**៣-វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ប្រែថា :** កម្ចាត់ អភិជ្ឈា និង ទោមនុស្សក្នុងលោកចេញ បានសេចក្តីថា ពេលបដិបត្តិ ចិត្តក៏នឹងរំដោះអកុសលចេញបាន មិនជាប់ជំពាក់នូវសេចក្តីប្រាថ្នា និង សេចក្តីទាស់ចិត្ត ។

**៤-អត្ថិ កាយោតិ វា បនស្ស សតិ បច្ចុបដ្ឋិតា ហោតិ យាវទេវ ញាណមត្តាយ បដិស្សតិមត្តាយ ប្រែថា :** ចូរមានសតិប្រាកដ

ជាក់ថា ‹កាយមានមែន› ត្រឹមតែជាការដឹង នឹងសម្រាប់រលឹកប៉ុណ្ណោះដោយមានសតិកំណត់ជាក់ច្បាស់ត្រង់តាមសេចក្ដីពិតថា មានតែកាយមិនមែនសត្វបុគ្គលស្រីប្រុសតួខ្លួនរបស់គេ យើង របស់អ្នកណាជាដើម ដើម្បីចម្រើនសតិសម្បជញ្ញៈ ឬ ដើម្បីឱ្យសតិកើតបញ្ញាចម្រើនកពូនឡើង សូម្បីក្នុងវេទនា ចិត្ត ធម៌ ក៏មានន័យតែមួយដូចគ្នាទាំងអស់ ។

**៥-អនិស្សិតោ ច វិហរតិ ប្រែថា:** មិនពឹងអាស្រ័យ គឺមានចិត្តជាឥស្សរៈ មិនយកចិត្តទុកដាក់ជាមួយរបស់នេះរបស់នោះ ឬបុគ្គលនេះបុគ្គលនោះជាដើម ពោលតាមគោលធម៌ គឺមិនយកតណ្ហានិងទិដ្ឋិនោះ ដូចជា ពេលជួបនិងរបស់ផ្សេងៗក៏ទទួលដឹងតាមត្រង់ដោយការនឹកគិតនូវសុខនិងទុក្ខជាមួយនឹងតណ្ហាទិដ្ឋិនោះ ។

**៦-ន ច កិញ្ចិ លោកេ ឧបាទិយតិ ប្រែថា:** មិនប្រកាន់មាំនូវអ្វីៗក្នុងលោក គឺមិនប្រកាន់នូវរបស់ណាៗមិនថារូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ជាអត្តា ឬ អត្តនិយា ដូចជាថារបស់ខ្លួន ឬ តួខ្លួនជាដើម ។ ប្រសិនបើគេនិយាយពីសតិប្បដ្ឋាន គឺគេលើកឡើងពីរបស់ទាំងអស់ សម្លឹងឃើញថា ពុំមានអ្វីក្រៅពីហេតុនិងបច្ច័យ គ្មានខ្លឹមសារអ្វីសោះព្រោះរបស់ទាំងឡាយទាំងពួងកើតឡើងត្រូវវិនាសទៅវិញជាធម្មតា ពុំមាននរណាម្នាក់ទៅឃាត់ឬចាប់ទុកបាន គ្រាន់តែរបស់ទាំងនោះជាទីតាំងនៃសតិ រលឹក

ដើម្បីឱ្យកើតបញ្ញាស្មារតី មិនដើម្បីជាទីពឹងពាក់គួរឱ្យកក់ក្ដៅចិតថែរ ទៀងទាត់នឹងយក មកធ្វើជាពំនាក់អាស្រ័យជ្រកនៅ ឬ យកមកធ្វើជាម្លប់ សម្រាប់ជួយការពារកុំឱ្យមានសត្រូវចូលមកបៀតបៀន ដែលអ្វីទាំងនោះ សំដៅទៅលើរូបធម៌នាមធម៌ជាសភាវៈកើតឡើងធម្មតាតាមហេតុប្បច្ច័យ ព្រោះមានសតិឈ្មោះថា សតិប្បដ្ឋានរលឹកដឹង ។ ការចម្រើនសតិធ្វើឱ្យ អកុសលធម៌មានតណ្ហាជាសមុទយទុក្ខជ្រុះជាបណ្ដើរ ព្រោះសតិជា សោភណចេតសិកកើតជាមួយនឹងកុសល តែបើសិក្សាឱ្យល្អិតបន្តិចសតិ ក៏ កើតជាមួយចិត្តប្រភេទដទៃ ដូចជាវិបាកចិត្តជាផលរបស់កម្មក៏ជា កុសល វិបាកឬថាជាកិរិយាចិត្តក៏បាននឹងធ្វើឱ្យយើងផ្ដើមយល់ត្រូវ មានការឃើញ ត្រូវថាធម្មៈជារបស់មានពិតអាស្រ័យពីស្ដាប់ដោយល្អ ទើបយល់បាននូវ អ្វីដែលបានស្ដាប់អាចនឹងពិចារណាយល់បានថា អ្វីនោះត្រឹមត្រូវ ឬ មិន ត្រឹមត្រូវ ប្រសិនបើមិនត្រឹមត្រូវក៏មិនមែនជាពាក្យប្រៀនប្រដៅរបស់ ព្រះអរហន្តសម្មាសម្ពុទ្ធ ប្រសិនបើត្រឹមត្រូវ គឺត្រង់ជាមួយនឹងសភាវធម៌ ដែលកំពុងប្រាកដតាមសេចក្ដីពិត ការស្ដាប់នោះគឺការសិក្សាធ្វើឱ្យយល់ធម៌ ច្រើនឡើងដែលមិនមែនយើងជាអ្នកដើរតួ ព្រោះបញ្ញាមានការយល់ ចម្រើនឡើងតាមលំដាប់ដែលជាបច្ច័យប្រជុំគាក់តែងជាសង្ខារក្ខន្ធ ធ្វើឱ្យ សតិដទៃទៀតកើតឡើងបន្តបន្ទាប់ជាសតិប្បដ្ឋាន ។

ពាក្យថាត្រូវត្រង់ជាមួយសភាវធម៌ពិត គឺសភាវធម៌កំពុងប្រាកដ ដែលសតិជាសតិប្បដ្ឋានរលឹកដឹងមួយខណៈៗជា **តទង្គប្បហាន** (គឺរលឹកដើម្បីលះបង់កិលេសជាខណៈៗ របស់ចិត្តពុំមានយើងរួមផ្សំក្នុងពេលនោះទេ) ។ ក្នុងផ្លូវលោកដែលពោលថា មនុស្សមានបញ្ញា ក៏ត្រឹមតែជាការចាំរឿង **(មនសិការៈ)** ដោយមិនដឹងនូវសភាវធម៌ ដូច្នោះវិជ្ជាផ្លូវលោកជារបស់អ្នកមានចំណេះផ្សេងៗ មិនមែនជាបញ្ញាចេតសិក ។ ពេលមានបញ្ញាចេតសិក ក៏នឹងត្រូវយល់ត្រូវដឹងត្រូវត្រង់តាមសេចក្តីពិតរបស់សភាវធម៌ដែលប្រាកដតាមលំដាប់ថ្នាក់ ទើបជាសមាទិដ្ឋិ ឬបញ្ញាចេតសិក ។

ដំណើរនេះត្រូវសិក្សាឱ្យបានយល់ជាមុន ទើបអាចយល់ក្នុងការរលឹកដឹងសភាវធម៌កំពុងប្រាកដ បើមិនដូច្នោះទេប្រាកដថា ជាយើង ព្រោះសភាវធម៌កំពុងប្រាកដនេះកើតឡើងពីហេតុប្បច្ច័យ ដែលសតិរលឹកនោះជា សតិប្បដ្ឋាន ។

សតិប្បដ្ឋានមិនមែនជាសតិនឹកគិត ព្រោះថាខណៈនោះបញ្ញាមិនអាចប្រត្យក្សលក្ខណៈរបស់សភាវធម៌មិនមែនយើង គឺសភាវធម៌ ជារូបធម៌ និងសភាវធម៌ជានាមធម៌ ដែលកំពុងប្រាកដក្នុងខណៈនេះត្រូវតែឃ្លាតចាកគ្នាដែលធ្វើការរលឹករឿយៗនឹងបាត់យើងរហូតថា ការប្រកាន់ខុសថា ជាយើងត្រូវរលត់នៅពេលសោតាបត្តិមគ្គចិត្តកើតឡើងដឹងច្បាស់ថា និព្វាន គឺ រលត់

សេចក្ដីសង្ស័យនៃការមិនដឹងនូវការឃើញខុសក្នុងលក្ខណៈរបស់សភាវធម៌អស់ជាសមុច្ឆេទ ។

ក្នុងជីវិតប្រចាំថ្ងៃ វិបាកឱ្យផលមានទាំងកុសលវិបាកភាគតិចទេ ច្រើនតែអកុសលវិបាក ។ នៅពេលណាមានសតិកើតឡើងក៏បានដឹងថា នេះជាកុសលវិបាក នេះជាអកុសលវិបាកដែលបញ្ញាធ្វើកិច្ចលះកិលេសជាតទង្គប្បហាន ក្នុងខណៈនោះភ្លាម ជាសតិប្បដ្ឋានវិបស្សនា ។

## លក្ខណពិសេសរបស់អនត្តា

### មើលលោកនេះដោយការពិចារណា ថាតើលោកមានលក្ខណៈបែបណា?

លោកនេះជាជម្រកនៃសេចក្ដីទុក្ខ ដែលមនុស្សគ្រប់គ្នាចង់បានសុខ ប៉ុន្តែស្រេកឃ្លានដើរទៅរកសេចក្ដីទុក្ខវិលវល់សំងំនៅជាប់ក្នុងកាមគុណទាំងឡាយមានរូបសំឡេង ក្លិនរស ផោដ្ឋព្វៈ និងធម្មារម្មណ៍ ដោយចេះគិតត្រឹមតែធ្វើយ៉ាងណាឱ្យបានដេកស្រួល ហូបឆ្ងាញ់ មានកិត្តិយស និង ទ្រព្យសម្បត្តិច្រើន ទោះបីមានព្រះធម៌របស់ព្រះសម្មាសម្ពុទ្ធ ដែលជាសារៈសំខាន់ដល់ជីវិតសម្រាប់រំដោះចេញពីសេចក្ដីទុក្ខ ក៏មិនសូវវីវរវល់អើពើយកចិត្តទុកដាក់

នឹងស្លាប់ ព្រោះជីវិតរបស់គេបានប្រគល់ឱ្យតណ្ហា និង ទិដ្ឋិទាំងស្រុងរួចទៅហើយ ។

រឿងនេះមិនមែនថា ហួសពេលដោះស្រាយមិនបានឱ្យតែអ្នកនោះព្រមដាក់ចិត្ត (មានៈ) ប្រគល់ជីវិតមករកព្រះធម៌វិញដែលអ្នកនោះធ្លាប់បានប្រព្រឹត្តអំពើខុសឆ្គងយ៉ាងណាក៏ដោយ តួយ៉ាងអង្គុលិមាលជាដើម ព្រះគាថា ធម្មបទទ្រង់ត្រាស់សម្តែងថា :

**យស្ស បាបំ កតំ កម្មំ កុសលេន បិថិយតិ**

**សោមំ លោកំ បភាសេតិ អព្ភា មុត្តោវ ចន្ទិមា ។**

**ប្រែ** អ្នកណាលះចោលនូវបាបកម្ម ដែលខ្លួនបានធ្វើរួចហើយដោយកុសល បុគ្គនោះនឹងញុំាងលោកនេះឱ្យភ្លឺស្វាង ដូចជាព្រះចន្ទរះផុតស្រឡះចេញពីពពក បំភ្លឺលោកនេះឱ្យភ្លឺស្វាងត្រចះត្រចង់យ៉ាងនោះឯង ។

អ្វីៗក្នុងលោកមានត្រឹមតែសភាវៈកើតឡើង ដោយការភាន់ច្រឡំយល់ថាលោកនេះ គឺទ្រព្យសម្បត្តិមាសប្រាក់ ដីស្រែចម្ការជាវត្ថុកាមដោយបញ្ញត្តិ អាស្រ័យបរមត្ថដែលជាអារម្មណ៍របស់វិញ្ញាណកើតឡើង រួចក៏ត្រូវប្រែប្រួលវិនាសទៅវិញសន្សំផលទុក្ខក្នុងសង្សារ ម៉្លោះហើយបានជាគេខំកសាងលោកដូចជាធ្វើស្ពានថ្នល់ ធ្វើយន្តហោះទំនើបៗ ធ្វើលំនៅដ្ឋានល្អៗកសាងសម្លៀកបំពាក់ស្អាតល្អៗ ផលិតគ្រឿងតុបតែងខ្លួននិងគ្រឿង

ក្រអូបសម្រាប់បំបាត់ក្លិនអាក្រក់ ផលិតថ្នាំច្រើនមុខសម្រាប់ព្យាបាលជំងឺផ្សេងៗដើម្បីចៀសវាងពីសេចក្តីទុក្ខ ព្រោះសង្ខារទាំងនោះពុំមានសារៈខ្លឹមសារសំខាន់រឹងមាំ ពុំមានអ្វីជួយទល់ទ្រ ដូចដើមចេកពុំមានបណ្តូលយ៉ាងណា លក្ខណៈពិសេសរបស់សង្ខារធម៌ សម្តែងចេញជាអនត្តា នឹងមានជម្រាបជូន ដូចតទៅនេះ :

តាមគោលធម៌របស់ព្រះពុទ្ធសាសនា ស្រង់ចាគគម្ពីរ បដិសម្ភិទាមគ្គ បានសរសេរពន្យល់នូវអត្ថរបស់អនត្តា ទុកថា ឈ្មោះថា អនត្តា ដោយសេចក្តីសម្គាល់ថាមិនមានសារៈ **អសារកដ្ឋេន** ដែលថាមិនមានសារៈក៏គឺមិនមានខ្លឹមសារ មិនមានស្នូល មិនមានវត្ថុ ដែលជាតួពិត ឋិតនៅរៀងរហូតតទៅ ដូចពាក្យអធិប្បាយថា មិនមានសារៈ គឺមិនមានតួខ្លួន (អត្តសារៈ = តួខ្លួន ដែលជាខ្លឹម ឬ តួខ្លួនជាស្នូល) ដែលកំណត់យកថាជាអត្តន (អត្ត = តួខ្លួន) ជាបុគ្គលនៅគ្រប់គ្រង (ទីអាស្រ័យ) ជាអ្នកសាង (ធ្វើអំពើ) ជាអ្នកសោយ (វេទនៈ) ជាអ្នកមានអំណាចក្នុងខ្លួន ព្រោះថារបស់ណាមិនទៀងរបស់នោះ ជាទុក្ខតាំងនៅមិនបាន មិនអាចហាមឃាត់ការមិនទៀង ឬ ការបៀតបៀនក្បៀសង្កត់នូវរបស់ដែលកើតឡើង និងវិនាសអស់ទៅសូម្បីតួខ្លួនឯងក៏ត្រូវវិនាសទៅវិញ ដូចគ្នាទាំងអ្នកសាង និងអ្នកបង្កហេតុជាដើមនឹងមានមកពីណា ព្រោះហេតុនោះព្រះដ៏

មានព្រះភាគជាម្ចាស់ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ប្រសិនបើរូបនេះមានអត្តាមែន រូបនេះមិនប្រព្រឹត្តទៅដើម្បីអាពាធ ព្រោះពុំមានសារៈគឺតួខ្លួននេះទើបលោកពោលទុក ដោយសម្គន្ធសេចក្ដីថា : អ្នកបង្កហេតុមិនមានអំណាចក្នុងខ្លួន ប្រសិនបើមានតួខ្លួនរស់នៅ មែនជាខ្លឹម ឬ ស្នូលនោះក៏រមែងទំនាស់នឹងការប្រែប្រួលទៅវិញ ក៏រមែងមានអំណាចបង្គាប់បញ្ជារបស់ដែលត្រូវគ្រប់គ្រងឱ្យប្រព្រឹត្តយ៉ាងណាៗបានតាមប្រាថ្នា តែតាមពិតមិនមានតួខ្លួននៅគ្រប់គ្រង ទើបមានការកត់សម្គាល់ ថាមិនមានអំណាចបង្គាប់បញ្ជា មិនប្រព្រឹត្តទៅក្នុងអំណាចតាមសេចក្ដីប្រាថ្នា ដោយន័យនេះ អដ្ឋកថាសម្ដែងនូវសេចក្ដីសម្គាល់របស់អនត្តាថា "អនត្តាដោយសេចក្ដីថា មិនប្រព្រឹត្តទៅក្នុងអំណាច **អវសវត្តនដ្ឋេន ឬ អវសវត្តនតោ** " ព្រោះមិនប្រព្រឹត្តទៅក្នុងអំណាច" ដែលអធិប្បាយថា មិនមានអ្នកណាមានអំណាចបង្គាប់ (តាមចិត្តប្រាថ្នាដោយមិនធ្វើតាមហេតុប្បច្ច័យ) ដល់សង្ខារទាំងឡាយថា : សង្ខារដែលកើតឡើងហើយ ចូរកុំឋិតនៅប្រសិនបើឋិតនៅហើយចូរកុំឱ្យជរា បើដល់ជរាហើយចូលកុំបែកធ្លាយ ចូរកុំទ្រុឌទ្រោម និងវិនាសដែលមានពុទ្ធវចនៈត្រាស់ថា : បុគ្គលរមែងមិនបាន (តាមប្រាថ្នា) ក្នុងរូប និងក្នុងខន្ធដទៃៗ ថារូបរបស់យើងចូរជាយ៉ាងនេះ រូបរបស់យើងកុំបានយ៉ាងនេះ ។

ដោយសរុបព្រះអដ្ឋកថាចារ្យ ទ្រង់ពោលទុកនូវការកំណត់របស់អនត្តា មាន ៤ ន័យដូចតទៅនេះ ÷

**១-សុញ្ញតោ** ជាសភាវទទេ សូន្យចាកតួខ្លួនដែលជាខ្លឹម ឬ ស្នូល (អត្តសារៈ = សារៈ គឺ តួខ្លួន) ឬទំនេរចាកភាពជាសត្វ បុគ្គលតួខ្លួនយើងគេ ដែលពិតមិនមានតួអ្នកអាស្រ័យនៅគ្រប់គ្រង មិនមានតួអ្នកសាងបង្កហេតុ និង មិនមានតួអ្នកសោយ ។

**២-អស្សាមិកតោ** ពុំមានម្ចាស់តួខ្លួននិង មិនជារបស់តួខ្លួនណាៗ មិនមានតួខ្លួនផ្សេងដែលជាម្ចាស់គ្រប់គ្រងលើសង្ខារទាំងឡាយ ។

**៣-អវសវត្តនតោ** ព្រោះមិនប្រព្រឹត្តទៅក្នុងអំណាចគឺ មិននៅក្នុងអំណាចរបស់អ្នកណា មិនមានអ្នកណាមានអំណាចបង្គាប់ស្រែកហៅ ឬ ប្រាថ្នាយ៉ាងណាៗមិនមានអ្វីក្រៅពីហេតុប្បច្ច័យ ដែលប្រើសព្ទម្យ៉ាងទៀតថា **អនិស្សរតោ ប្រែថា** :ព្រោះមិនជាម្ចាស់ ឬ មិនជាធំក្នុងខ្លួននិងការពារ ឬ ប្រើអំណាចបង្គាប់ឱ្យប្រព្រឹត្តទៅតាមហេតុបច្ច័យ ជូនណាប្រើជា **អកាមការិយតោ ប្រែថា** ព្រោះជាសភាពមិនអាចធ្វើបានតាមប្រាថ្នា នេះជារឿងរបស់ ហេតុប្បច្ច័យ គឺមិននៅក្នុងអំណាច ឬ ក៏មានអ្នកធំមកបង្គាប់បញ្ជា ។

**៤-អត្តបដិក្ខេបតោ** ព្រោះទំនាស់នឹងអត្តា, បដិសេធអត្តាក្នុងខ្លួនជាគោលធម៌ គឺអង្គប្រកបទាំងឡាយសម្ពន្ធគ្នាប្រព្រឹត្តទៅតាមហេតុប្បច្ច័យនោះឯងជាការបដិសេធមិនមានតួខ្លួនដោយថា បើមិនដូច្នោះមិនអាចប្រព្រឹត្តទៅតាមហេតុប្បច្ច័យ ។ម្យ៉ាងទៀតគោលធម៌ដែលប្រព្រឹត្តទៅតាមហេតុប្បច្ច័យមានការសម្រេចព្រមគ្រប់គ្រាន់នៅក្នុងខ្លួន មិនអាចមានអ្វីផ្សេងមកជ្រៀតចូលរួមផ្សំបានទៀតទេ ។ នៅមានការកត់សម្គាល់ ២ យ៉ាងទៀតដែលអាចរួមផ្សំចូលក្នុង **ខ** ទាំង ៤ ខាងលើនេះ :

**៥-សុញ្ញសង្ខារ បុញ្ញតោ ឬ សុញ្ញធម្មបុញ្ញតោ** ព្រោះជាកងនៃសង្ខារទាំងឡាយ ឬ ជាកងនៃធម៌ទាំងឡាយ (រូបធម៌នាមធម៌) ឬ អង្គ **សម្ភារតោ** ព្រោះជាការរួមផ្សំគ្នាដោយចំណែកផ្សេងៗ កើតពីចំណែកប្រកបរឿយៗដែលមិនមែនជាតួខ្លួន មិនមានសត្វបុគ្គលពិតក្រៅពីចំណែកប្រកបទាំងនោះ ។

**៦-យថាបច្ចយបវត្តិតោ** ព្រោះប្រព្រឹត្តទៅតាមហេតុប្បច្ច័យ ដោយអង្គប្រកបទាំងឡាយយកមកប្រជុំគ្នា កើតឡើងសម្ពន្ធជាបច្ច័យដល់គ្នាហៅរួមថា គោលធម៌ដែលប្រព្រឹត្តតាមហេតុប្បច្ច័យ មិនប្រព្រឹត្តទៅតាមសេចក្តីប្រាថ្នារបស់អ្នកណា និងមិនមានតួខ្លួន មិនថាមានតួស្នូលខាងក្នុង ឬតួខ្លួនខាងក្រៅដែលនឹងកើតឡើង ឬ ការពារក៏មិនបាន ។ រួមសេចក្តីថា របស់

ទាំងឡាយប្រព្រឹត្តទៅតាមហេតុប្បច្ច័យខ្លួនឯងធម្មតា ។ សេចក្តីសម្គាល់នូវអនត្តាដែលពោលមកនេះ ជាលក្ខណៈរបស់សង្ខារ ឬ សង្ខតធម៌ តែភាពជាអនត្តារបស់អសង្ខតធម៌គឺ និព្វាន ។

ការដឹងលោកត្រឹមមួយខណៈៗនៃចិត្តកើតឡើង រួចក៏វិនាសបាត់ទៅឯរបស់ដែលយើងសម្គាល់ថាមាននោះត្រឹមតែមួយជួរខណៈនៃវិថីចិត្តដឹងអារម្មណ៍ ដែលពុំមែនជារបស់អ្នកណា ដោយលោកនេះសន្មតថា មានរបស់ពិតប្រាកដ ជាបញ្ញត្តិផ្សេងៗ ។ ការមិនដឹងនូវសភាវៈពិតនាំឱ្យមានការហួងហែង ធ្វើឱ្យទំនាស់គ្នាមិនចេះចប់ ថានេះជារបស់អញ នោះជាអញនោះជាខ្លួនរបស់អញ ដោយតណ្ហាទិដ្ឋិមានះ ជ្រួលច្របល់ពេញលោកក៏ត្រូវជាប់ជុំពាក់លោកធ្វើឱ្យកិលេសកើតរឹតតែច្រើន ជាការមិនមានសតិសម្បជញ្ញៈ ដើម្បី ដោះស្រាយនូវសេចក្តីទុក្ខព្រោះយល់ថាទីនេះជាសុខពិត ។ ការអប់រំ ចម្រើនសតិប្បដ្ឋានកំចាត់សេចក្តីប្រកាន់ ជាការចម្រើនអរិយមគ្គអង្គ ៨ ដែលមានទាំងបញ្ញានិងសមថៈដោយ សម្មាទិដ្ឋិនិងសម្មាសង្កប្បៈដើរតួជាបញ្ញាចេតសិក ឯអង្គមគ្គដទៃទៀត ដើរតួជាសមថៈ ដែលចិត្តនោះបានជ្រកនៅសុខស្ងប់តាំងមាំក្នុងកម្មដ្ឋាន ធ្វើកិច្ចលះកិលេសជាបណ្តើរៗជានិច្ចកាលគ្រប់ពេលវេលារាប់ ខែ រាប់ឆ្នាំ រាប់ជាតិមិនថាមួយជាតិ ២ជាតិ ៣ជាតិ រាប់កប្បជាតិទៅមុខ ទោះបីទៅ រស់នៅ

ទីកន្លែងភព ភូមិឋានណាក៏ដោយ ក៏ការប្រព្រឹត្តរបស់ចិត្តតាម កាយវាចា ចិត្តដុះដោតជាប់នៅក្នុង កន្លែងត្រូវរបស់សច្ចធម៌មិចម្រើនឡើងៗ ជាលំដាប់ រៀងរាល់ពេលដែលបញ្ញាចូលទៅលាងជម្រះ ព្រោះចិត្តជាធម្មជាតិសន្សំនូវវិបាកដោយជវនវថី សូម្បីកំពុងប្រព្រឹត្តធ្វើការងារអ្វីជាដើមក្តី ក៏ការសន្សំបារមីក្នុងសន្តានប្រព្រឹត្តទៅរៀងរហូតនឹងបានសម្រេច ឱ្យតែមានបញ្ញាចេតសិតស្របតាមធម្មជាតិដូចទ្រង់ត្រាស់សម្តែងទោះបីក្នុងបច្ចុប្បន្នកំពុងរស់នៅក្តី ។ (ដកស្រង់ចាកព្រះធម្មបិដក ៧០/១៧-១៨-៧០/២១)

បញ្ញាកើតពីស្តាប់ ប្រឹងត្រងត្រាប់ស្រង់ខ្លឹមសារ
ពាក្យពេចន៍ក្នុងអក្ខរា សូមកត់ត្រាកុំឱ្យបាត់ ។
យកមកត្រិះរិះគិត រៀនពិនិត្យធម៌បរមត្ថ
ចម្រើនឱ្យម៉ឺងម៉ាត់ ដោយស្ទៀមស្ទាត់តាមសប្បាយ។
ជីវិតគេអប់រំ ប្រមូលផ្តុំគុណទាំងឡាយ
ដើម្បីជួយរំសាយ ឱ្យនឿយណាយពីកិលេស ។
បើកូនខំសង្វាត កូននឹងឆ្លាតកើតចំណេះ
ជួយដល់អ្នកមិនចេះ ដែលគេចវេះខ្ជិលមករៀន ។
ពាក្យល្អកើតពីចិត្ត វាចាពិតមិនខ្មាស់អៀន
អ្នកប្រាជ្ញមិនទិទៀន ព្រោះកូនញៀនស្តាប់មិនឈប់ ។

កូននឹងបានទីពឹង ធម៌មិនខឹងជ្រកជាម្លប់
កុសលកើតសព្វគ្រប់ ជួយរុញផ្ទប់បណ្ដេញបាប ។
ធ្វើទានសីលភាវនា កើតវិជ្ជាលះក្លិនធ្លាប
កូនពិតជាមិនសាប ចេះឱនក្រាបបង្គំព្រះ ។
បើកូនរៀនបានចេះ កុំប្រហែសរើបម្រះ
កុសលលាងជម្រះ កូននឹងឈ្នះលើសត្រូវ ។
ឪផ្ដាំឱ្យកូនដឹង ទុកទីពឹងដើរតាមផ្លូវ
វាចាមិនអាស្រូវ កាយត្រឹមត្រូវចិត្តល្អស្អាត ។
សុចរិតនេះឯងណា កូនរក្សាគិតសង្វាត
ធ្វើទានកុំឱ្យខាត ម្ហូបដាក់បាត្រថ្វាយព្រះសង្ឃ ។
បុណ្យច្រើនរាប់មិនអស់ មិនអាឡោះផ្ដាច់ចំណង់
លោកិយមិនទៀងត្រង់ ចិត្តតម្រង់ព្រះនិព្វាន ។
កូនមានគំនិតប្រាជ្ញ ខ្លាំងអង់អាចព្រោះមានញាណ
សង្គ្រោះមនុស្សរាប់លាន ដោយធ្វើទានជាបារមី ។
សាងឈ្មោះក្នុងត្រកូល ជួយប្រមូលញាតិប្រុសស្រី
ឱ្យមានសុខសិរី ដោយមេត្រីចំពោះសត្វ ។
កូនពិតនឹងបានភ្លឺ ប្រាជ្ញាជ្រៅចូលទៅកាត់
មេបាបត្រូវកម្ចាត់ បុណ្យលេបបាត់អស់ពីខន្ធ ។

រៀនច្រើនស្ដាប់ច្រើននាំឱ្យកើតបញ្ញា

# សំយោគមតិ

**មើលលោកនេះដោយការវាយតម្លៃ** ទៅលើសង្ខារធម៌ទាំងឡាយ ទាំងពួងមិនទៀងតែងវិនាសប្រែប្រួល ជាធម្មតាមានភាពបង្ហាញពីការពិតរបស់ធម្មជាតិដែលព្រះបរមគ្រូនៃយើង ទ្រង់ត្រាស់ដឹងដោយសមន្តចក្ខុ ។

លោកនេះបានដល់ រូប វេទនា សញ្ញា សង្ខារ និងវិញ្ញាណកើតឡើងរួមផ្សំ ពីធាតុដី ធាតុទឹក ធាតុភ្លើង ធាតុខ្យល់ មនោធាតុ និង អាកាសធាតុ មានតួនាទីជាអ្នកចងក្រងលោក រៀបចំលោកតាមហេតុប្បច្ច័យធ្វើលោកនេះឱ្យងងឹតកង្វល់ ឬ ភ្លឺស្វាងអាស្រ័យពីកាយកម្ម វចីកម្ម មនោកម្ម ជាតួចេតនាចេតសិក បន្តភពជាតិកំណើតមិនចេះចប់អន្ទោលទៅមកក្នុងសង្សារវដ្តមិនដឹងខាងដើមពីត្រឹមណានិងខាងចុងគ្មានទីកំណត់ (អដ្ឋកថា) ដូចគំនរគ្រាប់ខ្សាច់នៅលើផែនដីរាប់មិនអស់ ។ លោកនៃវិញ្ញាណធ្វើកិច្ចដឹងអារម្មណ៍មិនដែលប្រកាន់អ្វីយកមកធ្វើជារបស់ខ្លួន ព្រោះខ្លួនឯងក៏គ្មានដោយគ្រាន់តែមានមុខងារបណ្តោះអាសន្នក្នុងជីវិតទុកគ្រាន់តែសម្រាប់ប្រើប្រាស់របស់ខន្ធ របស់អាយតនៈ របស់ធាតុដើម្បីចម្រើនបញ្ញាស្មារតីបំពេញនូវប្រយោជន៍ ៣ យ៉ាង ក្នុងលោកនិងទេវលោកព្រមទាំង

បរមត្ថប្រយោជន៍ រួចផុតចាកទុក្ខ និង ជួយថែរក្សាលោកប្រកបដោយចិត្តមេត្តា ករុណា មុទិតា ឧបេក្ខា ផ្សព្វផ្សាយដល់ពពួកសត្វទាំងឡាយគ្រប់ទិសទាំង ១០ ទោះបីសត្វស្លូត សត្វកាច សត្វមានឋានៈ ថោកទាបឋានៈខ្ពង់ខ្ពស់ សូមឱ្យបានទទួលនូវសេចក្តីសុខប្រាសចាកទុក្ខកុំព្យាបាទបៀតបៀនគ្នា ព្រោះថាសត្វទាំងអស់ សុទ្ធតែប្រាថ្នានូវសេចក្តីសុខគ្រប់រូប ។

តាមការសិក្សា ឃើញថាលោកនេះជាតម្រេករបស់សត្វគួរឱ្យរីករាយ (នន្ទិ សញ្ញោជនោ លោកោ) និងគួរឱ្យសោកសង្រេងរីងរៃ ព្រោះជួប នូវសេចក្តីទុក្ខដែលគ្រាន់តែបានសោយនូវឥដ្ឋារម្មណ៍ ឬអនិដ្ឋារម្មណ៍មួយភ្លែត១ របស់កាមគុណរួចក៏ត្រូវទទួលទុក្ខទោសគ្រោះថ្នាក់ជាយូរអង្វែងដែល លោភៈ មានទោសតិចតែលំបាកផ្តាច់ ទោសៈមានទោស ច្រើនតែងាយលះផ្តាច់ ចំណែកមោហៈ មានទោសច្រើនផង កម្រលះផ្តាច់ ឱ្យជ្រះស្រឡះផងធ្វើឱ្យសត្វជាប់នៅក្នុងទ្រុងមច្ចុមារព្រោះតែការរីករាយ ត្រេកត្រអាល ព្រោះតែការទោមនស្សអាក់អន់ចិត្តចងកំហឹងប្រទូលវ៉ាយដាក់គ្នាដោយ ភ្លើងទោសៈ ឆាបឆេះពេញ **ពិភពលោកជីវិត** និងការវង្វេងភាន់ក្រឡំមិនដឹងការពិតនៅកន្លែងណា ក៏ចេះតែចង់បានគ្មានស្រាកស្រាន្តដោយឱ្យតម្លៃពិសេសផង ។ លុះបានស្តាប់ធម៌របស់ព្រះសម្ពុទ្ធក៏ផ្ទុយគ្នាស្រឡះថា សេចក្តីសុខឋិតនៅលើការមិនរវល់ មិនប្រកាន់ទៅលើ

សង្ខារទាំងពួង ដែលទ្រង់ត្រាស់សម្តែងនៅក្នុងខុទ្ទកនិកាយ ចូឡនិទ្ទេស បឋមភាគ កប្បមាណវកប្ប បញ្ញានិទ្ទេស បិដកលេខ ៦៧/៣០០ ថា:

**អកិញ្ចនំ អនាទានំ ឯតំ ទីបំ អនាបរំ**
**និព្វានំ ឥតិ នំ ព្រូមិ ជរាមច្ចុបរិក្ខយំ ។**

**ប្រែ** ការមិនកង្វល់ ការមិនប្រកាន់ នុ៎ះឯងជាទីពឹង ឯទីពឹងក្រៅពីនេះពុំមានឡើយ តថាគតហៅនូវទីពឹងនោះថា និព្វាន ជាទីអស់ជរា និងមច្ចុ ដោយប្រការដូច្នេះ ។

ម្យ៉ាងទៀតក្នុងការមានគូស្រករបស់គ្រួសារនីមួយៗ គិតគូរឱ្យតម្លៃត្រឹមតែស្វែងរកសុភមង្គលទៅលើទ្រព្យសម្បត្តិ ទៅណាមកណាជួបគ្នាសួរគ្នាចេះត្រឹមតែពាក្យថា "សុខសប្បាយ" ក៏នៅក្នុងគំនិតគិតតែពីទ្រព្យសម្បត្តិដដែល រៀនសូត្រវិជ្ជា ផ្លូវលោក មានចំណេះជ្រៅជ្រះយ៉ាងណាក៏គិតត្រឹមតែពីប្រាថ្នាចង់បាននេះចង់បាននោះ ម្ល៉ោះហើយ ទើបព្រះសម្មាសម្ពុទ្ធត្រាស់ដឹងធម៌ជ្រាបការពិតទ្រង់សម្តែងធម៌ប្រោសសត្វដោយករុណាទិគុណដើម្បី ឱ្យតម្លៃទៅលើគុណភាពជីវិតរបស់មនុស្សតាមថ្នាក់ តាមលំដាប់ដូចជា មាតាបិតាសង្គ្រោះកូន ដោយព្រហ្មវិហារធម៌ ៤ ឯកូនត្រូវ

គោរពប្រណិបត័ន៍ ចំពោះគុណមាតាបិតាដោយស្ថាន ៥៧ គ្រូនិងសិស្ស ស្វាមីនិង ភរិយាក៏ដូចគ្នា ចំណែកមិត្តសម្លាញ់ក៏មានធម៌ សង្គ្រោះគ្នាដែរ ។

ការរស់នៅក្នុងលោកត្រូវជួយលោកដើម្បីធ្វើឱ្យលោកបានសុខមិនគិតគួរពីប្រយោជន៍ផ្ទាល់ខ្លួន ដោយជួយធ្វើការងារបម្រើលោកនៅពេលណាលោកត្រូវការចូលរួម បំពេញមុខងារតួនាទីក្នុងឋានៈជាឧបាសកឧបាសិកា ដូចជា បម្រើព្រះភិក្ខុសង្ឃតាមវត្តអារាម ក្នុងបំណងជួយជាកម្លាំងលើក តម្កើងព្រះពុទ្ធសាសនា ជួយកូន ជួយចៅ ឱ្យមានការប្រព្រឹត្តនូវសីលធម៌ ល្អ ដល់អ្នកដទៃក្នុងសង្គម គោរពគុណព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ដឹងគុណ មាតាបិតា និងលោកគ្រូអាចារ្យ ក៏កុំភ្លេចជួយខ្លួនឯង ដូចជាសិក្សា មុខវិជ្ជា ផ្លូវលោក ផ្លូវធម៌ឱ្យបានចេះជ្រៅជ្រះ ដើម្បីយកមកសម្តែងប្រាប់ដល់ ពុទ្ធបរិស័ទទូទៅ ចូលរួមធ្វើបុណ្យទានគ្រប់និន្នាការលោក និងព្រះពុទ្ធសាសនាព្រមទាំងជួយផ្សព្វផ្សាយព្រះធម៌តាមរយៈការសរសេរសៀវភៅធម៌និង សមាទានសីល ៥ ឧបោសថសីល ឬ អតិរេកសីលតាមអធ្យាស្រ័យ ដោយហោចត្រូវសម្លឹងពិនិត្យនូវលក្ខណៈសម្បត្តិខ្លួនឱ្យបានសមរម្យក្នុងសង្គមបំណងជួយសង្គ្រោះគ្នាហៅថា សង្គហវត្ថុ៤ យ៉ាង (ដកស្រង់ពីក្នុងសៀវភៅពរ ៤ ប្រការ របស់លោកគ្រូអគ្គបណ្ឌិតជាម្ចាស់) ដូចតទៅនេះ ÷

**១-ទាន** : ឱ្យនូវវត្ថុដែលគួរឱ្យ មានបច្ច័យ៤ ឬ ជួយសង្គ្រោះដោយឱ្យដើមទុនសម្រាប់មុខរបររកទទួលទាន ឱ្យការចេះដឹងនូវសិល្បវិទ្យា ទាំងឡាយនិងចំណេះដឹងផ្សេងៗព្រមទាំងបង្រៀននូវសីលធម៌ ចៀសវាងការប្រកបអាជីវកម្មខុសក្នុងសង្គម ។

**២-បិយវាចា** : ពោលពាក្យពីរោះមានប្រយោជន៍ដល់អ្នកស្ដាប់ដោយពាក្យសំដីល្អដូចផ្កា ឬ ដូចទឹកឃ្មុំប្រាប់នូវប្រយោជន៍តាមហេតុផលជាក់ស្ដែងចេះនិយាយឱ្យកម្លាំងចិត្តក្នុងផ្លូវល្អ និយាយឱ្យកើតការព្រមព្រៀងដល់គ្នា នឹង គ្នាជាដើម ។

**៣-អត្ថចរិយា** ធ្វើនូវប្រយោជន៍ឱ្យដល់អ្នកដទៃ គឺជួយដោយកម្លាំងកាយ ខ្វល់ខ្វាយក្នុងកិច្ចការផ្សេងៗ បំពេញនូវសាធារណប្រយោជន៍ ព្រមទាំងជួយដោះស្រាយនូវបញ្ហា ទំនុកបម្រុង ផ្ដុងផ្ដើមក្នុងការរៀនសូត្រជាដើម ។

**៤-សមានត្តា** រៀបចំខ្លួនឱ្យចូលចុះជាមួយមនុស្សល្អ មិនក្បត់ចិត្តមិត្តភក្តិ បដិបត្តិស្មោះស្មើជាមួយនឹងមនុស្សទាំងឡាយ មិនប្រព្រឹត្តបោកប្រាសទៅលើជនទាំងឡាយ រួមសុខរួមទុក្ខ រួមដឹង រួមដោះស្រាយដើម្បីប្រយោជន៍សុខទាំងអស់គ្នា ។

សរុបសង្គហវត្ថុ បានសេចក្តីថា ជួយឱ្យរស់ ជួយឱ្យរបស់ ជួយឱ្យដើមទុន ជួយឱ្យចេះដឹងនេះជាសង្គហវត្ថុទី ១ ។ ជួយដោយពាក្យសម្តីនេះជាសង្គហវត្ថុទី ២ ។ ជួយដោយកម្លាំងការងារឱ្យបាននូវប្រយោជន៍នេះជាវត្ថុសង្គហទី ៣ ។ ចំណែកការជួយដោយការតម្កល់ខ្លួនស្មើ រួមសុខរួមទុក្ខ មិនរត់ចោលគ្នា បើមានបញ្ហាជួយដោះស្រាយនេះជាសង្គហវត្ថុ ប្រការទី ៤ (គោលធម៌ ស្រង់ចាកសិង្គាលកសូត្រ) ។

ម្យ៉ាងទៀតលោកនេះសម្បូណ៌ទៅដោយគ្រឿងស្ពោកគ្រោក ជារបស់សេនាមារដែលចូលចិត្តទាញយកមនុស្សសត្វឱ្យរស់នៅក្រោមអំណាចដោយបន្លឺវាចាស្រែកហ៊ោតឹកកងថា សប្បាយណាស់ៗ ព្រោះ អាមិសៈហាក់ដូចជាកំពុងធ្លាក់ក្នុងអន្លង់ ៤ មាន **កាមោឃៈ ភវោឃៈ ទិដ្ឋោឃៈ និង អវិជ្ជោឃៈ** ក៏ស្រែកដង្ហោយហៅគេឱ្យជួយស្រង់ទៅវិញ ។ ទាំងនេះជានិមិត្តរបស់កិលេសមារ សម្រាប់អ្នកវង្វេងផ្លូវ ឯបុគ្គលមួយចំនួនមិនធ្លាក់ក្នុងអន្លង់នេះ បានធ្វើដំណើរឆ្លងស្ពាន ឬកំពុងដើរឆ្លង គឺអរិយមគ្គអង្គ ៨ ដោយអ្នកខ្លះបានដល់ត្រើយរួចពីលោក តាមការអប់រំចម្រើនសតិប្បដ្ឋានវិបស្សនាមានព្រះសម្មាសម្ពុទ្ធជាម្ចាស់ ព្រះអង្គសម្តែងប្រាប់នូវព្រះធម៌តម្កល់ទុកជាគម្ពីរក្បួនច្បាប់ ក្នុងព្រះត្រៃបិដក និងដល់អនុពុទ្ធជាព្រះសង្ឃសាវក ឧបាសក ឧបាសិកា ព្រមទាំង ពុទ្ធបរិស័ទ

ទាំងអស់គ្នាប្រតិបត្តិតាម ។ តាមធម្មតា ការដឹង ការមើល លោកឃើញច្បាស់លុះត្រាតែចេញរួចពីលោកទៅឈរនៅពីក្រៅលោក ទើបសម្លឹងមើលឃើញលោកច្បាស់ពិតប្រាកដជាក់លាក់ (ឃើញ សច្ចធម៌) បើមិនទាន់ចេញពីលោក នៅក្នុងលោកពិតជាមើលលោកមិនឃើញច្បាស់ឡើយ ដោយហេតុនោះលទ្ធិសាសនាដទៃ ពុំអាចមើលឃើញលោកច្បាស់បាន ត្រឹមតែឈរនៅក្នុងលោកមើលឃើញសើៗ ស្មានៗ សូម្បីខ្លួន ឯងក៏មើលមិនឃើញច្បាស់ដែរហើយក៏ចេះតែសរសេរចម្លងពាក្យប្រៀនប្រដៅអប់រំ តាមការយល់ឃើញនូវ **ទិដ្ឋិ** នោះៗ ឱ្យដល់អ្នកសិក្សាតៗគ្នាជំនាន់ក្រោយ ។ យ៉ាងដូច្នេះបានជា លោកត្រូវភ្លើងរាគៈ ភ្លើងទោសៈ ភ្លើងមោហៈ ឆេះសន្ធោសន្ធៅនៅពីលើក្បាលយើងរាល់ថ្ងៃ រួចក៏ស្រែកថាក្តៅណាស់ៗ ដែលបណ្តាលឱ្យមនុស្សទូទៅដណ្តើមគ្នារស់ ប្រណាំងប្រជែង ដោយសម្ការវាយប្រហារគ្នាជានិច្ចកាល ទោះបី ***"អង្គការ សហប្រជាជាតិ"*** ជួយសម្រុះសម្រួលផ្សះផ្សារយ៉ាងណាក៏នៅតែដោះស្រាយមិនបាន ព្រោះកិលេសតណ្ហាចម្រើនខ្លាំងពេក ដូចជា នៅសម័យ ពុទ្ធកាលព្រះរាជាវិឌូឌភៈ ខឹងនឹងព្រះញាតិវង្សដោយសេចក្តីថា ប្រមាថ មើលងាយទ្រង់តាំងពីកាលនៅព្រះកុមារ ក៏ចងគំនុំថា បើពេលណាបាន ឡើងសោយរាជគ្រប់គ្រងរាជសម្បត្តិ នឹងលើកកងទ័ពមកកម្ទេចសក្យ ត្រកូលឱ្យអស់សូម្បីកូន

តូចនៅបៅដោះក៏មិនទុកដែរ លុះផែនការបានសម្រេច ព្រះអង្គក៏ធ្វើ ដូច្នោះ មែននេះឯងភ្លើងទោសៈស្រេបជាមួយគ្នា ក្នុងពេលនោះ ព្រះសម្មាសម្ពុទ្ធ ទ្រង់យាងទៅឃាត់បីដង ហើយទ្រង់គង់ នៅក្រោមដើម ឈើគ្មានស្លឹក ដោយទុកឱកាសឱ្យព្រះរាជាវិឌូឌភៈទ្រង់គិត ពិចារណា ។

ព្រះរាជាទតឃើញព្រះសមណគោតមភ្លាម ក៏នមស្ការថ្វាយបង្គំទូល សុំឱ្យព្រះអង្គនិមន្តយាងទៅគង់ក្រោមម្លប់ដើមឈើវិញ ឯព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់ថា : ម្នាល វិឌូឌភៈ "ក្រោមដើមឈើក្តៅមែនហើយ តែសូមកុំ ឱ្យញាតិរបស់តថាគតក្តៅ" រួចស្តេចយាងត្រឡប់ទៅវិញ លុះលើកទីបី មិនស្តាប់ពាក្យទូន្មានព្រះសម្ពុទ្ធក៏បានប្រព្រឹត្តអំពើកាប់សម្លាប់តាមកំហឹង របស់ខ្លួន ឥតត្រាប្រណីដោយព្រះសម្មាសម្ពុទ្ធមិនទ្រង់យាងទៅឃាត់ដូច កាលពីមុនព្រោះទ្រង់ពិចារណា ឃើញដោយព្រះប្រាជ្ញាញាណថា សត្វពួកនេះ មានកម្មពីអតីតជាតិចងពៀរវេរា និង គ្នាដូចមានព្រះគាថាទ្រង់សម្តែងទុក :

**នត្ថិ កម្មំ សមំ ពលំ**

**នត្ថិ ទោសោ សមោ កលិ**

កម្លាំងអ្វីស្មើដោយកម្លាំងកម្មមិនមាន កំហុសអ្វីស្មើដោយទោសៈ មិនមាន ។

ព្រះសម្មាសម្ពុទ្ធប្រៀនប្រដៅមនុស្ស ឱ្យចេះអាណិតអាសូរគ្នា មិនឱ្យឈ្លោះទាស់ទែងគ្នា បានអ្វីៗចែកគ្នារស់ទោះតិចក្តីច្រើនក្តីក៏ខំអត់ធ្មត់ ដើម្បីធ្វើដំណើរទៅរកទីបរមសុខ ។ ការរស់នៅប្រកបដោយធម៌ជាការរស់នៅយ៉ាងសុខស្ងប់ជាងការរស់នៅសម្បូណ៌ហូរហៀរទៅដោយទ្រព្យសម្បត្តិ ព្រោះថាទីណាក៏ដោយគេត្រូវការធម៌សម្រាប់រស់ បើខ្វះព្រះធម៌ គឺ បញ្ញាយល់ហេតុផលយកមកទុកក្នុងខ្លួន សម្រាប់ជួយដោះស្រាយទេ ការមានទ្រព្យសម្បត្តិច្រើនៗយ៉ាងណា ក៏ប្រែក្លាយទៅ ជាពិសពុលសម្លាប់ខ្លួនឯងទៅវិញ ដូចមានរឿងក្នុងជាតករបស់ "សត្វសុនខព្រះពោធិសត្វ" នៅក្នុងមង្គលត្ថទីបនីប្រែ ភាគ៣ ទំព័រ ១៦៩ ទ្រង់សម្តែង ដូចតទៅ :

ក្នុងអតីតកាល ព្រះពោធិសត្វ សោយព្រះជាតិជាសត្វសុនខចោមរោមទៅដោយពួកសត្វសុនខយ៉ាងច្រើនរស់នៅក្នុងព្រៃស្មសានដ៏ធំមួយ ។ ថ្ងៃមួយ ព្រះរាជាក្រុងពារាណសីទ្រង់ព្រះក្រសាលក្នុងឧទ្យានរហូតអស់ មួយថ្ងៃ លុះព្រះអាទិត្យអស្តង្គត ទ្រង់ស្តេចយាងត្រឡប់មកកាន់ព្រះនគរ ដោយរាជរថដ៏ប្រសើរ ។ ពេលនោះភ្លៀងកំពុងធ្លាក់រហូតពេលរាត្រីដែលមានពួកមនុស្សបញ្ឈប់រាជរថត្រង់ទីព្រះលានហ្លួងធ្វើឱ្យពួកសត្វសុនខដែលគេចិញ្ចឹមទុកក្នុងរាជត្រកូលទាំងឡាយចុះពីប្រាសាទនាំគ្នាកកេរស៊ីនូវខ្សែសម្រាប់រុំព័ទ្ធនិងខ្សែសម្រាប់ចងរាជរថ ។ លុះថ្ងៃស្អែកឡើងពួក

មនុស្សទាំងនោះបានក្រាបទូលដល់ព្រះរាជា ធ្វើឱ្យព្រះអង្គទ្រង់ព្រះពិរោធ ។ ព្រះរាជាទ្រង់ត្រាស់បញ្ជាឱ្យគេសម្លាប់សត្វសុនខទាំងឡាយចោលក្នុង ទីកន្លែងដែលពួកគេបានឃើញ ។ តាំងពីពេលនោះពួកសត្វសុនខទាំងនោះភិតភ័យញាប់ញ័រ ក៏បានគេចខ្លួនរត់ទៅរកព្រះពោធិសត្វ ព្រះពោធិសត្វ ដឹងហេតុនោះហើយ ទើបនឹករលឹក ដល់បារមីទាំងឡាយ រួចទ្រង់អធិដ្ឋានថា " សូមកុំឱ្យអ្នកណាម្នាក់ហ៊ាន បោះដុំដី ឬ អន្លូងវាយលើខ្នងខ្ញុំឡើយ " រួចក៏ដើរចូលទៅកាន់ព្រះនគរ តែម្នាក់ឯង ពុំមានមនុស្សណាម្នាក់ក្រោធខឹង នឹងព្រះពោធិសត្វទាំង ក្រឡេកមើលក៏មិនឃើញដែរ ។ ព្រះពោធិសត្វបាន ស្ទុះចូលទៅក្រោម ព្រះរាជអាសនៈរបស់ព្រះរាជាដែលស្តេចកំពុងគង់នៅក្នុងសាលាវិនិច្ឆ័យ ។ ព្រះរាជាទ្រង់ហាមឃាត់រាជបុរសទាំងឡាយមិនឱ្យបណ្តេញព្រះពោធិសត្វចេញទៅក្រៅ ។ ព្រះពោធិសត្វសម្រាកបន្តិចក៏ចេញមកថ្វាយបង្គំព្រះរាជា ទើបក្រាបទូលសួរថា " ព្រះអង្គទ្រង់ត្រាស់បញ្ជាឱ្យរាជបុរស សម្លាប់សព្វសត្វសុនខទាំងឡាយមែនឬ? " ។

**-ព្រះរាជា :** អើមែនហើយ យើងឱ្យសម្លាប់ ។

**-ព្រះពោធិសត្វ :** បពិត្រព្រះអង្គជាធំជាងនរជន តើសត្វសុនខទាំងនោះមានការខុសឆ្គងយ៉ាងដូចម្តេចទៅ ?

**-ព្រះរាជា :** ពួកវាខាំស៊ីខ្សែជ្រាម និង ខ្សែចងរាជរថ ។

**-ព្រះពោធិសត្វ :** ព្រះអង្គទ្រង់ជ្រាបនូវសុនខ ដែលកកេរស៊ី ឬ ?

**-ព្រះរាជា :** យើងមិនដឹង ។

**-ព្រះពោធិសត្វ :** បពិត្រព្រះសម្មតិទេព ការដែលព្រះអង្គមិនទ្រង់ជ្រាប ហើយត្រាស់បញ្ជាឱ្យរាជបុរសសម្លាប់សុនខទាំងឡាយក្នុងទីកន្លែងដែលឃើញនោះមិនសមគួរឡើយ ។

**-ព្រះរាជា :** យើងបញ្ជាឱ្យសម្លាប់សុនខដោយសេចក្តីថា ចូរសម្លាប់ពួកសុនខទាំងឡាយខាំស៊ីស្បែកជ្រាមរាជរថ ។

**-ព្រះពោធិសត្វ :** តើពួកទាំងនោះសម្លាប់សុនខទាំងអស់ ឬ នៅសល់ខ្លះដែរយ៉ាងណា? ។

**-ព្រះរាជា :** ពួកសុនខដែលមិនត្រូវសម្លាប់នៅមាន គឺ ពួកសត្វសុនខដែលគេចិញ្ចឹមក្នុងសំណាក់របស់យើង ។

**-ព្រះពោធិសត្វ :** ក្រាបទូលថា " បពិត្រព្រះមហារាជ ក្នុងពេលឥឡូវនេះ បើពិតប្រាកដដូច្នេះមែន ព្រះអង្គទ្រង់ដល់នូវអគតិដោយអំណាចនៃឆន្ទាគតិជាដើមមិនមែនទេឬ? កិរិយាដល់នូវអគតិ មិនសមគួរទេ និងមិនមែនជារាជធម៌ឡើយ ឈ្មោះថាព្រះរាជាទ្រង់ជាអ្នកស្វែងរកហេតុ និងមិនមែនហេតុ និងដូចជាជញ្ជីង " ។

ព្រះរាជាទ្រង់ត្រាស់សួរថា : ម្នាលបណ្ឌិតតើអ្នកដឹងបានថា សុនខឈ្មោះឯណាកកេរស៊ីស្បែកនៃរថ? ។ ព្រះពោធិសត្វទូលថា ទូលព្រះបង្គំដឹង ស្បែករាជរថនោះ ពួកសុនខដែលព្រះអង្គចិញ្ចឹមទុកក្នុងរាជត្រកូលកកេរស៊ីនោះឯង សូមព្រះអង្គត្រាស់ឱ្យរាជបុរស នាំយកទឹកដោះរាវជូរនិងស្មៅ ចិញ្ច្រៀនបានបន្តិចរួច ត្រាស់ឱ្យច្របាច់លាយចូលគ្នាទើបបញ្ច្រុកចូលទៅក្នុងពោះសុនខទាំងឡាយនោះ ព្រះរាជាទ្រង់ធ្វើតាមព្រះពោធិសត្វ ។ គ្រានោះសុនខទាំងឡាយបានក្អួតនូវទឹកដោះរាវជូរនិងស្មៅចិញ្ច្រៀនព្រមទាំងស្បែកចេញមកក្រៅ ។ ទ្រង់ទតឃើញយ៉ាងដូច្នេះ ព្រះរាជាមានសេចក្ដីត្រេកអរ ជាពន់ពេកដោយពោលថា " ព្យាករណ៍ របស់ស្ដេចសុនខនេះប្រៀបដូចការព្យាករណ៍របស់ព្រះសព្វញ្ញុពុទ្ធ" រួចក៏ទ្រង់បូជា ដល់ព្រះពោធិសត្វនូវស្វេតច្ឆត្រ ។ ពេលនោះព្រះពោធិសត្វ សម្ដែងធម៌ដល់ព្រះរាជាដោយ ធម្មចរិយគាថាទាំង ១០ មានជាអាទិថា :

បពិត្រព្រះមហារាជដ៏ជាក្សត្រ សូមព្រះអង្គទ្រង់ប្រព្រឹត្តធម៌ចំពោះព្រះជនកនិងព្រះជននី រួចទូលថា " សូមព្រះអង្គទ្រង់ស្ដេច កុំប្រមាទឡើយ" ដោយបានញ៉ាំងព្រះរាជាឱ្យស្ថិតនៅក្នុងបញ្ចសីល រួចក៏ថ្វាយស្វេតច្ឆ័ត្រត្រឡប់ទៅព្រះរាជាវិញ ក៏បានគេចខ្លួនចេញទៅ ។ ព្រះរាជាទ្រង់តាំងនៅនិច្ចភត្ត ដូចជាក្រយាស្ងោយរបស់ព្រះអង្គក៏ប្រទានដល់សត្វសុនខ

ទាំងឡាយទាំងពួង ។ ចំណែកពួកជនជាច្រើនតាំងនៅក្នុងឱវាទ របស់ព្រះពោធិសត្វ បានធ្វើកុសលមានទានជាដើមលុះស្លាប់ទៅក៏បានទៅកើតក្នុងទេវលោក ។ **កុក្កុរោវាទ** បានប្រព្រឹត្តទៅរហូតមួយម៉ឺនឆ្នាំយ៉ាងនេះឯង។ (សម្ដែងនៅក្នុង អដ្ឋកថា កុក្កុរជាតកក្នុង តតិយវគ្គឯកនិបាត ) ។

សេចក្ដីក្នុងរឿងព្រះជាតកនេះទុកជាគតិធមិមួយ ដល់សង្គមមនុស្ស ដើម្បីជ្រាបថា មានតែសប្បុរស (បញ្ញា) ទេដែលជ្រាបដឹងការពិតក្រៅពីសប្បុរសពុំមានសមត្ថភាព នឹងយល់ហេតុយល់ផលឱ្យបានជាក់ច្បាស់ ដើម្បីជួយដោះស្រាយនូវសេចក្ដីទុក្ខសោកដល់សត្វទាំងឡាយ ដូចជាសុនខព្រះពោធិសត្វនេះ ឯង សំខាន់ចេះនិយាយភាសាមនុស្ស ទ្រង់ជ្រាបដោយព្រះបញ្ញាញាណ ហើយក៏គ្មានអ្វីក្រៅពីចិត្តចេតសិករូបដូចជានៅក្នុងរឿងវិឌូឌភៈ ដូចគ្នា (បើកបញ្ញត្តិចេញ) មានតែបរមត្ថធមិ គឺ លោភៈ (ប្រាថ្នាចង់បាន) ជាតួតណ្ហា ទោសៈប្រទូស្ត មោហៈវង្វេង អលោភៈ មិនលោភៈ អទោសៈ មិនខឹងក្រោធ អមោហៈ មានបញ្ញា ស្មារតីតាំងនៅក្នុងការមិនប្រមាទ ដែលធ្វើកិច្ចកសាងលោក ឬ បំផ្លាញដោយអកុសល ១២ដួង មានទោសខ្លាំងក្លាជាដើម ចំណែកព្រះពោធិសត្វតួអង្គព្រះសព្វញ្ញុពុទ្ធ មានមេត្តា ករុណាជួយប្រោសសត្វជាសោភណចិត្ត មិនក្រៅអ្វីពីមហាកុសល ៨ ដួង ដែលបានអប់រំកសាងបារមីច្រើនកប្បមក

ហើយដើម្បីសម្អាសម្ពោធិញ្ញាណ របស់ព្រះអង្គក្នុងបំណងតែមួយ គឺសេចក្ដីសុខដល់សត្វទូទៅរហូតដល់ទេវតាព្រមទាំងពពួកព្រហ្មទាំងឡាយផង ។

លោកនេះចម្រើនទៅដោយកិលេស ដណ្ដើមគ្នារស់ពិតមែន ប៉ុន្តែនៅពេលដែលមានព្រះសម្មាសម្ពុទ្ធត្រាស់ដឹងឡើងក្នុងលោកបានធ្វើឱ្យ ពួកសត្រូវទាំងឡាយភ័យខ្លាចរត់ចៀសចេញពីចិត្តសន្តានរបស់មនុស្ស ដោយធម្មទេសនា បង្ហូរស្រោចដូចទឹកភ្លៀងលាងជម្រះនូវក្អែល គឺកិលេសរសាត់ហូរបាត់តាម ទឹកដោយព្រះធម្មទេសនា ដ៏មានខ្លឹមសារពីរោះចាក់ចូលជ្រៅទៅក្នុងដួងចិត្ត របស់ពួកសត្វទាំងឡាយ ប្រៀបដូចព្រួញសរដ៏មុតបាញ់ទម្លុះនូវពពួកជនអន្ធពាល នៃពួកកិលេសមារ ធ្វើឱ្យរត់ប៉ាកខ្លបខ្លាច ចុះចាញ់ដោយ ព្រះបញ្ញាញាណ ដ៏មានឥទ្ធិពលសក្តិសិទ្ធដូចទឹកអម្រិតអាស្រ័យឧបនិស្សយបច្ច័យ រហូតបានសម្រេចអរហត្តផល កម្ចាត់បង់នូវជាតិជរាមរណៈមួយចំនួនខ្លះដែលមាន ទេវតា និង មនុស្សជាច្រើនចុះមកអបអរសាទរគោរព បូជាព្រះទសពល គ្រប់ទិសទីធ្វើឱ្យកក្រើករំជើបរំជួលដល់ស្ដេចមារនៅ ស្ថានសួគ៌ ៦ ជាន់ (បរនិម្មិតវសវត្តី) ចុះមកធ្វើអន្តរាគម សូមយាងព្រះអង្គបរិនិព្វាន ដើម្បីចងសត្វទុកក្នុងអំណាចខ្លួន ។ ចំណែកនាង បជាបតិគោតមី បានរួចខ្លួន ចេញពីលោកជាព្រះអរហន្តីក៏

ទៅសុំវរោកាស គឺឱកាសដ៏ វិសេសនូវពរពីព្រះដ៏មានព្រះភាគ បំណងនឹងទ្រង់យាងចេញចាកពួកគណៈ ទៅគង់នៅម្នាក់ឯងក្នុងទីកន្លែងណាមួយពិចារណាធម៌ ។ ព្រះសម្មាសម្ពុទ្ធ បានទ្រង់ប្រទាននូវកថាវត្ថុ ១០យ៉ាង ដល់នាងទុកជាទីរលឹកសម្រាប់លោក និងសាសនាព្រះអង្គក្នុងអនាគតកាលដូចខាងក្រោមនេះ :

**១-អប្បិច្ឆ កថា** ពាក្យពោលនូវ ការប្រាថ្នាតិច

**២-សន្តុដ្ឋិ កថា** ពាក្យពោលនូវ ការសន្តោសក្នុងបច្ច័យ ៤

**៣-បវិវេក កថា** ពាក្យពោលនូវ ការស្ងប់ស្ងាត់

**៤-អសំសគ្គ កថា** ពាក្យពោលនូវ ការមិនរួមជាមួយពួកគណៈ

**៥-វិរិយារម្ភកថា** ពាក្យពោលនូវ ការព្យាយាមចម្រើនកុសល

**៦-សីលកថា** ពាក្យពោលនូវ សីល

**៧-សមាធិ កថា** ពាក្យពោលនូវ សមាធិ

**៨-បញ្ញា កថា** ពាក្យពោលនូវ បញ្ញារួចផុតចាកទុក្ខ

**៩-វិមុត្តិ កថា** ពាក្យពោលនូវ ការរួចផុតចាកទុក្ខ ( អរហត្តមគ្គ)

**១០-វិមុត្តិញាណ ទស្សនកថា** ពាក្យពោលនូវញាណរួចផុតចាកទុក្ខ គឺ អរហត្តផល ។

មនុស្សយើងគ្រប់រូបត្រូវការឱ្យអ្នកនៅជុំវិញ មានមេត្តាករុណាជាកុសលធម៌ អនុគ្រោះជួយគ្រប់ដង្ហើមចេញចូលរាល់ថ្ងៃ មករកយើង ។

**មើលលោកនេះ ដោយការសិក្សាពីលោក** ឱ្យបានដឹងញឹកញាប់រឿយៗថា លោកនេះមានភាពមិនទៀងទាត់ជាធម្មតាតាមទ្វារទាំង ៦ ណាមួយដូចជា :

| | | | |
|---|---|---|---|
| ភ្នែក | ឃើញរូប | ថា | មិនទៀង ជាទុក្ខ |
| ត្រចៀក | ឮសំឡេង | ថា | មិនទៀង ជាទុក្ខ |
| ច្រមុះ | ដឹងក្លិន | ថា | មិនទៀង ជាទុក្ខ |
| អណ្តាត | ដឹងរស | ថា | មិនទៀង ជាទុក្ខ |
| កាយ | ដឹងផោដ្ឋព្វៈ | ថា | មិនទៀង ជាទុក្ខ |
| ចិត្ត | ដឹងធម្មារម្មណ៍ | ថា | មិនទៀង ជាទុក្ខ |

ដែលសភាវៈទាំងអស់សុទ្ធតែមិនទៀងតែងវិនាសប្រែប្រួលទៅវិញជា ធម្មតា អ្វីនោះហៅថាទុក្ខ ជារបស់គ្មានម្ចាស់ហួងហែងថែរក្សាឱ្យឈ្មោះថា អនត្តាពុំមានខ្លួន គឺ ពុំមាន អត្តា តួខ្លួន ពិតប្រាកដ របស់ខ្លួន របស់ខន្ធ របស់អាតនៈ របស់ធាតុ ពុំមានសារៈខ្លឹមសារ កើតឡើងហើយទៀង តែវិនាសទៅវិញ ។

ដោយហេតុនេះបានជាព្រះសម្ពុទ្ធទ្រង់បង្ហាញសភាពពិត នូវលក្ខណៈលោកធ្វើឱ្យមានសេចក្តីសង្វេគដល់លោកគ្មានទីពឹង ដើម្បីកសាងបញ្ញាដើរចេញតាមផ្លូវដ៏ប្រសើររបស់ធម្មជាតិយ៉ាងកម្រ ដែលមានតែការត្រាស់

ដឹងនៃព្រះសម្មាសម្ពុទ្ធបរមគ្រូប៉ុណ្ណោះឯង ។ ការរួចខ្លួនពីលោកក៏មិនមែនជាការលំបាកពេកដែលមនុស្សយើងប្រព្រឹត្តធ្វើមិនបាននោះទេ គ្រាន់តែដាក់ចិត្តថាមិនប្រកាន់នូវរបស់អ្វីទាំងឡាយក្នុងលោករួមផ្សំជាមួយការកំចាត់យើងចេញពីខន្ធ និង ការកសាងបារមីប្រកបដោយសេចក្ដីព្យាយាមមិនដាក់ធុរៈ ជាការប្រសើរយ៉ាងក្រៃលែងរកអ្វីមកប្រៀបឱ្យស្មើពុំបានឡើយ តែសូមកុំភ្លេចស្មារតីថា អបាយភូមិ និងសុគតិសួគ៌នៅជាប់ជាមួយគ្នាក្នុងលោកអាយតន ៦ ។

សេចក្ដីបញ្ចប់ក្នុងខ្លឹមសារ នៃលោកទស្សនៈនេះជាការបង្ហាញនូវសភាវៈទាំងឡាយថា :

សព្វេ សង្ខារា អនិច្ចាតិ យទា បញ្ញាយ បស្សតិ
អថ និព្វិន្ទតិ ទុក្ខេ ឯស មគ្គោ វិសុទ្ធិយា ។
សព្វេ សង្ខារា ទុក្ខាតិ យទា បញ្ញាយ បស្សតិ
អថ និព្វិន្ទតិ ទុក្ខេ ឯស មគ្គោ វិសុទ្ធិយា ។
សព្វេ ធម្មា អនត្តាតិ យទា បញ្ញាយ បស្សតិ
អថ និព្វិន្ទតិ ទុក្ខេ ឯស មគ្គោ វិសុទ្ធិយា ។

**ប្រែ** សង្ខារទាំងឡាយទាំងពួកមិនទៀងជាទុក្ខ ធម៌ទាំងឡាយទាំងពួងជាអនត្តា ក៏ជាទុក្ខទាំងអស់ បញ្ញាបានដឹងយ៉ាងដូច្នេះ ក៏មានសេចក្ដីនឿយណាយប្រាសចាកតម្រេក នោះឯង ជាសេចក្ដីបរិសុទ្ធនៃចិត្ត ។

ដោយសេចក្ដីបញ្ជាក់ច្បាស់លាស់ថា លោកនេះមានលក្ខណៈមិនទៀង ជាសេចក្ដីទុក្ខដែលបៀតបៀនគៀបសង្កត់ មានបច្ច័យប្រជុំតាក់តែង ក្ដៅរោលរាល ប្រែប្រួលតាមធម្មតារបស់ហេតុប្បច្ច័យ ពុំមានម្ចាស់គ្រប់គ្រងឡើយ ។ ម្យ៉ាងទៀតពាក្យពេចន៍ អក្ខរាវិរុទ្ធទាំងអស់ ក្នុងដំណើររឿងនេះក៏សូមជនានុជនអ្នកសិក្សា ព្រះធម៌មេត្តាជួយកែសម្រួលដោយអនុគ្រោះបើឃើញ ខុសឆ្គាំឆ្គង ។

## មេរៀនជីវិត

សម្លឹងមើលលោកគួរសង្វេគ តក់ស្លុតក្រៃពេកគ្មានកក់ក្ដៅ
តែងតែប្រែប្រួលវិនាសទៅ គ្មានសល់អ្វីនៅទីពឹងបាន ។
ទោះបីខំប្រឹងធ្វើការងារ គ្រប់ទិនទិវាលំបាកប្រាណ
ស្វែងរកសម្បត្តិជូនក៏បាន តែចិត្តក្លាហានស៊ូមិនឈប់ ។
រកទ្រព្យបានហើយមិនគង់វង់ ចេះតែបាត់បង់គ្មានអ្វីផ្ទប់
ខំរត់ម្ទូតូឆ្មៀតពេលយប់ ខន្ធប្រាំមេជប់ស្រូបយកអស់ ។
ងាកទៅពឹងកូនញាតិសន្ដាន គេច្រានយើងចេញគ្មានស្រណោះ
រកសព្វរកគ្រប់តាមកៀនកោះ រកគ្មានចន្លោះក្នុងលោកិយ ។
មានតែពឹងធម៌ក្នុងខ្លួនប្រាណ ទើបបានស្រាកស្រាន្តជួយប្រណី
ពឹងចិត្តខ្លួនឯងទើបប្រពៃ ចៀសអ្នកដទៃសង្ឃឹមសុខ ។

ចប់

**សៀវភៅដែលបានរៀបរៀងចងក្រងរួចមាន ៦ ចំណងជើង :**

១- សង្គាយនា

២- ពុទ្ធព្យាករណ៏

៣- សភាវៈ

៤- ធម្មដ្ឋិតិ

៥- ក្រសែជីវិត

៦- លោកទស្សនៈ

ដែលខ្ញុំនឹងកំពង់បន្តការងារនេះរៀងរហូត ។ ចំពោះវិភាគទានក្នុងការជួយឧបត្ថម្ភបោះពុម្ព កើតចេញពីសន្តានចិត្តជ្រះថ្លារបស់ពុទ្ធបរិស័ទទាំងអស់គ្នា ។

អាស្រ័យហេតុនេះ លោកអ្នកមានបំណងចង់ជួយចូលរួមបំពេញនូវមហាកុសលក្នុងដំណើរការធម្មទានដ៏កម្រ និង បច្ច័យ៤ សូមមេត្តាទំនាក់ទំនងតាម ទូរស័ព្ទលេខ **០១១ ៦៧៣ ៤០៦** ឬ ក៏អាចផ្ញើតាមរយៈអ្នកដទៃណាក៏បាន ។

***សូមអរព្រះគុណ!***

# ពុទ្ធបរិស័ទចូលរួមបោះពុម្ព

- លោក **សុខ សូរិយា** និងអ្នកស្រី **ធូ វេជ្ជសា** ព្រមទាំងបុត្រ 50$
- លោក **ញិប ប៉េងហាក់** និងភរិយា ព្រមទាំងបុត្រ } 50$
- លោក **ថាប ឆេង** និងភរិយា ព្រមទាំងបុត្រ }
- ឧបាសិកា **ឧត្តមា ពេជ្រ អូន** ព្រមទាំងកូនចៅ 20$
- ឧបាសក **ប៉ុល នាង** និងឧបាសិកា ក្រៀល ស៊ីយ៉ា ព្រមទាំងកូនចៅ 20$
- ឧបាសក **សុខ ឡុង** ព្រមទាំងកូនចៅ 20$
- ឧបាសិកា **មាឃ យ៉ារី** ព្រមទាំងកូនចៅ 20$
- ពុទ្ធបរិស័ទចូលរួម 1$ ចំនួន 12 នាក់ ស្មើនឹង 20$
- ឧបាសិកា **ឈាង គីមណា** ព្រមទាំងកូនចៅ 10$
- លោក **កាំង លាងខ័ណ្ឌ** និងអ្នកស្រី **សួន ចំពូរ** 10$
- លោក **គង់ តារា** និងឧបាសិកា ព្រមទាំងកូនចៅ 10$
- ឧបាសក **ធូ វ៉ា** និងឧបាសិកា **រស់ ធួក** ព្រមទាំងកូនចៅ 10$
- លោក **ហ៊ួត ស៊ីវន** និងភរិយា 10$
- ឧបាសក **អ៊ុក អូន** និងភរិយា ព្រមទាំងកូនចៅ 10$
- ឧបាសិកា **ង៉ូយ ងីម** នៅអូស្ត្រាលី 10$
- ឧបាសក **ជិន ជេត** និងឧបាសិកា **ផៃ ចាន់ឌី** ព្រមទាំងបុត្រ 10$
- ឧបាសិកា **អ៊ួង ឈុនហួង** និងស្វាមី ព្រមទាំងបុត្រ 10$
- លោក **អ៊ុក សាម៉ាណារ៉ា** និងឧបាសិកា **ហាប តេង** ព្រមទាំងបុត្រ 10$

- ឧបាសក **ឈឹម ហុកអៀន** ព្រមទាំងបុត្រ 10$
- ឧបាសិកា **យឹម សាមុន** ព្រមទាំងកូនចៅ 5$
- ឧបាសិកា **តាំង មុយគាង** និងស្វាមី ព្រមទាំងបុត្រ 5$
- ឧបាសិកា **យូ ផលលាញ** និងស្វាមី ព្រមទាំងកូនចៅ 5$
- ឧបាសក **ចាន់ ប៉ែត** ព្រមទាំងកូនចៅ 5$
- ឧបាសិកា **ខាំ នាងសុខី** ព្រមទាំងកូនចៅ 5$
- ឧបាសិកា **ម៉ម សុខហេង** និងស្វាមី ព្រមទាំងបុត្រ 5$
- លោក **ហៀង សារ៉ា** និងឧបាសិកា **ស្រី ស៊ីវុឌ្ឍា** ព្រមទាំងបុត្រ 5$
- ឧបាសក **ខៀវ កូឡា** និងឧបាសិកា **លឿង លៀងហួរ** ព្រមទាំងបុត្រ 5$
- ឧបាសិកា **តែ ហាន** ព្រមទាំងកូនចៅ 5$
- ឧបាសិកា **យាយ ថូ** ព្រមទាំងកូនចៅ 5$
- ឧបាសិកា **ញ៉ែម ណារីន** ព្រមទាំងកូនចៅ 5$
- អ្នកគ្រូ **ប៉ែន និស្ស័យជាតិ** និងមាតា 5$
- ឧបាសក **ឈួរ ទ្រី** ហៅសាន្ត និងភរិយា ព្រមទាំងបុត្រ 5$
- ឧបាសិកា **ជៅ ស៊ីមន** ព្រមទាំងកូនចៅ 5$
- ឧបាសក **លន់ គីមស៊ុយ** និងឧបាសិកា **លាង មួយហ៊ួត** ព្រមទាំងបុត្រ 5$
- ឧបាសក **ណយ សំប៊ូ** និង **អ៊ុង គីមសឿង** ព្រមទាំងបុត្រ 5$
- ឧបាសក **សំ សាន** និង **ឡៅ ស្រួយ** ព្រមទាំងកូនចៅ 5$
- លោក **អៀង កៅ** និងអ្នកស្រី **លន់ ច័ន្ទថុល** ព្រមទាំងបុត្រ 5$
- ក្មួយ **រមនា** 5$

- លោក **ទូត ស៊ីម៉ារា** និងអ្នកស្រី **ឈៀង សុវណ្ណា** ព្រមទាំងបុត្រ 5$
- លោក **ទ្រឿង សរិទ្ធ** និងអ្នកស្រី **ងី សុវណ្ណធីតា** 5$
- ឧបាសិកា **តាំង លីតាង** និងស្វាមី ព្រមទាំងបុត្រ 5$
- ឧបាសក **អ៊ុម ជួង** ព្រមទាំងកូនចៅ 5$
- ឧបាសិកា **តាំង អ៊ុម** 2$
- លោក **មេង ហុងសួជាតិដារីង** និងភរិយា ព្រមទាំងបុត្រី 80,000៛
- ឧបាសក **យន្ត សួន** និងភរិយា ព្រមទាំងបុត្រ 50,000៛
- ឧបាសក **ឡោ សេងជ្រុន** និងភរិយា ព្រមទាំងកូនចៅ 50,000៛
- ឧបាសក **ពា ពេងស៊ាង** និងឧបាសិកា **យឹម អ៊ាងស្រ៊ុន** ព្រមទាំងកូនចៅ 40,000៛
- ឧបាសិកា **កាំង ប៉ោទាង** ព្រមទាំងបុត្រ 40,000៛
- ឧបាសក **ឃួន យ៉ារ** និងឧបាសិកា **មាស ឡៅស្រ៊ួយ** ព្រមទាំងបុត្រ 40,000៛
- ឧបាសិកា **ហេង នីម** ព្រមទាំងប្អូនស្រី 30,000៛
- ឧបាសិកា **ជួង រ៉ាវី** និងស្វាមី ព្រមទាំងបុត្រ 30,000៛
- ឧបាសក **តេន សាមាន** និងឧបាសិកា **នន្ទ ឈឿញ** 20,000៛
- ឧបាសក **ផុន ភឿង** និងឧបាសិកា **យ៉េត** ព្រមទាំងកូនចៅ 20,000៛
- ឧបាសក **ឈឹម ហុកអៀន** ព្រមទាំងបុត្រ 20,000៛
- ឧបាសិកា **កាំង គួលីន** និងស្វាមី ព្រមទាំងកូនចៅ 20,000៛
- លោក **ទន់ ផារ៉ែន** និងភរិយា ព្រមទាំងកូនចៅ 20,000៛
- លោក **ង៉ូវ ឃៀកហ៊ួ** និងភរិយា ព្រមទាំងបុត្រ 20,000៛

- ឧបាសិកា **ប៉ែន យឿន** និងស្វាមី ព្រមទាំងបុត្រ 20,000៛
- លោក **ម៉េង ហ៊ាង** និងអ្នកស្រី តូច សុខគង់ 20,000៛
- ឧបាសិកា **គីម វ៉ាន់នី** ព្រមទាំងកូនចៅ 20,000៛
- លោក **លី សុទ្ធិ** និងលោកស្រី ព្រមទាំងបុត្រ 20,000៛
- ឧបាសិកា **ជុំ ទូច** ព្រមទាំងកូនចៅ 20,000៛
- ឧបាសិកា **តោ ឡោ** ព្រមទាំងកូនចៅ 20,000៛
- ឧបាសិកា **ឈឹម ផលវិទ្យា** និងមាតាបិតា 20,000៛
- ពុទ្ធបរិស័ទចូលរួម 3000៛ ចំនួន 6 នាក់ ស្មើនឹង 18,000៛
- ពុទ្ធបរិស័ទចូលរួម 2000៛ ចំនួន 7 នាក់ ស្មើនឹង 14,000៛
- ឧបាសិកា **ហេង សុចិន្តា** ព្រមទាំងបុត្រ 10,000៛
- ឧបាសិកា **គីម ថេង** ព្រមទាំងបុត្រ 10,000៛
- ឧបាសិកា **ស៊ុន ជីម** ព្រមទាំងកូនចៅ 10,000៛
- ឧបាសិកា **លឹម ប៊ូ** ព្រមទាំងកូនចៅ 10,000៛
- ឧបាសិកា **វ៉ាន់ មុនី** ព្រមទាំងកូនចៅ 10,000៛
- ឧបាសិកា **ខុន** ព្រមទាំងកូនចៅ 10,000៛
- អ្នកស្រី **ហៃ នីម** និងស្វាមី ព្រមទាំងបុត្រ 10,000៛
- ឧបាសក **ឌុក សារ៉ាត** និងឧបាសិកា **នូ ឆេងហុង** 10,000៛
- ឧបាសិកា **ពៅ គីមឡេង** ព្រមទាំងបុត្រ 10,000៛
- ឧបាសក **ជួន ប៊ុនស្រេង** និង **ទាម អ៊ាងជួន** ព្រមទាំងកូនចៅ 10,000៛
- ឧបាសក **សូ អំ** ព្រមទាំងបុត្រ 10,000៛

- ឧបាសិកា **សុទ្ធ នី** 10,000៛
- ឧបាសិកា **ផន ចន្ធា** និងស្វាមី ព្រមទាំងបុត្រ 10,000៛
- ឧបាសិកា **រស់ សុបញ្ញា** និងស្វាមី ព្រមទាំងបុត្រ 10,000៛
- ឧបាសក **ចំរើន សុខា** ព្រមទាំងកូនចៅញាតិមិត្រ 10,000៛
- ឧបាសក **គង់ សាន** និងឧបាសិកា **ទេព សាម៉ុន** ព្រមទាំងកូនចៅ 10,000៛
- ឧបាសិកា **ចែ ថាំង** 10,000៛
- ឧបាសិកា **ហឺ ហ៊ន** ព្រមទាំងបុត្រ **ឃុន លីហេង** 10,000៛
- ឧបាសិកា **កែន វ៉េត** ព្រមទាំងបុត្រ 10,000៛
- លោកស្រី **អ៊ុក គីម** ព្រមទាំងកូនចៅ 10,000៛
- លោក **ហ៊ឹង ហ៊ន** ព្រមទាំងកូនចៅ 10,000៛
- ឧបាសិកា **សុខ ហៀង** និងស្វាមី ព្រមទាំងបុត្រ 10,000៛
- ឧបាសិកា **អ៊ុក សារុន** ព្រមទាំងបុត្រ 10,000៛
- ឧបាសិកា **ចៅ ឡៃស៊ីម** និងមាតា ព្រមទាំងកូនចៅ 10,000៛
- អ្នកស្រី **សី ណាត** និងស្វាមី 10,000៛
- លោក **សាំង តុល** និងភរិយា ព្រមទាំងបុត្រ 10,000៛
- ឧបាសក **នរ មេត្តា** និងឧបាសិកា **ដួង គុយអេង** ព្រមទាំងបុត្រ 10,000៛
- ឧបាសក **ព្រំ សាធ** និងឧបាសិកា **ហែម រឿន** ព្រមទាំងបុត្រ 10,000៛
- ឧបាសក **ហាង កិន** និងភរិយា ព្រមទាំងបុត្រ 10,000៛
- ឧបាសិកា **នឹម វ៉ាន់នី** ព្រមទាំងបុត្រ 10,000៛
- ឧបាសិកា **សន គីមសេង** ព្រមទាំងកូនចៅ 10,000៛

- ឧបាសិកា **ស្រី កា** ព្រមទាំងកូនចៅ 10,000៛
- លោក **តាំង ហួយ** និងភរិយា ព្រមទាំងបុត្រ 10,000៛
- ឧបាសិកា **ម៉ែន សាត់** ព្រមទាំងកូនចៅ 10,000៛
- ឧបាសិកា **ជុំ ទូច** ព្រមទាំងកូនចៅ 10,000៛
- ឧបាសិកា **ទូច ស៊ីហាន** ព្រមទាំងបុត្រ 10,000៛
- ឧបាសិកា **យាយ រ៉ា** ព្រមទាំងបុត្រ 10,000៛
- ឧបាសក **ប្រាក់ ជុំ** និងភរិយា ព្រមទាំងបុត្រ 10,000៛
- ឧបាសក **កែវ សារ៉ន** និងភរិយា ព្រមទាំងបុត្រ 10,000៛
- ឧបាសិកា **តាំង អ៊ីម** ព្រមទាំងកូនចៅ 10,000៛
- ឧបាសិកា **តូច លីណារ៉ា** និងស្វាមី ព្រមទាំងបុត្រ 10,000៛
- ឧបាសិកា **លាស់ ទេព្វវត្តី** និងស្វាមី ព្រមទាំងបុត្រ 10,000៛
- ឧបាសិកា **អៀង ណារី** និងស្វាមី ព្រមទាំងបុត្រ 10,000៛
- ឧបាសិកា **ម៉ែន សាត់** ព្រមទាំងកូនចៅ 10,000៛
- ឧបាសិកា **ជា កែវមុនី** និងស្វាមី ព្រមទាំងបុត្រ 10,000៛
- ឧបាសិកា **ជា អាយទាង** ព្រមទាំងកូនចៅ 10,000៛
- ឧបាសិកា **ឃុត វ៉ាន់ថា** និងស្វាមី ព្រមទាំងកូនចៅ 10,000៛
- ឧបាសក **អ៊ុង ជា** និងឧបាសិកា **ម៉ម សារ៉ុន** ព្រមទាំងកូនចៅ 10,000៛
- ពុទ្ធបរិស័ទចូលរួម 1000៛ ចំនួន 9 នាក់ ស្មើនឹង 9,000៛
- ឧបាសិកា **តង់ សុម៉ាលី** និងគ្រួសារ **អឿ គន្ធា** និងមាតាបិតា 6,000៛
- ឧបាសិកា **ចាន់ ត្រី** ព្រមទាំងកូនចៅ 5,000៛

| | |
|---|---|
| - ឧបាសិកា **ហែម ណយ** ព្រមទាំងកូនចៅ | 5,000៛ |
| - ឧបាសិកា **ឈឹង យុត** ព្រមទាំងកូនចៅ | 5,000៛ |
| - ឧបាសក **តាម៉ិល** ព្រមទាំងកូនចៅ | 5,000៛ |
| - ឧបាសិកា **ស៊ាង សាវៀម** ព្រមទាំងបុត្រ | 5,000៛ |
| - ឧបាសក **លឿង អ៊ឹម** និងយូ **ម៉ែន** ព្រមទាំងកូនចៅ | 5,000៛ |
| - ឧបាសក **គង់ សន** និងឧបាសិកា **យាយ ផៃ** ព្រមទាំងបុត្រ | 5,000៛ |
| - ឧបាសក **ហួត ហេង** និង **ឈុន បួរ** ព្រមទាំងបុត្រ | 5,000៛ |
| - ឧបាសិកា **គិម សូផាន** ព្រមទាំងបុត្រ | 5,000៛ |
| - ឧបាសក **ស៊ិន ជិម** និង **កែវ ស៊ីវ៉ាន់** ព្រមទាំងបុត្រ | 5,000៛ |
| - ឧបាសក **គុយ យេន** និង **ចក់ គន្ធិ** ព្រមទាំងបុត្រ | 5,000៛ |
| - ឧបាសិកា **កែវ សុផារី** ព្រមទាំងបុត្រ | 5,000៛ |
| - ឧបាសក **បាន ថុង** និងភរិយា ព្រមទាំងបុត្រ | 5,000៛ |
| - ឧបាសិកា **ជួង ខេន** ព្រមទាំងកូនចៅ | 5,000៛ |
| - ឧបាសក **ម៉ែន រាម** និងឧបាសិកា **ទំ សុទ្ធ** ព្រមទាំងបុត្រ | 5,000៛ |
| - លោក **លាង ហ៊ត** និងភរិយា ព្រមទាំងបុត្រ | 5,000៛ |
| - លោកតា **អ៊ឹង ផេងប៊ូ** ព្រមទាំងកូនចៅ | 5,000៛ |
| - លោក **ថោង សាយយុន** ព្រមទាំងកូនចៅ | 5,000៛ |
| - លោក **យិន ឈិញ** និង **ហាក់** ព្រមទាំងកូនចៅ | 5,000៛ |
| - ឧបាសិកា **ម៉ៅ សាមុន** ព្រមទាំងកូនចៅ | 5,000៛ |
| - ឧបាសិកា **ហ៊ិន សុខេង** ព្រមទាំងកូនចៅ | 5,000៛ |

- ឧបាសិកា **យាយអនាម័យ** ព្រមទាំងកូនចៅ 5,000៛
- ឧបាសិកា **អាយ ស្រ៊ីម** ព្រមទាំងកូនចៅ 5,000៛
- ឧបាសិកា **អាយ ស៊ីម** ព្រមទាំងកូនចៅ 5,000៛
- ឧបាសិកា **អ៊ុច សារី** ព្រមទាំងកូនចៅ 5,000៛
- ឧបាសិកា **ចាន់ ខាង** ព្រមទាំងកូនចៅ 5,000៛
- ឧបាសិកា **សុខ ស៊ីផុន** ព្រមទាំងកូនចៅ 5,000៛
- ឧបាសិកា **ឡោ គីមរ៉ូច** ព្រមទាំងកូនចៅ 5,000៛
- ឧបាសិកា **សូ យឿន** ព្រមទាំងកូនចៅ 5,000៛
- ឧបាសក **ផាង ថាន** និង **ង៉ែត ណារឿន** ព្រមទាំងកូនចៅ 5,000៛
- លោក **តី សំអឿន** និងអ្នកស្រី**ឈាង គីមហេង**ព្រមទាំងកូនពុធ នីតា5,000៛
- ឧបាសិកា **ហាយ ធី** និងឧបាសិកា **ឈូ ហ៊ាម** ព្រមទាំងកូនចៅ 5,000៛
- ឧបាសិកា **កែវ ម៉ារិយា** ព្រមទាំងកូនចៅ 5,000៛
- ឧបាសិកា **ឱក ប៊ុន** ព្រមទាំងកូនចៅ 5,000៛
- ឧបាសិកា **ស្រី សារឿន** ព្រមទាំងកូនចៅ 5,000៛
- ឧបាសិកា **កើត វណ្ណី** ព្រមទាំងកូនចៅ 5,000៛
- ឧបាសិកា **សៅ សយ** ព្រមទាំងកូនចៅ 5,000៛
- ឧបាសក **ជៀប ហឿន** និងឧបាសិកា **ហង់ វីរិយា** ព្រមទាំងកូនចៅ 5,000៛
- ឧបាសិកា **ខា នាងសុខី** ព្រមទាំងកូនចៅ 5,000៛
- ឧបាសិកា **ស៊ាង សាវៀម** ព្រមទាំងកូនចៅ 5,000៛
- ឧបាសក **នួន អ៊ិត** និងឧបាសិកា **អ៊ួច គីមហ៊ាន** ព្រមទាំងកូនចៅ 5,000៛

# ពុទ្ធបរិស័ទនៅឡុងប៊ិចសហរដ្ឋអាមេរិក

| | |
|---|---|
| ១- ឧ/ស **ជឹម អេងស្រ៊ន** និងឧ/សិ **វ៉ា សុខគីន** ព្រមទាំងបុត្រ | 50$ |
| ២- ឧ/សិ **តឹម ឡុម** និងកូនចៅ | 30$ |
| ៣- **វ៉ា សុខគីន** | 20$ |
| ៤- **អា ភន** | 20$ |
| ៥- **ចៅ លីតេង** | 20$ |
| ៦- **អ៊ួន ញ៉** | 15$ |
| ៧- **កែវ ឃីម** និង **វង ធន** | 10$ |
| ៨- **អា ជូ** | 10$ |
| ៩- **នួន ប៊ុច** | 10$ |
| ១០- **សុភ តារា** | 10$ |
| ១១- **ប៊ុក សារី** | 10$ |
| ១២- **អ៊ុក ណៃម** | 5$ |
| ១៣- **សោ** | 5$ |
| ១៤- **ខៀ ហ៊ុម** | 5$ |
| ១៥- **អោក សារ៉ុម** | 5$ |
| ១៦- **មាសា ម៉ាន** និង **ស៊ុន ស៊ុនួន** | 5$ |
| ១៧- លោកយាយ **សន** | 5$ |
| ១៨- **ម៉ា ខេម** | 5$ |
| ១៩- យាយ **មុំ** | 5$ |

| | |
|---|---|
| ២០- លោកយាយ ផុល | 5$ |
| ២១- ម៉ៅ សុភាព | 5$ |
| ២២- គីម លន់ | 5$ |
| ២៣- យាយ | 5$ |
| ២៤- ប៊ុន គីមលី | 5$ |
| ២៥-ប្រពន្ធបង រីយ | 5$ |
| ២៦- អ៊ី អៃ | 5$ |
| ២៧- រស់ លីណា | 5$ |
| ២៨- អា ខុម | 5$ |
| ២៩- ជិន សុភា | 5$ |
| ៣០- ទា ស៊ីណា | 5$ |
| ៣១- អា ផល | 5$ |
| ៣២- អ៊ី មួយ | 4$ |
| ៣៣- អ៊ុច ហៃម និង ធូ មីងសាន | 3$ |
| ៣៤- ហ៊ា សិម | 3$ |
| ៣៥- ម៉ែ សឿន | 3$ |
| ៣៦- គីម សុន | 3$ |
| ៣៧- យាយ ឈាន | 3$ |
| ៣៨- គីម លុន | 3$ |
| ៣៩- ហាត និង ស៊ា សុភា | 4$ |

| | | |
|---|---|---|
| ៤០- | **ជុំ យ៉ាន** និង **អុង សែម** | 4$ |
| ៤១- | **អួច ហែម** និង **ធូ មីងសាន** | 2$ |
| ៤២- | បង **កែវ អុំផន** និងភរិយា | 2$ |
| ៤៣- | បង **មីវ៉ាន់** និង **ចេត ហុន** | 4$ |
| ៤៤- | **លាស ស៊ុម** និង **ចោម សារិន** | 4$ |
| ៤៥- | **អ៊ី ឡេង** និង **ជុំ យ៉ា** | 4$ |
| ៤៦- | បង **ឃុំ ទិននាង** និង **ង៉ិន សំអាន** | 4$ |
| ៤៧- | យាយ **វ៉ា ហៀក** និងយាយ **ស៊ី** | 4$ |
| ៤៨- | **ស៊ីម បូផា** និង **ស៊ី ណារុន** | 10$ |
| ៤៩- | ម៉ែ **ស៊ុម** | 10$ |
| ៥០- | បង **ផុន** និង**នារី** | 4$ |

**សរុបទាំងអស់** 383$

## ជយំ វេរំ បសបតិ ទុក្ខំ សេតិ បរាជិតោ

## ឧបសន្តោ សុខំ សេតិ ហិត្វា ជយបរាជយំ ។

បុគ្គលអ្នកឈ្នះ តែងរងនូវពៀរ បុគ្គលអ្នកចាញ់

តែងដេកជាទុក្ខ ចំណែកបុគ្គលលះបង់ការឈ្នះនិងការចាញ់

ចេញហើយ ជាអ្នកស្ងប់រម្ងាប់ ទើបដេកជាសុខ ។

( ដកស្រង់ពីក្នុង ខុទ្ទកបាឋ ធម្មបទគាថា ឧទាន

បឋមភាគ បិដកលេខ ៥២/៦៣)

អ្នកឈ្នះតែងជាប់ពៀរ ចាញ់យំទារឱ្យគេជួយ

កើតទុក្ខសៅហ្មងព្រួយ សុខខ្លួនមួយលះចាញ់ឈ្នះ ។